ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីព្រាងផ្លូវការ
៣ មិថុនា ២០២១

# រាជរដ្ឋាភិបាលកម្ពុជា

# ផែនការមេ

## អភិវឌ្ឍន៍វិស័យទេសចរណ៍

## ខេត្តមណ្ឌលគិរី

## ២០២១ - ២០៣៥







**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## អារម្ភកថា

លក្ខណៈអំណោយផលនៃអាកាសធាតុ ខ្យល់បរិសុទ្ធ ទេសភាពធម្មជាតិដ៏ទាក់ទាញ វាលស្មៅបៃតង និងពណ៌មាស ដងទន្លេស្រែពក ធនធានរ៉ែ ព្រៃឈើ ដែនជម្រកសត្វព្រៃទាំង០៥ វប្បធម៌បងប្អូនជនជាតិដើមភាគតិច និងធនធានជាច្រើនទៀត បង្កើតបានជាសក្តានុពលដ៏ពិសេសសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ពិសេសទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍ ដែលមានលក្ខណៈពិសេសដោយឡែក ខុសប្លែកពីតំបន់ដទៃក្នុងប្រទេស និងបណ្តាប្រទេសមួយចំនួនក្នុងតំបន់។

ទន្ទឹមនឹងនេះ វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី កំពុងស្ថិតក្នុងដំណាក់កាលកំណើន (Growth Stage) នៃវដ្តជីវិតនៃការអភិវឌ្ឍវិស័យទេសចរណ៍ (Life Cycle) ដែលពោរពេញទៅដោយសក្តានុពលសម្រាប់ការអភិវឌ្ឍនាពេលអនាគត បង្កើតជាកាលានុវត្តភាពសក្យានុម័តសម្បូរបែបសម្រាប់ការវិនិយោគ និងបង្កើតតម្លៃបន្ថែមក្នុងវិស័យទេសចរណ៍ និងអន្តរវិស័យនានាគាំទ្រដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចខេត្តមណ្ឌលគិរី និងសេដ្ឋកិច្ចជាតិទាំងមូល។

ជាមួយសក្តានុពលទាំងអស់នេះ និងក្រោមការគិតគូរវែងឆ្ងាយ ទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ រាជរដ្ឋាភិបាលរៀបចំ និងដាក់ចេញ “**ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី**” ដើម្បីជាត្រីវិស័យចង្អុលបង្ហាញយន្តការ និងទិសដៅយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្លើយតបទៅនឹងចក្ខុវិស័យនៃការអភិវឌ្ឍជាតិក្នុងរយៈពេល (២០២១-២០៣៥) និងបណ្តាឆ្នាំខាងមុខ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលតម្រង់ទិសការអភិវឌ្ឍក្នុងក្របខណ្ឌយុទ្ធសាស្ត្ររបស់ខេត្តមណ្ឌលគិរី ដោយឈរលើស្ថានភាពជាក់ស្តែង និងប្រភពធនធានសក្តានុពលសម្រាប់ការវិនិយោគ និងអភិវឌ្ឍន៍វិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រ ក្នុងក្តីសង្ឃឹមប្រកបដោយសុទិដ្ឋិនិយមថា ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវនៃវិស័យនេះ នឹងបង្កើតបានជាផលប្រយោជន៍សេដ្ឋកិច្ច-សង្គមសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន និងរួមចំណែកដល់ការថែរក្សាការពារ និងអភិរក្សធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងរក្សាបាននូវអត្តសញ្ញាណដើមរបស់ខេត្ត។

រាជរដ្ឋាភិបាលឯកភាពកំណត់យកខេត្តមណ្ឌលគិរី ជាគោលដៅអេកូទេសចរណ៍លំដាប់អន្តរជាតិ និងជាខេត្តដ៏សំខាន់ក្នុងការផ្គត់ផ្គង់ផ្កា បន្លែ និងផ្លែឈើ សម្រាប់បំពេញតម្រូវការក្នុងប្រទេស និងឈានដល់ការនាំចេញទៅទីផ្សារក្រៅប្រទេស។

រាជរដ្ឋាភិបាលក៏ឯកភាពក្នុងការកំណត់អាទិភាពសំខាន់ៗចំនួន០៦ ដែលត្រូវរក្សាទុកសម្រាប់ការអភិវឌ្ឍ និងត្រូវកំណត់អំពីវិសាលភាពនៃសកម្មភាពវិនិយោគ និងអភិវឌ្ឍតំបន់ទាំងនេះឱ្យបានច្បាស់លាស់ ដែលរួមមាន÷ **១). តំបន់របៀងអេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិនៃដែនជម្រកសត្វព្រៃទាំង៥ ២). តំបន់របៀងទេសចរណ៍វប្បធម៌ និងអេកូទេសចរណ៍ ប៉ូស្រា-ដាក់ដាំ ៣). ក្រុងសែនមនោរម្យ ៤). តំបន់ស្រុកអូររាំងភ្ជាប់ជាមួយការអភិវឌ្ឍព្រលានយន្តហោះមណ្ឌលគិរី ៥). តំបន់ប្រជុំជននៃស្រុកកោះញែក និង ៦). តំបន់ទេសចរណ៍សមាហរណតាមច្រកព្រំដែន។**

ដើម្បីសម្រេចមហិច្ឆតាខាងលើ រាជរដ្ឋាភិបាលគាំទ្រការដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលបានកំណត់ក្នុងផែនការមេនេះ និងសូមស្នើឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ យកផែនការទាំងអស់នេះ ទៅរៀបចំផែនការគាំទ្រតាមវិស័យរៀងខ្លួន និងអនុវត្តឱ្យមានប្រសិទ្ធភាព ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ អនុលោមតាមទស្សនទាន "**ការអភិវឌ្ឍបម្រើការអភិរក្ស ការអភិរក្សទ្រទ្រង់ដល់ការអភិវឌ្ឍ**"។

ជោគជ័យ និងផ្លែផ្កានៃការអនុវត្តផែនការមេនេះ ក៏អាស្រ័យផងដែរលើការចូលរួម និងសហការស្អិតរមួត ស៊ីជម្រៅ និងការទទួលខុសត្រូវរវាងភាគីពាក់ព័ន្ធនានា ជាពិសេសការជម្រុញកិច្ចសហការនៃភាពជាដៃគូ "**រដ្ឋ-ឯកជន-ប្រជាពលរដ្ឋ-ដៃគូអភិវឌ្ឍ**" (4Ps)។ ក្នុងន័យនេះ រាជរដ្ឋាភិបាលក៏សូមគាំទ្រឱ្យមានការបង្កើតនូវយន្តការស្ថាប័នច្បាស់លាស់ក្នុងការគ្រប់គ្រង និងសម្រួលកិច្ចដំណើរការនៃការអនុវត្តផែនការមេនេះ ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ព្រមជាមួយការបង្កើត**អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍អាទិភាពទាំង០៦** ដូចបានកំណត់ក្នុងផែនការមេនេះ។

រាជរដ្ឋាភិបាល នឹងខិតខំគ្រប់គ្រង និងដោះស្រាយហានិភ័យ និងបញ្ហាប្រឈមនានាដែលអាចកើតមានឡើងឥតគ្រោងទុកដូចជាករណីវិបត្តិជំងឺកូវីដ-១៩ជាដើម ដើម្បីបង្កើតលក្ខខណ្ឌអំណោយផលក្នុងបរិយាកាសបរិយាប័ន្ន សម្រេចឱ្យបានតាមចក្ខុវិស័យ និងគោលដៅដែលបានកំណត់ ដោយឈរលើភាពបត់បែន និងការប្រកាន់ខ្ជាប់នូវអប្បមាទខ្ពស់។

ជាទីបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមអំពាវនាវ និងស្នើឱ្យគ្រប់ភាគីពាក់ព័ន្ធ ផ្តល់អាទិភាពខ្ពស់ដល់ការអនុវត្តជាក់ស្តែងផែនការមេនេះ ទាំងលើទិដ្ឋភាពបច្ចេកទេស និងហិរញ្ញវត្ថុ ពិសេសការគៀងគរធនធានហិរញ្ញវត្ថុចាំបាច់ ដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងដំណើរការនៃការអនុវត្តផែនការមេ។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកាសង្ខេប

**ខ្លឹមសារសង្ខេបប្រតិបត្តិ**......i-ii
**សេចក្តីផ្តើម៖ ភាពចាំបាច់នៃផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី**......១
**ជំពូកទី១៖ ការវិភាគវិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រក្នុងខេត្តមណ្ឌលគិរី ចក្ខុវិស័យ ២០២១-២០៣៥**.៣
**ផ្នែកទី១៖ ការវិភាគយុទ្ធសាស្ត្រ**......៤
១- វិស័យទេសចរណ៍ក្នុងបរិបទមិនច្បាស់លាស់......៤
២- ទិដ្ឋភាពរួមនៃការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី......៧
៣- បរិការណ៍សំខាន់ៗនៃអន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី......១៥
៤- ការវិភាគ SWOT នៃវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី......៣៣
**ផ្នែកទី២៖ ការកំណត់ចក្ខុវិស័យ គោលបំណង និងគោលដៅ**......៣៦
១- ចក្ខុវិស័យ......៣៦
២- គោលបំណង......៣៧
៣- គោលដៅ......៣៧
**ជំពូកទី២៖ ការកំណត់ក្របខណ្ឌយុទ្ធសាស្ត្រ និងយន្តការអនុវត្ត**......៣៨
**ផ្នែកទី១៖ ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍**......៣៩
១- ការកំណត់តំបន់ទេសចរណ៍អាទិភាពសម្រាប់ការអភិវឌ្ឍ......៣៩
២- ការអភិវឌ្ឍផលិតផលទេសចរណ៍ និងវិនិយោគក្នុងវិស័យទេសចរណ៍......៤២
៣- ការពង្រឹងគុណភាពទេសចរណ៍ និងធនធានមនុស្សគាំទ្រ......៤៩
៤- ការផ្សព្វផ្សាយ និងពង្រឹងរូបភាពវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី......៥១
៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍......៥៣
៦- ការតភ្ជាប់ ការសម្រួលការធ្វើដំណើរ និងធ្វើសមាហរណកម្មក្នុងក្របខណ្ឌជាតិ និងតំបន់......៦៨
**ផ្នែកទី២៖ ការកំណត់យន្តការអនុវត្ត**......៧៣
១- ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តផែនការមេ......៧៣
២- យន្តការស្ថាប័ន និងអភិក្រមនៃការអនុវត្ត......៧៤
៣- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ......៧៤
៤- ការគ្រប់គ្រងហានិភ័យដើម្បីត្រៀមដាក់ចេញសេណារីយ៉ូកែតម្រូវ......៧៥
**សេចក្តីសន្និដ្ឋាន**......៧៦
**ឧបសម្ព័ន្ធ ក- ផែនការសកម្មភាពអនុវត្តផែនការមេ**......៧៧
**ឧបសម្ព័ន្ធ ខ- វិធីសាស្ត្រស្រាវជ្រាវ និងចងក្រងផែនការមេ**......៩៦
**ឧបសម្ព័ន្ធ គ- ទិន្នន័យបន្ថែមជាក្រាហ្វិក តារាង និងរូបភាព**......៩៧
ឯកសារយោង......១០៣

ដើម្បី

**“ការអភិវឌ្ឍខេត្តមណ្ឌលគិរី**

**ជាគោលដៅទេសចរណ៍ប្រកបដោយឧត្តមានុវត្តន៍**

**រួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន**

**ទាំងផ្នែកសេដ្ឋកិច្ច-សង្គមមូលដ្ឋាន និងការអភិរក្សធនធានធម្មជាតិ”**

# ខ្លឹមសារសង្ខេបប្រតិបត្តិ

១. ការរៀបចំ និងដាក់ចេញ "**ផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី**" ឆ្លុះបញ្ចាំងពីភាពចាំបាច់របស់ខេត្តមណ្ឌលគិរី ក្នុងការត្រៀមលក្ខណៈសម្បត្តិក្នុងការចាប់យកកាលានុវត្តភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍ ដែលកំពុងមានកំណើនគួរឲ្យកត់សម្គាល់ ដោយឈរលើភាពរឹងមាំនៃសក្តានុពលរបស់ខ្លួន។

២. ភាពចាំបាច់នៃការរៀបចំផែនការមេនេះ គឺអាស្រ័យលើចំណុចខ្លាំងរបស់ខេត្តមណ្ឌលគិរី រួមមាន ទី១). លក្ខណៈពិសេសនៃសក្តានុពល និងធនធានទេសចរណ៍ដ៏សម្បូរបែប ជាពិសេសអេកូទេសចរណ៍ ទេសចរណ៍ធម្មជាតិ និងវប្បធម៌ជនជាតិដើមភាគតិច ដែលមានថាមភាពក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ជាច្រើនទម្រង់ និងច្រើនប្រភេទ ទី២). ទីតាំងភូមិសាស្ត្រ និងអាកាសធាតុអំណោយផល បង្កើតបានជាមូលដ្ឋានដ៏រឹងមាំក្នុងការជំរុញការអភិវឌ្ឍអន្តរវិស័យគាំទ្រ ជាពិសេសវិស័យ កសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មកែច្នៃ និងអន្តរវិស័យនានាដែលមានសក្តានុពលក្នុងការបង្កើតតម្លៃបន្ថែមសម្រាប់វិស័យសេដ្ឋកិច្ច ទី៣). ការវិនិយោគក្នុងវិស័យទេសចរណ៍ និងវិស័យពាក់ព័ន្ធនានា ដែលមានការកើនឡើងជាបន្តបន្ទាប់ ស្របជាមួយការប្រមើលមើលអំពីអនាគតប្រកបដោយសុទិដ្ឋិនិយមរបស់ខេត្តមណ្ឌលគិរី និង ទី៤). ការធានាបាននូវសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមក្នុងខេត្តមណ្ឌលគិរី ដែលជាកត្តាធានាបាននូវទំនុកចិត្តជូនភ្ញៀវទេសចរ និងអ្នកវិនិយោគ។

៣. ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ទាមទារឲ្យមានគិតគូរនូវកត្តាសំខាន់ៗមួយចំនួនរួមមាន ទី១). ប្រព័ន្ធតភ្ជាប់ទៅគោលដៅទេសចរណ៍សំខាន់ៗនៅជួបការលំបាក ដែលធ្វើឲ្យការអភិវឌ្ឍគោលដៅទាំងនោះនៅមិនទាន់មានភាពទូលំទូលាយ ទី២). ហេដ្ឋារចនាសម្ព័ន្ធអន្តរវិស័យទ្រទ្រង់វិស័យទេសចរណ៍ រួមមានការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ការគ្រប់គ្រងសំណល់ ការជំរុញផលិតកម្មក្នុងខេត្ត ប្រព័ន្ធទំនាក់ទំនង និងវិស័យពាក់ព័ន្ធនានា នៅមិនទាន់មានភាពល្អប្រសើរពេញលេញ ដែលទាមទារឲ្យមានការវិនិយោគ និងកែលម្អបន្ថែម ប្រកបដោយបច្ចេកវិទ្យា និងនវានុវត្តន៍ខ្ពស់ ទី៣). ធនធានមនុស្សបម្រើការក្នុងវិស័យទេសចរណ៍ហាក់នៅមានកម្រិត និងត្រូវការពង្រឹងបន្ថែម ខណៈដែលចំនួនភ្ញៀវទេសចរ ត្រូវបានព្យាករណ៍ថាមានកំណើនកាន់តែច្រើននាពេលអនាគត និងទី៤). គុណភាពផលិតផល និងសេវាកម្មទេសចរណ៍ ចាំបាច់ត្រូវមានការពង្រឹងបន្ថែម ឆ្លើយតបតាមស្តង់ដាជាតិ និងអាស៊ាន។

៤. ស្ថានភាពវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ក៏កំពុងប្រឈមបញ្ហាគន្លឹះមួយចំនួនរួមមាន ទី១). ការគ្រប់គ្រងដីធ្លី និងការបែងចែកតំបន់អភិរក្ស និងអភិវឌ្ឍន៍ក្នុងខេត្ត នៅមានភាពប្រទាញប្រទង់ និងទាមទារឲ្យមានការកំណត់ព្រំប្រទល់ឲ្យច្បាស់លាស់ ទី២). ការទន្ទ្រានដីព្រៃក្នុងតំបន់អភិរក្ស នៅតែកើតមានជាបន្តបន្ទាប់ ដែលទាមទារឲ្យមានការចាត់វិធានការច្បាប់ដោយភាពម៉ឺងម៉ាត់ ទី៣). បម្រែបម្រួលអាកាសធាតុ បានកំពុងជះឥទ្ធិពលទៅលើបរិស្ថានធនធានធម្មជាតិក្នុងខេត្ត ដែលធ្វើឲ្យប៉ះពាល់ការដាំដុះ និងវិស័យមួយចំនួន និងទី៤). ការហូរចូលវប្បធម៌ពីខាងក្រៅដែលបានកំពុងជះឥទ្ធិពលដល់ការអភិរក្សប្រពៃណីវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច។

៥. ចក្ខុវិស័យក្នុងផែនការមេនេះ គឺជំរុញការអភិវឌ្ឍខេត្តមណ្ឌលគិរីជាគោលដៅទេសចរណ៍លំដាប់អន្តរជាតិ និងជាខេត្តដ៏សំខាន់ក្នុងការផ្គត់ផ្គង់ផ្កា បន្លែ និងផ្លែឈើ សម្រាប់បំពេញតម្រូវការក្នុងប្រទេស និងឈានដល់ការនាំទៅកាន់ទីផ្សារក្រៅប្រទេស រួមចំណែកធ្វើឲ្យតំបន់ភូមិភាគឦសានដែលមានខេត្តមណ្ឌលគិរីជាស្នូល ក្លាយជាប៉ូលសេដ្ឋកិច្ចទី៤ ខណៈដែលនៅឆ្នាំ២០៣៥ ចំនួនភ្ញៀវអន្តរជាតិមកកាន់ខេត្តមណ្ឌលគិរី ត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ប្រមាណ ៩០ ម៉ឺននាក់ ស្របពេលដែលចំនួនភ្ញៀវក្នុងស្រុក នឹងកើនឡើងដល់ជាង ២ លាននាក់ បង្កើតការងារប្រមាណ ៨ ម៉ឺនកន្លែង និងបង្កើតចំណូលដោយផ្ទាល់ប្រមាណ ៥០០ លានដុល្លារ និងដោយប្រយោលប្រមាណ ១.០០០ លានដុល្លារ

ជាមួយមេគុណប្រសិទ្ធភាព (Multiplier Coefficient) ចំនួន ២ដង ចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចខេត្តមណ្ឌលគីរី ព្រមជាមួយការរក្សាតុល្យភាពឱ្យបានម៉ឺងម៉ាត់រវាងការអភិវឌ្ឍសេដ្ឋកិច្ច ទេសចរណ៍ និងអន្តរវិស័យគាំទ្រជាមួយការអភិរក្សធនធានធម្មជាតិ វប្បធម៌ជនជាតិដើមភាគតិច ដើម្បីធានាផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាអតិបរមា ឈរលើគោលការណ៍នៃការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌ទៅដល់ភាគីពាក់ព័ន្ធ។

**៦.** ដើម្បីសម្រេចចក្ខុវិស័យនៃផែនការមេនេះ រាជរដ្ឋាភិបាលកំណត់នូវគោលដៅគន្លឹះចំនួន៤គឺ ទី១). លើកកម្ពស់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគីរី ឱ្យក្លាយជាវិស័យអាទិភាពមួយ រួមចំណែកបង្កើនប្រាក់ចំណូល ឱកាសការងារ និងកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍មូលដ្ឋាន ទី២). ជំរុញឱ្យវិស័យទេសចរណ៍ក្លាយជាយន្តការដ៏មានប្រសិទ្ធភាព ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចខេត្ត និងការអភិរក្សធនធានធម្មជាតិ និងវប្បធម៌ ឈរលើគោលការណ៍និរន្តរភាព និងការទទួលខុសត្រូវ ទី៣). ផ្សព្វផ្សាយកិត្យានុភាពរបស់ខេត្ត ជាគោលដៅអេកូទេសចរណ៍ និងទេសចរណ៍វប្បធម៌ លំដាប់អន្តរជាតិ ទាំងក្នុងប្រទេស តំបន់ និងពិភពលោក និងទី៤). ជំរុញការចូលរួម និងសហការពីគ្រប់ភាគីពាក់ព័ន្ធ (4Ps) ទាំងផ្នែកសាធារណៈ ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន ព្រមជាមួយភ្ញៀវទេសចរ ដើម្បីធានានិរន្តរភាពនៃវិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រនៅខេត្តមណ្ឌលគីរី ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

**៧.** ដើម្បីសម្រេចចក្ខុវិស័យ និងគោលដៅដែលបានលើកឡើងខាងលើ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រអាទិភាពចំនួន ០៦ គឺ÷ ទី១). កំណត់តំបន់ទេសចរណ៍អាទិភាពសម្រាប់ការអភិវឌ្ឍ ទី២). អភិវឌ្ឍផលិតផលទេសចរណ៍ និងវិនិយោគក្នុងវិស័យទេសចរណ៍ ទី៣). ពង្រឹងគុណភាពទេសចរណ៍ និងធនធានមនុស្សគាំទ្រ ទី៤). ផ្សព្វផ្សាយ និងពង្រឹងរូបភាពវិស័យទេសចរណ៍ខេត្តមណ្ឌលគីរី ទី៥). អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ និងទី៦). សម្រួលការធ្វើដំណើរ ការតភ្ជាប់ និងការធ្វើសមាហរណកម្មក្នុងក្របខណ្ឌជាតិ និងតំបន់ ដែលយុទ្ធសាស្ត្រទាំងអស់នេះនឹងរួមចំណែកបង្កើតបានជានិម្មាបនកម្មសេដ្ឋកិច្ចជាក់លាក់មួយសម្រាប់ការអភិវឌ្ឍខេត្តមណ្ឌលគីរី។

**៨.** ក្រៅពីកិច្ចខិតខំប្រឹងប្រែងដូចបានគិតគូរខាងលើ ប្រសិទ្ធភាពនៃការអនុវត្តផែនការមេនេះ ក៏អាស្រ័យផងដែរលើការប្រែប្រួលនៃសភាពការណ៍សាកលលោក និងតំបន់ ដែលអាចបង្កជាហានិភ័យ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ និងត្រៀមលក្ខណៈដោះស្រាយ រួមមាន ទី១). ហានិភ័យពាក់ព័ន្ធនឹងភាពងាយរងគ្រោះនៃវិស័យទេសចរណ៍ ទី២). ហានិភ័យពាក់ព័ន្ធនឹងការកើតឡើងនៃវិបត្តិសាកលដែលមិនអាចគ្រោងទុកបាន និងទី៣). ហានិភ័យពាក់ព័ន្ធនឹងកត្តាបម្រែបម្រួលធម្មជាតិ ដើម្បីត្រៀមដាក់ចេញសេណារីយ៉ូកែតម្រូវ ក្នុងដំណើរការត្រួតពិនិត្យ និងវាយតំលៃការអនុវត្តផែនការមេ។

**៩.** ជាយន្តការអនុវត្ត គណៈកម្មការអន្តរក្រសួងមួយ ត្រូវបានស្នើឱ្យបង្កើតឡើងដើម្បីជាសេនាធិការឱ្យរាជរដ្ឋាភិបាល ដែលមានតួនាទីបុរេសកម្ម និងស៊ីជម្រៅក្នុងការគ្រប់គ្រង និងសម្រួលកិច្ចដំណើរការនៃការអនុវត្តផែនការមេនេះ។

**១០.** ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត រាជរដ្ឋាភិបាលដាក់ចេញនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគីរី (២០២១-២០៣៥) ដែលនឹងត្រូវធ្វើឡើងរៀងរាល់ ០៥ ឆ្នាំម្តង ដោយគណៈកម្មការអន្តរក្រសួងដែលត្រូវបានស្នើឱ្យបង្កើតឡើង គឺលើកទី១ នៅឆ្នាំ២០២៥ និងលើកទី២ នៅឆ្នាំ២០៣០ ដោយផ្តោតលើចំណុចសំខាន់ៗដើម្បីជាមូលដ្ឋានកែតម្រូវ និងតម្រង់ទិសក្នុងការអនុវត្តបន្ត។ ដោយឡែក លើកទី៣ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នឹងធ្វើឡើងនៅឆ្នាំ ២០៣៥ ដើម្បីបូកសរុបលទ្ធផលនៃការអនុវត្តជារួម និងដាក់ចេញនូវផែនការសម្រាប់រយៈពេលបន្ទាប់។

## សេចក្តីផ្តើម៖ ភាពចាំបាច់នៃផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី

ខេត្តមណ្ឌលគិរី ត្រូវបានបង្កើតឡើងដោយផ្តាច់ស្រុកឆ្លូងលើចេញពីខេត្តក្រចេះ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៦១ ដែលមាន ៣ស្រុក គឺស្រុកកោះញែក ស្រុកច្បារ និងស្រុកអូររាំង។ ការផ្តល់ឈ្មោះខេត្តមណ្ឌលគិរី (មណ្ឌល= តំបន់ និង គិរី= ភ្នំ) មានទំនាក់ទំនងទៅនឹងលក្ខណៈសណ្ឋានដីពិសេសរបស់ខេត្ត ដែលសម្បូរទៅដោយប្រជុំភ្នំ ខ្ពង់រាប ទឹកធ្លាក់ និងជ្រលងជងអូរជាច្រើន។

ខេត្តមណ្ឌលគិរី មានផ្ទៃដី ១៤.២៨៨ គីឡូម៉ែត្រក្រឡា ចែកចេញជាក្រុងចំនួន ១ និងស្រុកចំនួន ៤ ដែលរួមមាន ៤ សង្កាត់ និង ១៧ ឃុំ។ ខេត្តមានព្រំប្រទល់ខាងលិចទល់នឹងខេត្តក្រចេះ ខាងជើងទល់នឹងខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ខាងកើត និងខាងត្បូងទល់នឹងខេត្តដាក់ឡាក់ ខេត្តដាក់ណុង និងខេត្តប៊ិញហ្វឿកនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ខេត្តមានដង់ស៊ីតេប្រជាជន ៦នាក់/គ.ម² គឺតិចជាងគេក្នុងចំណោមរាជធានី ខេត្តទាំង២៥ទូទាំងប្រទេស ហើយក៏ជាខេត្តសម្បូរដោយជនជាតិដើមភាគតិចរស់នៅ។ ក្នុងចំណោមឃុំ/សង្កាត់ទាំងអស់ ឃុំរយ៉នៃស្រុកកោះញែក មានផ្ទៃដីធំជាងគេស្មើនឹង ១៦,៧៥% ហើយសង្កាត់មនោរម្យនៃក្រុងសែនមនោរម្យ មានផ្ទៃដីតូចជាងគេស្មើនឹង ០,៥៥% នៃផ្ទៃដីខេត្ត។

រូបភាពទី១៖ ផែនទីបំណែងចែកតំបន់រដ្ឋបាលខេត្តមណ្ឌលគិរី



(ប្រភព៖ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តមណ្ឌលគិរី)

តារាងទី១៖ សង្ខេបព័ត៌មានរដ្ឋបាលដែនដីខេត្តមណ្ឌលគិរី ឆ្នាំ២០១៩

| ល.រ | បរិយាយ | សរុប | ឯកតា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ១៤.២៨៨ | គ.ម² |
| ២ | ចំនួនក្រុង/ស្រុក | ០៥ | ក្រុង/ស្រុក |
| ៣ | ចំនួនឃុំ/សង្កាត់ | ២១ | ឃុំ/សង្កាត់ |
| ៤ | ចំនួនភូមិ | ៩២ | ភូមិ |

| | | | |
|---|---|---|---|
| ៥ | ចំនួនគ្រួសារ | ១៨.៨០៧ | គ្រួសារ |
| ៦ | ចំនួនជនជាតិដើមភាគតិច | ៤១.១២៥ | នាក់ |
| ៧ | ចំនួនគ្រួសារជនជាតិដើមភាគតិច | ៩.៦១៥ | គ្រួសារ |
| ៨ | ចំនួនប្រជាពលរដ្ឋសរុប | ៨៤.៦២៤ | នាក់ |
| ៩ | ចំនួនស្ត្រីសរុប | ៤២.០៨៧ | នាក់ |

(ប្រភព÷ រដ្ឋបាលខេត្តមណ្ឌលគិរី)

ជាការមិនអាចប្រកែកបានដែលខេត្តមណ្ឌលគិរីមានភ័ព្វវាសនាខ្ពស់ពីធម្មជាតិ អាស្រ័យដោយស្ថានភាពអាកាសធាតុល្អ ទិដ្ឋភាព និងទេសភាពដ៏ទាក់ទាញ រួមមានទឹកជ្រោះជាច្រើនកន្លែង ជួរភ្នំបន្តជាប់គ្នា ជ្រលងដងអូរ វាលស្មៅបៃតងលាតសន្ធឹងលើកំពូលភ្នំ ខ្យល់បរិសុទ្ធ ដងទន្លេស្រែពកជាប់ព្រំប្រទល់ខេត្តរតនគិរី ធនធានរ៉ែ ព្រៃឈើ និងសត្វព្រៃនៃដែនជម្រកសត្វព្រៃទាំង០៥ និងធនធានជាច្រើនទៀត។ ធនធានទាំងអស់នេះ សុទ្ធសឹងជាសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍បែបធម្មជាតិ និងអេកូទេសចរណ៍ ដែលមានលក្ខណៈពិសេសដោយឡែក ខុសពីតំបន់ដទៃក្នុងប្រទេស និងបណ្តាប្រទេសមួយចំនួនក្នុងតំបន់។

ទន្ទឹមនឹងនេះ ភាពសម្បូរបែបនៃវប្បធម៌របស់ជនជាតិដើមភាគតិចផ្សេងៗគ្នា សិល្បៈរបាំបុរាណ ប្រពៃណីជនជាតិព្រឹត្តិការណ៍វប្បធម៌ សិប្បកម្មតាមទំលាប់ អាហារពិសេសរបស់ជនជាតិប្រចាំតំបន់ ចម្ការពនេចរ និងការទស្សនាដំរីជាដើម សុទ្ធសឹងជាធនធាន និងសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍បែបវប្បធម៌ ពិសេសទេសចរណ៍ជនជាតិដើមភាគតិចតាមបែបសហគមន៍។

ធនធានធម្មជាតិ និងវប្បធម៌មិនអាចកាត់ថ្លៃបានទាំងអស់នេះ ត្រូវបានប្រដូចទៅនឹងគ្រាប់ពេជ្រ ដែលអាចទ្រទ្រង់ការអភិវឌ្ឍវិស័យទេសចរណ៍ និងសេដ្ឋកិច្ចខេត្តមណ្ឌលគិរីទាំងមូល ទាំងសម្រាប់បច្ចុប្បន្ន និងអនាគត ខណៈដែលចក្ខុវិស័យក្នុងការអភិវឌ្ឍ និងវិនិយោគរបស់ខេត្តស្ថិតនៅកម្រិតខ្ពស់។

ដូច្នេះ ខេត្តមណ្ឌលគិរីត្រូវត្រៀមលក្ខណៈសម្បត្តិដើម្បីចាប់យកកាលានុវត្តភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍ដែលកំពុងមានកំណើនគួរឲ្យកត់សម្គាល់ ស្របពេលដែលបញ្ហាប្រឈមថ្មីៗក្នុងពិភពលោក ដូចជាភាពតានតឹងនៃស្ថានភាពនយោបាយ និងសេដ្ឋកិច្ចពិភពលោក និងហេតុការណ៍ដែលកើតឡើងឥតគ្រោងទុក ដូចជាករណីវិបត្តិជំងឺកូវីដ-១៩ជាដើម ដោយឈរលើភាពរឹងមាំនៃសក្តានុពលរបស់ខ្លួន។

ក្នុងន័យនេះ ការរៀបចំផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ដែលមានលក្ខណៈជាផែនការសមាហរណកម្មជាមួយអន្តរវិស័យគាំទ្រសំខាន់ៗមួយចំនួន គឺជាត្រីវិស័យដ៏សំខាន់ចង្អុលបង្ហាញយន្តការ និងទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីឆ្លើយតបនឹងចក្ខុវិស័យនៃការអភិវឌ្ឍជាតិក្នុងរយៈពេល (២០២១-២០៣៥) និងបណ្តាឆ្នាំខាងមុខ ដោយផ្អែកលើស្ថានភាពបច្ចុប្បន្ន និងការប្តេជ្ញាចិត្តច្បាស់លាស់របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

# ជំពូកទី១

# ការវិភាគវិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រក្នុងខេត្តមណ្ឌលគិរី ចក្ខុវិស័យ (២០២១-២០៣៥)

- ផ្នែកទី១៖ ការវិភាគយុទ្ធសាស្ត្រ
- ផ្នែកទី២៖ ការកំណត់ចក្ខុវិស័យ គោលបំណង និងគោលដៅ

## ជំពូកទី១÷ ការវិភាគវិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រក្នុងខេត្តមណ្ឌលគិរី ចក្ខុវិស័យ (២០២១-២០៣៥)

### ផ្នែកទី១÷ ការវិភាគយុទ្ធសាស្ត្រ

#### ១- វិស័យទេសចរណ៍ក្នុងបរិបទមិនច្បាស់លាស់

យោងតាមអង្គការទេសចរណ៍ពិភពលោក វិស័យទេសចរណ៍ ត្រូវបានកំណត់ជាវិស័យអាទិភាពក្នុងការរួមចំណែកសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់អង្គការសហប្រជាជាតិ ជាពិសេសចូលរួមសម្រេចបាននូវ**គោលដៅទី៤ "ការសិក្សាពេញមួយជីវិត"** និង**គោលដៅទី៨ "ការងារសមរម្យ"**។

#### ១.១- បម្រែបម្រួលវិស័យទេសចរណ៍សាកលលោក និងតំបន់

ក្នុងឆ្នាំ២០១៩ ពិភពលោកទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ ១,៥ ពាន់លាននាក់ ក្នុងកំណើន ប្រមាណ ៣,៨%។ កំណើននេះមានកម្រិតទាបជាងឆ្នាំ២០១៨ ដោយសារកត្តាមួយចំនួនដូចជា÷

- ការថយចុះកំណើនសេដ្ឋកិច្ចតំបន់អឺរ៉ុប ជាពិសេសសំណុំរឿង Brexit របស់ចក្រភពអង់គ្លេស ដែលបានធ្វើឱ្យបែកបាក់ផ្ទៃក្នុងរបស់បណ្តាប្រទេសអឺរ៉ុប
- សង្គ្រាមពាណិជ្ជកម្មចិន និងអាមេរិក ដែលបានរាលដាលទៅបណ្តាប្រទេសផ្សេងៗ
- ការប្រកាន់យកគំនិតអភិរក្សនិយមរបស់បណ្តាប្រទេសមួយចំនួន
- ជម្លោះនៅតំបន់មជ្ឈិមបូព៌ា
- បញ្ហាបម្រែបម្រួលអាកាសធាតុ
- ការងើបឡើងនូវមហាអំណាចសេដ្ឋកិច្ច និងបញ្ហាមួយចំនួនទៀត ដែលបានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ពិភពលោក និងជះឥទ្ធិពលមកលើវិស័យទេសចរណ៍ ក៏ដូចជាឥរិយាបថនៃការធ្វើដំណើររបស់ភ្ញៀវទេសចរ។

តាមការព្យាករណ៍បឋមរបស់អង្គការទេសចរណ៍ពិភពលោក នៅឆ្នាំ២០២០ វិស័យទេសចរណ៍នឹងនៅតែមានកំណើនវិជ្ជមាន ប៉ុន្តែបន្ទុរងឥទ្ធិពលនៃកត្តាខាងលើ បើទោះបីជាសំណុំរឿង Brexit របស់ចក្រភពអង់គ្លេស និងសង្គ្រាមពាណិជ្ជកម្មចិន និងអាមេរិក ហាក់មានការធូរស្រាលខ្លះ។

តារាងទី២÷ ស្ថិតិទេសចរណ៍ពិភពលោក ក្នុងឆ្នាំ២០១៨-២០១៩

| ទ្វីប | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ព្យាករណ៍ឆ្នាំ២០២០ |
|---|---|---|---|
| **- ពិភពលោក** | **៥,៦%** | **៣,៨%** | **+៣% ទៅ +៤%** |
| - អឺរ៉ុប | ៥,៨% | ៣,៧% | +៣% ទៅ +៤% |
| - អាស៊ី-ប៉ាស៊ីហ្វិក | ៧,៣% | ៤,៦% | +៥% ទៅ +៦% |
| - អាមេរិក | ២,៤% | ២,០% | +២% ទៅ +៣% |
| - អាហ្វ្រិក | ៨,៥% | ៤,២% | +៣% ទៅ +៥% |
| - មជ្ឈិមបូព៌ា | ៣,០% | ៧,៦% | +៤% ទៅ +៦% |

(ប្រភព÷ អង្គការទេសចរណ៍ពិភពលោក)

ផ្ទុយពីការព្យាករណ៍បឋម ឆ្នាំ២០២០ ជាឆ្នាំដ៏អាក្រក់បំផុតសម្រាប់វិស័យទេសចរណ៍ពិភពលោក ដោយចំនួនភ្ញៀវអន្តរជាតិ បានធ្លាក់ចុះប្រមាណ **៧៤%** ដែលមានទំហំធំខ្លាំងជាងក្នុងដំណាក់កាលវិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ២០០៨ ដែលមានត្រឹម **៤%**។ គោលដៅទេសចរណ៍នៅទូទាំងពិភពលោក បានទទួលភ្ញៀវទេសចរតិចជាងឆ្នាំ២០១៩ប្រមាណជាង **១ ពាន់លាននាក់** ដោយសារការធ្លាក់ចុះក្នុងផ្នែកតម្រូវការ និងការដាក់ចេញវិធានការរឹតត្បិតការធ្វើដំណើរ។

រូបភាពទី២÷ បម្រែបម្រួលភ្ញៀវទេសចរអន្តរជាតិតាមទ្វីបនីមួយៗ




(ប្រភព÷ អង្គការទេសចរណ៍ពិភពលោក)

ការធ្លាក់ចុះដ៏គំហុកនៃចំនួនភ្ញៀវទេសចរអន្តរជាតិ បានបណ្តាលឱ្យមានការខាតបង់ប្រាក់ចំណូលប្រមាណ **១,៣ ពាន់លានដុល្លារ** ប៉ះពាល់ការងារដោយផ្ទាល់ប្រមាណ **១០០-១២០ លាននាក់** ដែលភាគច្រើនស្ថិតក្នុងវិស័យសហគ្រាសធុនតូច និងមធ្យម។

ដោយសារតែការវិវត្តន៍នៃជំងឺកូវីដ-១៩ ប្រទេសជាច្រើនកំពុងរឹតបន្តឹងវិធានការរឹតត្បិតការធ្វើដំណើរ ដែលរួមមានដូចជាការធ្វើតេស្តជាកាតព្វកិច្ច ការធ្វើចត្តាឡីស័កឱ្យបានម៉ត់ចត់ និងក្នុងករណីខ្លះឈានដល់ការបិទព្រំដែនពេញលេញ។ ជាមួយក្តីសង្ឃឹមនៃការចាក់វ៉ាក់សាំងជាបណ្តើរៗ ពិភពលោករំពឹងថានឹងអាចជួយស្តារទំនុកចិត្តអ្នកប្រើប្រាស់ និងភ្ញៀវទេសចររួមចំណែកដល់ការបន្ធូរបន្ថយការរឹតត្បិតលើការធ្វើដំណើរ និងធ្វើឱ្យដំណើរទៅរកប្រក្រតីភាព មានការវិវត្តន៍ជាបណ្តើរៗក្នុងឆ្នាំខាងមុខ។

ទន្ទឹមនឹងនេះ អង្គការទេសចរណ៍ពិភពលោកព្យាករណ៍ថា វិស័យទេសចរណ៍ពិភពលោកត្រូវការពេលវេលាប្រមាណពី **២ឆ្នាំកន្លះ ទៅ៤ឆ្នាំ** ទើបអាចត្រឡប់ទៅរកកម្រិតឆ្នាំ២០១៩វិញ ក្រោមសេណារីយ៉ូ ដូចខាងក្រោម÷

- **សេណារីយ៉ូទី១÷** ទេសចរអន្តរជាតិនឹងងើបឡើងវិញនៅឆ្នាំ២០២១ ហើយបន្តកើនឡើង ដោយត្រឡប់ទៅរកភាពដើមវិញដូចកាលពីឆ្នាំ២០១៩ ក្នុងរយៈពេល**២ឆ្នាំកន្លះ (ពាក់កណ្តាលឆ្នាំ២០២៣)**
- **សេណារីយ៉ូទី២÷** ទេសចរអន្តរជាតិនឹងងើបឡើងវិញនៅឆ្នាំ២០២១ តែមានការអូសបន្លាយរហូតដល់**៣ឆ្នាំ (នៅចុងឆ្នាំ២០២៣)** ទើបត្រឡប់ទៅកម្រិតឆ្នាំ២០១៩វិញ។
- **សេណារីយ៉ូទី៣÷**ទេសចរអន្តរជាតិនឹងងើបឡើងវិញនៅឆ្នាំ២០២១ តែមានការអូសបន្លាយរហូតដល់ **៤ឆ្នាំ (នៅចុងឆ្នាំ២០២៤)**។

ដោយឡែក មិនខុសពីតំបន់ផ្សេងៗនៅជុំវិញពិភពលោក តំបន់អាស៊ានទទួលបានភ្ញៀវទេសចរអន្តរជាតិតែប្រមាណ **២៥,៩៦ លាននាក់** នៅឆ្នាំ២០២០ ធ្លាក់ចុះប្រមាណ **៨០,៥%** ធៀបនឹងឆ្នាំ២០១៩ ដែលធ្វើឲ្យបាត់បង់ចំណូលប្រមាណ **៧៥,៨%**។

តារាងទី៣÷ ស្ថិតិភ្ញៀវទេសចរនៅប្រទេសអាស៊ាន ក្នុងឆ្នាំ២០២០

| ល.រ | ប្រទេស | ចំនួន | កំណើន |
|---|---|---|---|
| ១ | ព្រុយណេ | ៦២.៣២៥ | -៨១,៣០% |
| ២ | **កម្ពុជា** | **១.៣០៦.១៤៣** | **-៨០,២៤%** |
| ៣ | ឥណ្ឌូនេស៊ី | ៣.៨៨៩.២៦៣ | -៧៣,៦០% |
| ៤ | ឡាវ | ៨៨៦.៤៤៧ | -៨១,៥០% |
| ៥ | ម៉ាឡេស៊ី | ៤.២៩៩.៤១៩ | -៧៨,៦២% |
| ៦ | មីយ៉ានម៉ា | ៩០៣.៣៤៣ | -៧៩,៣០% |
| ៧ | ហ្វីលីពីន | ១.៤៨២.៥៣៥ | -៨២,០៥% |
| ៨ | សិង្ហបុរី | ២.៧៤២.៣០៨ | -៨៥,៦៥% |
| ៩ | ថៃ | ៦.៧០២.៣៩៦ | -៨៣,២១% |
| ១០ | វៀតណាម | ៣.៦៨៦.៧៧៩ | -៧៩,៥៣% |

(ប្រភព÷ ក្រសួងទេសចរណ៍)

### ១.២- ភាពធន់នឹងវិបត្តិនៃវិស័យទេសចរណ៍កម្ពុជា

ដោយផ្អែកលើសក្តានុពលទេសចរណ៍ និងធនធានធម្មជាតិដ៏សម្បូរបែប រាជរដ្ឋាភិបាលបានចាត់ទុកវិស័យទេសចរណ៍ជា "មាសបៃតង" រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជំរុញផលិតផលក្នុងស្រុកសរុប ផ្តល់ឱកាសការងារ ប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

ទន្ទឹមនឹងនេះ វិស័យទេសចរណ៍ គឺជាវិស័យអាទិភាពមួយក្នុងការចូលរួមសម្រេចបាននូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនាពេលកន្លងមក។ រាជរដ្ឋាភិបាលបានកំណត់វិស័យទេសចរណ៍កម្ពុជាជា "**ទេសចរណ៍វប្បធម៌ និងធម្មជាតិ**" និងបានបែងចែកជា ០៤ តំបន់អាទិភាពសម្រាប់ធ្វើការអភិវឌ្ឍវិស័យទេសចរណ៍ រួមមាន÷

- តំបន់វប្បធម៌-ប្រវត្តិសាស្ត្រសៀមរាបអង្គរ និងតំបន់ជុំវិញបឹងទន្លេសាប
- តំបន់រាជធានីភ្នំពេញ និងតំបន់ជុំវិញ
- តំបន់ឆ្នេរសមុទ្រ (កែប កំពត ព្រះសីហនុ និងកោះកុង)
- តំបន់អេកូទេសចរណ៍ភូមិភាគឦសាន (ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី)។

ជាមួយសក្តានុពលខាងលើ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ វិស័យទេសចរណ៍កម្ពុជាមានការរីកលូតលាស់គួរឲ្យកត់សម្គាល់ និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជាតិ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៩កន្លងមក ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិ មានចំនួនប្រមាណ ៦,៦ លាននាក់ កើនឡើង ៣ដង ប្រៀបធៀបនឹងរយៈពេល ១០ឆ្នាំមុន ដែលមានចំនួនត្រឹមតែប្រមាណ ២,១៦ លាននាក់។

ក្នុង២០១៩ ចំណូលដុលពីលំហូរទេសចរណ៍អន្តរជាតិ មានទំហំប្រមាណ ៤.៩១៩ លានដុល្លារ ឬស្មើប្រមាណ ១៣% នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា។ បើគិតជាតម្លៃបន្ថែម វិស័យទេសចរណ៍ ចូលរួមចំណែកប្រមាណ ៤,៥% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៩ និងជាអនុវិស័យធំជាងគេទី៤ ក្នុងវិស័យសេវាកម្ម បន្ទាប់ពីអនុវិស័យពាណិជ្ជកម្ម ដឹកជញ្ជូន និងទូរគមនាគមន៍ និងអចលនទ្រព្យ។ វិស័យទេសចរណ៍បានបង្កើតមុខរបរ និងការងារទេសចរណ៍ដោយផ្ទាល់ប្រមាណជាង ៦៣ ម៉ឺននាក់ និងការងារដោយប្រយោលរាប់សិបម៉ឺននាក់ផ្សេងទៀត។

ប៉ុន្តែការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កជាផលប៉ះពាល់ធ្ងន់ធ្ងរដល់វិស័យទេសចរណ៍កម្ពុជា និងកំពុងស្ថិតក្នុងដំណាក់កាល "**ប្រឈមផង និងកាលានុវត្តភាពផង**"។ តួយ៉ាង ទេសចរអន្តរជាតិមកទស្សនាកម្ពុជានៅឆ្នាំ២០២០ មានចំនួន **១,៣១ លាននាក់ ថយចុះ៨០%** ធៀបនឹងឆ្នាំ២០១៩។ ប៉ុន្តែសកម្មភាពទេសចរណ៍ផ្ទៃក្នុងបានបង្ហាញសញ្ញានៃការងើបឡើងដោយទទួលបានភ្ញៀវទេសចរប្រមាណ **៩ លាននាក់** ថយចុះត្រឹមតែប្រមាណ **២០%**ប៉ុណ្ណោះ។ និន្នាការនេះបានជួយទ្រទ្រង់វិស័យទេសចរណ៍កម្ពុជាមួយផ្នែក ពិសេសបានជួយឱ្យមូលដ្ឋានអាជីវកម្មទេសចរណ៍មួយចំនួនបើកដំណើរការឡើងវិញ និងបានបង្កើតប្រាក់ចំណូលដោយផ្ទាល់ជូនបងប្អូនប្រជាពលរដ្ឋមូលដ្ឋានផងដែរ។

ប្រឈមទប់ទល់នឹងវិបត្តិកូវីដ-១៩ និងដើម្បីស្តារវិស័យទេសចរណ៍ឡើងវិញ ក្រសួងទេសចរណ៍បានរៀបចំនូវ **"ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ (២០២១-២០២៥)"** ដោយចែកចេញជា ០៣ ដំណាក់កាល÷

១- **ដំណាក់កាលទី១** ÷ ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី (New Normal) និងរៀបចំផែនការសម្រាប់ការស្តារឡើងវិញ (២០២១)

២- **ដំណាក់កាលទី២** ÷ ការជំរុញ និងការស្តារឡើងវិញនៃវិស័យទេសចរណ៍ក្រោយវិបត្តិ (២០២២-២០២៣)

៣- **ដំណាក់កាលទី៣** ÷ ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា (២០២៤-២០២៥)

## ២- ទិដ្ឋភាពរួមនៃការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី

ផែនការមេសម្រាប់អភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ត្រូវបានរៀបចំឡើងដោយផ្អែកលើការវិភាគស្ថានភាពជាក់ស្តែងរបស់ខេត្តមណ្ឌលគិរី តាមរយៈការចុះអង្កេត និងការប្រមូលទិន្នន័យពីមន្ទីរ និងអង្គភាពជំនាញពាក់ព័ន្ធក្នុងខេត្ត ដោយផ្តោតលើចំណុចសំខាន់ ០៣ គឺ÷

- ផ្នែកតម្រូវការរបស់ភ្ញៀវទេសចរ (Demand Side)
- ផ្នែកផ្គត់ផ្គង់ក្នុងវិស័យទេសចរណ៍ (Supply Side)
- ផ្នែកបុគ្គលិកបម្រើការ និងធនធានមនុស្សក្នុងវិស័យទេសចរណ៍។

### ២.១- ចរិតលក្ខណៈ និងតម្រូវការភ្ញៀវទេសចរ

**ក- <u>ការវិវត្តនៃចំនួនភ្ញៀវទេសចរ</u>**

យោងតាមស្ថិតិរបស់មន្ទីរទេសចរណ៍ ខេត្តមណ្ឌលគិរីមានទីតាំងទាក់ទាញភ្ញៀវទេសចរប្រមាណ ១០២ កន្លែង ដែលអាចចែកចេញជាតំបន់អេកូទេសចរណ៍ ទេសចរណ៍ធម្មជាតិ ទេសចរណ៍វប្បធម៌ជនជាតិដើមភាគតិច កសិ-ទេសចរណ៍ ទេសចរណ៍ផ្សងព្រេង និងទេសចរណ៍កែច្នៃជាដើម ក្នុងនោះ ក្រុងសែនមនោរម្យមាន ១០ កន្លែង ស្រុកអូររាំង ៥៩ កន្លែង ស្រុកពេជ្រាដា ១៦ កន្លែង ស្រុកកែវសីមា ០៥ កន្លែង និងស្រុកកោះញែក ១២ កន្លែង។

ជាទូទៅ ក្រុងសែនមនោរម្យ គឺជាគោលដៅទេសចរណ៍ដ៏សំខាន់ ដោយសារតែទីតាំងទេសចរណ៍ភាគច្រើនស្ថិតនៅក្នុងក្រុង ជាពិសេសរមណីយដ្ឋានទេសចរណ៍ភ្នំដោះក្រមុំ និងសមុទ្រឈើ។ ក្រុងសែនមនោរម្យ ក៏មានសម្បទា និងសេវាកម្មជាច្រើន គាំទ្រដល់សកម្មភាពទេសចរណ៍។

ជាមួយសក្តានុពលទាំងនេះ ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ចំនួនភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរី មានការកើនឡើងជាលំដាប់គួរឲ្យកត់សម្គាល់។ ជាក់ស្តែងនៅឆ្នាំ២០២០ បើទោះបីវិស័យទេសចរណ៍កម្ពុជាទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរី មានចំនួនប្រមាណ **២៦ ម៉ឺននាក់** កើនឡើង **៦៨%** ប្រៀបធៀបនឹងរយៈពេល ១០ ឆ្នាំមុន ដែលមានចំនួនត្រឹមតែប្រមាណ **៤,៤ ម៉ឺននាក់**។

ក្រាហ្វិកទី១÷ ការវិវត្តចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិមកកាន់ខេត្តមណ្ឌលគិរី (២០១០-២០២០)




| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|
| ទេសចរជាតិ | 40,652 | 58,757 | 78,784 | 95,059 | 108,716 | 129,712 | 142,104 | 170,898 | 202,144 | 244,828 | 257,594 |
| ទេសចរអន្តរជាតិ | 3,916 | 4,879 | 5,138 | 5,215 | 6,498 | 7,253 | 8,679 | 11,759 | 13,276 | 14,532 | 4,777 |

(ប្រភព÷ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី)

ដោយឡែកក្នុងឆ្នាំ២០១៩ គឺមុនដែលទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ខេត្តមណ្ឌលគិរីទទួលបានភ្ញៀវទេសចរជាតិប្រមាណ **២៤ ម៉ឺននាក់** និងទេសចរអន្តរជាតិប្រមាណ **១,៤ ម៉ឺននាក់**។ តាមរយៈការធ្វើផលធៀបរវាងភ្ញៀវទេសចរសរុបទូទាំងប្រទេស និងខេត្តមណ្ឌលគិរី គេសង្កេតឃើញថា ខេត្តមណ្ឌលគិរីទទួលបានភ្ញៀវទេសចរជាតិ ត្រឹមតែ **២,១៦%** និងទេសចរអន្តរជាតិត្រឹមតែប្រមាណ **០,២២%** ដែលនេះជាអនុបាតទាបបំផុតបើធៀបទៅនឹងតំបន់គោលដៅទេសចរណ៍ផ្សេងៗទៀតក្នុងប្រទេស។

ទាំងនេះបង្ហាញនូវកាលានុវត្តភាពជាច្រើនសម្រាប់វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ខណៈដែលចំនួនភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិ រំពឹងថានឹងកើនឡើងក្នុងកម្រិតខ្ពស់ ពិសេសនៅពេលដែលមានការតភ្ជាប់ផ្លូវអាកាសមកកាន់ខេត្តមណ្ឌលគិរីនេះ។

តារាងទី៤÷ អនុបាតភ្ញៀវទេសចរខេត្តមណ្ឌលគិរីធៀបនឹងភ្ញៀវទេសចរសរុបទូទាំងប្រទេស

| ភ្ញៀវ | ភ្ញៀវជាតិ | ភ្ញៀវអន្តរជាតិ |
|---|---|---|
| ខេត្តមណ្ឌលគិរី | ២៤៤.៨២៨ | ១៤.៥៣២ |
| ទូទាំងប្រទេស | ១១.៣ លាន | ៦.៦១០.៥៩២ |
| **ផលធៀប** | **២,១៦%** | **០,២២%** |

(ប្រភព÷ ក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី)

**ខ- <u>អំពីជម្រើស និងគោលបំណងរបស់ភ្ញៀវទេសចរ</u>**

យោងតាមការចុះអង្កេត ភ្ញៀវទេសចរប្រមាណ ៨០% បានជ្រើសយកខេត្តមណ្ឌលគិរី ជាគោលដៅទេសចរណ៍ចម្បងសម្រាប់ដំណើរកម្សាន្ត និងការសម្រាកលំហែ។ តួលេខនេះបង្ហាញនូវភាពខ្លាំងនៃវិស័យទេសចរណ៍ខេត្តមណ្ឌលគិរីក្នុងនាមជាគោលដៅទេសចរណ៍ចម្បង ឬជាគោលដៅចុងក្រោយនៃដំណើរកម្សាន្ត និងមិនមែនគ្រាន់តែជាគោលដៅឆ្លងកាត់ ឬគោលដៅភ្ជាប់ជាមួយគោលដៅទេសចរណ៍ផ្សេងទេ។

ទន្ទឹមនឹងនេះ គោលបំណងសំខាន់ៗរបស់ភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរី រួមមាន (៥៤%) មកសម្រាកលំហែនាចុងសប្តាហ៍ និងពិធីបុណ្យជាតិ, (១៤%) មកលេងសាច់ញាតិ និងមិត្តភក្តិ, (១២%) មកបំពេញការងារ, (២%) មកធ្វើអាជីវកម្ម និងធុរកិច្ច និង (១៨%) មកកម្សាន្តក្នុងគោលបំណងផ្សេងៗ (ដូចមានក្នុងក្រាហ្វិកបន្ថែមទី១នៃឧបសម្ព័ន្ធ គ)។

ផ្អែកលើទិន្នន័យនេះ ភាគច្រើននៃភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកកម្សាន្តខេត្តមណ្ឌលគិរីតែក្នុងឱកាសចុងសប្តាហ៍ និងពិធីបុណ្យជាតិធំៗ ដែលជាមូលហេតុធ្វើឱ្យប្រតិបត្តិករទេសចរណ៍មួយចំនួន ជួបការលំបាកក្នុងការផ្គត់ផ្គង់សេវាកម្មទេសចរណ៍ ខណៈដែលក្នុងថ្ងៃធ្វើការ មិនសូវមានភ្ញៀវទេសចរ ដូចថ្ងៃឈប់សម្រាកទេ។ ត្រង់ចំណុចនេះ គេអាចសន្និដ្ឋានបានថា ភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរីមួយភាគធំជាភ្ញៀវមកតាមរដូវកាល។ ក្នុងន័យនេះ ដើម្បីឱ្យប្រតិបត្តិករទេសចរណ៍អាចទទួលទេសចរទៀងទាត់ពេញមួយឆ្នាំ ចាំបាច់ត្រូវមានការគិតគូរចាប់យកនូវទីផ្សារទេសចរណ៍ថ្មីបន្ថែមទៀត ដូចជាប្រភេទទេសចរណ៍អាជីវកម្ម និងធុរកិច្ច កិច្ចប្រជុំ សន្និសីទ (MICE) ទេសចរណ៍បែបសិក្សាស្រាវជ្រាវ និងប្រភេទទេសចរណ៍ដែលចំណាយច្រើន និងស្នាក់នៅយូរ។

**គ- <u>អំពីការចំណាយរបស់ភ្ញៀវទេសចរ</u>**

យោងតាមការចុះអង្កេត របាយមុខរបរភ្ញៀវទេសចរដែលមកកម្សាន្តនៅខេត្តមណ្ឌលគិរី រួមមាន (៣២%) ជាមន្ត្រីរាជការ, (២២%) ជាអាជីវករ, (១៨%) ជាសិស្ស-និស្សិត, (១៤%) ជាបុគ្គលិកក្រុមហ៊ុនឯកជន និង (១៤%) មានមុខរបរផ្សេងៗ (ដូចមានក្នុងក្រាហ្វិកបន្ថែមទី២នៃឧបសម្ព័ន្ធ គ)។ ដោយផ្អែកលើស្ថានភាពមុខរបរប្រចាំថ្ងៃខាងលើ គេអាចធ្វើការវិភាគបានថា ការចំណាយរបស់ភ្ញៀវនៅមានកម្រិតទាបនៅឡើយធៀបជាមួយភ្ញៀវទេសចរដែលទៅកម្សាន្តនៅតំបន់ផ្សេងក្នុងប្រទេស ពិសេសនៅមិនទាន់អាចទាក់ទាញភ្ញៀវទេសចរដែលចំណាយច្រើន ដូចជាទេសចរណ៍ធុរកិច្ច (Business Tourism) និងទេសចរណ៍កីឡាវាយកូនហ្គោល (Golf Tourism) ជាដើម។

ទន្ទឹមនឹងនេះ ភាគច្រើននៃភ្ញៀវទេសចរដែលចូលចិត្តមកកម្សាន្តខេត្តមណ្ឌលគិរី គឺជាភ្ញៀវទេសចរក្នុងស្រុក ដែលរយៈពេលនៃការស្នាក់នៅមាន ០៤ ប្រភេទផ្សេងគ្នាគឺ÷

- ភ្ញៀវទៅកម្សាន្ត ១ថ្ងៃ មានប្រមាណ ៦% (ភាគច្រើនជាភ្ញៀវដែលមកពីខេត្តជុំវិញខេត្តមណ្ឌលគិរី ដែលមកកម្សាន្តវិលល្ងាច)
- ភ្ញៀវទៅកម្សាន្ត ២ថ្ងៃ មានប្រមាណ ៥០%
- ភ្ញៀវទៅកម្សាន្ត ៣ថ្ងៃ មានប្រមាណ ៣០%
- ភ្ញៀវទៅកម្សាន្ត លើសពី ៣ថ្ងៃ មានប្រមាណ ១៤%។

ដោយឡែក ភ្ញៀវទេសចរប្រមាណ ៧៤% មានការពេញចិត្តចំពោះការមកកម្សាន្តក្នុងខេត្តមណ្ឌលគិរី និងមានបំណងមកកម្សាន្តម្តងទៀត ក៏ដូចជាផ្សព្វផ្សាយបន្តដល់អ្នកដទៃ ខណៈ ២៦% ផ្សេងទៀត ហាក់គ្មានយោបល់ចំពោះការវិលត្រលប់មកកម្សាន្តខេត្តមណ្ឌលគិរីម្តងទៀត។

តាមការសិក្សារបស់មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី និងការចុះធ្វើអង្កេត ភ្ញៀវទេសចរជាតិចំណាយជាមធ្យមប្រមាណ ២០-៣០ ដុល្លារក្នុងមួយថ្ងៃ ដោយមិនគិតថ្លៃធ្វើដំណើរ និងមានគម្លាតគ្នាច្រើនពីប្រភេទទេសចរណ៍នីមួយៗ។ ភ្ញៀវទេសចរអន្តរជាតិ ចំណាយជាមធ្យមប្រមាណ ២០-៥០ ដុល្លារក្នុងមួយថ្ងៃ ដោយហាក់មិនសូវចំណាយលើការទិញផលិតផល វត្ថុអនុស្សាវរីយ៍ សេវាកម្ម និងសកម្មភាពទេសចរណ៍ផ្សេងទៀតច្រើននៅឡើយ។ ត្រង់ចំណុចនេះ ទាមទារឱ្យមានការចាប់យកឱកាសក្នុងការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ និងធ្វើការកែលម្អសេវាកម្មទេសចរណ៍នានាដែលមានស្រាប់ ឱ្យសមស្របតាមស្តង់ដា និងអាចចាត់ទុកថាជាកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍ និងការធ្វើអាជីវកម្មផ្សេងៗក្នុងខេត្តមណ្ឌលគិរី ឆ្លើយតបនឹងតម្រូវការរបស់ភ្ញៀវទេសចរនាពេលអនាគត។ ទន្ទឹមនឹងនេះ ចាំបាច់ត្រូវមានការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការចាប់យកទីផ្សារភ្ញៀវទេសចរលំដាប់ខ្ពស់ និងស្នាក់នៅបានយូរដើម្បីបង្កើនការចំណាយរបស់ភ្ញៀវ។

ចំពោះការជ្រើសរើសសេវាស្នាក់នៅ ភ្ញៀវទេសចរមានជំរើស រួមមាន (៣២%) ជ្រើសរើសយកកន្លែងស្នាក់នៅបែបលក្ខណៈជារីស៊ត, (២៤%) ជ្រើសរើសស្នាក់នៅផ្ទះសំណាក់ (Guesthouse), (១៦%)ជ្រើសរើសស្នាក់នៅផ្ទះស្នាក់ (Homestay), (១៤%) ជ្រើសរើសស្នាក់នៅសណ្ឋាគារ, (៨%) ជ្រើសរើសស្នាក់នៅដោយការបោះតង់ និង (៦%) ជ្រើសរើសប្រភេទសេវាផ្សេងៗ។ តាមរយៈការជ្រើសរើសកន្លែងស្នាក់នៅនេះ គេអាចវិភាគពីកម្រិតជីវភាពរស់នៅប្រចាំថ្ងៃ និងរយៈពេលស្នាក់នៅរបស់ភ្ញៀវទេសចរ ដូចខាងក្រោម÷

**តារាងទី៥÷ ការវិភាគអំពីជម្រើសសេវាស្នាក់នៅរបស់ភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរី**

| ល.រ. | ប្រភេទសេវាស្នាក់នៅ | ការវិភាគឥរិយាបថភ្ញៀវទេសចរ |
|---|---|---|
| ១. | ស្នាក់នៅរីស៊ត | ជាភ្ញៀវទេសចរដែលមានកម្រិតជីវភាពធូរធារ ឬកម្រិតខ្ពស់ ជាមួយនឹងការស្នាក់នៅរយៈពេលមធ្យម និងយូរ ចន្លោះពី ២-៤ យប់ ដោយសារកន្លែងស្នាក់នៅមានជាសុខភាព និងមានសម្បទាទ្រទ្រង់គ្រប់គ្រាន់ (អាងហែលទឹក ទេសភាពស្អាត កន្លែងស្ងប់ស្ងាត់ និងមានលក្ខណៈឯកជន)។ |
| ២. | ស្នាក់នៅសណ្ឋាគារ | ភ្ញៀវទេសចរដែលមានកម្រិតជីវភាពធូរធារជាមួយនឹងការស្នាក់នៅរយៈពេលមធ្យម ចន្លោះពី ១-២ យប់ (ដោយផ្អែកទៅលើតំបន់ទេសចរណ៍ក្នុងខេត្ត និងរយៈពេលថ្ងៃឈប់សម្រាក)។ |
| ៣. | ស្នាក់នៅផ្ទះសំណាក់ | ជាភ្ញៀវទេសចរដែលមានកម្រិតជីវភាពមធ្យម ដែលការស្នាក់នៅចន្លោះពី ១-២ យប់ (ដោយផ្អែកទៅលើតំបន់ទេសចរណ៍ក្នុងខេត្ត និងរយៈពេលថ្ងៃឈប់សម្រាក)។ |
| ៤. | ស្នាក់នៅផ្ទះស្នាក់ | ជាភ្ញៀវទេសចរដែលមានកម្រិតជីវភាពមធ្យមជាមួយការស្នាក់នៅចន្លោះពី ១-៣ យប់ (ដោយផ្អែកទៅលើតំបន់ទេសចរណ៍ក្នុងខេត្ត និងរយៈពេលថ្ងៃឈប់សម្រាក)។ |
| ៥. | ស្នាក់នៅបោះតង់ | ភ្ញៀវទេសចរដែលមានកម្រិតជីវភាពមធ្យម ជាមួយនឹងការស្នាក់នៅរយៈពេលខ្លី ចន្លោះពី ១-២ យប់ (ដោយផ្អែកទៅលើតំបន់ទេសចរណ៍ក្នុងខេត្ត រយៈពេលថ្ងៃឈប់សម្រាក និងអាកាសធាតុ)។ |

**(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)**

ដោយឡែក ពាក់ព័ន្ធនឹងការចំណាយលើការទិញវត្ថុអនុស្សាវរីយ៍÷

- ៤៣,៦៦% នៃភ្ញៀវទេសចរ មានបំណងទិញផលិតផលកសិកម្ម
- ១៩,៧១% នៃភ្ញៀវទេសចរ មានបំណងទិញផលិតផលសិប្បកម្ម
- ១៥,៥០% នៃភ្ញៀវទេសចរ មានបំណងទិញផលិតផលជនជាតិដើមភាគតិច
- ៩,៨៥% នៃភ្ញៀវទេសចរ មានបំណងទិញឱសថបុរាណ
- ១២,២៧% នៃភ្ញៀវទេសចរ មានបំណងទិញវត្ថុអនុស្សាវរីយ៍ផ្សេងៗទៀត។

ត្រង់ចំណុចនេះ ភ្ញៀវទេសចរបានលើកឡើងថា ភាគច្រើននៃផលិតផលកសិកម្ម និងផ្លែឈើហូបផ្លែ ដែលត្រូវបានដាក់តាំងលក់ ជាផលិតផលនាំចូល ដែលជាមូលហេតុធ្វើឱ្យមានការលំបាកក្នុងការស្វែងរកផលិតផលពិតប្រាកដ និងប៉ះពាល់ដល់ទំនុកចិត្តរបស់អ្នកលក់ផលិតផលពិតប្រាកដ ក៏ដូចជាការចំណាយរបស់ភ្ញៀវ។

បន្ថែមពីលើនេះ ប្រសិនបើក្រឡេកទៅមើលចំណាយរបស់ភ្ញៀវទេសចរជាតិ គឺភាគច្រើនមានត្រឹមតែថ្លៃស្នាក់នៅ និងហូបចុកតែប៉ុណ្ណោះ។ ដោយឡែក ការចំណាយសំខាន់ៗរបស់ភ្ញៀវបរទេសរួមមានថ្លៃស្នាក់នៅ ថ្លៃហូបចុក និងថ្លៃជួលមធ្យោបាយធ្វើដំណើរក្នុងខេត្ត។ ក្នុងន័យនេះ ភ្ញៀវទេសចរមួយភាគធំ គឺមិនទាន់បានចំណាយទៅលើការទិញផលិតផល និងវត្ថុអនុស្សាវរីយ៍នៅឡើយទេ។

### ឃ- ការបង្កើតព្រឹត្តិការណ៍ទេសចរណ៍ថ្មីៗ

ដើម្បីបន្ថយសម្ពាធនៃវិបត្តិកូវីដ-១៩ ការចាប់យកទីផ្សារទេសចរណ៍ក្នុងស្រុក គឺជាជម្រើសដ៏មានប្រសិទ្ធភាពសម្រាប់ការស្តារឡើងវិញនូវកំណើនភ្ញៀវទេសចរក្នុងប្រទេស។ ជាក់ស្តែង ក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ-១៩នេះ និន្នាការភ្ញៀវទេសចរក្នុងស្រុកមានការកើនឡើងជាលំដាប់គួរឱ្យកត់សម្គាល់ទៅកាន់តំបន់ភូមិភាគឦសាន ជាពិសេសតំបន់អេកូទេសចរណ៍ ក្នុងគោលបំណងស្វែងរកដំណើរកម្សាន្តបែបលក្ខណៈធម្មជាតិ ដូចជាសកម្មភាពបោះតង់លើខ្នងភ្នំ ការដើរផ្សងព្រេងកម្សាន្តក្នុងព្រៃ និងការរស់នៅជាមួយប្រជាពលរដ្ឋក្នុងតំបន់ជាដើម ដើម្បីទទួលបានបទពិសោធន៍ពិតប្រាកដពីតំបន់ទាំងនោះ។

តាមការចុះអង្កេត ៨៨% នៃភ្ញៀវទេសចរ មានការចាប់អារម្មណ៍ និងគាំទ្រឱ្យមានការបង្កើតព្រឹត្តិការណ៍ទេសចរណ៍ថ្មីៗសម្រាប់ខេត្តមណ្ឌលគិរី ដែលរួមមាន ពិធីបុណ្យដំរី ពិធីបុណ្យអេកូទេសចរណ៍ កម្មវិធីបោះតង់ និងដើរកម្សាន្តក្នុងព្រៃ ព្រឹត្តិការណ៍កីឡាជាតិ និងអន្តរជាតិ និងសកម្មភាពកសិ-ទេសចរណ៍ជាដើម។

តាមការរំពឹងទុក កំណើនភ្ញៀវទេសចរនឹងមានកំណើនខ្ពស់ បន្ទាប់ពីស្ថានភាពជំងឺកូវីដ-១៩ មានភាពធូរស្រាលតាមរយៈការធ្វើពិពិធកម្មផលិតផលទេសចរណ៍ថ្មីៗក្នុងខេត្ត និងបណ្តាខេត្តជុំវិញ ពិសេសការបង្កើតព្រឹត្តិការណ៍ទេសចរណ៍ គោលដៅទេសចរណ៍ និងសេវាកម្មទេសចរណ៍នានា ដែលជាកត្តាដ៏សំខាន់ក្នុងការស្រូបទាញភ្ញៀវទេសចរឱ្យមកលេងកម្សាន្តច្រើនដង និងស្នាក់នៅឱ្យបានកាន់តែយូរ។

### ង- បញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលលើកឡើងដោយភ្ញៀវទេសចរ

#### *ង.១- តំបន់គោលដៅទេសចរណ៍សំខាន់ៗ*

ខេត្តមណ្ឌលគិរី មានតំបន់សក្តានុពលទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងសហគមន៍ទេសចរណ៍ជាច្រើនកន្លែង ដែលអាចទាក់ទាញភ្ញៀវទេសចរឱ្យមកលេងកម្សាន្ត និងស្នាក់នៅបានយូរ។ ប៉ុន្តែភ្ញៀវទេសចរភាគច្រើនប្រមូលផ្តុំតែនៅគោលដៅទេសចរណ៍សំខាន់ៗមួយចំនួនតែប៉ុណ្ណោះ ដូចជារមណីយដ្ឋានទឹកជ្រោះប៊ូស្រា រមណីយដ្ឋានវប្បធម៌

ភ្នំដោះក្រមុំ រមណីយដ្ឋានសមុទ្រឈើភ្នំបាយឆៅ និងរមណីយដ្ឋានចម្ការកាហ្វេជាដើម។ ចំណែកសហគមន៍ទេសចរណ៍ និងកន្លែងដែលមានសក្តានុពលផ្សេងៗទៀត មិនទាន់មានការពេញនិយមទៅកម្សាន្តនៅឡើយ។

**តារាងទី៦÷ គោលដៅតំបន់ទេសចរណ៍ក្នុងខេត្តមណ្ឌលគិរីដែលភ្ញៀវទេសចរទៅកម្សាន្ត**

| រមណីយដ្ឋានទេសចរណ៍ | សហគមន៍ទេសចរណ៍ |
|---|---|
| - រមណីយដ្ឋានទឹកជ្រោះប៊ូស្រា ១៧,១៤%<br>- រមណីយដ្ឋានវប្បធម៌ភ្នំដោះក្រមុំ ១៤,២៨%<br>- រមណីយដ្ឋានសមុទ្រឈើភ្នំបាយឆៅ ១០,៤៧%<br>- រមណីយដ្ឋានចម្ការកាហ្វេ ១០%<br>- រមណីយដ្ឋានសមុទ្រឈើភ្នំមិទ្វៀកា ១០%<br>- ផ្សេងៗ ៦,១៩% | - សហគមន៍វប្បធម៌ភ្នំក្រោល ២,៨៥%<br>- សហគមន៍ទឹកជ្រោះមនោរម្យ ៣,៨០%<br>- សហគមន៍ទឹកជ្រោះព្រៃធំ ១,៤០%<br>- សហគមន៍ទឹកធ្លាក់លែងឃិនលែងអង់ ២,៣៨% |
| **ទីកន្លែងមានសក្តានុពល** | |
| - ទឹកជ្រោះ ៧ ជាន់ ២,៣៨%<br>- អូរតឹងឡាង ១,៤២%<br>- អណ្តូងស្នេហ៍ ៣,៨០% | - ភ្នំណាមលៀរ ៥,២៣%<br>- ទឹកជ្រោះអូរតាំកន ០,៤៧%<br>- ផ្សេងៗ ១,៩% |

**(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)**

### ***ង.២- ការផ្សព្វផ្សាយតំបន់ទេសចរណ៍***

ការផ្សព្វផ្សាយគឺជាកត្តាដ៏សំខាន់មិនអាចខ្វះបានក្នុងការស្រូបទាញការចាប់អារម្មណ៍របស់ភ្ញៀវទេសចរ។ ឆ្លងតាមរយៈការចុះអង្កេត ភ្ញៀវទេសចរបានលើកឡើងនូវបញ្ហាមួយចំនួន រួមមាន កង្វះខាតព័ត៌មានពីគោលដៅទេសចរណ៍ កង្វះខាតស្លាកសញ្ញាបង្ហាញផ្លូវ ផ្លូវធ្វើដំណើរទៅកាន់រមណីយដ្ឋានមួយចំនួនមានលក្ខណៈមិនទាន់អំណោយផល និងបញ្ហាមួយចំនួនទៀត ដូចមានក្នុងក្រាហ្វិកបន្ថែមទី៣នៃឧបសម្ព័ន្ធ គ)។

### ***ង.៣- ផលិតផលទេសចរណ៍ និងតម្លៃ***

ខេត្តមណ្ឌលគិរី សម្បូរដីមានជីជាតិដែលមានសក្តានុពលក្នុងការដាំដុះកសិផលនានា ជាពិសេសប្រភេទបន្លែ និងផ្លែឈើជាច្រើនប្រភេទ។ ប៉ុន្តែដូចបានបង្ហាញក្នុងផ្នែកខាងលើ ភ្ញៀវទេសចរមានការលំបាកក្នុងការស្វែងរកទិញផលិតផលពិត (Authentic Products) ដោយសារមានការដាក់តាំងលក់ផលិតផលកសិផលមួយចំនួននាំចូលពីក្រៅប្រទេស។ ម្យ៉ាងវិញទៀត ផលិតផលទេសចរណ៍ និងទំនិញផ្សេងៗ ហាក់ដូចជាមានតម្លៃខ្ពស់ធៀបនឹងបណ្តាខេត្តផ្សេងៗ។

### ***ង.៤- មធ្យោបាយធ្វើដំណើរ***

ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ផ្លូវគោកមកកាន់ខេត្តមណ្ឌលគិរី ថ្វីត្បិតមានភាពល្អប្រសើរ តែមានចំងាយជិត ៤០០ គ.ម និងចំណាយពេលជាមធ្យមប្រមាណ ៦-៧ម៉ោង ទើបមកដល់ទីរួមខេត្ត។ ដូចនេះ ភ្ញៀវទេសចរត្រូវចំណាយពេលវេលា និងថាមពលច្រើនក្នុងការធ្វើដំណើរ។ បន្ថែមពីលើបញ្ហាមួយចំនួនខាងលើ ភ្ញៀវទេសចរក៏បានលើកឡើងនូវចំណុចមួយចំនួនដើម្បីធ្វើការកែលម្អបន្ថែម ធ្វើយ៉ាងណាឲ្យដំណើរកម្សាន្តក្នុងខេត្តមណ្ឌលគិរី ទទួលបានបទពិសោធន៍ និងការពេញចិត្តខ្ពស់ ទៅតាមលំដាប់នៃភាពចាំបាច់ (ដូចមានបង្ហាញក្នុងតារាងបន្ថែមទី១ ទី២ ទី៣ និងទី៤នៃឧបសម្ព័ន្ធ គ)។

### ២.២- ការផ្គត់ផ្គង់សេវា និងសម្បទានទ្រទ្រង់

សេវាកម្មទេសចរណ៍នៅខេត្តមណ្ឌលគិរី ហាក់នៅមានកម្រិតទាប និងមិនទាន់មានភាពសម្បូរបែប ធៀបនឹងសមាមាត្រភ្ញៀវទេសចរក្នុងខេត្ត និងធៀបជាមួយតំបន់ទេសចរណ៍ផ្សេងក្នុងប្រទេស ដែលទាមទារនូវការវិនិយោគបន្ថែម។

តារាងទី៧÷ មូលដ្ឋានអាជីវកម្មទេសចរណ៍ខេត្តមណ្ឌលគិរី ក្នុងឆ្នាំ២០១៩

| ល.រ. | ប្រភេទអាជីវកម្ម | ចំនួន | បន្ទប់ | បុគ្គលិក |
|---|---|---|---|---|
| ១ | សណ្ឋាគារ | ១១ | ៤២៨ | ៩៧ |
| ២ | បឹងហ្គាឡូ | ១ | ៦ | ២ |
| ៣ | ផ្ទះសំណាក់ | ៥១ | ៧៣៥ | ២១២ |
| ៤ | ម៉ូតែល | ២ | ៦៧ | ៩ |
| ៥ | ខារ៉ាអូខេ | ១៣ | ៥៧ | ២២៥ |
| ៦ | ភោជនីយដ្ឋាន និងអាហារដ្ឋាន | ៣៤ | ៣២០ | ១៧៩ |
| ៧ | រមណីយដ្ឋាន | ៨ | ៥៧ | ១១២ |
| ៨ | មគ្គុទ្ទេសក៍ទេសចរណ៍ | ៧៥ | ៧៥ | ៧៥ |
| ៩ | ម៉ាស្សា | ៤ | ៧ | ៥ |
| **សរុប** | | **១៩៩** | **១.៦៧៧** | **៩១៦** |

(ប្រភព÷ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី)

ទន្ទឹមគ្នានេះ សេវាកម្មស្នាក់នៅក៏នៅមានចំនួនទាប ក្នុងនោះ អត្រាកំណើនផ្ទះសំណាក់ចាប់ពីឆ្នាំ២០១០ មកដល់ឆ្នាំ២០២០ មាន ១៥,៥% ខណៈសណ្ឋាគារកើនឡើង ៤,៥%។ បើគិតជាចំនួនបន្ទប់ស្នាក់នៅក្នុងខេត្តមណ្ឌលគិរី មានការកើនឡើង ៨៣៨ បន្ទប់ ស្មើនឹង ២១% ក្នុងនោះ÷

- ចំនួនបន្ទប់ក្នុងផ្ទះសំណាក់ កើនឡើង ៤១៥ បន្ទប់ ស្មើនឹង ១២,៩% ធៀបនឹងឆ្នាំ២០១០
- ចំនួនបន្ទប់ក្នុងសណ្ឋាគារ កើនឡើង ៣៥០ បន្ទប់ ស្មើនឹង ៤៤,៨% ធៀបនឹងឆ្នាំ២០១០។

តារាងទី៨÷ ស្ថិតិសណ្ឋាគារ និងផ្ទះសំណាក់ ចាប់ពីឆ្នាំ ២០១០-២០២០

| សេវាស្នាក់នៅ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១. សណ្ឋាគារ | ចំនួន | ២ | ៣ | ៤ | ៤ | ៥ | ៥ | ៧ | ៨ | ៩ | ៨ | ១១ |
| | បន្ទប់ | ៧៨ | ១៤៤ | ១៦១ | ១៦១ | ១៧៣ | ១៧៣ | ២៩៣ | ៣៥៥ | ៣៧៤ | ៣៦៤ | ៤២៨ |
| ២. ផ្ទះសំណាក់ | ចំនួន | ២០ | ៣០ | ៣៥ | ៣៧ | ៣៩ | ៣៩ | ៤១ | ៥១ | ៤៥ | ៤៦ | ៥១ |
| | បន្ទប់ | ៧៨ | ១៤៤ | ១៦១ | ១៦១ | ១៧៣ | ១៧៣ | ២៩៣ | ៣៥៥ | ៣៧៤ | ៣៦៤ | ៤២៨ |

(ប្រភព÷ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី)

ដោយឡែក ប្រភេទភ្ញៀវទេសចរមកដោយខ្លួនឯង ស្ថិតក្នុងអត្រាមួយខ្ពស់ជាងប្រភេទភ្ញៀវទេសចរមកជាក្រុម ដោយសារកត្តាមួយចំនួន÷

- ខេត្តមណ្ឌលគិរី ពុំទាន់មានការីទេសចរណ៍ ដូចនេះពុំមានការរៀបចំកញ្ចប់ទស្សនកិច្ចដោយក្រុមហ៊ុនក្នុងខេត្ត គឺមានតែក្រុមហ៊ុននៅភ្នំពេញ និងខេត្តផ្សេងៗប៉ុណ្ណោះ ដែលបានរៀបចំកញ្ចប់ទស្សនកិច្ចនាំភ្ញៀវមកលេងខេត្តមណ្ឌលគិរី
- ភ្ញៀវទេសចរមកជាក្រុម គឺមកវិស្សមកាលតាមក្រុមហ៊ុន ឬមានកិច្ចប្រជុំ សិក្ខាសាលាណាមួយ ដែលបានរៀបចំឡើងនៅក្នុងខេត្តមណ្ឌលគិរីតែប៉ុណ្ណោះ។

ក្រៅពីទិន្នន័យពាក់ព័ន្ធខាងលើ មូលដ្ឋានអាជីវកម្ម បានលើកឡើងនូវចំណុចខ្វះខាតមួយចំនួន ដែលទាមទារឲ្យមានការគិតគូរបន្ថែមក្នុងការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី រួមមាន÷

- ការជួសជុល និងកែលម្អផ្លូវតភ្ជាប់ទៅគោលដៅទេសចរណ៍សំខាន់ៗ អមជាមួយការបំពាក់បង្គោលភ្លើងបំភ្លឺផ្លូវ
- ការដាក់ស្លាកសញ្ញាទៅគោលដៅទេសចរណ៍សំខាន់ៗឲ្យបានគ្រប់គ្រាន់
- ការពង្រឹងដំណើរការមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍
- ការរៀបចំឲ្យមានចំណតរថយន្តសាធារណៈ
- ការរៀបចំបន្ទប់ទឹកសាធារណៈឲ្យបានគ្រប់គ្រាន់
- ការបំពាក់ធុងសំរាមនៅតាមទីសាធារណៈឲ្យបានគ្រប់គ្រាន់
- ការពង្រឹងបន្ថែមមធ្យោបាយដឹកជញ្ជូន
- ការជំរុញឲ្យមានមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងខេត្ត ។

## ២.៣- ធនធានមនុស្ស និងបុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍

ការចុះជួបផ្ទាល់ជាមួយអ្នកគ្រប់គ្រង និងម្ចាស់មូលដ្ឋានអាជីវកម្មក្នុងសេវាកម្មទេសចរណ៍ បានបង្ហាញនូវព័ត៌មាន និងតួលេខសំខាន់ៗមួយចំនួន ដូចខាងក្រោម÷

- ប្រមាណ ៨០% នៃបុគ្គលិកដែលបម្រើការក្នុងវិស័យទេសចរណ៍ គឺជាស្ត្រី
- បុគ្គលិកក្នុងសេវាកម្មទេសចរណ៍មានត្រឹម ៣៨% ប៉ុណ្ណោះ ដែលមានដើមកំណើតក្នុងខេត្តមណ្ឌលគិរី
- ក្នុងចំណោមបុគ្គលិកក្នុងវិស័យទេសចរណ៍ ប្រមាណ ៧០% បានទទួលការបណ្តុះបណ្តាល ប៉ុន្តែភាគច្រើនជាកម្រិតអ្នកគ្រប់គ្រង និងម្ចាស់អាជីវកម្ម
- ម្ចាស់ និងអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្ម បានលើកឡើងពីការលំបាកក្នុងការជ្រើសរើសបុគ្គលិកដែលមានសមត្ថភាព និងអាចបម្រើការយូរក្នុងកន្លែងការងារ
- មូលដ្ឋានអាជីវកម្មមួយចំនួន ប្រឈមនឹងការខ្វះខាតធនធានមនុស្ស ដោយសារបុគ្គលិកមួយចំនួន ជាអ្នកចំណូលស្រុកមកធ្វើការតាមគ្នា ហើយខ្លះទៀតបម្រើការបានត្រឹម ២-៣ខែ ក៏សុំឈប់ ដើម្បីទៅធ្វើចម្ការ
- អត្រានៃការផ្លាស់ប្តូរបុគ្គលិកមានរហូតដល់ ៧៨% ពិសេសក្នុងវិស័យសណ្ឋាគារ ដោយហេតុផលថា បុគ្គលិកដែលបម្រើការក្នុងសណ្ឋាគារ គឺតម្រូវឲ្យមានសមត្ថភាព និងជំនាញច្បាស់លាស់។

បន្ថែមពីលើនេះ លក្ខខណ្ឌការងារក្នុងវិស័យទេសចរណ៍ រួមមាន÷

- បុគ្គលិកដែលបម្រើសេវាក្នុងវិស័យទេសចរណ៍មានត្រឹមប្រមាណ ២៥% ដែលមានកិច្ចសន្យាការងារ ហើយភាគច្រើននៃការចូលធ្វើការគឺគ្រាន់តែនិយាយផ្ទាល់មាត់
- ៣៥% មានធានារ៉ាប់រងការងារ ប៉ុន្តែមិនទាន់មានលក្ខណៈពេញលេញនៅឡើយ។

ផ្អែកលើការសិក្សាខាងលើ គេអាចសន្និដ្ឋានបានថា ស្ថានភាពនៃធនធានមនុស្ស និងបុគ្គលិកដែលបម្រើការងារក្នុងវិស័យទេសចរណ៍នៅមានកម្រិត ទាំងបរិមាណ និងគុណភាព ពិសេសការពង្រឹងសមត្ថភាព ជំនាញរបស់បុគ្គលិក។ ជាចក្ខុវិស័យ ផែនការមេផ្តោតលើគោលដៅសំខាន់ចំនួន ២គឺ÷

- សម្រេចឱ្យបានការផ្គត់ផ្គង់សេវាកម្ម និងសម្បទាទ្រទ្រង់ស្របតាមកំណើនភ្ញៀវទេសចរ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស្របតាមស្តង់ដាក្រសួងទេសចរណ៍ និងស្តង់ដាអាស៊ាន
- បង្កើតឱ្យមានវិទ្យាស្ថានទេសចរណ៍ជាតិ ឬសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍សម្រាប់ខេត្តមណ្ឌលគិរី។

## ៣- បរិការណ៍សំខាន់ៗនៃអន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី

ការវិភាគទិន្នន័យបែបគុណភាពវិស័យ ទៅលើទិន្នន័យដែលទទួលបានពីចុះជួបពិភាក្សាជាមួយមន្ទីរជំនាញ និងស្ថាប័នពាក់ព័ន្ធក្នុងខេត្តមណ្ឌលគិរី បង្ហាញអំពីស្ថានភាព ផលប៉ះពាល់ និងចក្ខុវិស័យសម្រាប់អន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី។

### ៣.១- ការរៀបចំដែនដី និងការប្រើប្រាស់ដីធ្លីខេត្តមណ្ឌលគិរី

យោងតាមរបាយការណ៍បច្ចេកទេសស្តីពីការរៀបចំដែនដីខេត្តមណ្ឌលគិរីរបស់គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តមណ្ឌលគិរី ការរៀបចំ និងការប្រើប្រាស់ដីធ្លីក្នុងខេត្តមណ្ឌលគិរី ត្រូវបានកំណត់ជា ៥ ប្រភេទ÷

- **តំបន់អភិរក្ស** រួមមានតំបន់ស្នូល និងតំបន់អភិរក្ស ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ ប្រព័ន្ធប្រើប្រាស់ដីប្រភេទនេះ បង្កើតបានជាប្រព័ន្ធតភ្ជាប់គ្នាលាតសន្ធឹងពីភាគនិរតីនៃស្រុកកែវសីមា រហូតដល់ភាគឦសាននៃស្រុកកោះញែក ព្រមទាំងជ្រុងមួយនៃភាគខាងត្បូងរបស់ដែនជម្រកសត្វព្រៃលំផាត់។ ប្រភេទការប្រើប្រាស់ដីសំខាន់ក្នុងតំបន់អភិរក្ស នេះ គឺគ្របដណ្តប់ដោយព្រៃល្បោះ ព្រៃពាក់កណ្តាលស្រោង និងព្រៃស្រោង។ ការប្រែប្រួលគម្របដីសំខាន់ៗដែលបានកើតឡើងក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ រួមមានការរានព្រៃឈើ និងការសឹករេចរិលនៃព្រៃឈើ ដោយសារតែការធ្វើអាជីវកម្មធនធានព្រៃឈើខុសលក្ខណៈបច្ចេកទេស។ ទោះបីយ៉ាងណា គេឃើញមានការកើនឡើងនូវតំបន់ដាំដុះព្រៃឡើងវិញក្នុងតំបន់អភិរក្សទាំងនេះ ដែលបង្ហាញពីភាពជោគជ័យនៃកិច្ចប្រឹងប្រែងការពារ និងអភិរក្សព្រៃឈើរបស់រាជរដ្ឋាភិបាល។
- **តំបន់ការពារធម្មជាតិមានការគ្រប់គ្រងរួមគ្នា** រួមមានតំបន់ប្រើប្រាស់ដោយនិរន្តរភាព និងតំបន់សហគមន៍។ ការប្រែប្រួលគម្របដីសំខាន់ៗដែលបានកើតឡើងក្នុងរយៈពេល២០ឆ្នាំចុងក្រោយ គឺដោយសារកត្តាចំណូលស្រុកដែលនាំឱ្យមានការថយចុះបរិមាណព្រៃឈើមួយចំនួន។ ប្រព័ន្ធប្រើប្រាស់ដីបច្ចុប្បន្នមានលក្ខណៈជាព្រៃឈើលាយឡំជាមួយដីលំនៅឋាន និងដីកសិកម្ម។
- **តំបន់កសិ-ឧស្សាហកម្មខ្នាតធំ (ដីសម្បទានសេដ្ឋកិច្ច)** រួមមានភាគច្រើនជាដីឯកជនរបស់រដ្ឋ ដែលបានជួលឱ្យក្រុមហ៊ុនសម្រាប់ដាំដំណាំចម្ការខ្នាតធំក្នុងខេត្តមណ្ឌលគិរី ពិសេសដំណាំកៅស៊ូ។
- **តំបន់កសិកម្មខ្នាតតូច (កម្រិតខ្ពស់)** រួមមានតំបន់ដែលប្រើប្រាស់កសិកម្មខ្នាតតូចជាចម្បង (លើកលែងតែតំបន់សាងសង់)។ ប្រព័ន្ធប្រើប្រាស់ដីប្រភេទនេះ មានលក្ខណៈសកម្ម ដោយសារមានការប្រែប្រួលគម្របដី និងកំណើនប្រជាជនដែលកើតមានក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ។ ប្រព័ន្ធដាំដុះបង្កើតឡើងដោយកសិករខ្នាតតូច មានលក្ខណៈជាដុំៗតាមជាយព្រៃ ដោយមានការត្រួសត្រាយព្រៃដើម្បីដាំដំណាំប្រចាំឆ្នាំ (ភាគច្រើនជាដំឡូង និងសណ្តែក) និងដំណាំរយៈពេលវែង (ភាគច្រើន គឺដំណាំកៅស៊ូ និងស្វាយចន្ទី)។ ដោយឡែកនៅស្រុកកោះញែក មានការធ្វើស្រែ និងការដាំដុះដំណាំស្រូវច្រើនជាងគេ។

- **តំបន់កសិកម្មខ្នាតតូច (កម្រិតទាប)** ជាតំបន់ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ និងទាប និងត្រូវបានប្រើដោយកសិករខ្នាតតូចសម្រាប់កសិកម្មជាចម្បង ប៉ុន្តែក៏ជាតំបន់នៃបណ្តុំប្រភេទព្រៃឈើសំខាន់ផងដែរ។ តំបន់នេះជាទូទៅពាក់ព័ន្ធនឹងរបៀងអភិរក្សជីវៈចម្រុះ។

យោងតាមរបាយការណ៍បច្ចេកទេសស្តីពីការរៀបចំដែនដីខេត្តមណ្ឌលគិរី ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍដែនដីខេត្តមណ្ឌលគិរីចក្ខុវិស័យឆ្នាំ២០៤០ កំណត់ថា***“ខេត្តមណ្ឌលគិរី គឺជាមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតងដែលមានជីវភាពរស់រវើក ផ្អែកលើធនធានធម្មជាតិ និងវប្បធម៌សម្បូរបែបរបស់ខេត្ត រួមចំណែកជាចម្បងក្នុងការលើកកម្ពស់ប៉ូលអភិវឌ្ឍន៍ជាតិនៅភាគឦសាន ស្របតាមការតម្រង់ទិសការអភិវឌ្ឍដែនដីដ៏ត្រឹមត្រូវមានសណ្តាប់ធ្នាប់ និងគុណភាពបរិស្ថានរស់នៅល្អប្រសើរ តាមរយៈការលើកស្ទួយការអភិវឌ្ឍទេសចរណ៍វប្បធម៌ និងបរិស្ថាន ដែលផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចសង្គម និងបរិស្ថានប្រកបដោយនិរន្តរភាពដល់ប្រជាជន ទេសចរ និងវិនិយោគទាំងអស់។”***

ក្នុងន័យនេះ ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី តម្រង់ទិសទៅរកការអភិវឌ្ឍវិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រ ស្របតាមផែនការ និងប្លង់គោលប្រើប្រាស់ដីធ្លីខេត្តមណ្ឌលគិរី ពិសេសការកំណត់តំបន់អាទិភាពសម្រាប់ធ្វើការអភិវឌ្ឍ។

ផ្អែកលើចក្ខុវិស័យខាងលើ ការរៀបចំដែនដីខេត្តមណ្ឌលគិរី ផ្តោតលើសសរស្តម្ភសំខាន់០៥ ដូចខាងក្រោម÷

- **ការការពារ និងគ្រប់គ្រងសេវាកម្មអេកូឡូស៊ីរួមគ្នា÷** ខេត្តមណ្ឌលគិរី មានធនធានធម្មជាតិយ៉ាងសម្បូរបែប ដែលផ្តល់នូវសេវាកម្មធម្មជាតិសេដ្ឋកិច្ច សង្គម និងវប្បធម៌យ៉ាងច្រើន សុទ្ធសឹងមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍខេត្តប្រកបដោយនិរន្តរភាព។
- **អេកូទេសចរណ៍ដែលផ្តល់តម្លៃអត្តសញ្ញាណវប្បធម៌ចម្រុះជនជាតិ និងបរិស្ថានរបស់ខេត្ត÷**ភាពវិសេសនៃវប្បធម៌ និងបរិស្ថានរបស់ខេត្តមណ្ឌលគិរី គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍។ ភាពចម្រុះ និងសម្បូរបែបនៃព្រៃឈើ ទេសភាពកសិកម្ម ក៏ដូចជាវប្បធម៌ជនជាតិដើមភាគតិចរបស់ខេត្ត គឺជាសម្បត្តិដ៏សំខាន់ និងវិសេសវិសាលសម្រាប់ការអភិវឌ្ឍវិស័យនេះ។ ស្របពេលជាមួយគ្នា ការអភិវឌ្ឍទេសចរណ៍ដោយមានទំនួលខុសត្រូវផ្សារភ្ជាប់នឹងគុណតម្លៃបរិស្ថាន និងវប្បធម៌ប្រពៃណី មានសារៈសំខាន់ដើម្បីថែរក្សាភាពវិសេសគ្មានពីរសម្រាប់ខេត្តមណ្ឌលគិរី។
- **ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព ដែលគិតគូរដល់ជីវៈចម្រុះ និងផលប្រយោជន៍កសិករខ្នាតតូច÷** ការអភិវឌ្ឍដោយយកចិត្តទុកដាក់លើការនាំចេញដែលមានទុនពឹងផ្អែកលើផ្នែកកសិ-ឧស្សាហកម្ម (ដីសម្បទានសេដ្ឋកិច្ច និងចម្ការដំណាំឯកជនខ្នាតមធ្យម) និងកសិកម្មខ្នាតតូចជាលក្ខណៈគ្រួសារដែលកំពុងមានកំណើន។ វិស័យទាំងពីរ នឹងវិវត្តរួមគ្នាតាមរយៈភាពជាដៃគូប្រកបដោយទំនួលខុសត្រូវ និងផ្តល់ផលប្រយោជន៍ទៅវិញទៅមក។ មាគ៌ានេះ ត្រូវដើរតាមគោលការណ៍ពិពិធកម្មកសិកម្មតាមបែបធម្មជាតិដែលអនុញ្ញាតឱ្យមានការបង្កើនផលិតកម្ម និងផលិតភាព ការអភិវឌ្ឍធនធានធម្មជាតិ ដូចជាដី និងទឹក ព្រមទាំងបង្កើនភាពធន់របស់គ្រួសារ និងជីវភាពកសិករទប់ទល់ពេលអាកាសធាតុមិនទៀងទាត់។
- **មជ្ឈមណ្ឌលប៉ូលអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិភាគឦសានប្រកបដោយភាពរស់រវើកផ្សារភ្ជាប់ទៅនឹងការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម÷** ខេត្តមណ្ឌលគិរីជាខេត្តមួយស្ថិតក្នុងតំបន់

ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម ដែលមានសេដ្ឋកិច្ចរស់រវើក និងចូលរួមចំណែកក្នុងការខិតខំប្រឹងប្រែងសមាហរណកម្មអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ តាមរយៈការផ្តល់សេវាកម្មដឹកជញ្ជូន ការជំរុញផលិតកម្មកសិ-ឧស្សាហកម្មមានគុណភាពខ្ពស់ ការអភិវឌ្ឍឧស្សាហកម្មធុនស្រាលផ្អែកលើចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ ការជំរុញពាណិជ្ជកម្មឌីជីថល និងជាច្រកទ្វារពាណិជ្ជកម្មជាមួយប្រទេសវៀតណាម និងតំបន់។

- **ការរីកចម្រើននៃនគរូបនីយកម្មដែលផ្តល់តម្លៃលើធម្មជាតិ និងទេសភាព÷** ក្នុងបរិបទនៃការរីកលូតលាស់នៃសេដ្ឋកិច្ច និងការកើនឡើងនៃអត្រាចំណូលស្រុកខ្ពស់នាពេលអនាគត ចំនួនប្រជាជននៅតាមទីប្រជុំជនក្នុងខេត្ត នឹងមានសម្ពាធទាំងលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តលើដី និងសេវាកម្មគ្រប់ប្រភេទ។ ការលើកកម្ពស់ការអភិវឌ្ឍទីក្រុង និងទីប្រជុំជនបៃតងក៏នឹងកាត់បន្ថយ ឧស្ម័នផ្ទះកញ្ចក់ និងកម្រិតផលប៉ះពាល់នៃនគរូបនីយកម្មចំពោះការប្រែប្រួលអាកាសធាតុ។

ព្រមជាមួយសសរស្តម្ភទាំង៥ខាងលើ ការរៀបចំដែនដីខេត្តមណ្ឌលគិរី តម្រង់គោលបំណងអភិវឌ្ឍ រយៈពេលវែងសំខាន់ៗចំនួន៥ រួមមាន÷

- ទទួលបានការអភិរក្សជីវៈចម្រុះប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍជីវភាពរស់នៅរបស់ប្រជាជននៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ (ដែនជម្រកសត្វព្រៃ និងរបៀងអភិរក្សជីវៈចម្រុះ)
- ជំរុញការអភិវឌ្ឍអេកូទេសចរណ៍ផ្សារភ្ជាប់នឹងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន
- លើកកម្ពស់ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាពសម្រាប់កសិករខ្នាតតូច ព្រមទាំងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាននៅក្រៅតំបន់ការពារធម្មជាតិ
- ពង្រឹងតួនាទីរបស់ខេត្តមណ្ឌលគិរីនៅក្នុងការអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់
- ជំរុញការអភិវឌ្ឍនគរូបនីយកម្មដែលយកចិត្តទុកដាក់លើការផ្តល់សេវាសាធារណៈប្រកបដោយនិរន្តរភាព និងបរិយាបន្នទៅគ្រប់កម្រិត។

### ៣.២- ការអភិរក្សបរិស្ថាន និងធនធានធម្មជាតិ

ខេត្តមណ្ឌលគិរី មានតំបន់ការពារធម្មជាតិចំនួន ៥ ដែលមានផ្ទៃដីសរុបប្រមាណ ១.១៨៥.៦៦១ ហិកតា ដែលជាប្រភេទដែនជម្រកសត្វព្រៃ សម្បូរទៅដោយព្រៃស្រោង ព្រៃល្បោះ និងវាលស្មៅ។ តំបន់ការពារធម្មជាតិទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន បន្ទាប់ពីមានការកែសម្រួលសមត្ថកិច្ចគ្រប់គ្រងជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួងបរិស្ថានបានកំពុងរៀបចំក្រមបរិស្ថាន ដើម្បីធានាប្រសិទ្ធភាពការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ។ ការបង្កើតនូវដែនជម្រកសត្វព្រៃស្រែពក ក៏ជាលទ្ធផលនៃកំណែទម្រង់ការងារអភិរក្សនេះផងដែរ។ ដែនជម្រកសត្វព្រៃទាំង ៥ រួមមាន ដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃណាមលៀរ ដែនជម្រកសត្វព្រៃលំផាត់ ដែនជម្រកសត្វព្រៃស្រែពក និងដែនជម្រកសត្វព្រៃកែវសីមា។

តារាងទី៩÷ សង្ខេបព័ត៌មានទូទៅរបស់ដែនជម្រកសត្វព្រៃទាំង០៥

| ល.រ. | ដែនជម្រកសត្វព្រៃ | ឆ្នាំបង្កើត | ផ្ទៃដី | ទីតាំង | ខេត្ត |
|---|---|---|---|---|---|
| ១ | ភ្នំព្រេច | ០១/១១/៩៣ | ២២២.៥០០ | កែវសីមា | មណ្ឌលគិរី |
| ២ | ណាមលៀរ | ០១/១១/៩៣ | ៤៧.៥០០ | ពេជ្រាដា | មណ្ឌលគិរី |

| | | | | | |
|---|---|---|---|---|---|
| ៣ | លំផាត់ | ០១/១១/៩៣ | ២៥០.០០០ | លំផាត់ | មណ្ឌលគិរី រតនគិរី |
| ៤ | ស្រែពក | ០៩/០៥/១៦ | ៣៧២.៩៧១ | កោះញែក | មណ្ឌលគិរី |
| ៥ | កែវសីមា | ០៩/០៥/១៦ | ២៩២.៦៩០ | កែវសីមា ស្នួល | មណ្ឌលគិរី ក្រចេះ |

(ប្រភព៖ មន្ទីរបរិស្ថានខេត្តមណ្ឌលគិរី)

- **ដែនជម្រកសត្វព្រៃភ្នំព្រេច៖** មានទីតាំងស្ថិតនៅចន្លោះដែនជម្រកសត្វព្រៃស្រែពក និងដែនជម្រកសត្វព្រៃកែវសីមា ដែលមានផ្ទៃដីប្រមាណជាងម៉ឺនគីឡូម៉ែត្រក្រឡា និងត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យនៅឆ្នាំ១៩៩៣។ សត្វព្រៃយ៉ាងហោចណាស់ ៣០ប្រភេទ បានកំពុងរស់នៅក្នុងដែនជម្រកសត្វព្រៃភ្នំព្រេចនេះ ដែលមួយចំនួនធំគឺជាសត្វក្នុងបញ្ជីនៃអង្គការអភិរក្សធនធានធម្មជាតិអន្តរជាតិ (IUCN)។ ដែនជម្រកសត្វព្រៃភ្នំព្រេច មានសារសំខាន់ផ្នែកវប្បធម៌ សេដ្ឋកិច្ច និងសង្គម សម្រាប់សហគមន៍មូលដ្ឋានដែលរស់នៅ និងអាស្រ័យផលនៅទីនោះ
- **ដែនជម្រកសត្វព្រៃភ្នំណាមលៀរ៖** គឺជាកន្លែងអភិរក្សសត្វព្រៃ និងជាជម្រកសត្វព្រៃ និងសត្វស្លាបជាច្រើនប្រភេទ និងពោរពេញទៅដោយច្រាំងថ្មស្អាតៗ ទឹកជ្រោះតូចៗ អូរ និងទេសភាពខៀវស្រងាត់
- **ដែនជម្រកសត្វព្រៃកែវសីមា៖** មានប្រព័ន្ធអេកូឡូស៊ីសម្បូរបែប ក្នុងនោះប្រភេទសត្វកម្រ និងប្រភេទសត្វជិតផុតពូជនៅលើពិភពលោកប្រមាណ ៦០ ប្រភេទ ដូចជាសត្វស្វាព្រាមជាដើម។ ពិសេសជាងនេះទៅទៀត ដែនជម្រកសត្វព្រៃកែវសីមា ជាកន្លែងដែលមានសត្វឆ្មារចំនួន ៧ ប្រភេទ ហើយក៏ជាកន្លែងអភិរក្សអន្តរជាតិលើប្រភេទសត្វដំរីអាស៊ីផងដែរ
- **ដែនជម្រកសត្វព្រៃស្រែពក៖** គឺជាជម្រកសម្រាប់ប្រភេទសត្វកំពុងរងគ្រោះជាសាកលជាច្រើនដូចជាដំរីអាស៊ី ខ្លារខិន ខ្លាពពក ទន្សោង ត្រយ៉ងយក្ស ត្រយ៉ងចង្កឹកស និងក្រពើភ្នំជាដើម
- **ដែនជម្រកសត្វព្រៃលំផាត់៖** គឺជាជម្រកសត្វជាច្រើន ដូចជា ដំរី ខ្ទីង ខ្លា ក្របីព្រៃ ខ្លាឃ្មុំ ពពួកសត្វស្វា និងសត្វស្លាបប្រមាណ ១០០ ប្រភេទផងដែរ។ ក្រៅពីផ្តល់ជម្រកដល់សត្វព្រៃ ដែនជម្រកសត្វព្រៃលំផាត់ ក៏ជាជម្រក និងប្រភពចំណូលដល់អ្នកស្រុកជាច្រើនគ្រួសារ ដែលភាគច្រើនជាជនជាតិដើមភាគតិច។

តាមការសិក្សា ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិក្នុងខេត្តមណ្ឌលគិរី បានកំពុងទទួលរងនូវផលប៉ះពាល់អវិជ្ជមានមួយចំនួន រួមមាន៖

- ផ្ទៃដីខេត្តមណ្ឌលគិរីប្រមាណ ៨០% ជាតំបន់អភិរក្សធនធានធម្មជាតិ ដែលតម្រូវឱ្យមានការគ្រប់គ្រងតំបន់ទាំងនោះប្រកបដោយនិរន្តរភាព ខណៈដែលផ្ទៃដីជាក់ស្តែងមួយចំនួននាពេលបច្ចុប្បន្ន កំពុងទទួលរងនូវការទន្ទ្រាន និងការកាន់កាប់ផ្ទុយពីមូលដ្ឋានច្បាប់
- ការរៀបចំឱ្យមានការគ្រប់គ្រងធនធានតាមបែបសហគមន៍ អាចជាដំណោះស្រាយមួយដូចបានកំណត់ក្នុងអនុក្រឹត្យបែងចែកតំបន់ដែនជម្រកសត្វព្រៃ។ ប៉ុន្តែការកំណត់ព្រំប្រទល់តំបន់នីមួយៗឱ្យបានច្បាស់លាស់ និងការតាមដានជាប្រចាំការអនុវត្តលក្ខន្តិកៈដោយសមូហភាពសហគមន៍ ជាកិច្ចការសំខាន់ធានាការអាស្រ័យផលធនធានព្រៃឈើស្របតាមលក្ខណៈបច្ចេកទេស

- ការបណ្តុះបណ្តាល និងការផ្តល់មុខរបរ ជាជម្រើសជំនួសការប្រមូលអនុផលព្រៃឈើ និងកសិកម្មវិលជុំ ដូចជាទេសចរណ៍បែបសហគមន៍ជាដើម ដែលអាចបង្វែរទំនៀមទម្លាប់ចាស់របស់សហគមន៍ជនជាតិដើមភាគតិច និងបង្កើនប្រាក់ចំណូល។

ជាចក្ខុវិស័យក្នុងផែនការមេទាក់ទងនឹងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ គួរមានការគិតគូរនូវការងារចាំបាច់មួយចំនួន រួមមាន÷

- ធ្វើការចុះបញ្ជី និងកំណត់ព្រំប្រទល់នៃដែនជម្រកសត្វព្រៃទាំង៥ ឱ្យបានច្បាស់លាស់ឡើងវិញ ឈរលើគោលនយោបាយច្បាស់លាស់របស់រាជរដ្ឋាភិបាល
- រៀបចំផែនការអភិវឌ្ឍក្នុងតំបន់ដែនជម្រកសត្វព្រៃទាំង៥ និងកំណត់វិសាលភាពនៃសកម្មភាពវិនិយោគ និងអភិវឌ្ឍន៍ ដែលគួរត្រូវបានលើកទឹកចិត្ត និងអនុញ្ញាតឱ្យមានក្នុងតំបន់ទាំង៥
- ពិនិត្យលទ្ធភាពរៀបចំតំបន់ដែនអភិរក្សទាំង៥ ជាតំបន់ឧទ្យានជាតិ ដោយមានការសិក្សាបញ្ចូលសកម្មភាពទេសចរណ៍ អេកូទេសចរណ៍ និងទេសចរណ៍សហគមន៍ជាដើម ឈរលើទស្សនទាន "ការអភិវឌ្ឍបម្រើដល់ការអភិរក្ស ការអភិរក្សទ្រទ្រង់ដល់ការអភិវឌ្ឍ"។

### ៣.៣- ការប្រើប្រាស់ និងផ្គត់ផ្គង់ទឹកស្អាត

**ក- <u>ការប្រើប្រាស់ទឹកស្អាតរបស់មូលដ្ឋានអាជីវកម្មទេសចរណ៍</u>**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងអភិវឌ្ឍន៍ជនបទ បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តិទី៦ ដោយបានផ្តល់អាទិភាពខ្ពស់ដល់ការអភិវឌ្ឍវិស័យទឹកស្អាតនៅតំបន់ទីប្រជុំជន និងទីជនបទ ជូនដល់ប្រជាពលរដ្ឋឱ្យទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់ប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាជនដែលរស់នៅក្នុងតំបន់ទីប្រជុំជនជាយក្រុង និងជនបទ តាមរយៈការពង្រីកសមត្ថភាពផលិត និងលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជនក្នុងការវិនិយោគលើវិស័យផ្គត់ផ្គង់ទឹកស្អាត។

ការគ្រប់គ្រងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជាសិទ្ធិផ្តាច់មុខរបស់រដ្ឋ។ ក្នុងស្ថានភាព និងកាលៈទេសៈចាំបាច់ រដ្ឋអាចធ្វើការផ្ទេរសិទ្ធិនេះជូនដល់វិស័យឯកជន ដើម្បីផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ និងផ្នែកផលិតកម្ម-សេវាកម្ម។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានសមត្ថកិច្ចរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រផែនការមេ សម្រាប់ដឹកនាំគ្រប់គ្រងវិស័យទឹកស្អាត និងគ្រប់គ្រង ត្រួតពិនិត្យសេវាផ្គត់ផ្គង់ទឹកស្អាតដែលមានលក្ខណៈអាជីវកម្មទាំងរូបវន្តបុគ្គល ឬនីតិបុគ្គល ទាំងវិស័យសាធារណៈ ចម្រុះរដ្ឋ-ឯកជន និងឯកជន។

ផ្អែកតាមរបាយការណ៍របស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅទូទាំងខេត្តមណ្ឌលគិរី មានអង្គភាព/ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ៥ ទីតាំង ក្នុងនោះ អង្គភាពរដ្ឋាករទឹកសាធារណៈមាន ១ ទីតាំង គឺអង្គភាពរដ្ឋាករទឹកខេត្តមណ្ឌលគិរី ស្ថិតនៅក្នុងក្រុងសែនមនោរម្យ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនដែលទទួលបានអាជ្ញាប័ណ្ណពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មាន៤ ទីតាំង គឺ ២ ទីតាំងស្ថិតនៅក្នុងស្រុកកែវសីមា ១ ទីតាំងស្ថិតនៅក្នុងស្រុកកោះញែក និង ១ ទីតាំងស្ថិតនៅក្នុងស្រុកពេជ្រាដា។

## ខ- ការប្រើប្រាស់ទឹកស្អាតរបស់ប្រជាពលរដ្ឋមូលដ្ឋាន

យោងតាមស្ថិតិរបស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចំនួនគ្រួសារក្នុងខេត្តមណ្ឌលគិរី ដែលមានទឹកស្អាតប្រើប្រាស់មានប្រមាណ ១៥%។ ភាគច្រើននៃប្រជាពលរដ្ឋនៅតាមបណ្តាស្រុក និងជនបទបានប្រើប្រាស់ទឹកអណ្តូង និងប្រភពទឹកផ្សេងៗសម្រាប់ប្រើប្រាស់ និងបរិភោគ។

ដោយឡែក តាមការចុះសម្ភាសន៍ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ការប្រើប្រាស់ទឹកស្អាតរបស់រដ្ឋមានប្រមាណ ៨% ខណៈដែលភាគរយនៃអ្នកប្រើប្រាស់ទឹកអណ្តូងមានចំនួនរហូតដល់ ៦២% (ភាគច្រើនជាសមាជិកគ្រួសារស្ថិតនៅតាមមូលដ្ឋានសហគមន៍ដាច់ស្រយាល) ក្នុងនោះ ការប្រើប្រាស់ទឹកភ្លៀងមាន ១០% (នៅរដូវវស្សា) ការប្រើប្រាស់ទឹកអូរមានចំនួន ១៧% ហើយ ៣% ប្រជាពលរដ្ឋប្រើប្រាស់ប្រភពទឹកផ្សេងៗ (ដូចមានក្នុងក្រាហ្វិកបន្ថែមទី៤ និងទី៥នៃឧបសម្ព័ន្ធ គ)។

ផ្អែកទៅលើលទ្ធផលខាងលើ ការផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្តមណ្ឌលគិរីនៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់ពេញលេញនៅឡើយក្នុងស្ថានភាពបច្ចុប្បន្ន និងនាពេលអនាគតដែលភ្ញៀវទេសចរនឹងមានកំណើនខ្ពស់ ព្រមជាមួយការកើនឡើងនូវសកម្មភាពសេដ្ឋកិច្ចនានា។ កង្វះខាតទឹកស្អាត និងអនាម័យក៏ជាបញ្ហាប្រឈមសម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមជនបទ និងនៅតាមសហគមន៍ជនជាតិដើមភាគតិច។ ប្រជាពលរដ្ឋបានលើកឡើងថា នៅរដូវប្រាំងពួកគាត់មិនត្រឹមតែប្រឈមនឹងបរិមាណទឹកស្អាតប្រើប្រាស់មិនគ្រប់គ្រាន់នោះទេ ប៉ុន្តែគឺជួបប្រទះនឹងកង្វះខាតទឹកប្រើប្រាស់តែម្តង ដោយសារតែអណ្តូងដែលពួកគាត់ប្រើប្រាស់ រីងហួតមិនមានទឹក ហើយពួកគាត់ត្រូវទិញទឹកពីតំបន់ផ្សេងមកប្រើប្រាស់។

ដោយឡែក ចាប់តាំងពីមុនឆ្នាំ២០០៦ ខេត្តមណ្ឌលគិរីមិនដែលមានរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតទេ។ នៅឆ្នាំ២០១៦ ដោយមានការជ្រោមជ្រែងពីរាជរដ្ឋាភិបាល ជាពិសេសពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រោមគម្រោងកិច្ចសហប្រត្តិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ខេត្តមណ្ឌលគិរីទទួលបានគម្រោងមួយ គឺគម្រោងផ្គត់ផ្គង់ទឹកស្អាតខេត្តមណ្ឌលគិរី ក្រោមក្របខណ្ឌគម្រោងអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម និងជំនួយហិរញ្ញប្បទានឥតសំណងពី (Japan Asean Integrated Fund) ដើម្បីសាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អាត ដែលមានសមត្ថភាពផលិតទឹកស្អាតបាន ២.០០០ ម៉ែត្រគូបក្នុងមួយថ្ងៃ។

ជារួម ការប្រើប្រាស់ និងផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្តមណ្ឌលគិរី អាចប្រឈមនឹងបញ្ហាមួយចំនួន រួមមាន÷

- ទីតាំងភូមិសាស្ត្រខេត្តមណ្ឌលគិរី ហាក់មិនមានលក្ខណៈអំណោយផលពេញលេញដល់ការរៀបចំបណ្តាញផ្គត់ផ្គង់ទឹកស្អាត មានន័យថា ការតភ្ជាប់បណ្តាញទឹកអាចធ្វើទៅបាន ប៉ុន្តែកម្លាំងជំរុញទឹកនៅមានកម្រិត
- មិនទាន់មានប្រភពទឹកឆៅគ្រប់គ្រាន់ និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទូលំទូលាយ ដើម្បីធានាបាននូវនិរន្តរភាពក្នុងការផ្គត់ផ្គង់ទឹកស្អាតនៅទូទាំងខេត្តមណ្ឌលគិរីនៅឡើយ
- ការទន្ទ្រានរំលោភយកដីប្រភពទឹកសំខាន់ៗ ដែលត្រូវយកមកធ្វើជាប្រភពទឹកសម្រាប់ផលិតទឹកស្អាតជូនប្រជាពលរដ្ឋ
- ការបង្ហូរសារធាតុដែលមានជាតិពុលផ្សេងៗចូលទៅក្នុងប្រភពទឹកសម្រាប់ផលិតទឹកស្អាត
- របាយរាយប៉ាយនៃការរស់នៅរបស់ប្រជាជន ក៏ជាហេតុនាំឲ្យពិបាកក្នុងការផ្គត់ផ្គង់ទឹកស្អាតឲ្យបានពេញលេញដល់ប្រជាពលរដ្ឋទាំងអស់
- ការគ្រប់គ្រងសំណល់រឹង និងរាវរបស់ប្រជាពលរដ្ឋនៅជុំវិញប្រភពទឹក នៅមិនទាន់មានភាពល្អប្រសើរ និងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ជាចក្ខុវិស័យពាក់ព័ន្ធនឹងបញ្ហាទឹកស្អាតនេះ គួរមានការគិតគូរនូវការងារចាំបាច់មួយចំនួន រួមមាន÷

- ជំរុញឲ្យមានការសិក្សាបង្កើតអនុស្ថានីយទឹកស្អាតយ៉ាងហោច ១ នៅតាមស្រុកទាំង៤
- ជំរុញឲ្យមានទឹកស្អាតប្រើប្រាស់នៅតាមភូមិ ឃុំ និងស្រុកទាំងអស់ មិនថាក្នុងក្របខណ្ឌរដ្ឋ និងឯកជន ឬលក្ខខណ្ឌណាមួយផ្សេងទៀត
- ជំរុញឲ្យមានការសិក្សាទៅលើប្រភពទឹកឆៅបន្ថែម ដើម្បីធានាឲ្យបានគ្រប់គ្រាន់នូវការផ្គត់ផ្គង់ទឹកស្អាត
- រក្សាការពារឲ្យបាននូវប្រភពទឹកដែលមានស្រាប់ ជៀសវាងការសាងសង់សំណង់ក្បែរប្រភពទឹក និងការបង្ហូរសំណល់ចូលប្រភពទឹកទាំងនោះ
- បន្តកិច្ចសហប្រតិបត្តិការស្នើភាពល្អជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីរកហិរញ្ញប្បទានសម្រាប់ការស្តារ និងពង្រីកសមត្ថភាពផ្គត់ផ្គង់ស្របតាមផែនការអភិវឌ្ឍន៍
- សិក្សា និងជំរុញលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់ផ្នែកឯកជនតាមរយៈការសហការជាមួយបណ្តាស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងធនាគារក្នុង និងក្រៅប្រទេស ដើម្បីជួយគាំទ្រដល់ផ្នែកឯកជនក្នុងការទទួលបានប្រាក់កម្ចីដែលមានលក្ខណៈអនុគ្រោះដល់វិស័យឯកជន
- ជំរុញលើកទឹកចិត្តឱ្យមានការចូលរួមវិនិយោគពីវិស័យឯកជន តាមរយៈការបង្កើតនូវគោលនយោបាយក្របខណ្ឌច្បាប់នានា សម្រួលដល់បរិយាកាសវិនិយោគក្នុងការទាក់ទងភាពជាដៃគូសាធារណៈ ឯកជន ព្រមទាំងការលើកទឹកចិត្តដល់ការវិនិយោគឯកជន
- សហការជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍វិស័យទឹកស្អាតឱ្យបានរលូន។

### ៣.៤- ការប្រើប្រាស់ និងផ្គត់ផ្គង់អគ្គិសនី

ខេត្តមណ្ឌលគិរី មានសក្តានុពលសាងសង់វារីអគ្គិសនីខ្នាតធំ មធ្យម និងតូច ដោយសារមានទន្លេ ស្ទឹង ភ្នំ ខ្ពង់រាប និងជ្រលង។ ជាក់ស្តែង នៅផ្នែកខាងលើនៃទន្លេស្រែពកក្នុងប្រទេសវៀតណាម កំពុងមានការសាងសង់ទំនប់វារីអគ្គិសនី។ នៅក្នុងអាងទន្លេស្រែពកនៅក្នុងខេត្តមណ្ឌលគិរី ក៏មានគម្រោងស្រែពក ក្រោម៣ (អានុភាព ៣៣០ មេហ្គាវ៉ាត់) និងស្រែពកក្រោម៤ (អានុភាព ៤៨មេហ្គាវ៉ាត់) ដែលបានកំពុងសិក្សាសមិទ្ធិលទ្ធភាព។

យោងតាមស្ថិតិរបស់មន្ទីររ៉ែ និងថាមពលខេត្តមណ្ឌលគិរី ភូមិសរុបទូទាំងខេត្តមានចំនួន ៩២ភូមិ និងមានខ្នងផ្ទះសរុប ៤១.២០៧ខ្នងផ្ទះ ហើយភូមិទទួលបានប្រភពអគ្គិសនីពីបណ្តាញជាតិមានចំនួន ៧៣ភូមិ ដែលត្រូវជាខ្នងផ្ទះចំនួន ១១.៣០៦ខ្នងផ្ទះ ស្មើនឹង ២៧%នៃខ្នងផ្ទះសរុបទូទាំងខេត្ត ក្រៅពីនោះគឺជាការផ្គង់ផ្គង់ថាមពលបានមកពីការប្រើប្រាស់អាគុយ និងថាមពលពន្លឺព្រះអាទិត្យ ហើយក្នុងនោះផងដែរ បានត្រៀមធ្វើការផ្គត់ផ្គង់ថាមពលអគ្គិសនីតាមរយៈខ្សែបណ្តាញអគ្គិសនី ២៣០ គីឡូវ៉ុល ទៅឲ្យក្រុមហ៊ុនរ៉ែអាលុយមីញ៉ូម ៦០ មេហ្គាវ៉ាត់ និង ១៥ មេហ្គាវ៉ាត់ ទៅឲ្យក្រុមហ៊ុនផ្សេងៗទៀត។ ប្រភពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីសំខាន់ៗ ក្នុងខេត្តមណ្ឌលគិរី រួមមាន÷

- អគ្គិសនីដើរដោយម៉ាស៊ីនភ្លើង ដែលមានអានុភាព ៣០០ គីឡូវ៉ាត់ នៅក្នុងក្រុងសែនមនោរម្យ
- វារីអគ្គិសនីចំនួន ២ អានុភាព ៣៧០ គីឡូវ៉ាត់ កំពុងដំណើរការ (វារីអគ្គិសនីអូរម្លែងអានុភាព ១៨៥ គីឡូវ៉ាត់ និងវារីអគ្គិសនីអូររមើស អានុភាព ១៨៥ គីឡូវ៉ាត់)
- ការនាំចូលប្រភពថាមពលចំនួន ៣ ច្រក រួមមាន÷
  + ច្រកទ្វារដាក់ដាំ (ស្រុកអូររាំង ២ មេហ្គាវ៉ាត់)
  + ច្រកទ្វារឡាប៉ាខេ (ស្រុកកែវសីម៉ា ២ មេហ្គាវ៉ាត់)
  + ស្រុកកោះញែក (ស្រុកលំផាត់ខេត្តរតនគិរី ៤ មេហ្គាវ៉ាត់)។

តារាងទី១០÷ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តមណ្ឌលគិរី ឆ្នាំ២០២០

| ល.រ | ឈ្មោះក្រុង/ស្រុក | ខ្នងផ្ទះសរុប | ខ្នងផ្ទះប្រើប្រាស់អគ្គិសនី | គិតជាភាគរយ |
|---|---|---|---|---|
| ១ | សែនមនោរម្យ | ៦ ២៣៣ | ៤ ៧១៩ | ៧៦% |
| ២ | អូររាំង | ៣ ២៧៤ | ១ ៣១១ | ៤០% |
| ៣ | កែវសីមា | ១៣ ២១៧ | ២ ៤៤៩ | ១៩% |
| ៤ | កោះញែក | ៩ ៣៧១ | ១ ៧១៣ | ១៨% |
| ៥ | ពេជ្រាដា | ៩ ១១២ | ១ ១១៤ | ១២% |
| សរុប | | ៤១ ២០៧ | ១១ ៣០៦ | ២៧% |

(ប្រភព÷ មន្ទីររ៉ែ និងថាមពលខេត្តមណ្ឌលគិរី)

ដោយឡែក តាមរយៈការធ្វើអង្កេតការប្រើប្រាស់ថាមពលអគ្គិសនីនៅតាមមូលដ្ឋានអាជីវកម្មភាគច្រើនពឹងផ្អែកលើប្រភពអគ្គិសនីពីបណ្តាញជាតិ ប៉ុន្តែម្ចាស់អាជីវកម្មមួយចំនួនក៏បានលើកអំពីបញ្ហារអាក់រអួល (ដាច់ចរន្ត) នៅពេលមានភ្លៀងធ្លាក់។

ផ្អែកលើទិន្នន័យ និងការវិភាគបច្ចេកទេស ថាមពលអគ្គិសនីក្នុងខេត្តមណ្ឌលគិរីត្រូវបានប្រើប្រាស់ ទៅលើវិស័យលំនៅដ្ឋាន សកម្មភាពអាជីវកម្ម និងពាណិជ្ជកម្ម ហើយក្នុងនោះអនុវិស័យដែលប្រើប្រាស់ថាមពលធំ គឺអាជីវកម្មរ៉ែ និងមួយផ្នែកទៀតផ្គត់ផ្គង់ទៅលើវិស័យសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម។

ជារួម ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តមណ្ឌលគិរី បានកំពុងរងនឹងកត្តាប៉ះពាល់មួយចំនួន រួមមាន÷

- កង្វះខាតថាមពលអគ្គិសនីប្រើប្រាស់មិនទាន់ពេញលេញនៅតាមបណ្តាភូមិ និងរមណីយដ្ឋានទេសចរណ៍មួយចំនួនក្នុងខេត្ត
- ការពង្រីកបណ្តាញអគ្គិសនីនៅពុំទាន់បានគ្របដណ្តប់ក្នុងភូមិទាំងអស់ទូទាំងខេត្តមណ្ឌលគិរី
- ការរអាក់រអួលខ្លះៗ (ដាច់ចរន្តអគ្គិសនី) នារដូវវស្សា ដោយសារការទាញយកថាមពលអគ្គិសនីមួយចំនួនមានរយៈចំងាយឆ្ងាយពីប្រទេសវៀតណាម

ជាចក្ខុវិស័យ គួរមានការគិតគូរនូវការងារចាំបាច់នាពេលបច្ចុប្បន្នមួយចំនួន រួមមាន÷

- ធានាការផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យបានគ្រប់គ្រាន់ អាចទុកចិត្តបាន មានគុណភាព និងថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទនៅទូទាំងខេត្តមណ្ឌលគិរី។
- លើកទឹកចិត្តឱ្យមានការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន
- លើកទឹកចិត្តឱ្យមានការសិក្សា រុករក និងការអភិវឌ្ឍប្រភពថាមពលបៃតង (ថាមពលដើរដោយខ្យល់ និងថាមពលពន្លឺព្រះអាទិត្យ) ដើម្បីបំពេញបន្ថែមការផ្គត់ផ្គង់ទៅគ្រប់វិស័យក្នុងខេត្ត
- ពិនិត្យលទ្ធភាពក្នុងការសិក្សាស្វែងរកប្រភពថាមពលវារីអគ្គិសនីទន្លេស្រែពក ដើម្បីផលិតថាមពលអគ្គិសនីឱ្យបានកាន់តែច្រើនសម្រាប់ផ្គត់ផ្គង់ក្នុងខេត្ត និងចែកចាយទៅតំបន់ផ្សេងទៀតក្នុងប្រទេស។

### ៣.៥- ការគ្រប់គ្រងសំណល់

#### ក- ការគ្រប់គ្រងសំរាម និងសំណល់រឹង

ខេត្តមណ្ឌលគិរី មានទីលានចាក់សំរាម ២ កន្លែង ក្នុងនោះ ១ កន្លែងមានទំហំប្រមាណ ១ ហិកតា ស្ថិតក្នុងក្រុងសែនមនោរម្យ ភូមិស្វាយចេក សង្កាត់សុខដុម និង ១ កន្លែងទៀតស្ថិតក្នុងស្រុកកែវសីមា ភូមិអូរណា ឃុំស្រែខ្ទុម ខាងលិចផ្សារកែវសីមា ចម្ងាយប្រមាណ ១ គីឡូម៉ែត្រ។

ដោយឡែក ស្រុកពេជ្រាដា និងស្រុកអូររាំង មិនទាន់មានទីតាំងចាក់សំរាមនៅឡើយ។ ប៉ុន្តែអាជ្ញាធរស្រុកទាំង ២ កំពុងដំណើរការ និងកំណត់ទីតាំងដើម្បីដាក់ស្នើរួចរាល់ហើយ។ ទីតាំងនៅក្នុងស្រុកពេជ្រាដា អាចមាន ៤ កន្លែងសម្រាប់ជ្រើសរើស គឺនៅភូមិពូទិល ឃុំប៊ូស្រា (៣,៤១ ហិកតា) ភូមិពូតាំង ឃុំពូជ្រៃ (២,១៧ ហិកតា) ភូមិពូក្រែង ឃុំអំពូម (៥,៣៦ ហិកតា) និងភូមិពូរ៉ាប៉ែត ឃុំក្រង់តេះ (៥,៨៦ ហិកតា)។ ចំណែកនៅស្រុកអូររាំង បានកំណត់ទីតាំង ១ កន្លែង គឺនៅភូមិអណ្តូងក្រឡឹង ឃុំសែនមនោរម្យ (០,៨ ហិកតា) តែមិនទាន់គ្រប់គ្រាន់សម្រាប់ការរក្សាទុកសំណល់ទូទាំងស្រុកបានទេ។ ស្រុកកោះញែកបានស្នើទីតាំង ២ កន្លែង នៅភូមិមេមុំ ឃុំរយ៉ (៥,២៧៨ ហិកតា) និងភូមិចំរើន ឃុំស្រែសង្គម (៥,០៧ ហិកតា)។

ទន្ទឹមនឹងនេះ ទីលានចាក់សំរាមដែលមានស្រាប់នៅមិនទាន់សមស្របទៅនឹងស្តង់ដាបច្ចេកទេសនៅឡើយ ខណៈដែលផ្ទៃដីមានទំហំតូច មិនទាន់សមស្របទៅតាមតម្រូវការជាក់ស្តែង ក៏ដូចជាថ្ងៃអនាគត។ ម៉្យាងវិញទៀត ទីលានចាក់សំរាមនៅក្នុងក្រុងសែនមនោរម្យនឹងក្លាយជាគោលដៅពង្រីកទីក្រុងក្នុងថ្ងៃខាងមុខ។ ការរៀបចំឱ្យមានទីលានចាក់សំរាមត្រូវផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង ទុកដាក់ និងការចោលសំរាមនៅទីលានដែលបានកំណត់ជាសាធារណៈរបស់រដ្ឋដើម្បីសុខភាពសាធារណៈ ជាពិសេសនិរន្តរភាពទេសចរណ៍។ ការប្រមូល និងទុកដាក់សំរាមប្រកបដោយអនាម័យចាំបាច់ត្រូវមានការចូលរួមពីសាធារណជន និងអាជីវកម្មឯកជន។ នៅឆ្នាំ២០១៨ សមាសភាពគ្រួសារ ដែលទទួលសេវាប្រមូលសំរាមនៅក្រុងសែនមនោរម្យ មានប្រមាណ ២៨% និង ០,៨% នៅស្រុកកែវសីមា។ ចំណែកស្រុកដទៃទៀត ពុំទាន់មានសេវាកម្មប្រមូលសំរាមនៅឡើយ។ រដ្ឋបាលខេត្ត បានកំពុងជំរុញដល់រដ្ឋបាលក្រុង/ស្រុក ឱ្យសិក្សារកទីតាំងចាក់សំរាមបន្ថែម ដែលអាចឆ្លើយតបទៅនឹងកំណើនប្រជាជន និងភ្ញៀវទេសចរ ដោយត្រូវសាងសង់តាមស្តង់ដាបច្ចេកទេសឱ្យបានត្រឹមត្រូវ។

ចំពោះមូលដ្ឋានអាជីវកម្មទេសចរណ៍ ដូចជាសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន ដែលមានទីតាំងក្នុងក្រុងសែនមនោរម្យ បានលើកឡើងពីការប្រមូលសំរាមមិនសូវទៀងទាត់។ ការប្រមូលសំរាមនៅមានកម្រិតនៅតាមរមណីយដ្ឋាន និងភោជនីយដ្ឋាននៅក្រៅក្រុង និងតំបន់ជាយក្រុង។ នៅកន្លែងដែលមិនទាន់ទទួលបានសេវាប្រមូលសំរាម ប្រជាពលរដ្ឋធ្វើការជីករណ្តៅកប់ ដុតចោល ឬទុកចោលតាមកន្លែងមួយចំនួន។ ចំពោះប្រជាពលរដ្ឋមូលដ្ឋានរស់នៅដាច់ស្រយាល ការទុកដាក់សំរាមគឺយកទៅកប់ ឬដុតចោល (ទិន្នន័យដូចមានក្នុងក្រាហ្វិកបន្ថែមទី៧នៃឧបសម្ព័ន្ធ គ)។

ទន្ទឹមនឹងនេះ សំរាមដែលមិនត្រូវបានប្រមូល ជាញឹកញាប់បានកកស្ទះនៅក្នុងបណ្តាញលូ (លូរំដោះទឹកភ្លៀង)។ នៅពេលមានភ្លៀងខ្លាំង សមត្ថភាពលូបង្ហូរនៅមានកម្រិត ដោយសារការកកស្ទះសំរាមទាំងនោះ។ តាមការព្យាករណ៍ដោយសារការប្រែប្រួលអាកាសធាតុ អត្រាភ្លៀងធ្លាក់កាន់តែខ្លាំង និងមានភាពញឹកញាប់ជាងមុន ដូច្នេះការប្រមូលសំរាមចាំបាច់ត្រូវតែធ្វើការកែលម្អឱ្យបានគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា ដើម្បីធានាឱ្យបានថា បណ្តាញលូរំដោះទឹកភ្លៀងមិនមានការហូរចូលនូវសំរាមដែលមិនបានប្រមូលពេញលេញ។

ដោយឡែក សំរាមដែលបានប្រមូល ត្រូវបានដឹកជញ្ជូនទៅចាក់នៅទីលានចាក់សំរាម ដែលស្ថិតនៅក្នុងក្រុង ដែលជាដីរបស់ឯកជន និងបន្តចាក់រហូតដល់បច្ចុប្បន្ន។ សាលាក្រុងសែនមនោរម្យ បានស្នើសុំទីតាំងចាក់សំរាមថ្មី ដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរបរិស្ថាន ដែលមានទំហំ ១៣៤ ហិកតា និងមានចំងាយប្រមាណ ១៥ គីឡូម៉ែត្រ ពីក្រុងសែនមនោរម្យ។

យោងតាមអនុក្រឹត្យលេខ ១១៣ អនក្រ/បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ការគ្រប់គ្រងសំរាមក្នុងទីប្រជុំជន ត្រូវបានផ្ទេរិមជ្ឈការទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការទទួលខុសត្រូវ ដោយបានផ្លាស់ប្តូរទៅថ្នាក់រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ។ ជាលទ្ធផល សាលាខេត្តមណ្ឌលគិរី បានផ្ទេរការទទួលខុសត្រូវលើការប្រមូលសំរាម ទៅឱ្យរដ្ឋបាលក្រុងសែនមនោរម្យ។

យោងតាមការចុះជួបជាមួយមន្ទីរ-អង្គភាពជំនាញក្នុងខេត្ត មានអង្គភាពមួយចំនួនពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុងសែនមនោរម្យ។ សាលាក្រុងសែនមនោរម្យ ជាអ្នកទទួលខុសត្រូវក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណល់ ដែលរួមមានការប្រមូល និងការដឹកជញ្ជូន។ ប៉ុន្តែ លទ្ធភាពក្នុងការអនុវត្តតាមគោលការណ៍ណែនាំនៅមានកម្រិត។ បច្ចុប្បន្ន សាលាក្រុងសែនមនោរម្យ បានកំពុងរៀបចំផែនការសម្រាប់កែលម្អការគ្រប់គ្រងសំណល់ក្នុងក្រុងសែនមនោរម្យ ដែលផែនការទាំងនេះ រួមមាន ៖

- គ្រប់គ្រងក្រុមហ៊ុនឯកជនដែលចូលរួមដេញថ្លៃក្នុងការប្រមូលសំរាម
- ការបែងចែកសំណល់
- ការប្រមូលសំរាម និងការដឹកជញ្ជូន
- ការកែច្នៃសំរាមឱ្យទៅជាជីកំប៉ុស
- ការប្រើប្រាស់ដី ១៣៤ ហិកតា ឱ្យទៅជាកន្លែងចាក់សំរាមរិលជុំ។

ជារួម ការគ្រប់គ្រងសំរាមនៅខេត្តមណ្ឌលគិរី បានកំពុងទទួលរងនូវបញ្ហាមួយចំនួន រួមមាន៖

- ការប្រមូលសំរាមនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍មួយចំនួនក្នុងក្រុងសែនមនោរម្យ នៅមិនទាន់មានភាពទៀងទាត់ពេញលេញ
- សំរាមនៅតាមជាយក្រុង និងគោលដៅទេសចរណ៍ ដែលស្ថិតនៅឆ្ងាយពីទីប្រជុំជនក្នុងក្រុង មិនទាន់ត្រូវបានប្រមូលឱ្យបានសមស្រប ខណៈដែលលទ្ធភាពក្រុមហ៊ុនប្រមូលសំរាម ហាក់នៅមានកម្រិតនៅឡើយ
- ការគ្រប់គ្រងសេវាប្រមូលសំរាមក៏ហាក់មិនទាន់មានភាពល្អប្រសើរពេញលេញ ដោយមិនសូវមានក្រុមហ៊ុនច្រើនចូលរួមដេញថ្លៃ និងមានភាពមិនដាច់ស្រេចក្នុងសមត្ថកិច្ចគ្រប់គ្រង ជាពិសេសរវាងសាលាក្រុងសែនមនោរម្យ និងមន្ទីរបរិស្ថានខេត្ត
- ផ្ទៃដី ១៣៤ ហិកតា ដែលបានស្នើសុំការអនុញ្ញាតសម្រាប់ធ្វើការចាក់សំរាមរិលជុំ កំពុងស្ថិតក្នុងការពិនិត្យអនុញ្ញាតពីក្រសួងបរិស្ថាន ប៉ុន្តែបានកំពុងត្រូវបានប្រើប្រាស់នាពេលបច្ចុប្បន្នរួចទៅហើយ។

**ខ- <u>ការគ្រប់គ្រងសំណល់រាវ</u>**

យោងតាមការចុះអង្កេតជាមួយមូលដ្ឋានអាជីវកម្មទេសចរណ៍ និងប្រជាពលរដ្ឋមូលដ្ឋាន សំណល់រាវដែលចេញពីមូលដ្ឋានអាជីវកម្ម និងពីផ្ទះប្រជាពលរដ្ឋត្រូវស្តុកទុកក្នុងអាងស្តុក ហើយប្រព័ន្ធលូសាធារណៈប្រើប្រាស់សម្រាប់តែរំដោះទឹកភ្លៀងប៉ុណ្ណោះ ដែលមកដល់សព្វថ្ងៃមិនទាន់មានការរៀបចំប្រព័ន្ធលូបង្ហូរសំណល់រាវនៅឡើយ។

ការគ្រប់គ្រងសំណល់រាវ ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដូចជាសាលាខេត្តមណ្ឌលគិរី សាលាក្រុងសែនមនោរម្យ មន្ទីរបរិស្ថាន និងមន្ទីរសាធារណៈការ និងដឹកជញ្ជូន ដើម្បីជំរុញធ្វើយ៉ាងណាធានាឱ្យការគ្រប់គ្រងសំណល់រាវមានភាពច្បាស់លាស់ និងឆ្លើយតបទៅនឹងកំណើនប្រជាជន និងកំណើនភ្ញៀវទេសចរនាពេលអនាគត។

បញ្ហាប្រឈមមួយចំនួនដែលកំពុងចោទឡើង រួមមាន÷

- ប្រជាពលរដ្ឋមួយចំនួន បានតភ្ជាប់ប្រព័ន្ធលូពីទីតាំងអាជីវកម្មទៅកាន់លូសាធារណៈ (លូរំដោះទឹកភ្លៀង) ដោយពុំបានឆ្លងកាត់ការអនុញ្ញាតពីសមត្ថកិច្ចជំនាញ
- មិនទាន់មានការសិក្សាអំពីទីតាំងសម្រាប់រៀបចំអាងប្រព្រឹត្តកម្មសំណល់រាវ
- ភូមិសាស្ត្រក្នុងខេត្តមណ្ឌលគិរី មិនមានលក្ខណៈអំណោយផលពេញលេញក្នុងការរៀបចំប្រព័ន្ធលូសាធារណៈ។

ជាចក្ខុវិស័យក្នុងផែនការមេទាក់ទងនឹងបញ្ហាគ្រប់គ្រងសំណល់រឹង រាវ និងបង្គន់អនាម័យ គួរមានការគិតគូរនូវការងារចាំបាច់មួយចំនួន រួមមាន÷

- ជំរុញឱ្យមានការអនុញ្ញាតលើការប្រើប្រាស់ដីដែលបានស្នើសុំនៅក្រសួងបរិស្ថាន ទៅជាទីលានចាក់សំរាមឱ្យបានឆាប់
- សិក្សា និងរៀបចំផែនការសម្រាប់ការប្រមូលសំរាមនៅតាមទីតាំងអាជីវកម្មដែលស្ថិតក្នុងក្រុងសែនមនោរម្យឱ្យបានទៀងទាត់
- សិក្សារៀបចំឱ្យមានការប្រមូលសំរាមនៅតាមបណ្តាទីប្រជុំជននៃស្រុកទាំង ៤
- សិក្សាគម្រោងក្នុងការប្រើប្រាស់សំរាមសម្រាប់កែច្នៃឡើងវិញ ឬកែច្នៃជាជីកំប៉ុស
- ជំរុញ និងលើកទឹកចិត្តឱ្យមានការវិនិយោគក្នុងការកែច្នៃសំរាម និងសំណល់នានា
- ជំរុញឱ្យមានការសិក្សាលទ្ធភាពក្នុងការរៀបចំអាងស្តុកប្រព្រឹត្តកម្មសំណល់រាវក្នុងខេត្តមណ្ឌលគិរី បើទោះបីជាទីតាំងតភ្ជាប់ប្រព័ន្ធលូក្នុងខេត្តមានការលំបាក ដោយសារកត្តាទីតាំងភូមិសាស្ត្រ
- បញ្ជ្រាបការយល់ដឹងដល់ប្រជាពលរដ្ឋនៅតាមភូមិ ឃុំ ស្រុក អំពីការងារបរិស្ថាន និងអនាម័យ។

### ៣.៦- ការអភិរក្សវប្បធម៌ និងជនជាតិដើមភាគតិច

ខេត្តមណ្ឌលគិរី មានជនជាតិដើមភាគដើមសំខាន់ៗចំនួន ៧ ក្រុម រួមមាន ពួង ស្ទៀង ក្រោល ថ្មូន ទំពួន ចារាយ និងគ្រឹង។ ជនជាតិដើមភាគតិចពួងមានចំនួនច្រើនជាងគេ ដែលមានប្រមាណ ៩២,៦៧% ស្ថិតនៅរាយប៉ាយពាសពេញក្រុង/ស្រុកនៃខេត្តមណ្ឌលគិរី។ ចំពោះជនជាតិដើមភាគតិច ៦ ក្រុមផ្សេងទៀតមានចំនួនតិចតួច ដែលភាគច្រើនស្ថិតនៅឃុំស្រែខ្ទុម ស្រុកកែវសីមា និងឃុំរយ៉ ស្រុកកោះញែក។

តារាងទី១១÷ របាយជនជាតិដើមភាគតិចក្នុងខេត្តមណ្ឌលគិរី ក្នុងឆ្នាំ២០១៨

| ប្រភេទប្រជាជនភាគតិច | ចំនួនគ្រួសារ | ចំនួនប្រជាជន |
|---|---|---|
| ពួង | ៨.៩៧៦ | ៣៨.១៦៦ |
| ស្ទៀង | ២១១ | ៩១៦ |
| ក្រោល | ២២៩ | ១.០០២ |
| ថ្មូន | ៥២ | ២៧៦ |

| | | |
|---|---|---|
| ទំពួន | ៦៨ | ៣៧២ |
| ចារាយ | ៣៤ | ១៥២ |
| គ្រឹង | ១៣ | ៦៣ |
| សរុប | ៩.៦១៥ | ១៧៨ |

(ប្រភព÷ មន្ទីរផែនការខេត្តមណ្ឌលគីរី)

ការអភិរក្សវប្បធម៌ជនជាតិដើមភាគតិច បានកំពុងទទួលរងនូវបញ្ហាមួយចំនួន រួមមាន÷

- ការបោះបង្គោលព្រំប្រទល់គ្រប់គ្រងដីធ្លីនៅមជ្ឈមណ្ឌលវប្បធម៌ភ្នំដោះក្រមុំ នៅមិនទាន់ដោះស្រាយចប់សព្វគ្រប់
- ការរីកចម្រើនសេដ្ឋកិច្ច និងការវិវត្តនៃសង្គម បានធ្វើឱ្យមានការផ្លាស់ប្តូររបៀបរបបការរស់នៅ ទំនៀមទម្លាប់ វប្បធម៌ ប្រពៃណីរបស់ពួកគេ
- ការបាត់បង់ផ្ទះជនជាតិដើមភាគតិច ដែលបានចាប់យកភាពស៊ីវិល័យលឿនពេក ដោយរយៈពេល ២-៣ឆ្នាំចុងក្រោយនេះ ស្ទើរតែបាត់បង់នូវអត្តសញ្ញាណដើមទាំងស្រុង។

ជាចក្ខុវិស័យក្នុងផែនការមេទាក់ទងនឹងការអភិរក្សវប្បធម៌ជនជាតិដើមភាគតិចនេះ គួរមានការគិតគូរនូវការងារចាំបាច់មួយចំនួន រួមមាន÷

- រៀបចំបញ្ជីសារពើភណ្ឌ និងកំណត់ផែនទីវប្បធម៌ (Cultural Mapping) និងទីតាំងសក្ការៈរបស់ជនជាតិដើមភាគតិច ដើម្បីអភិរក្សមរតកវប្បធម៌ ប្រពៃណី និងការពារតំបន់បេតិកភណ្ឌវប្បធម៌
- សិក្សារៀបចំភូមិវប្បធម៌សហគមន៍ (Community-Based Cutural Village) នៅតាមតំបន់ដែលមានសក្តានុពលធនធានវប្បធម៌របស់ជនជាតដើមភាគតិច ដើម្បីបង្ហាញពីភាពផ្សេងៗគ្នានៃវប្បធម៌ជនជាតិដើមភាគតិចដ៏សម្បូរបែបនៅតាមសហគមន៍នានា
- រៀបចំឱ្យមានគោលនយោបាយគាំទ្រដល់ជនជាតិដើមភាគតិច
- សិក្សាបង្កើតមជ្ឈមណ្ឌលវប្បធម៌សហគមន៍ សារមន្ទីរ សាលតាំងពិព័រណ៍ រោងមហោស្រព សម្តែងសិល្បៈសម្រាប់ជនជាតិដើមភាគតិច
- សិក្សាបង្កើតឱ្យមានសាលាវប្បធម៌វិចិត្រសិល្បៈសម្រាប់ជនជាតិដើមភាគតិច ដើម្បីអភិរក្សអត្តសញ្ញាណចំណេះដឹងប្រពៃណី និងលើកស្ទួយផលិតផលវប្បធម៌របស់ជនជាតិដើមភាគតិច
- ផ្សព្វផ្សាយសក្តានុពល និងទីតាំងអំណោយផលដល់ការថតភាពយន្តក្នុងស្រុក និងបរទេស
- រៀបចំបង្កើតព្រឹត្តិការណ៍វប្បធម៌ ពិព័រណ៍ និងពិធីបុណ្យនានារបស់ជនជាតិដើមភាគតិច
- លើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមពីសាធារណជនក្នុងការថែរក្សាការពារ វប្បធម៌ ប្រពៃណីរបស់ជនជាតិដើមភាគតិច។

### ៣.៧- ការគ្រប់គ្រង និងអភិវឌ្ឍធនធានរ៉ែ

បន្ថែមពីលើកត្តាអាកាសធាតុ និងទីតាំងភូមិសាស្ត្រអំណោយផល ភាពសម្បូរបែបនៃធនធានធម្មជាតិ ពិសេសធនធានរ៉ែមានតម្លៃសំខាន់ៗដែលមានក្នុងខេត្តនេះមានដូចជារ៉ែមាស រ៉ែសំណ និងរ៉ែបុកស៊ីតជាដើម បានកំពុងរួមចំណែកប្រែក្លាយខេត្តមណ្ឌលគីរីជាតំបន់ដ៏ទាក់ទាញអ្នកវិនិយោគចូលមកបណ្តាក់ទុនដើម្បីធ្វើការស្រាវជ្រាវរកសក្តានុពលរ៉ែ និងឈានដល់ការធ្វើអាជីវកម្មថែមទៀតផង។ ជាមួយគ្នានេះដែរធនធានធម្មជាតិទាំងនេះមិនត្រឹមតែសម្រាប់ភ្ញៀវទេសចរ

ជាតិ និងអន្តរជាតិប៉ុណ្ណោះទេ តែក៏សម្រាប់ក្រុមហ៊ុនវិនិយោគធំៗ ដែលអាចផ្តល់ឱកាសក្នុងការគៀងគរចំណូលសម្រាប់ការអភិវឌ្ឍខេត្តស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល "ការអភិវឌ្ឍធនធានរ៉ែដើម្បីផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយអភិបាលកិច្ចល្អ និងការទទួលខុសត្រូវខ្ពស់ផ្នែកបរិស្ថាន"។

ការផ្តល់តំបន់សម្បទានស្វែងរុករក និងតំបន់សម្រាប់ការធ្វើអាជីវកម្មធនធានរ៉ែ បានអនុវត្តអនុលោមទៅតាមបទដ្ឋានគតិយុត្តមួយចំនួន ដូចជាសេចក្តីណែនាំ ប្រកាស អនុក្រឹត្យ និងច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ។ បច្ចុប្បន្ន ខេត្តមណ្ឌលគិរីមានក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណស្វែងរុករករ៉ែ និងអាជ្ញាបណ្ណអាជីវកម្មធនធានរ៉ែចំនួន ០៩ក្រុមហ៊ុន ស្មើនឹង ១៤ អាជ្ញាបណ្ណ ក្នុងនោះ÷

- ក្រុមហ៊ុនអាជីវកម្មខ្សាច់សំណង់ មានចំនួន ០១ ក្រុមហ៊ុន ស្មើនឹង ០១ អាជ្ញាបណ្ណ
- ក្រុមហ៊ុនអាជីវកម្មរ៉ែមាស មានចំនួន ០២ ក្រុមហ៊ុន ស្មើនឹង ០២ អាជ្ញាបណ្ណ
- ក្រុមហ៊ុនអាជីវកម្មរ៉ែបុកស៊ីត មានចំនួន ០១ ក្រុមហ៊ុន ស្មើនឹង ០១ អាជ្ញាបណ្ណ
- ក្រុមហ៊ុនស្វែងរុករករ៉ែលោហៈ មានចំនួន ០៥ ក្រុមហ៊ុន ស្មើនឹង ១០ អាជ្ញាបណ្ណ។

ការវិនិយោគលើវិស័យធនធានរ៉ែក្នុងខេត្តមណ្ឌលគិរី បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាបច្ចេកទេស សេដ្ឋកិច្ចជាតិ បញ្ហាសុវត្ថិភាព ផលប៉ះពាល់បរិស្ថាន និងការស្តារឡើងវិញនៅពេលបិទការដ្ឋាន។ រាជរដ្ឋាភិបាលបានសម្រេចផ្តល់អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ (អាជីវកម្មរ៉ែមាស) ដល់ក្រុមហ៊ុនអូស្ត្រាលីមួយ ដែលមានឈ្មោះ Renaissance Minerals (Cambodia) ដែលមានសុពលភាពរយៈពេល ១៥ ឆ្នាំ លើទំហំផ្ទៃដី ១១,៥ គីឡូម៉ែត្រក្រឡា ដែលស្ថិតនៅក្នុងតំបន់អូរខ្វាវ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ហើយក្រុមហ៊ុននេះកំពុងស្ថិតក្នុងដំណាក់កាលរៀបចំការដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធដោយធ្វើការសាងសង់រោងចក្រចម្រាញ់រ៉ែមាសក្នុងទំហំខ្នាតអន្តរជាតិសម្រាប់តំបន់ជម្រករ៉ែទី១ នឹងអាចផ្តល់ជាផលិតផលសម្រេច (មាសសុទ្ធ) ចំនួនជិត ១ លានតម្លឹងមាស ដែលអាចនឹងដំណើរការក្នុងឆ្នាំ២០២១នេះ។

ទោះបីជាយ៉ាងណាក៏ដោយ ការគ្រប់គ្រង និងការវិនិយោគលើវិស័យរ៉ែ បានកំពុងទទួលរងនូវផលប៉ះពាល់ពីសកម្មភាពមួយចំនួន ដូចខាងក្រោម÷

- ការធ្វើអាជីវកម្មរ៉ែខុសលក្ខណៈបច្ចេកទេសរបស់ប្រជាពលរដ្ឋជាលក្ខណៈគ្រួសារនៅតាមតំបន់ដាច់ស្រយាលមួយចំនួនដែលអាចបង្កផលប៉ះពាល់ដល់ធនធានធម្មជាតិ និងចាំបាច់ត្រូវមានការត្រួតពិនិត្យឱ្យបានហ្មត់ចត់
- ការធ្វើអាជីវកម្មរ៉ែដោយជ្រកក្រោមអាជ្ញាបណ្ណស្វែងរុករកដែលមិនមានផែនការអាជីវកម្ម ផែនការផលិតកម្ម និងបច្ចេកទេសពិតប្រាកដ អាចបង្កឱ្យមានផលប៉ះពាល់ផ្សេងៗ ដូចជាការបាក់ស្រុតរណ្តៅរ៉ែ ការបំពុលប្រភពទឹកធនធានធម្មជាតិដោយសារធាតុគីមី ខ្យល់ សុខភាពរបស់កម្មកររ៉ែ និងប្រជាពលរដ្ឋដែលរស់នៅជុំវិញតំបន់អាជីវកម្ម។

ជាចក្ខុវិស័យក្នុងផែនការមេទាក់ទងទៅនឹងការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ គួរមានការគិតគូរនូវការងារចាំបាច់មួយចំនួន រួមមាន÷

- ការអភិវឌ្ឍវិស័យរ៉ែដើរតួនាទីសំខាន់ក្នុងការបង្កើនចំណូល សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងបានចូលរួមបង្កើតការងារដល់ប្រជាពលរដ្ឋមូលដ្ឋាន ជាពិសេសប្រជាពលរដ្ឋក្នុងខេត្តផ្ទាល់
- ធានាបានលើការធ្វើប្រតិបត្តិការធនធានរ៉ែ ដោយឈរលើមូលដ្ឋានបច្ចេកទេស សេដ្ឋកិច្ច សុវត្ថិភាព និងសង្គមដោយត្រូវធ្វើការត្រួតពិនិត្យ និងធ្វើអធិការកិច្ចឱ្យបានត្រឹមត្រូវ និងទៀងទាត់

- កំណត់តំបន់អាទិភាពក្នុងការធ្វើអាជីវកម្មធនធានរ៉ែ និងត្រូវរៀបចំផែនការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានរ៉ែឱ្យបានច្បាស់លាស់
- ពិនិត្យលទ្ធភាពប្រែក្លាយតំបន់ដែលបញ្ចប់ការធ្វើអាជីវកម្មធនធានរ៉ែទៅជាតំបន់ទេសចរណ៍។

### ៣.៨- កសិកម្ម និងការផ្គត់ផ្គង់ផ្កា បន្លែ ផ្លែឈើ និងសាច់

យោងតាមរបាយការណ៍របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី គិតត្រឹមឆ្នាំ២០១៩ ការធ្វើកសិកម្មនៅខេត្តមណ្ឌលគិរីបែងចែកជា ៥ប្រភេទ រួមមានដំណាំស្រូវ កសិ-ឧស្សាហកម្ម ដំណាំអចិន្ត្រៃយ៍ ដំណាំរួមផ្សំ និងការចិញ្ចឹមសត្វ។

- ផ្ទៃដីដាំដុះដំណាំស្រូវ សរុបមានប្រមាណ ២២.៩៨៨ ហិកតា ទិន្នផលជាមធ្យម ២.៩៣៩ តោន/ហិកតា បរិមាណផលសរុប ៦៧.៥៥៥ តោន
- ដំណាំកសិ-ឧស្សាហកម្ម មានផ្ទៃដីដាំដុះ ប្រមាណ ២២.២២៥ ហិកតា ក្នុងនោះមានសណ្ដែកបាយ សណ្ដែកដី សណ្ដែកអង្គុយ ដំឡូងមី អំពៅ ម្រេច និងកៅស៊ូជាដើម។ ផ្ទៃដីដាំដុះកៅស៊ូជាលក្ខណៈគ្រួសារមានប្រមាណ ១.១៣០.៥៤៣ ហិកតា ស្មើនឹង ១.៥៨៩ គ្រួសារ និងកៅស៊ូក្រុមហ៊ុនមានចំនួន ៣.១២៣.១៩៥ ហិកតា
- ដំណាំអចិន្ត្រៃយ៍ មានផ្ទៃដីដាំដុះសរុប ៩.៦៤៦ ហិកតា រួមមានដំណាំស្វាយចន្ទី កាហ្វេ ដូង ចេក ប៉ះ ស្វាយ សាវម៉ាវ ទុរេន ក្រូច និងទៀប
- ដំណាំរួមផ្សំមានផ្ទៃដីដាំដុះសរុប ៥៦០ ហិកតា រួមមានដំណាំ ពោតស និងដំណាំបន្លែផ្សេងៗ
- ការចិញ្ចឹមសត្វ ក្នុងនោះមានសត្វគោ ក្របី សេះ ពពែ ចៀម ជ្រូក មាន់ ទា ព្រាប។ល។

យោងតាមលទ្ធផលដែលបានពីការចុះអង្កេត និងប្រមូលទិន្នន័យពីមូលដ្ឋានអាជីវកម្មទេសចរណ៍ ក្នុងចំណោមផលិតផលកសិកម្មដែលត្រូវបានប្រើប្រាស់ ការប្រើប្រាស់បន្លែមានប្រមាណ ៣៣% ក្នុងនោះ ដាំដុះក្នុងខេត្តមាន ២៣% និង ១០% នាំចូលមកពីបណ្ដាខេត្តជុំវិញ និងប្រទេសជិតខាង។ ចំពោះការប្រើប្រាស់ផ្លែឈើ មាន ១៦% ក្នុងនោះ ដាំដុះក្នុងខេត្ត ១៤% និងនាំចូលមានប្រមាណ ២% (ដូចមានក្នុងក្រាហ្វិកបន្ថែមទី៨នៃឧបសម្ព័ន្ធ គ)។

ប៉ុន្តែទោះយ៉ាងណា ការប្រើប្រាស់ផលិតផលកសិកម្មក្នុងស្រុកនាពេលបច្ចុប្បន្ន មិនទាន់ចោទជាបញ្ហានៅឡើយទេធៀបទៅនឹងកំណើនភ្ញៀវទេសចរ ប៉ុន្តែគួរមានការគិតគូរច្បាស់លាស់ក្នុងការជំរុញការផលិតនូវផលិតផលកសិកម្មក្នុងស្រុក ដោយសារអត្រានៃការនាំចូលផលិតផលកសិកម្មស្ថិតក្នុងកម្រិតមួយខ្ពស់គឺប្រមាណ ៣១%។ ដោយឡែក ប្រសិនបើកំណើនភ្ញៀវទេសចរកើនឡើងខ្លាំងនាពេលអនាគត ការផ្គត់ផ្គង់ផលិតផលកសិកម្មក្នុងខេត្ត និងមិនអាចធានាបរិមាណគ្រប់គ្រាន់បានទេ។

ក្រាហ្វិកទី២÷ បរិមាណនៃផលិតផលកសិកម្មក្នុងស្រុក និងផលិតផលនាំចូល




| | សណ្ឋាគារ | ផ្ទះសំណាក់ | ភោជនីយដ្ឋាន | ភោជនីយដ្ឋាន |
|---|---|---|---|---|
| ផលិតផលកសិកម្មក្នុងស្រុក | ៥៨% | ៤៨% | ៧៥% | ៧២% |
| ផលិតផលកសិកម្មនាំចូល | ៤២% | ៥២% | ២៥% | ២៧% |

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

ជាមួយទិន្នន័យខាងលើ បើទោះបីជាខេត្តមណ្ឌលគិរីអំណោយផលដល់ការដាំដុះដំណាំផ្កា បន្លែ និងផ្លែឈើក៏ដោយ ប៉ុន្តែក៏នៅមានការនាំចូលបន្លែ ផ្លែឈើ និងកសិផលមួយចំនួនពីប្រទេសជិតខាង។ បញ្ហាមួយចំនួន ដែលបានកំពុងចោទឡើងទាក់ទងនឹងការជំរុញផលិតផលកសិកម្មក្នុងខេត្ត រួមមាន÷

- កសិករមួយចំនួននៅនិយមដាំដុះតាមទម្លាប់ចាស់ ដែលធ្វើឱ្យមានការរំខានពីសត្វល្អិត ការប្រើប្រាស់ពូជពុំសុទ្ធល្អ និងទិន្នផលទាប
- កង្វះខាតប្រព័ន្ធស្រោចស្រព និងប្រភពទឹក
- ការយល់ដឹងរបស់កសិករអំពីការប្រើប្រាស់បច្ចេកទេសកសិកម្ម សម្ភារៈកសិកម្ម និងការគ្រប់គ្រងជីជាតិដីនៅមានកម្រិត ខណៈដែលការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មដល់ប្រជាពលរដ្ឋក៏នៅពុំទាន់មានលក្ខណៈគ្រប់គ្រាន់
- គុណភាព និងស្តង់ដាផលិតផលនៅមានកម្រិតទាប ខណៈដែលទីផ្សារលក់ផលិតផលកសិកម្មមិនទាន់មានភាពទូលំទូលាយ
- កង្វះខាតកម្លាំងពលកម្មបម្រើក្នុងការងារផលិតផលកសិកម្ម
- កង្វះខាតការវិនិយោគក្នុងវិស័យកសិកម្ម ពិសេសការប្រើប្រាស់បច្ចេកទេសទំនើប។

ជាចក្ខុវិស័យ ការជំរុញផលិតកម្មកសិកម្ម គួរមានការគិតគូរនូវការងារចាំបាច់មួយចំនួន រួមមាន÷

- សម្រេចចក្ខុវិស័យធ្វើឱ្យខេត្តមណ្ឌលគិរី ក្លាយជាមជ្ឈមណ្ឌលផ្គត់ផ្គង់ផ្កា បន្លែ និងផ្លែឈើ សម្រាប់បំពេញតម្រូវការក្នុងប្រទេស និងឈានដល់ការនាំចេញទៅទីផ្សារក្រៅប្រទេស
- សិក្សាពីតម្រូវការទីផ្សារឱ្យបានច្បាស់លាស់
- ជំរុញការផលិតនូវផលិតផលកសិកម្ម តាមរយៈការពង្រឹងការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងបច្ចេកវិទ្យាទំនើប
- បង្កើតស្លាកសញ្ញាសម្គាល់ផលិតផលប្រចាំតំបន់ និងប្រចាំខេត្តមណ្ឌលគិរី និងបង្កើតផ្សារសហគមន៍ដើម្បីរកទីផ្សារជូនកសិករ
- ប្រមូលផ្តុំ ឬចងក្រងកសិករជាក្រុម ឬជាសហគមន៍ដាំដុះ ដើម្បីពង្រឹងដល់ការផលិត និងងាយស្រួលក្នុងការស្វែងរកទីផ្សារ។

### ៣.៩- វិស័យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម

ចំនួនសហគ្រាស និងសិប្បកម្ម ជាសូចនាករបង្ហាញពីការរីកចម្រើនសេដ្ឋកិច្ចក្នុងខេត្តមណ្ឌលគិរី និងសេដ្ឋកិច្ចជាតិ។ ដូចបានរៀបរាប់ខាងលើ ខេត្តមណ្ឌលគិរីគ្របដណ្តប់ដោយតំបន់ការពារធម្មជាតិ និងមានដង់ស៊ីតេប្រជាជនទាប ដូច្នេះសកម្មភាពសេដ្ឋកិច្ច គឺស្ថិតក្នុងស្ថានភាពកំពុងចាប់ផ្តើមអភិវឌ្ឍន៍នៅឡើយ។ ថ្វីត្បិតយ៉ាងនេះក៏ដោយ បច្ចុប្បន្នខេត្តមណ្ឌលគិរីមានរោងចក្រ សហគ្រាស និងសិប្បកម្ម សរុបចំនួន ៤៧០ កន្លែង ដែលបានរួមចំណែកយ៉ាងសំខាន់ជាឆ្អឹងខ្នងនៃកំណើនសេដ្ឋកិច្ចខេត្ត ដែលចាំបាច់ទាមទារឱ្យមានការយកចិត្តទុកដាក់ និងជំរុញឱ្យវិស័យមួយនេះកាន់តែមានភាពសកម្មបន្ថែមទៀត។

សកម្មភាពទូទាំងខេត្ត ត្រូវបានបែងចែកដូចខាងក្រោម÷

- ប្រភេទចំណីអាហារ រួមមានសិប្បកម្មផលិតទឹកសុទ្ធ ទឹកកកអនាម័យ ផលិតស្រា ទឹកផ្លែឈើ សិប្បកម្ម និងនំជាដើម

- ប្រភេទកែច្នៃផលិតផលផ្សេងៗ រួមមានសិប្បកម្មកែច្នៃសំបកដប កៅស៊ូកែ្រប កាត់កញ្ចក់ ដំដែក ចាក់លូ ផ្សារប៉ោត កែច្នៃឫស្សី កិនស្រូវ ជាន់ភ្លីស័ង្កសី ម្ចាងសិលា ផលិតឥដ្ឋ ក្រឡឹង ផលិតទ្វារបង្អួច និងសង្ហារឹមជាដើម
- ប្រភេទជួសជុល រួមមានសិប្បកម្មជួសជុលម៉ូតូ ជួសជុលទូរស័ព្ទ ជួសជុលទូរទស្សន៍ ទូទឹកកក និងម៉ាស៊ីនត្រជាក់ជាដើម។

ក្រាហ្វិកទី៣÷ ស្ថិតិមូលដ្ឋានសិប្បកម្មក្នុងខេត្តមណ្ឌលគិរី




(ប្រភព÷ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តមណ្ឌលគិរី)

យ៉ាងណាក៏ដោយ វិស័យនេះ បានកំពុងប្រឈមនឹងបញ្ហាមួយចំនួន រួមមាន÷
- សហគ្រាសធុនតូច មធ្យម និងសិប្បកម្មមួយចំនួន មិនទាន់មានការចុះបញ្ជីត្រឹមត្រូវ
- កង្វះខាតដើមទុន ក្នុងការពង្រីកអាជីកម្ម និងពង្រឹងគុណភាពផលិតផលរបស់ខ្លួន ដើម្បីប្រកួតប្រជែងក្នុងទីផ្សារ
- បច្ចេកទេសក្នុងការផលិតឲ្យស្របតាមស្តង់ដា នៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់
- ការផ្សព្វផ្សាយទីផ្សារផលិតផលក្នុងស្រុកនៅមានកម្រិត។

ជាចក្ខុវិស័យក្នុងផែនការមេទាក់ទងនឹងការជំរុញសកម្មភាពសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម គួរមានការគិតគូរនូវការងារចាំបាច់មួយចំនួន ដូចជា÷
- ជំរុញការបណ្តុះបណ្តាលបច្ចេកទេសឲ្យបានត្រឹមត្រូវ និងអនុលោមតាមក្បួនអនាម័យស្អាត និងផលិតកម្មស្អាត
- ជំរុញការប្រើប្រាស់ផលិតផលដែលមានស្លាកសញ្ញាស្តង់ដា ដូចជាទឹកសុទ្ធ ស្រា កាហ្វេ និងផលិតផលចំណីអាហារមួយចំនួនផ្សេងទៀត
- ជំរុញកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសវិស័យឯកជន ស្ថាប័នធនាគារ និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ គាំទ្រដល់រាល់គម្រោងវិនិយោគសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ដើម្បីឲ្យមានដំណើរការល្អ និងមានលទ្ធភាពក្នុងការប្រកួតប្រជែងក្នុងប្រទេស និងតំបន់អាស៊ានជាដើម។

### ៣.១០- ការដឹកជញ្ជូន និងប្រព័ន្ធគមនាគមន៍ និងការតភ្ជាប់

ខេត្តមណ្ឌលគិរី មានការតភ្ជាប់ជាមួយបណ្តារាជធានី-ខេត្តផ្សេងៗ តាមផ្លូវជាតិលេខ ៧៦ ដោយឆ្លងកាត់តាមខេត្តកណ្តាល ព្រៃវែង ត្បូងឃ្មុំ កំពង់ចាម និងក្រចេះ ព្រមជាមួយការតភ្ជាប់ផ្លូវលេខ៧៦ ដែលមានប្រវែង ១៧០ គ.ម ចាប់ពីក្រុងសែនមនោរម្យ ស្រុកកោះញែក ទៅដល់ស្រុកលំផាត់ ខេត្តរតនគិរី ខណៈដែលលំហូរភ្ញៀវទេសចរមកពីទិសដៅខេត្តរតនគិរី ក៏មានការកើនឡើងគួរឲ្យកត់សម្គាល់។

លំហូរភ្ញៀវទេសចរមកខេត្តមណ្ឌលគិរី ក៏អាចត្រូវបានជំរុញតាមរយៈច្រកទ្វារភាគីចំនួន ០៤ ជាមួយប្រទេសវៀតណាម រួមមាន÷

- ច្រកទ្វារទ្វេភាគីដាក់ដាំ (ស្រុកអូររាំង) ប៊ូប្រាំង (ខេត្តដាក់ណុង)
- ច្រកទ្វារទ្វេភាគីឡាប៉ាខេ (ស្រុកកែវសីម៉ា) ហ្វាងយីវ (ខេត្តបិញភឿក)
- ច្រកទ្វារទ្វេភាគីជីមៀត (ស្រុកកោះញែក) ដាក់រ៉េ (ខេត្តដាក់ឡាក់)
- ច្រកទ្វារទ្វេភាគីណាមលៀរ (ស្រុកពេជ្រាដា) ដាក់ប៊ល (ខេត្តដាក់ណុង)។

ទន្ទឹមនឹងនេះ ខេត្តមណ្ឌលគិរីក៏ត្រូវបានធ្វើសមាហរណកម្មជាមួយប្រទេសក្នុងតំបន់ ជាពិសេសក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) និងក្របខណ្ឌមហាអនុតំបន់មេគង្គ (GMS) ផងដែរ។

ក្របខណ្ឌកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ត្រូវបានបង្កើតឡើងក្នុងគោលបំណងជំរុញកិច្ចសហប្រតិបត្តិការអភិវឌ្ឍតំបន់ព្រំដែន កម្ពុជា-ឡាវ-វៀតណាម (CLV) ក្រោមគំនិតផ្តួចផ្តើមរបស់ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងបី កាលពីឆ្នាំ១៩៩៩។ ក្របខណ្ឌនេះ រួមបញ្ចូលការអភិវឌ្ឍខេត្តទាំង១៣ (ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តសារ៉ាវ៉ាន់ ខេត្តសេកុង ខេត្តអត្តពើ ខេត្តចំប៉ាសាក់ ខេត្តកន្ទុម ខេត្តយ៉ាឡាយ ខេត្តដាក់ឡាក់ ខេត្តដាក់ណុង និងខេត្តបិញភឿក) នៃតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម។ សម្រាប់កម្ពុជា ខេត្តចំនួន ០៤ រួមមានខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ បានកំពុងក្លាយជាប៉ូលសេដ្ឋកិច្ចតាមយៈការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងលំហូរភ្ញៀវទេសចររវាងប្រទេសទាំង៣។

តំបន់ត្រីកោណអភិវឌ្ឍន៍ មានផ្ទៃដីសរុបប្រមាណ ១៤៩.០០០ គីឡូម៉ែត្រក្រឡា និងមានប្រជាជនប្រមាណ ៩ លាននាក់ ក្នុងនោះ÷

- កម្ពុជា មាន ៣២% នៃផ្ទៃដី និង ៨% នៃប្រជាជន
- ឡាវ មាន ៣៣% នៃផ្ទៃដី និង ១៦% នៃប្រជាជន
- វៀតណាម មាន ៣៥% នៃផ្ទៃដី និង ៧៦% នៃប្រជាជន។

ទីក្រុង និងទីប្រជុំជនសំខាន់ៗក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ រួមមាន÷

- ប្រទេសវៀតណាម÷ ទីក្រុង Buon Ma Thuot (៤១៦.០០០ នាក់) ទីក្រុង Pleiku (៣៧០.០០០ នាក់) ទីក្រុង Kon Tum (១៦០.០០០ នាក់) ទីក្រុង Dong Xoai (១៥០.០០០ នាក់) និងទីប្រជុំជន Chi Nghia (៥២.០០០ នាក់)
- ប្រទេសឡាវ÷ ទីប្រជុំជន Pakse (៨៨.០០០ នាក់) ទីក្រុង Salavan (៥.៥០០ នាក់) ខេត្ត Lamam (Sekong) (៤.៥០០នាក់) និងខេត្ត Attapeu (៤.២០០នាក់)
- ប្រទេសកម្ពុជា÷ ទីក្រុងក្រចេះ (៣៤.៥៣៤ នាក់) ទីក្រុងស្ទឹងត្រែង (៣៧.៣៥០ នាក់) ទីក្រុងបានលុង (ខេត្តរតនគិរី) (២០.០០០ នាក់) និងទីក្រុងសែនមនោរម្យ (មណ្ឌលគិរី) (១៦.០៣៥ នាក់)។

ជាមួយគ្នានេះ ក្នុងក្របខណ្ឌមហាអនុតំបន់ទន្លេមេគង្គ បណ្តាប្រទេសដែលជាសមាជិកទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍ ក្នុងការអនុវត្តគម្រោងអាទិភាពក្នុងវិស័យជាច្រើន ដូចជាកសិកម្ម ថាមពល បរិស្ថាន ប្រព័ន្ធសុខាភិបាល និង

ការអភិវឌ្ឍធនធានមនុស្សបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ទេសចរណ៍ ដឹកជញ្ជូន ការសម្របសម្រួលពាណិជ្ជកម្ម និងការអភិវឌ្ឍទីក្រុង។ យុទ្ធសាស្ត្រសំខាន់ចំនួន ០៣ ក្នុងក្របខណ្ឌមហាអនុតំបន់ទន្លេមេគង្គ រួមមាន÷

- ពង្រឹងការតភ្ជាប់តាមរយៈហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ច
- លើកកម្ពស់សមត្ថភាពប្រកួតប្រជែងតាមរយៈការធ្វើសមាហរណកម្មទីផ្សារ និងការសម្របសម្រួលពាណិជ្ជកម្ម រួមទាំងការធ្វើដំណើរឆ្លងកាត់ព្រំដែន
- ការកសាងស្មារតីជាសហគមន៍មួយ តាមរយៈការដោះស្រាយបញ្ហាសង្គម និងបរិស្ថានរួមគ្នា។

ក្នុងន័យនេះ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាអាទិភាពចម្បងក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិទាំងមូល ក៏ដូចជាផ្តល់នូវសារៈសំខាន់ថែមទៀតសម្រាប់ខេត្តមណ្ឌលគិរី ដែលជាប៉ូលសេដ្ឋកិច្ចមួយដ៏សំខាន់ក្នុងចំណោមប៉ូលទាំង៤។ បច្ចុប្បន្ន ការធ្វើដំណើរមកកាន់ខេត្តមណ្ឌលគិរី មានតែមធ្យោបាយផ្លូវគោក។ ក្នុងន័យនេះ គម្រោងបង្កើតអាកាសយានដ្ឋានខេត្តមណ្ឌលគិរី ប្រភេទ 4C សម្រាប់រយៈពេលខ្លី ២០២០-២០២៥ (ដែលអាចចុះចតយន្តហោះប្រភេទ B737, A319/320, DC9-80/MD80) និងប្រភេទ 4E សម្រាប់រយៈពេលមធ្យម ២០២៥-២០៣៥ (ដែលអាចចុះចតយន្តហោះប្រភេទ B747-400, A330/340, B777) ដែលស្ថិតនៅចម្ងាយប្រមាណ ២០ គីឡូម៉ែត្រ ភាគខាងត្បូងនៃក្រុងសែនមនោរម្យ នឹងពង្រឹងការតភ្ជាប់ទៅគោលដៅទេសចរណ៍សំខាន់ៗ ទាំងក្នុងប្រទេស និងក្នុងតំបន់។

តាមរយៈការវិភាគ និងការគណនា ធ្វើឱ្យគេសន្និដ្ឋាន និងធ្វើការព្យាករណ៍ចរាចរណ៍តាមផ្លូវអាកាសបានថា អ្នកដំណើរតាមផ្លូវអាកាសឆ្លងកាត់អាកាសយានដ្ឋានខេត្តមណ្ឌលគិរីថ្មី នឹងមានការកើនឡើងជាលំដាប់ក្នុងអត្រាប្រចាំឆ្នាំចំនួន ៨% នៅចន្លោះឆ្នាំ ២០៣៥ ដល់ ២០៥៥ និងអត្រាកំណើនប្រចាំឆ្នាំជាមធ្យមចំនួន ៦% នៅចន្លោះឆ្នាំ ២០៥៥ ដល់ ២០៧៥។ រីឯចំណុះអ្នកដំណើរ ក្នុងឆ្នាំ ២០៥៥ មានចំនួន ៩៤០,០០០ នាក់ ហើយនៅឆ្នាំ ២០៧៥ គឺមានចំនួនប្រមាណ ២ លាននាក់។

នេះជាដំណាក់កាល និងជម្រើសមួយ ដែលធានាបាននូវការឆ្លើយតបប្រកបដោយសន្និទានភាព បង្ហាញពីទស្សនទាន (ចក្ខុវិស័យយូរអង្វែង) និងជាបំណងប្រាថ្នារយៈពេលវែងសំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិការណ៍សមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក ហើយក៏ជាមូលដ្ឋានគ្រឹះក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន ដើម្បីឈានទៅសម្រេចបាននូវទិសដៅ និងបង្គោលចរ (Milestone) ឆ្នាំ២០៣០ ក៏ដូចជាចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

តារាងទី១២ ÷ ការព្យាករណ៍ចរាចរណ៍តាមផ្លូវអាកាស (Air Traffic Forecast)

| ល.រ | គម្រោងរំពឹងទុក | ២០៣៥ | ២០៥៥ | ២០៧៥ |
|---|---|---|---|---|
| ១. | **អ្នកដំណើរឆ្លងកាត់ប្រចាំឆ្នាំ** (Annual Passenger Throughput/ Passenger Movement) | ២០០.០០០ នាក់/ឆ្នាំ | ៩៤០០.០០០ នាក់/ឆ្នាំ | ២.០០០.០០០ នាក់/ឆ្នាំ |
| ២. | **ទំនិញឆ្លងកាត់ប្រចាំឆ្នាំ (តោន)** (Annual Cargo Throughput /Cargo movement (tons) | ៥០០ តោន/ឆ្នាំ | ៣.០០០ តោន/ឆ្នាំ | ៧.៥០០ តោន/ឆ្នាំ |
| ៣. | **ចំនួនជើងយន្តហោះប្រចាំឆ្នាំ (ជើង)** (Annual Aircraft Movement (Time) | ៣.៣៣៤ | ៨.៧១៧ | ១៦.៤៧៨ |

| | | | | |
|---|---|---|---|---|
| ៤. | **ចំនួនជើងយន្តហោះ ចេញដំណើរ-មកដល់ក្នុងអំឡុងពេលម៉ោងរវល់** (Annual Aircraft Takeoff and Landing (departure & arrival) in peak hour) | ២ | ៦ | ១១ |
| ៥. | **ចំនួនអ្នកដំណើរក្នុងអំឡុងពេលម៉ោងរវល់** (Number of Passenger in Peak Hour (pax)) | ១២៤ | ៤៩៦ | ១០៦០ |
| ៦. | **តំបន់ស្ថានីយអ្នកដំណើរ** (Terminal Area (m2)) | ១.៦០០ | ១១.០០០ | ២៤.០០០ |
| ៧. | **ចំនួនចំណតយន្តហោះ** (Aircraft parking stand on apron /Aircraft stand requirement) | ២ C | ៥ C | ៩ C1E |

(ប្រភព៖ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល)

ជារួម ប្រព័ន្ធដឹកជញ្ជូន និងគមនាគមន៍ក្នុងខេត្តមណ្ឌលគិរី បានកំពុងជួបប្រទះនូវបញ្ហាមួយចំនួន រួមមាន៖

- ប្រព័ន្ធគមនាគមន៍ទៅកាន់គោលដៅទេសចរណ៍ភាគច្រើន នៅមិនទាន់មានភាពល្អប្រសើរ
- ការអភិវឌ្ឍប្រព័ន្ធតភ្ជាប់ពីផ្លូវជាតិទៅកាន់ជនបទ មិនទាន់មានលក្ខណៈគ្រប់គ្រាន់
- ការស្ថាបនាផ្លូវតភ្ជាប់ មិនទាន់សមស្របទៅនឹងកំណើនភ្ញៀវមកកម្សាន្តខេត្តមណ្ឌលគិរី
- ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពុំទាន់ឆ្លើយតបតាមតម្រូវការរបស់ភ្ញៀវទេសចរបានគ្រប់គ្រាន់ ក្នុងនោះបណ្តាញផ្លូវសំខាន់ៗក្នុងខេត្ត មានលក្ខណៈតូច និងមិនទាន់ឆ្លើយតបតាមស្តង់ដា
- សេវាដឹកជញ្ជូនសាធារណៈក្នុងខេត្ត នៅពុំទាន់មានដំណើរការ
- ការដាក់ស្លាកសញ្ញាបង្ហាញផ្លូវនៅមានកម្រិត។

ជាចក្ខុវិស័យ ប្រព័ន្ធដឹកជញ្ជូន និងគមនាគមន៍ក្នុងខេត្ត គួរត្រូវបានអភិវឌ្ឍ និងកែលម្អបន្ថែម រួមមាន៖

- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងការសម្រួលការធ្វើដំណើរទេសចរណ៍ គឺជាកត្តាគន្លឹះក្នុងការទាក់ទាញ ការជំរុញ និងការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ដែលមានភាពប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និត
- ស្ថាបនា ស្តារ និងពង្រីកផ្លូវទៅកាន់គោលដៅទេសចរណ៍ ជាពិសេសតំបន់រមណីយដ្ឋាន និងគោលដៅទេសចរណ៍សំខាន់ៗ
- អភិវឌ្ឍសម្បទាទ្រទ្រង់ ដូចជាចំណតរថយន្តក្រុងជាដើម
- ជំរុញការដាក់សញ្ញាបង្ហាញគោលដៅ ពិសេសផ្លូវទៅកាន់គោលដៅទេសចរណ៍សំខាន់ៗក្នុងខេត្ត
- ប្រព័ន្ធផ្លូវថ្នល់មួយចំនួនក្នុងក្រុងសែនមនោរម្យ គួរត្រូវបានពង្រីក និងកែលម្អ
- ប្រែក្លាយខេត្តមណ្ឌលគិរី ជាច្រកចេញចូលអន្តរជាតិ តាមរយៈការជំរុញការបង្កើតព្រលានយន្តហោះឱ្យបានឆាប់រហ័ស
- សិក្សាលទ្ធភាពក្នុងការពង្រីកច្រកព្រំដែនទ្វេភាគីខាងលើជាច្រកអន្តរជាតិ ទៅតាមស្ថានភាពជាក់ស្តែង ដើម្បីទាក់ទាញភ្ញៀវទេសចរពីប្រទេសទីបី។

### ៤- ការវិភាគ SWOT នៃវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី

ផ្អែកលើសក្តានុពល ធនធាន ស្ថានភាពជាក់ស្តែង ទិន្នន័យដែលប្រមូលបាន និងការវិភាគអំពីនិន្នាការនាពេលបច្ចុប្បន្ន និងការវិវត្តនាពេលអនាគតរបស់វិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រ ការវិភាគអំពីភាពខ្លាំង ភាពខ្សោយ

ឱកាស និងការគំរាមកំហែង (SWOT) ត្រូវបានធ្វើឡើងដើម្បីជាមូលដ្ឋានក្នុងការកំណត់យុទ្ធសាស្ត្រផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី។

**ក- ភាពខ្លាំង**

- លក្ខណៈពិសេសនៃសក្តានុពល និងធនធានទេសចរណ៍ដ៏សម្បូរបែប និងកម្រមាន ធៀបជាមួយតំបន់ផ្សេងៗក្នុងប្រទេស និងប្រទេសជិតខាងមួយចំនួន ជាពិសេសអេកូទេសចរណ៍ ទេសចរណ៍ធម្មជាតិ និងវប្បធម៌ជនជាតិដើមភាគតិច ដែលមានថាមភាពក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ជាច្រើនទម្រង់ និងច្រើនប្រភេទ
- ទីតាំងភូមិសាស្ត្រ និងអាកាសធាតុអំណោយផល បង្កើតបានជាមូលដ្ឋានដ៏រឹងមាំក្នុងការជំរុញការអភិវឌ្ឍអន្តរវិស័យគាំទ្រ ជាពិសេសវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មកែច្នៃ និងអន្តរវិស័យនានាដែលមានសក្តានុពលក្នុងការបង្កើតតម្លៃបន្ថែមសម្រាប់វិស័យសេដ្ឋកិច្ច
- ការវិនិយោគក្នុងវិស័យទេសចរណ៍ និងវិស័យពាក់ព័ន្ធនានា មានការកើនឡើងជាបន្តបន្ទាប់ ស្របជាមួយការប្រមើលមើលពីអនាគតប្រកបដោយសុទិដ្ឋិនិយមរបស់ខេត្តមណ្ឌលគិរី
- ការធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមក្នុងខេត្តមណ្ឌលគិរី ជាកត្តាធានាបាននូវទំនុកចិត្តជូនភ្ញៀវទេសចរ និងអ្នកវិនិយោគ។

**ខ- ភាពខ្សោយ**

- ផ្លូវទៅកាន់គោលដៅទេសចរណ៍សំខាន់ៗនៅជួបការលំបាក ពិសេសនៅរដូវវស្សា ដែលធ្វើឱ្យការអភិវឌ្ឍគោលដៅទាំងនោះ នៅមិនទាន់មានភាពទូលំទូលាយនៅឡើយ
- ហេដ្ឋារចនាសម្ព័ន្ធអន្តរវិស័យទ្រទ្រង់វិស័យទេសចរណ៍ រួមមានការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ការគ្រប់គ្រងសំណល់ ការជំរុញផលិតកម្មក្នុងខេត្ត ប្រព័ន្ធទំនាក់ទំនង និងវិស័យពាក់ព័ន្ធនានា នៅមិនទាន់មានភាពល្អប្រសើរពេញលេញ ដែលទាមទារឲ្យមានការវិនិយោគ និងកែលម្អបន្ថែម
- ធនធានមនុស្សបម្រើការក្នុងវិស័យទេសចរណ៍ នៅមានកម្រិត និងត្រូវការពង្រឹងបន្ថែម ខណៈដែលចំនួនភ្ញៀវទេសចរ ត្រូវបានព្យាករណ៍ថា នឹងមានកំណើនកាន់តែច្រើននាពេលអនាគត
- គុណភាពផលិតផល និងសេវាកម្មទេសចរណ៍ ចាំបាច់ត្រូវមានការពង្រឹងបន្ថែម ឆ្លើយតបតាមស្តង់ដាក្រសួងទេសចរណ៍ និងស្តង់ដាអាស៊ាន។

**គ- ឱកាស**

- កំណើនភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរី មានកម្រិតខ្ពស់ និងត្រូវបានចាត់ទុកជាគោលដៅទេសចរណ៍ចម្បងទាំងភ្ញៀវជាតិ និងអន្តរជាតិ ទោះបីស្ថិតនៅក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ក៏ដោយ
- វិស័យទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាវិស័យអាទិភាពមួយ សម្រាប់ការអភិវឌ្ឍខេត្តមណ្ឌលគិរីជាក់ស្តែងដូចជាការអនុញ្ញាតឲ្យមានសិក្សារៀបចំផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរីជាដើម
- សក្តានុពល និងធនធានជាច្រើននៅមិនទាន់ត្រូវបានកែច្នៃ និងប្រើប្រាស់អស់លទ្ធភាព ដែលបង្កើតបានជាកាលានុវត្តភាពជាច្រើនសម្រាប់ការវិនិយោគ

- ហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា បាននឹងកំពុងសាងសង់ និងស្ថិតក្នុងគម្រោងអភិវឌ្ឍន៍ បង្កលក្ខណៈងាយស្រួលដល់ការវិនិយោគ ពិសេសគម្រោងសាងសង់ព្រលានយន្តហោះខេត្តមណ្ឌលគិរី។

**ឃ- ការគំរាមកំហែង**

- ការគ្រប់គ្រងដីធ្លី និងការបែងចែកតំបន់អភិរក្ស និងអភិវឌ្ឍន៍ក្នុងខេត្ត នៅមានភាពប្រទាញប្រទង់ និងទាមទារឱ្យមានការកំណត់ព្រំប្រទល់ឱ្យច្បាស់លាស់
- ការទន្ទ្រានដីព្រៃក្នុងតំបន់អភិរក្ស នៅតែកើតមានជាបន្តបន្ទាប់ ដែលទាមទារឱ្យមានការចាត់វិធានការច្បាប់ប្រកបដោយភាពម៉ឺងម៉ាត់
- បម្រែបម្រួលអាកាសធាតុ បានកំពុងជះឥទ្ធិពលទៅលើបរិស្ថានធនធានធម្មជាតិក្នុងខេត្ត ដែលធ្វើឱ្យប៉ះពាល់ដល់ការដាំដុះ និងវិស័យមួយចំនួន
- ការហូរចូលវប្បធម៌ពីខាងក្រៅ បានបង្កជាហានិភ័យមួយចំនួនដល់ការអភិរក្សប្រពៃណី និងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច។

តាមរយៈការវិភាគខាងលើ គេអាចសន្និដ្ឋានបានថា វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ស្ថិតក្នុងដំណាក់កាលទី២ នៃវដ្តជីវិតនៃការអភិវឌ្ឍទេសចរណ៍ (Life Cycle) ដែលជាដំណាក់កាលកំណើនដំបូង និងមានសក្តានុពលក្នុងការអភិវឌ្ឍខ្លាំងបន្ថែមទៀតនាពេលអនាគត បង្កើតបានជាកាលានុវត្តភាពសត្យានុម័ត ជាច្រើនសម្រាប់ការវិនិយោគ និងបង្កើតតម្លៃបន្ថែមក្នុងវិស័យទេសចរណ៍ និងអន្តរវិស័យនានាគាំទ្រដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច។

រូបភាពទី៣÷ ដំណាក់កាលនៃការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ផ្អែកលើការវិភាគ SWOT




ប្រភព÷ ការវិភាគដោយផ្អែកលើគំរូ Bulter ស្តីពីវដ្តជីវិតនៃការអភិវឌ្ឍគោលដៅទេសចរណ៍ (Butler"s Tourism Area Life Cycle model)

## ផ្នែកទី២÷ ការកំណត់ចក្ខុវិស័យ គោលបំណង និងគោលដៅ

### ១- ចក្ខុវិស័យ

យោងតាមការសិក្សា និងវិភាគខាងលើ ចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ក្នុងចក្ខុវិស័យឆ្នាំ២០៣៥ ត្រូវបានព្យាករណ៍ ដូចខាងក្រោម÷

- **ក. សម្រាប់ភ្ញៀវទេសចរជាតិ**
  + ចន្លោះឆ្នាំ ២០១០-២០២០ ចំនួនភ្ញៀវទេសចរ មានកំណើនជាមធ្យមប្រមាណ ២០%។ ជាមួយការកើនឡើងនៃនិន្នាការទេសចរណ៍ផ្ទៃក្នុងនៅក្នុងដំណាក់កាលជំងឺកូវីដ-១៩ ចំនួនភ្ញៀវទេសចរក្នុងស្រុកទៅកាន់ខេត្តមណ្ឌលគិរី អាចនឹងបន្តកើនឡើងបន្តិចក្នុងឆ្នាំ២០២១ ពោលគឺស្ថិតក្នុងរង្វង់ប្រមាណ ២៥%។
  + បន្ទាប់ពីកំណើនខ្ពស់ក្នុងរយៈពេល២ឆ្នាំនេះ អត្រាកំណើនអាចនឹងស្ថិតក្នុងរង្វង់ជាមធ្យមប្រមាណ ១០% ចាប់ពីឆ្នាំ២០២២ ក្នុងស្ថានភាពវិវត្តន៍ធម្មតានៃវិស័យទេសចរណ៍។
- **ខ. សម្រាប់ភ្ញៀវទេសចរអន្តរជាតិ**
  + ចន្លោះឆ្នាំ ២០១០-២០២០ ចំនួនភ្ញៀវទេសចរ មានកំណើនជាមធ្យមប្រមាណ ២៥%។ ទោះស្ថិតក្នុងដំណាក់កាលជំងឺកូវីដ-១៩ ខេត្តមណ្ឌលគិរីនៅតែជាគោលដៅពេញនិយមសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង។ ក្នុងន័យនេះ ចំនួនភ្ញៀវទេសចរបរទេស អាចនឹងរក្សាកំណើនថេរ ២៥% សម្រាប់ឆ្នាំ ២០២១-២០២៣។
  + ជាមួយការគ្រោងដាក់ឲ្យដំណើរការព្រលានយន្តហោះមណ្ឌលគិរីនៅឆ្នាំ២០២៣ ព្រមជាមួយ លទ្ធភាពនៃការពង្រីកជើងហោះហើរទាំងក្នុងស្រុក និងអន្តរជាតិមកកាន់ខេត្តមណ្ឌលគិរី កំណើនភ្ញៀវទេសចរអន្តរជាតិ ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ ៤០% ចាប់ពីឆ្នាំ ២០២៤-២០២៨ ខណៈដែលកំណើននេះនឹងមានប្រមាណ ២៥% ចាប់ពីឆ្នាំ ២០២៩-២០៣៥ បន្ទាប់ពីកំណើនខ្ពស់ក្នុងរយៈពេល ៥ឆ្នាំនេះ។

ផ្អែកលើការព្យាករណ៍ខាងលើ ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី តម្រង់ចក្ខុវិស័យ សម្រេចឲ្យបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ជាតិ ដើម្បីជំរុញការអភិវឌ្ឍមួយដែលមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយត្រឹមត្រូវ ឈរលើគុណតម្លៃសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ក្នុងន័យនេះ ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ត្រូវបានកំណត់ចក្ខុវិស័យក្របខណ្ឌអនុវត្តរយៈពេលវែង (២០២១-២០៣៥) ដោយឈរលើចក្ខុវិស័យសំខាន់ចំនួន ០៤÷

- **ទី១÷** ខេត្តមណ្ឌលគិរី ត្រូវកំណត់ជាគោលដៅអេកូទេសចរណ៍លំដាប់អន្តរជាតិ និងជាខេត្តដ៏សំខាន់ក្នុងការផ្គត់ផ្គង់ផ្កា បន្លែ និងផ្លែឈើ សម្រាប់បំពេញតម្រូវការក្នុងប្រទេស និងឈានដល់ការនាំចេញទៅទីផ្សារក្រៅប្រទេស
- **ទី២÷** ឆ្នាំ២០៣៥ ចំនួនភ្ញៀវទេសចរអន្តរជាតិមកកាន់ខេត្តមណ្ឌលគិរី នឹងកើនឡើងដល់ប្រមាណ ៩០ ម៉ឺននាក់ ខណៈដែលចំនួនភ្ញៀវទេសចរក្នុងស្រុក នឹងកើនឡើងដល់ប្រមាណ ២ លាននាក់ បង្កើតការងារប្រមាណ ៨ ម៉ឺនកន្លែង និងបង្កើតចំណូលដោយផ្ទាល់ប្រមាណ ៥០០ លានដុល្លារ និងដោយប្រយោលប្រមាណ ១.០០០ លានដុល្លារ ជាមួយមេគុណប្រសិទ្ធភាព (Multiplier Coefficient) ចំនួន២ដង ចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចខេត្តមណ្ឌលគិរី

- **ទី៣÷** រួមចំណែកធ្វើឱ្យភូមិភាគឦសានដែលមានខេត្តមណ្ឌលគិរីជាស្នូល ជាប៉ូលសេដ្ឋកិច្ចទី៤ បន្ទាប់ពីតំបន់រាជធានីភ្នំពេញ តំបន់ឆ្នេរ និងតំបន់សៀមរាប និងធ្វើសមាហរណកម្មខេត្តមណ្ឌលគិរីជាមួយតំបន់ផ្សេងៗក្នុងប្រទេស និងក្នុងតំបន់
- **ទី៤÷** រក្សាតុល្យភាពឱ្យបានម៉ឺងម៉ាត់រវាងការអភិវឌ្ឍសេដ្ឋកិច្ច ទេសចរណ៍ និងអន្តរវិស័យគាំទ្រ ជាមួយការអភិរក្សធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ជនជាតិដើមភាគតិច ធានាបានផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាអតិបរមា ឈរលើគោលការណ៍នៃការបែងចែកផលប្រយោជន៍ប្រកប ដោយសមធម៌ទៅដល់ភាគីពាក់ព័ន្ធ។

## ២- គោលបំណង

ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) មានគោលបំណងតម្រង់ទិសដៅអភិវឌ្ឍក្នុងក្របខណ្ឌយុទ្ធសាស្ត្ររបស់ខេត្តមណ្ឌលគិរី ដោយឈរលើទិន្នន័យ ការវិភាគស្ថានភាពជាក់ស្តែង និងប្រភពធនធានសក្តានុពលសម្រាប់ការវិនិយោគ និងអភិវឌ្ឍន៍លើវិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រ ក្នុងក្តីសង្ឃឹមប្រកបដោយសុទិដ្ឋិនិយមថា ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវនៃវិស័យនេះ នឹងបង្កើតបានជាផលប្រយោជន៍សេដ្ឋកិច្ច-សង្គមដល់ប្រជាពលរដ្ឋមូលដ្ឋានទូទាំងខេត្ត និងរួមចំណែកយ៉ាងសំខាន់ដល់ការថែរក្សាការពារ និងអភិរក្សធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ រក្សាបាននូវអត្តសញ្ញាណដើមរបស់ខេត្ត។

គោលបំណងយុទ្ធសាស្ត្រនៃការរៀបចំផែនការមេនេះ នឹងផ្តោតលើចំណុច ០៣ ដែលមានលក្ខណៈប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមក ដែលរួមមាន÷

- **ទី១÷** ខេត្តមណ្ឌលគិរី ជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព ប្រកបដោយឧត្តមានុវត្តន៍
- **ទី២÷** ខេត្តមណ្ឌលគិរី ជាមជ្ឈមណ្ឌលសេដ្ឋកិច្ចប្រកបដោយភាពឆ្លាតវៃ និងច្នៃប្រឌិត និងជាមជ្ឈមណ្ឌលសម្រាប់តំបន់ភាគឦសាន
- **ទី៣÷** ខេត្តមណ្ឌលគិរី ជាខេត្តដែលមានការគិតគូរច្បាស់លាស់នូវទស្សនទាន "**ការអភិរក្សដើម្បីការអភិវឌ្ឍ ហើយការអភិវឌ្ឍទ្រទ្រង់ដល់ការអភិរក្ស**"។

## ៣- គោលដៅ

ជាមួយការដាក់ចេញនូវគោលបំណងជាក់លាក់ខាងលើ ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) បានកំណត់គោលដៅអភិវឌ្ឍន៍ ដូចខាងក្រោម÷

- **ទី១÷** លើកកម្ពស់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ឱ្យក្លាយជាវិស័យជន្ទល់សេដ្ឋកិច្ច រួមចំណែកបង្កើនប្រាក់ចំណូល ឱកាសការងារ និងកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍មូលដ្ឋាន
- **ទី២÷** ជំរុញវិស័យទេសចរណ៍ក្លាយជាយន្តការដ៏មានប្រសិទ្ធភាព ក្នុងការអភិរក្សធនធានធម្មជាតិ និងវប្បធម៌ ឈរលើគោលការណ៍និរន្តរភាព និងការទទួលខុសត្រូវ
- **ទី៣÷** ផ្សព្វផ្សាយកិត្យានុភាពរបស់ខេត្តមណ្ឌលគិរី ជាគោលដៅអេកូទេសចរណ៍ និងទេសចរណ៍វប្បធម៌ លំដាប់អន្តរជាតិ ទាំងក្នុងប្រទេស តំបន់ និងពិភពលោក
- **ទី៤÷** ជំរុញការចូលរួម និងសហការពីគ្រប់ភាគីពាក់ព័ន្ធ (4Ps) ទាំងផ្នែកសាធារណៈ ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន ព្រមជាមួយភ្ញៀវទេសចរ ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រនៅខេត្តមណ្ឌលគិរី ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

# ជំពូកទី ២

# ការកំណត់ក្របខណ្ឌយុទ្ធសាស្ត្រ និងយន្តការអនុវត្ត

- ផ្នែកទី១៖ ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍
- ផ្នែកទី២៖ ការកំណត់យន្តការអនុវត្ត

# ជំពូកទី ២÷ ការកំណត់ក្របខណ្ឌយុទ្ធសាស្ត្រ និងយន្តការអនុវត្ត

## ផ្នែកទី ១÷ ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍

ដើម្បីសម្រេចបាននូវចក្ខុវិស័យ ស្របតាមគោលបំណង និងគោលដៅយុទ្ធសាស្ត្រដែលបានកំណត់ខាងលើ ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) កំណត់ទិសដៅយុទ្ធសាស្ត្រអាទិភាពចំនួន ០៦ រួមមាន÷

- **ទី១÷** ការកំណត់តំបន់ទេសចរណ៍អាទិភាពសម្រាប់ការអភិវឌ្ឍ
- **ទី២÷** ការអភិវឌ្ឍផលិតផលទេសចរណ៍ និងវិនិយោគក្នុងវិស័យទេសចរណ៍
- **ទី៣÷** ការពង្រឹងគុណភាពទេសចរណ៍ និងធនធានមនុស្សគាំទ្រ
- **ទី៤÷** ការផ្សព្វផ្សាយ និងពង្រឹងរូបភាពវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី
- **ទី៥÷** ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍
- **ទី៦÷** ការសម្រួលការធ្វើដំណើរ ការតភ្ជាប់ និងការធ្វើសមាហរណកម្មក្នុងក្របខណ្ឌជាតិ និងតំបន់។

### ១- ការកំណត់តំបន់ទេសចរណ៍អាទិភាពសម្រាប់ការអភិវឌ្ឍ

ផ្អែកតាមការសិក្សារបស់ក្រុមការងារបច្ចេកទេស តំបន់ទេសចរណ៍អាទិភាពក្នុងខេត្តមណ្ឌលគិរី ត្រូវបានកំណត់ដូចខាងក្រោម÷

**ក្រុងសែនមនោរម្យ** មានដែនជម្រកសត្វព្រៃភ្នំព្រេច ទេសភាពវាលស្មៅ និងភ្នំល្អត្រកាល អាកាសធាតុត្រជាក់ល្មម ទឹកធ្លាក់ បឹងធម្មជាតិ ចម្ការផ្លែឈើ ចម្ការស្រល់ ភូមិជនជាតិដើមភាគតិច ក្រុមដំរី រមណីយដ្ឋានធម្មជាតិ សួនផ្កា ភ្នំដោះក្រមុំ អតីតព្រះរាជដំណាក់ និងជាទីប្រជុំជនក្រុងមានសក្តានុពលសម្រាប់ការអភិវឌ្ឍទេសចរណ៍បែបវប្បធម៌ ធម្មជាតិ និងលំហែកម្សាន្ត ទស្សនាភូមិជនជាតិ ទីលានវាយកូនហ្គោល ផ្សារទំនើប ផ្សាររាត្រី សេវាកម្មវិថីលក់ម្ហូបអាហារ មណ្ឌលកម្សាន្តមនុស្សពេញវ័យ សួនច្បារសម្រាប់ហាត់កីឡា និងលំហែកាយ។ ក្រុងសែនមនោរម្យគួរទទួលបានការវិនិយោគទ្រង់ទ្រាយធំ និងមធ្យម ដើម្បីរៀបចំសេវាកម្មទេសចរណ៍ និងតំបន់ទេសចរណ៍ទាំងអស់ខាងលើ។

**ស្រុកពេជ្រាដា** មានដងព្រៃព្រឹក្សា ជ្រោះជ្រលងដងអូរ ទឹកធ្លាក់ ភ្នំណាមលៀរ ភ្នំលុប្រាណ ទឹកជ្រោះ៧ជាន់ដែលមានដើមឈើធំៗដ៏កម្រ ទឹកជ្រោះប៊ូស្រាដែលជានិមិត្តរូបរបស់ខេត្ត ទេសភាពល្អប្រណិតជាច្រើនកន្លែង សត្វព្រៃគ្រប់ប្រភេទចូលចិត្តរស់នៅដែនជម្រកសត្វព្រៃណាមលៀរ ដែនជម្រកសត្វព្រៃស្រែពក ទឹកជ្រោះអូរតេ ទឹកជ្រោះអូរផ្លាយ ទឹកជ្រោះអូរតាំកន និងសហគមន៍ទេសចរណ៍ដេអេ ទីប្រជុំជនស្រុក ដែលជាតំបន់មានជនជាតិដើមភាគតិចរស់នៅ និងមានប្រពៃណីវប្បធម៌ជនជាតិដើម ក្រុមសិល្បៈ និងក្រុមសិប្បកម្ម។ ភូមិសាស្ត្រស្រុកពេជ្រាដានេះ គួរត្រូវបានបង្កើតជាតំបន់ទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍ និងទេសចរណ៍សហគមន៍ជនជាតិដើមភាគតិច ដើម្បីលើកទឹកចិត្តដល់បងប្អូនជនជាតិឱ្យថែរក្សាធនធានធម្មជាតិ និងប្រពៃណីវប្បធម៌របស់ពួកគេ ក៏ដូចជាផ្តល់ឱកាសបង្កើនប្រាក់ចំណូល បង្កើតការងារ ការកាត់បន្ថយភាពក្រីក្រ និងចំណាកស្រុក តាមរយៈវិស័យទេសចរណ៍នេះផងដែរ។ លើសពីនេះ ស្រុកពេជ្រាដាមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម បង្កើតបានជាសក្តានុពលទាក់ទាញភ្ញៀវទេសចរមកតាមច្រកព្រំដែនទ្វេភាគីណាមលៀរ (មណ្ឌលគិរី) ដាក់ប៉ូរ (ខេត្តដាក់ណុង វៀតណាម)។

**ស្រុកអូររាំង** មានរមណីយដ្ឋានធម្មជាតិ ទេសភាពព្រៃភ្នំ ដែនជម្រកសត្វព្រៃកែវសីមា មានសហគមន៍ជនជាតិដើមភាគតិចពូងអណ្ដូងក្រឡឹង ចម្ការស្រល់ ភូមិជនជាតិ ទឹកជ្រោះលែងឃិន លែងអង ទឹកជ្រោះលែងម្លូក ទឹកជ្រោះជ្រៃធំ ទឹកជ្រោះអូរតេ អណ្ដូងស្នេហ៍ ទឹកជ្រោះរមនា១ រមនា២ ក្រុមសិប្បកម្ម សត្វព្រៃ ដំរីស្រុក សុទ្ធសឹងជាសក្ដានុពលសម្រាប់អភិវឌ្ឍន៍ទេសចរណ៍បែបធម្មជាតិ វប្បធម៌ អេកូទេសចរណ៍ និងទេសចរណ៍សហគមន៍។ ស្រុកអូររាំង មានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម បង្កើតបានជាសក្ដានុពលទាក់ទាញភ្ញៀវទេសចរមកតាមច្រកព្រំដែនទ្វេភាគី ដាក់ដាំ (មណ្ឌលគិរី) ប៊ូប្រាំង (ខេត្តដាក់ណុង វៀតណាម)។

**ស្រុកកែវសីមា** មានដែនជម្រកសត្វព្រៃកែវសីមា ដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិកាទី (ផ្នូរខ្មោចជនជាតិបារាំងស្លាប់ក្នុងសម័យអាណានិគមនិយមបារាំង) សត្វព្រៃច្រើនប្រភេទ ភូមិជនជាតិដើមភាគតិច ដីមានជីជាតិ តំបន់កសិ-ឧស្សាហកម្ម (កៅស៊ូ ដំឡូងមី) និងដំណាំរួមផ្សំផ្សេងៗ។ ស្រុកកែវសីមា គួរត្រូវបានរក្សាទុកសម្រាប់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍ ទេសចរណ៍សហគមន៍ និងកសិ-ទេសចរណ៍។ ស្រុកនេះមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម និងមានសក្ដានុពលទាក់ទាញភ្ញៀវទេសចរមកតាមច្រកព្រំដែនទ្វេភាគីប៉ាខេ (មណ្ឌលគិរី) ហ្វាងយីវ (ខេត្តបិញភឿក វៀតណាម)។

**ស្រុកកោះញែក** មានដែនជម្រកសត្វព្រៃស្រែពក ដែនជម្រកសត្វព្រៃលំផាត់ វាលស្រែធំល្វឹងល្វើយ ទន្លេស្រែពក វាលខ្សាច់ទន្លេ សត្វព្រៃ រមណីយដ្ឋានភ្នំក្រាល ទំនប់ទឹកអូរហ្វ្រង់ ទំនប់ទឹកអូរយ៉េះ ទំនប់ទឹកអូរណំ ។ល។ ស្រុកកោះញែក មានសក្ដានុពលសម្រាប់អភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ទេសចរណ៍វប្បធម៌ អេកូទេសចរណ៍ កសិ-ទេសចរណ៍ និងទេសចរណ៍សហគមន៍។ ស្រុកកោះញែក មានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម និងមានសក្ដានុពលទាក់ទាញភ្ញៀវទេសចរមកតាមច្រកព្រំដែនទ្វេភាគីជីមៀ (មណ្ឌលគិរី) ដាក់រ៉េ (ខេត្តដាក់ឡាក់ វៀតណាម)។

ផ្អែកតាមសក្ដានុពលខាងលើ និងស្របតាមផែនការ និងប្លង់គោលប្រើប្រាស់ដីធ្លីខេត្តមណ្ឌលគិរីដែលបានកំពុងរៀបចំតំបន់អាទិភាពសំខាន់ៗដែលត្រូវរក្សាទុកសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ត្រូវបានកំណត់ ដូចខាងក្រោម÷

- **តំបន់របៀងអេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិនៃដែនជម្រកសត្វព្រៃទាំង៥** (ដែនជម្រកសត្វព្រៃភ្នំព្រេច ណាមលៀរ លំផាត់ កែវសីមា និងស្រែពក) ដែលអនុញ្ញាតឱ្យមានតែការវិនិយោគ និងអភិវឌ្ឍន៍សកម្មភាពទេសចរណ៍ ដែលមានការគិតគូរច្បាស់លាស់អំពីបរិស្ថាន
- **តំបន់របៀងទេសចរណ៍វប្បធម៌ និងអេកូទេសចរណ៍ ប៊ូស្រា-ដាក់ដាំ** ដែលលើកទឹកចិត្តឱ្យមានការអភិវឌ្ឍតែសកម្មភាពអេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិ ភ្ជាប់ជាមួយទេសចរណ៍វប្បធម៌ជនជាតិដើមភាគតិច
- **ក្រុងសែនមនោរម្យ** ដែលជាបណ្ដុំសកម្មភាពទេសចរណ៍ពហុបំណង
- **តំបន់ស្រុកអូររាំង** ភ្ជាប់ជាមួយគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះខេត្តមណ្ឌលគិរី ដែលអាចអភិវឌ្ឍន៍ជាតំបន់ប្រជុំជនរណប ភ្ជាប់ជាមួយក្រុងសែនមនោរម្យ
- **តំបន់ប្រជុំជននៃស្រុកកោះញែក** ដែលមានសក្ដានុពលក្នុងការរៀបចំអភិវឌ្ឍន៍ជាមណ្ឌលទេសចរណ៍នាពេលអនាគត ហើយដែលការអភិវឌ្ឍមានវិសាលភាពទូលំទូលាយជាងក្នុងតំបន់អភិរក្សនៃដែនជម្រកសត្វព្រៃ
- **តំបន់ទេសចរណ៍សមាហរណតាមច្រកព្រំដែន** ដែលអនុញ្ញាតឱ្យមានការអភិវឌ្ឍជារមណីយដ្ឋានសមាហរណ (ល្បែងកម្សាន្ត កីឡាកម្សាន្តនានា...)។

រូបភាពទី៤÷ ផែនទីកំណត់តំបន់អាទិភាពដែលត្រូវរក្សាទុកសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍




(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

ក្នុងន័យនេះ ដើម្បីសម្រេចចក្ខុវិស័យក្នុងការកំណត់តំបន់អាទិភាពខាងលើ ផែនការមេកំណត់ទិសដៅយុទ្ធសាស្រ្តដូចខាងក្រោម÷

- តំបន់ទាំង៦ ខាងលើ ត្រូវកំណត់ជាតំបន់អាទិភាពនៅក្នុងផែនការមេនេះ និងត្រូវមានការរៀបចំឱ្យមានការបង្កើតអង្គភាពគ្រប់គ្រងគោលដៅ (DMO-Destination Management Organization) ដាច់ដោយឡែកដែលដើរតួនាទីជាអ្នកគ្រប់គ្រង និងជំរុញការអភិវឌ្ឍសម្រាប់តំបន់នីមួយៗ

- គណៈកម្មការអន្តរក្រសួងដែលទទួលបន្ទុកដឹកនាំអនុវត្តផែនការមេនេះ ត្រូវរៀបចំគោលការណ៍ណែនាំពិសេសសម្រាប់ការអភិវឌ្ឍក្នុងតំបន់ទាំង០៦ ខាងលើ
- រាល់ការអភិវឌ្ឍសំខាន់ៗក្នុងតំបន់អាទិភាពទាំង០៦ ខាងលើ ត្រូវមានការពិនិត្យ និងជូនយោបល់ពីគណៈកម្មការអន្តរក្រសួងដឹកនាំអនុវត្តផែនការមេនេះ។

## ២- ការអភិវឌ្ឍផលិតផលទេសចរណ៍ និងវិនិយោគក្នុងវិស័យទេសចរណ៍

ពិតណាស់ថា ការអភិវឌ្ឍផលិតផលទេសចរណ៍ គឺជាសមាសភាពដ៏សំខាន់ក្នុងការកំណត់អំពីជោគជ័យនៃការអភិវឌ្ឍតំបន់ទេសចរណ៍។ ការកំណត់ប្រភេទផលិតផលទេសចរណ៍ណាមួយ គឺអាស្រ័យលើសក្តានុពល ធនធានជាក់ស្តែង និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។

### ២.១- ការជំរុញការវិនិយោគសម្បទាន្ទទ្រទ្រង់សំខាន់ៗសម្រាប់វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី

#### ក- ការវិនិយោគសណ្ឋាគារលំដាប់ផ្កាយ

ដូចបានបញ្ជាក់ក្នុងផ្នែកខាងលើ សេវាកម្មស្នាក់នៅក្នុងខេត្តមណ្ឌលគិរី នៅមានចំនួនតិចតួចបើប្រៀបធៀបទៅនឹងបណ្តាខេត្តផ្សេង និងពុំទាន់មានសណ្ឋាគារលំដាប់ផ្កាយ៤ និងផ្កាយ៥ ដែលអាចទាក់ទាញភ្ញៀវលំដាប់ខ្ពស់បាននៅឡើយ។ តាមការព្យាករណ៍នៅឆ្នាំ២០៣៥ តម្រូវការបន្ទប់ស្នាក់នៅក្នុងខេត្តមណ្ឌលគិរី នឹងកើនឡើងដល់ប្រមាណ ៧.០០០ បន្ទប់ ខណៈដែលបច្ចុប្បន្ន សេវាស្នាក់នៅក្នុងខេត្ត មានត្រឹមតែប្រមាណ ១.២៣០ បន្ទប់ ប៉ុណ្ណោះ។

ក្នុងន័យនេះ ផែនការមេជំរុញ និងលើកទឹកចិត្តឱ្យមានការអភិវឌ្ឍសេវាស្នាក់នៅបន្ថែម ទាំងសណ្ឋាគារ ផ្ទះសំណាក់អេកូឡូត (Eco-Lodge) បឹងហ្គាឡូ ម៉ូតែល និងសេវាស្នាក់នៅផ្សេងៗទៀត ទាំងចំនួនសម្បទា និងចំនួនបន្ទប់ ដើម្បីគាំទ្រដល់កំណើនភ្ញៀវទេសចរ ជាពិសេសការវិនិយោគទៅលើសណ្ឋាគារលំដាប់ផ្កាយ៤ និងផ្កាយ៥ ដើម្បីបំពេញតម្រូវការរបស់ភ្ញៀវទេសចរដែលមានកម្រិតខ្ពស់។

#### ខ- ការវិនិយោគលើផលិតផលទេសចរណ៍ (MICE)

ទេសចរណ៍បែប MICE រួមមានសកម្មភាពកិច្ចប្រជុំ សិក្ខាសាលា ពិព័រណ៍ និងសន្និសីទជាដើម។ តាមការចុះអង្កេត ភ្ញៀវទេសចរមួយចំនួនដែលមកកម្សាន្តខេត្តមណ្ឌលគិរី គឺដើម្បីចូលរួម និងរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទ និងកម្មវិធីនានា ដែលរៀបចំឡើងដោយស្ថាប័នសាធារណៈ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិនានា។ ក្នុងន័យនេះ ការពង្រឹងគុណភាពសម្បទាសាលប្រជុំ ដែលមានស្រាប់នៅតាមសណ្ឋាគារ និងមូលដ្ឋានអាជីវកម្មនានា គឺជាកិច្ចការចាំបាច់។ គួរកត់សម្គាល់ថា ក្រសួងទេសចរណ៍ បានដាក់ចេញស្តង់ដា MICE ប្រភេទបន្ទប់ប្រជុំកាលពីឆ្នាំ ២០១៦ ដែលកំពុងដាក់ឱ្យអនុវត្តនៅទូទាំងប្រទេស។ ទន្ទឹមនឹងនេះ នៅកម្រិតអាស៊ានក៏មានដាក់ចេញនូវស្តង់ដា MICE អាស៊ាន ប្រភេទបន្ទប់ប្រជុំ និងប្រភេទសាលពិព័រណ៍ ដែលបានកំពុងអនុវត្តនៅតាមបណ្តាប្រទេសអាស៊ានផងដែរ។

បន្ថែមពីលើនេះ ខេត្តមណ្ឌលគិរីមិនទាន់មានសាលប្រជុំដែលមានទំហំធំ និងឆ្លើយតបតាមស្តង់ដា ដែលអាចទទួលការរៀបចំកិច្ចប្រជុំដែលមានលក្ខណៈជាតិ និងអន្តរជាតិនៅឡើយ ដោយមានតែការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលាជាលក្ខណៈធម្មតាតែប៉ុណ្ណោះ។ ដូច្នេះការអភិវឌ្ឍសម្បទាទេសចរណ៍ដូចជា សណ្ឋាគារផ្កាយ៤ និងផ្កាយ៥ ភ្ជាប់ជាមួយសាលប្រជុំដែលមានលក្ខណៈស្តង់ដា គឺជាកាលានុវត្តភាព សម្រាប់ទាក់ទាញអ្នកវិនិយោគ និងភ្ញៀវទេសចរបែបធុរកិច្ច និងបែប MICE នេះ។

**គ- ការវិនិយោគលើទីលានវាយកូនហ្គោល**

ផែនការមេជំរុញ និងលើកទឹកចិត្តឱ្យមានការអភិវឌ្ឍទីលានវាយកូនហ្គោល ដែលអាចទាក់ទាញភ្ញៀវទេសចរលំដាប់ខ្ពស់ ចំណាយច្រើន និងស្នាក់នៅបានយូរ ដោយអាចសិក្សាយកតំបន់មួយចំនួនដែលមានលក្ខណៈសមស្រប ទាំងលើទីតាំងភូមិសាស្ត្រ អាកាសធាតុ និងទិសដៅខ្យល់ជាដើម។

**ឃ- ការវិនិយោគសួនកម្សាន្ត**

ផែនការមេជំរុញ និងលើកទឹកចិត្តឱ្យមានការអភិវឌ្ឍជាសួនកម្សាន្ត (Safari Theme Park) សួនសត្វ និងសកម្មភាពទេសចរណ៍ប្រហាក់ប្រហែល ដោយឈរលើលក្ខណៈពិសេសនៃអាកាសធាតុត្រជាក់បង្គួរដែលអំណោយផលដល់ការរៀបចំសួនកម្សាន្ត។ ជាក់ស្តែង ការអភិវឌ្ឍសួនសត្វសាហ្វារីនៅភ្នំពេញ បានកំពុងទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិឱ្យទៅកម្សាន្តបានច្រើន។

**ង- ការវិនិយោគពហុកីឡដ្ឋាន**

ព្រមជាមួយសកម្មភាពខាងលើ ការគិតគូរឱ្យមានការសាងសង់ និងកែលម្អពហុកីឡដ្ឋានក្នុងខេត្ត នឹងអាចបម្រើដល់ការរៀបចំជាព្រឹត្តិការណ៍កីឡាសម្រាប់ខេត្ត ក៏ដូចជាព្រឹត្តិការណ៍កីឡាទេសចរណ៍ ខណៈដែលវិស័យទេសចរណ៍កីឡាបានកំពុងក្លាយជាផលិតផលទេសចរណ៍ដ៏ពេញនិយមទាក់ទាញភ្ញៀវទេសចរបានកាន់តែច្រើន និងចំណាយខ្ពស់ ដូចជាកម្មវិធីរត់ប្រណាំងម៉ារ៉ាតុងអង្គរ នារៀងរាល់ខែធ្នូជាដើម។

**ច- ការវិនិយោគសកម្មភាព និងសេវាកម្សាន្ត**

បន្ថែមពីលើផលិតផលទេសចរណ៍ខាងលើ ផែនការមេនេះស្នើឱ្យមានការអភិវឌ្ឍសេវាកម្សាន្តនានា ជាពិសេសសកម្មភាពកម្សាន្តនាពេលរាត្រី ដូចជាផ្សាររាត្រីផាប់ស្ទ្រីត (Pub Street) ដែលបានរៀបចំនៅខេត្តសៀមរាបជាដើម ដែលបានទាក់ទាញភ្ញៀវទេសចរជាច្រើន។ ការរៀបចំផ្សាររាត្រីដែលមានលក្ខណៈស្តង់ដា ធានាបានសណ្តាប់ធ្នាប់ល្អ និងមានសកម្មភាពសម្បូរបែបនាពេលរាត្រី នឹងក្លាយជាផលិតផលដ៏សំខាន់មួយផ្សេងទៀតក្នុងការទាក់ទាញភ្ញៀវទេសចរមកខេត្តមណ្ឌលគិរី ជាពិសេសនាពេលរាត្រី បន្ទាប់ពីការធ្វើដំណើរទៅកាន់គោលដៅទេសចរណ៍ ធម្មជាតិ និងវប្បធម៌នៅពេលថ្ងៃ។ ការរៀបចំផាប់ស្ទ្រីត ក៏ត្រូវតែរៀបចំភ្ជាប់ជាមួយផ្សាររាត្រី ដែលបង្ហាញអំពីអត្តសញ្ញាណដើមរបស់ខេត្តមណ្ឌលគិរី និងមិនគួរលើកទឹកចិត្តឱ្យនាំយកផលិតផលនាំចូលពីបរទេស មកតាំងបង្ហាញ និងលក់ជូនភ្ញៀវទេសចរឡើយ។ ព្រមជាមួយនេះ គួរលើកទឹកចិត្តឱ្យមានការបង្កើតសេវាកម្ម និងសម្ភារទេសចរណ៍បន្ថែម ដូចជាភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ដែលមានស្តង់ដាជាដើម។

ទន្ទឹមនឹងនេះ ការអភិវឌ្ឍសេវាកម្សាន្តមនុស្សពេញវ័យ ដូចជាខារ៉ាអូខេ រង្គសាល ឌីស្កូតែក (ក្លឹប) និងបៀរហ្គាឌិនជាដើម ក៏ជាផ្នែកមួយសំខាន់ក្នុងការទាក់ទាញ និងពន្យាការស្នាក់នៅរបស់ភ្ញៀវទេសចរផងដែរ។ យោងតាមទិន្នន័យរបស់មន្ទីរទេសចរណ៍ សេវាកម្សាន្តមនុស្សពេញវ័យនាពេលបច្ចុប្បន្ន មិនទាន់ឆ្លើយតបនឹងកំណើនភ្ញៀវទេសចរនាពេលអនាគតបាននៅឡើយ។ ប៉ុន្តែការវិនិយោគសេវាកម្មប្រភេទនេះ ត្រូវមានការគិតគូរអំពីការរៀបចំទីតាំងសមស្រប ដែលមិនមានផលប៉ះពាល់ដល់បរិស្ថាន និងប្រជាពលរដ្ឋមូលដ្ឋាន ដោយត្រូវមានការកំណត់តំបន់ (Zoning) ឱ្យបានច្បាស់លាស់សម្រាប់ការវិនិយោគ។

## ២.២- ការអភិវឌ្ឍសហគមន៍ទេសចរណ៍ អេកូទេសចរណ៍ និងទេសចរណ៍បៃតង

### ក- ការជំរុញសកម្មភាពសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

ផ្ទៃដីខេត្តមណ្ឌលគិរីប្រមាណ ៨០% ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃ។ នៅក្នុងយុទ្ធសាស្ត្រទី១ បានកំណត់តំបន់អាទិភាពចំនួន ០៦ សម្រាប់ការអភិវឌ្ឍ ដែលក្នុងនោះ តំបន់ដែនជម្រកសត្វព្រៃទាំង ០៥ ត្រូវបានរក្សាទុកសម្រាប់ការអភិវឌ្ឍ តែការអភិវឌ្ឍសហគមន៍ទេសចរណ៍ អេកូទេសចរណ៍ និងទេសចរណ៍ បៃតង និងសកម្មភាពទេសចរណ៍ដែលមានផលប៉ះពាល់អប្បបរមាទៅលើបរិស្ថាន។ ផែនការមេលើកទឹកចិត្តឲ្យមានការវិនិយោគអេកូទេសចរណ៍ខ្នាតតូចនៅក្នុងតំបន់ដែនជម្រកសត្វព្រៃ ជាពិសេសការបញ្ចូលគំនិតក្នុងការអភិវឌ្ឍរមណីយដ្ឋាន ដែលមានការគិតគូរច្បាស់លាស់ដល់បរិស្ថាន និងស្របតាមនិន្នាការថ្មីនៃការអភិវឌ្ឍទេសចរណ៍ ដូចជាផ្ទះស្នាក់តាមដើមឈើជាដើម។

រូបភាពទី៥÷ ពង្រាងគំនូសប្លង់គំរូសម្រាប់ការអភិវឌ្ឍសម្បទាស្នាក់នៅបែបអេកូទេសចរណ៍



(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

ការបញ្ចូលសកម្មភាពទេសចរណ៍នៅក្នុងតំបន់ការពារធម្មជាតិ គឺស្របតាមស្មារតីនៃគោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០ ក្នុងការជំរុញឲ្យសហគមន៍ទាំងអស់ មិនថាសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ផ្សេងទៀត ដែលមានសក្តានុពលទេសចរណ៍ ហើយអាចបញ្ចូលសកម្មភាពទេសចរណ៍ ដើម្បីប្រែក្លាយទៅជាសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ បម្រើដល់វិស័យទេសចរណ៍។

ក្នុងន័យនេះ ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ត្រូវជំរុញកិច្ចការទាំងអស់នេះ ជាពិសេសជំរុញការបញ្ចូលសកម្មភាពទេសចរណ៍ទៅក្នុងសហគមន៍ ដែលស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃទាំង០៥។

### ខ- ការជំរុញសកម្មភាពទេសចរណ៍ផ្សងព្រេងកម្សាន្ត

សកម្មភាពទេសចរណ៍ផ្សងព្រេងបែបកម្សាន្តនៅក្នុងដែនជម្រកសត្វព្រៃទាំង០៥ ដូចជាការដើរក្នុងព្រៃ ការបោះតង់ ការឡើងភ្នំ និងសកម្មភាពផ្សេងៗ គួរត្រូវបានជំរុញការអភិវឌ្ឍ។ គួរបញ្ជាក់ថា សកម្មភាពទេសចរណ៍ផ្សងព្រេងនាពេលបច្ចុប្បន្ន បានកំពុងក្លាយជាផលិតផលទេសចរណ៍ដែលមានសក្តានុពល និងមានប្រជាប្រិយភាពខ្លាំង ពិសេសក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ ខណៈដែលភ្ញៀវទេសចរភាគច្រើន បានងាកមករកសកម្មភាពទេសចរណ៍ផ្សងព្រេង ដែលក្នុងនោះតំបន់ទេសចរណ៍ផ្សងព្រេងសំខាន់ៗ និងកំពុងទាក់ទាញភ្ញៀវទេសចរច្រើនមានដូចជា តំបន់ទេសចរណ៍ផ្សងព្រេងភ្នំឱរ៉ាល់ និងភ្នំខ្នងផ្សារក្នុងខេត្តកំពង់ស្ពឺ តំបន់ទេសចរណ៍ផ្សងព្រេងអារ៉ែង និងជីផាតក្នុងខេត្តកោះកុង តំបន់ទេសចរណ៍ផ្សងព្រេងសំឡូតក្នុងខេត្តបាត់ដំបង តំបន់ទេសចរណ៍ផ្សងព្រេងអូរសោម និងភ្នំទំព័រក្នុងខេត្តពោធិ៍សាត់ និងតំបន់ទេសចរណ៍ផ្សងព្រេងភ្នំត្បែងក្នុងខេត្តព្រះវិហារជាដើម។

ក្រៅពីសកម្មភាពខាងលើ ផែនការមេជំរុញឱ្យមានការអភិវឌ្ឍសកម្មភាពទេសចរណ៍កីឡា ដែលមានលក្ខណៈផ្សងព្រេង ដូចជាការជិះកង់ក្នុងព្រៃ ការឡើងភ្នំ និងប្រភេទកីឡាប្រហាក់ប្រហែលផ្សេងទៀត។ ប៉ុន្តែសកម្មភាពទាំងនោះត្រូវធ្វើឡើងដោយប្រយ័ត្នប្រយែង និងគោរពទៅតាមស្តង់ដាទេសចរណ៍ផ្សងព្រេងរបស់ក្រសួងទេសចរណ៍ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីឆ្នាំ២០១៦ ដោយត្រូវគិតគូរអំពីបញ្ហាសុវត្ថិភាពភ្ញៀវទេសចរឱ្យបានច្បាស់លាស់។

**គ- ការពង្រឹងគុណភាពសេវាកម្មនៅក្នុងសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍**

ការរៀបចំភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងសហគមន៍ គួរមានទ្រង់ទ្រាយតូច និងមានរចនាបថស្របតាមស្តង់ដាបរិស្ថាន។ ការវិនិយោគក្រោមទម្រង់ជាសហគមន៍ទេសចរណ៍ ឬអេកូទេសចរណ៍ ឬក៏សកម្មភាពណាមួយក្នុងតំបន់អភិរក្ស និងដែនជម្រកសត្វព្រៃខាងលើ ត្រូវតែគោរពឱ្យបានម៉ឺងម៉ាត់នូវគោលការណ៍និរន្តរភាព និងការទទួលខុសត្រូវ ពិសេសស្មារតីនៃគោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០។

ទន្ទឹមនឹងនេះ ត្រូវគិតគូរអំពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទៅដល់ប្រជាសហគមន៍មូលដ្ឋានលើមុខជំនាញចាំបាច់មួយចំនួន ដូចជាជំនាញបដិសណ្ឋារកិច្ច ការគ្រប់គ្រងសហគមន៍ ការរៀបចំផ្ទះស្នាក់ គេហកិច្ច ជំនាញចុងភៅ និងជំនាញចាំបាច់នានាសម្រាប់ទទួលភ្ញៀវទេសចរ។ ព្រមជាមួយនេះ ការរៀបចំឱ្យមានមគ្គុទ្ទេសក៍ និងអ្នកនាំភ្ញៀវនៅក្នុងតំបន់អភិរក្ស តាមរយៈការប្រើប្រាស់មន្ត្រីឧទ្យានុរក្ស និងប្រជាពលរដ្ឋមូលដ្ឋាន នឹងគាំទ្រដល់ការអភិវឌ្ឍសកម្មភាពទេសចរណ៍ផ្សងព្រេង ព្រមទាំងជួយលើកកម្ពស់ជីវភាព និងប្រាក់ចំណូលរបស់ប្រជាសហគមន៍។ លើសពីនេះ គួរជំរុញឱ្យមានការអភិវឌ្ឍមណ្ឌលព័ត៌មានឱ្យបានយ៉ាងតិចមួយនៅក្នុងដែនជម្រកសត្វព្រៃនីមួយៗ។

## ២.៣- ការជំរុញការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍

រមណីយដ្ឋានទេសចរណ៍ គឺជាសមាសភាពសំខាន់មួយក្នុងការទាក់ទាញភ្ញៀវទេសចរ ហើយដែលត្រូវបានបែងចែកជាច្រើនប្រភេទ និងច្រើនកម្រិតទៅតាមស្ថានភាពជាក់ស្តែង។ ក្នុងន័យនេះ ខេត្តមណ្ឌលគិរី ចាំបាច់ត្រូវមានការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍បែបកែច្នៃឱ្យបានច្រើនបន្ថែមពីលើរមណីយដ្ឋានទេសចរណ៍ដែលមានស្រាប់ ដូចជារមណីយដ្ឋានទេសចរណ៍ធម្មជាតិប៊ូស្រា និងរមណីយដ្ឋានទេសចរណ៍សមុទ្រឈើជាដើម។

ការអភិវឌ្ឍរមណីយដ្ឋាន ត្រូវគោរពឱ្យបានម៉ឺងម៉ាត់តាមស្តង់ដាក្រសួងទេសចរណ៍ ដែលរួមមាន÷

- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងឱ្យបានច្បាស់លាស់
- រៀបចំឱ្យមានផែនការមេអភិវឌ្ឍន៍រមណីយដ្ឋាន
- សម្ភារទ្រទ្រង់ក្នុងរមណីយដ្ឋាន ដូចជាតូបលក់ម្ហូបអាហារ ភេសជ្ជៈ តូបលក់វត្ថុអនុស្សាវរីយ៍ ត្រូវរៀបចំឱ្យមានរចនាបថ សោភ័ណភាព បង្ហាញអត្តសញ្ញាណរបស់រមណីយដ្ឋាន
- គិតគូរអំពីការបញ្ចូលទស្សនទានថ្មីៗក្នុងការអភិវឌ្ឍរមណីយដ្ឋាន ដូចជាការរៀបចំឱ្យមានរថយន្តអគ្គិសនី និងរថភ្លើងកែច្នៃសម្រាប់ជិះកម្សាន្តក្នុងរមណីយដ្ឋានជាដើម
- រៀបចំឱ្យមានយន្តការគ្រប់គ្រងបរិស្ថាន និងសំរាមឱ្យបានច្បាស់លាស់ ពិសេសការបំពាក់ធុងសំរាមឱ្យបានគ្រប់គ្រាន់ និងការបែងចែកសំរាមទៅតាមប្រភេទឱ្យបានត្រឹមត្រូវ
- រៀបចំចំណតក្នុងរមណីយដ្ឋានឱ្យបានសមរម្យ គ្រប់គ្រាន់ និងមានរបៀបរៀបរយ
- លើកទឹកចិត្តការប្រើប្រាស់ផលិតផលក្នុងតំបន់ និងក្នុងខេត្ត ដើម្បីលើកតម្កើងអត្តសញ្ញាណខេត្ត

- លើកទឹកចិត្តឱ្យមានការប្រើប្រាស់ផលិតផលជំនួស និងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ធានាបានគោលការណ៍ស្អាត និងបៃតង
- រៀបចំឱ្យមានបង្គន់អនាម័យឱ្យបានគ្រប់គ្រាន់នៅក្នុងរមណីយដ្ឋាន
- រៀបចំឱ្យមានមជ្ឈមណ្ឌលព័ត៌មាន ដើម្បីផ្តល់ព័ត៌មានបន្ថែមដល់ភ្ញៀវទេសចរ
- បុគ្គលិកដែលនៅក្នុងរមណីយដ្ឋានទាំងអស់ត្រូវទទួលបានការបណ្តុះបណ្តាល និងមានជំនាញច្បាស់លាស់ឆ្លើយតបតាមស្តង់ដាក្រសួងទេសចរណ៍ និងស្តង់ដាអាស៊ាន
- គិតគូរឱ្យបានច្បាស់លាស់អំពីការគ្រប់គ្រងសុវត្ថិភាពចំណីអាហារ និងសុវត្ថិភាពភ្ញៀវទេសចរ ជាពិសេសរៀបចំឱ្យមានកន្លែងសង្គ្រោះបឋមក្នុងករណីមានគ្រោះថ្នាក់ជាយថាហេតុណាមួយកើតឡើង។

បន្ថែមពីលើនេះ រមណីយដ្ឋានទាំងអស់ត្រូវចូលរួមចំណែកលើកស្ទួយការប្រើប្រាស់ផលិតផលក្នុងតំបន់ និងក្នុងខេត្ត ជាពិសេសផលិតផលកសិកម្ម ដូចជាបន្លែ ផ្លែឈើ និងផលិតផលសិប្បកម្មនានារបស់បងប្អូនជនជាតិដើមភាគតិច ដើម្បីលើកតម្កើនអត្តសញ្ញាណរបស់ខេត្ត។

ទន្ទឹមនឹងនេះ តាមរយៈការធ្វើអង្កេត ភ្ញៀវទេសចរភាគច្រើនមិនទាន់ទៅដល់គ្រប់គោលដៅទេសចរណ៍សំខាន់ៗក្នុងខេត្តទេ គឺនៅប្រមូលផ្តុំតែនៅតំបន់សំខាន់ៗ ដូចជារមណីយដ្ឋានទេសចរណ៍ធម្មជាតិប៊ូស្រា និងរមណីយដ្ឋានសមុទ្រឈើតែប៉ុណ្ណោះ។ ក្នុងន័យនេះ រដ្ឋបាលខេត្ត និងមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី ត្រូវរៀបចំផែនទីបង្ហាញគោលដៅទេសចរណ៍ឱ្យបានច្បាស់លាស់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីឱ្យភ្ញៀវទេសចរបានដឹង និងអាចទៅកម្សាន្តបានគ្រប់គោលដៅក្នុងខេត្ត។

### ២.៤- ការអភិវឌ្ឍផលិតផលទេសចរណ៍វប្បធម៌ជនជាតិដើមភាគតិច

ការជំរុញការអភិវឌ្ឍទេសចរណ៍វប្បធម៌ជនជាតិដើមភាគតិច មានសារៈសំខាន់ ដែលមិនត្រឹមតែជំរុញការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ចូលរួមចំណែកដល់ការអភិរក្សវប្បធម៌ប្រពៃណីរបស់ពួកគេផងដែរ។ ជាមួយនឹងការរៀបចំផលិតផលទេសចរណ៍របស់ជនជាតិដើមភាគតិច ក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្ត ត្រូវជំរុញការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍វប្បធម៌ជនជាតិដើម ភាគតិចតាមគ្រប់រូបភាព ដូចជាតាមប្រព័ន្ធឌីជីថល ការផលិតស្ប៉តវីដេអូ និងប្រព័ន្ធផ្សព្វផ្សាយនានា។

ផែនការមេជំរុញឱ្យមានការរៀបចំអភិវឌ្ឍ**ភូមិនិម្មិតជនជាតិដើមភាគតិច ឬហៅថាភូមិគំរូ** នៅតាមតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ពិសេសនៅ**ឃុំដាក់ដាំ ក្នុងស្រុកអូររាំង**។ ជាមួយគ្នានេះ ត្រូវសិក្សារៀបចំឱ្យមានពិធីបុណ្យជនជាតិដើមភាគតិច ដែលអាចប្រារព្ធឡើងជារៀងរាល់ឆ្នាំ ដើម្បីទាក់ទាញភ្ញៀវទេសចរមកទស្សនាបន្ថែម។ រដ្ឋបាលខេត្តត្រូវជំរុញឱ្យមានការរៀបចំចងក្រងឯកសារច្បាស់លាស់អំពីបច្ចុប្បន្នភាព និងការវិវត្តរបស់ជនជាតិដើមភាគតិចសម្រាប់ការសិក្សាស្រាវជ្រាវផងដែរ។

ទន្ទឹមនឹងនេះ គួរមានការសិក្សាបង្កើតឱ្យមាន**សារមន្ទីរ និងសាលមហោស្រពសម្តែងសិល្បៈសម្រាប់ជនជាតិដើមភាគតិច** ដែលនឹងបង្កើតជាសក្តានុពលមួយទៀតក្នុងការទាក់ទាញភ្ញៀវទេសចរអន្តរជាតិ ឱ្យស្គាល់អំពីអត្តសញ្ញាណ និងវប្បធម៌ប្រពៃណីរបស់ពួកគាត់។

រូបភាពទី៦÷ ពង្រាងគំនូសប្លង់សារមន្ទីរជនជាតិដើមភាគតិច



(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

ដោយឡែក រដ្ឋបាលខេត្តមណ្ឌលគិរី គួរសិក្សាបង្កើតឲ្យមានទីតាំងសមស្របណាមួយដើម្បីឲ្យបងប្អូនជនជាតិដើមភាគតិចទាំងអស់ អាចតាំងបង្ហាញ និងលក់ផលិតផលរបស់ខ្លួន ដូចជាផលិតផលកសិកម្ម និងសិប្បកម្មជាដើម ពិសេសភ្ជាប់ជាមួយគំនិតក្នុងការបង្កើតផ្សាររាត្រី និង Pub Street ជាដើម។

ផ្នែកឯកជនក៏ត្រូវចូលរួមរៀបចំកញ្ចប់ទស្សនកិច្ចឲ្យបានច្រើនទៅកាន់តំបន់ជនជាតិដើមភាគតិច ផ្សារភ្ជាប់ជាមួយគោលដៅទេសចរណ៍សំខាន់ៗដែលមានក្នុងខេត្ត និងតំបន់ជុំវិញ ជាពិសេសភូមិជនជាតិដើមភាគតិច ដែលត្រូវបានស្នើឲ្យបង្កើតឡើងនៅតាមតំបន់សំខាន់ៗមួយចំនួន។

### ២.៥- ការរៀបចំព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗ

ក្រៅពីផលិតផលទេសចរណ៍បែបរូបីយ៍ខាងលើ ការគិតគូររៀបចំជាព្រឹត្តិការណ៍ទេសចរណ៍ ក៏ជាកិច្ចការសំខាន់ក្នុងទាក់ទាញភ្ញៀវទេសចរ។ ព្រឹត្តិការណ៍ទេសចរណ៍ អាចជាព្រឹត្តិការណ៍ដែលរៀបចំជាលក្ខណៈរដូវកាល ឬជាលក្ខណៈទៀងទាត់។ តាមការចុះអង្កេត ភ្ញៀវទេសចរភាគច្រើនមកកម្សាន្តតែនៅតាមរមណីយដ្ឋានសំខាន់ៗមួយចំនួនក្នុងខេត្ត ដោយនៅមិនទាន់ត្រូវបានទាក់ទាញដោយព្រឹត្តិការណ៍ទេសចរណ៍ណាមួយនៅឡើយ។ ការរៀបចំព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំជាលក្ខណៈទៀងទាត់ ដូចជាពិធីបុណ្យអេកូទេសចរណ៍ ពិធីបុណ្យដំរី និងពិធីបុណ្យជនជាតិភាគតិចជាដើម នឹងចូលរួមចំណែកទាក់ទាញភ្ញៀវទេសចរមកកម្សាន្តក្នុងខេត្ត ដែលគប្បីរៀបចំទៅតាមពេលវេលាសមស្របមួយច្បាស់លាស់ពិសេសក្នុងរដូវកាលដែលមានភ្ញៀវតិច។ ទន្ទឹមនឹងនេះ ការរៀបចំកម្មវិធីតាមស្ថានភាពជាក់ស្តែង ដូចជាការរៀបចំតាំងពិព័រណ៍ផលិតផលក្នុងស្រុក ផលិតផលទេសចរណ៍ក្នុងខេត្ត កម្មវិធីបង្ហាញម្ហូបអាហាររបស់ជនជាតិដើមភាគតិច សុទ្ធតែជាកត្តារួមចំណែកក្នុងការទាក់ទាញភ្ញៀវទេសចរ។

ការរៀបចំនូវព្រឹត្តិការណ៍កីឡាមួយចំនួន ក៏អាចទាក់ទាញភ្ញៀវទេសចរបានច្រើនផងដែរ អាស្រ័យទៅលើទីតាំងភូមិសាស្ត្ររបស់ខេត្ត ដូចជាការប្រណាំងកង់ កម្មវិធីរត់កម្សាន្តបែបផ្សងព្រេង ការប្រណាំងរថយន្តលើផ្លូវគ្រោះថ្នាក់ ក៏ដូចជាសកម្មភាពទេសចរណ៍ផ្សេងទៀតដែលមានសក្តានុពល។

ប៉ុន្តែការរៀបចំព្រឹត្តិការណ៍ទាំងអស់នេះ ទាមទារឲ្យការចូលរួមពីភាគីពាក់ព័ន្ធ ពិសេសកិច្ចសហការជាមួយវិស័យឯកជន ទាំងការរៀបចំ ក៏ដូចជាការផ្សព្វផ្សាយ និងការរៀបចំកញ្ចប់ទស្សនកិច្ចសម្រាប់ភ្ញៀវទេសចរ។ ជាក់ស្តែង ការរៀបចំពិធីបុណ្យទន្លេ ដែលឆ្លាស់វេនគ្នាទៅតាមបណ្តាខេត្តជាប់ដងទន្លេ និងពិធីបុណ្យសមុទ្រដែលឆ្លាស់វេនគ្នាទៅតាមបណ្តាខេត្តជាប់តំបន់ឆ្នេរសមុទ្រ បានទាក់ទាញភ្ញៀវទេសចររាប់សិបម៉ឺននាក់ជារៀងរាល់ឆ្នាំ។

### ២.៦- ការជំរុញសកម្មភាពកសិ-ទេសចរណ៍

ខេត្តមណ្ឌលគិរី ជាខេត្តដែលសម្បូរទៅដោយព្រៃឈើ ធម្មជាតិ និងចម្ការដំណាំជាច្រើន រួមមានចម្ការប៉័រ ទុរេន សាវម៉ាវ កាហ្វេ ម្រេច កៅស៊ូជាដើម សម្រាប់ទាក់ទាញក្រសែភ្នែក និងចំណាប់អារម្មណ៍ភ្ញៀវទេសចរ។ ក្នុងន័យនេះ ការកែប្រែកសិដ្ឋានចម្ការដំណាំទាំងនោះ ដើម្បីទាក់ទាញភ្ញៀវទេសចរ មានសារៈសំខាន់ ដោយម្ចាស់កសិដ្ឋាន និងម្ចាស់ចម្ការទាំងអស់នោះ អាចរៀបចំសម្បទាទេសចរណ៍ សេវា ស្នាក់នៅ សេវាម្ហូបអាហារ ការបោះតង់ ការរៀបចំជាខ្សែទស្សនកិច្ចក្នុងកសិដ្ឋាន និងការផ្សារភ្ជាប់ទៅកាន់តំបន់ជនជាតិដើមភាគតិច ដែលមានរបៀបរបបនៃការដាំដំណាំខុសពីប្រជាជនកម្ពុជាទូទៅជាដើម។

ជាមួយគ្នានេះ គួរគិតគូរឲ្យមានការបង្កើត និងអភិវឌ្ឍន៍ជាភូមិកសិ-ទេសចរណ៍គំរូ ដោយជ្រើសរើសទីតាំងណាមួយសមស្រប ជាពិសេសនៅក្នុងក្រុងសែនមនោរម្យ ដែលសម្បូរទៅដោយចម្ការដំណាំ ដោយជំរុញឲ្យម្ចាស់កសិដ្ឋានធ្វើការបង្ហាញដំណើរការនៃការរៀបចំកសិដ្ឋាន និងអនុញ្ញាតឲ្យភ្ញៀវទេសចរចូលរួមសកម្មភាពដាំដុះដោយខ្លួនឯង។

បន្ថែមពីលើនេះ ត្រូវរៀបចំឲ្យមានស្លាកសញ្ញាសម្គាល់កសិផលសំខាន់ៗប្រចាំតំបន់ និងក្នុងខេត្ត ដូចជាម្រេចមណ្ឌលគិរី កាហ្វេមណ្ឌលគិរី ប៉័រមណ្ឌលគិរី សាវម៉ាវមណ្ឌលគិរី ដែលជាផលិតផលសម្គាល់អត្តសញ្ញាណរបស់ខេត្ត ព្រមជាមួយផលិតផលសិប្បកម្មមួយចំនួន ដូចជាស្រាផាស់សិនមណ្ឌលគិរីជាដើម។ ផលិតផលទាំងនេះ នឹងរួមចំណែកសម្រេចចក្ខុវិស័យខេត្តមណ្ឌលគិរី ជាខេត្តផ្គត់ផ្គង់ផ្កា បន្លែ ផ្លែឈើទៅកាន់គោលដៅខេត្តផ្សេងៗទៀតក្នុងប្រទេស និងមានលទ្ធភាពនាំចេញទៅបណ្តាប្រទេសជិតខាង។

### ២.៧- ការអភិវឌ្ឍទេសចរណ៍វ័យចំណាស់ ទេសចរណ៍សុខភាព និងទេសចរណ៍ផ្ទះទី២

ទីតាំងភូមិសាស្ត្រ អាកាសធាតុត្រជាក់ និងទឹកដីអំណោយផល បានជំរុញឲ្យខេត្តមណ្ឌលគិរីមានសក្តានុពលក្នុងការទាក់ទាញប្រភេទទេសចរណ៍មួយដែលកំពុងមានការកើនឡើងខ្លាំង គឺទេសចរណ៍វ័យចំណាស់ ទេសចរណ៍សុខភាព និងទេសចរណ៍ផ្ទះទី២ ពិសេសទេសចរអឺរ៉ុប ជប៉ុន និងអាមេរិកជាដើម ដែលស្វែងរកនូវកន្លែងលំហែ និងសម្រាកពេលចូលនិវត្តន៍។

ក្នុងន័យនេះ ផែនការមេជំរុញឲ្យមានការអភិវឌ្ឍតំបន់ទេសចរណ៍ពិសិដ្ឋ ដែលរាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ដឹកនាំរៀបចំ និងបានកំពុងធ្វើការអភិវឌ្ឍតំបន់មួយចំនួននៅតំបន់ឆ្នេរសមុទ្រ ព្រមជាមួយការរៀបចំជាតំបន់រមណីយដ្ឋានសមាហរណ៍ ដែលរួមបញ្ចូលនូវសកម្មភាព និងគោលនយោបាយលើកទឹកចិត្តពិសេស។

គោលនយោបាយពិសេស គួរត្រូវបានរៀបចំឡើងដើម្បីលើកទឹកចិត្តឲ្យភ្ញៀវទេសចរអន្តរជាតិមានលទ្ធភាពក្នុងការទិញអចលនទ្រព្យក្នុងកម្រិតណាមួយ និងមានសិទ្ធិប្រើប្រាស់អចលនទ្រព្យនោះក្នុងពេលស្នាក់នៅប្រទេសកម្ពុជា។ ដើម្បីជំរុញទេសចរណ៍នេះឲ្យបានទូលំទូលាយ ចាំបាច់ត្រូវមានការផ្សព្វផ្សាយឲ្យបានច្បាស់លាស់អំពីគោលនយោបាយពិសេសនេះ ពិសេសសិទ្ធិ និងកាតព្វកិច្ច ដែលភ្ញៀវទេសចរអាចមាន និងប្រកាន់យក។

បន្ថែមពីលើនេះ គួររៀបចំឲ្យមានទីតាំង ឬកន្លែងសមស្របណាមួយ សម្រាប់រៀបចំផលិតផលទេសចរណ៍បែបសមាធិ បង្កើតនូវភាពទាក់ទាញបន្ថែមសម្រាប់ភ្ញៀវទេសចរ។

### ៣- ការពង្រឹងគុណភាពទេសចរណ៍ និងធនធានមនុស្សគាំទ្រ

ការអភិវឌ្ឍផលិតផលទេសចរណ៍ ត្រូវដើរទន្ទឹមគ្នានឹងការបណ្តុះបណ្តាល និងការពង្រឹងធនធានមនុស្ស ស្របជាមួយកំណើនភ្ញៀវទេសចរ។ ក្នុងន័យនេះ ការពង្រឹងសេវាកម្មទេសចរណ៍ទាំងអស់ដែលមាននៅក្នុងខេត្ត ចាំបាច់ត្រូវឆ្លើយតបទៅនឹងស្តង់ដាដែលក្រសួងទេសចរណ៍បានដាក់ចេញ និងឈានទៅដល់ការអនុវត្តនូវស្តង់ដាអាស៊ាន។ ជាចក្ខុវិស័យ គឺគ្រប់សេវាកម្មទេសចរណ៍ត្រូវមានស្តង់ដា ហើយគ្រប់បុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ ត្រូវមានគុណភាព និងឆ្លងកាត់វគ្គបណ្តុះបណ្តាល។

#### ៣.១- ការពង្រឹងគុណភាពទេសចរណ៍

បើទោះបីជាចំនួនភ្ញៀវទេសចរ មកកាន់ខេត្តមណ្ឌលគិរីនាពេលបច្ចុប្បន្ន មានការកើនឡើងជាលំដាប់ ប៉ុន្តែចំនួននេះនឹងមានការកើនឡើងជាបន្តទៀតជាមួយគម្រោងព្រលានយន្តហោះខេត្តមណ្ឌលគិរី ដែលនឹងលេចចេញជារូបរាងនាពេលខាងមុខ ព្រមជាមួយការដាក់ឲ្យអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរីនេះ។

**ក- <u>ការពង្រឹងគុណភាពទេសចរណ៍សម្រាប់សេវាស្នាក់នៅ</u>**

ខណៈដែលចំនួនភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរីអាចនឹងកើនឡើងដល់ប្រមាណ ៣ លាននាក់ នៅចក្ខុវិស័យឆ្នាំ២០៣៥ តម្រូវការបន្ទប់ស្នាក់នៅនឹងកើនឡើងដល់ជាង ៧.០០០ បន្ទប់។ ក្នុងន័យនេះ គ្រប់សេវាស្នាក់នៅទាំងអស់ពិសេសសណ្ឋាគារ ចាំបាច់ត្រូវគោរពតាមបទដ្ឋានចំណាត់ថ្នាក់ផ្កាយរបស់ក្រសួងទេសចរណ៍។ បច្ចុប្បន្ន ខេត្តមណ្ឌលគិរីមានសណ្ឋាគារ ០៤ កន្លែងប៉ុណ្ណោះ ដែលមានចំណាត់ថ្នាក់ផ្កាយ ក្នុងនោះសណ្ឋាគារផ្កាយ៣ ០១កន្លែង ផ្កាយ២ ០១កន្លែង និងផ្កាយ១ ០២កន្លែង។ ព្រមជាមួយគ្នានេះ ត្រូវជំរុញការអនុវត្តស្តង់ដាបៃតង ជាពិសេសស្តង់ដាសណ្ឋាគារបៃតងកម្ពុជា និងស្តង់ដាសណ្ឋាគារបៃតងអាស៊ាន ឲ្យបានគ្រប់សណ្ឋាគារ។

សេវាស្នាក់នៅផ្សេងៗទៀត ដូចជាផ្ទះសំណាក់ រមណីយដ្ឋាន បឹងហ្គាឡូ អេកូឡូត និងសេវាស្នាក់នៅផ្សេងទៀត ក៏ត្រូវតែជំរុញឲ្យមានការអភិវឌ្ឍបន្ថែម ស្របតាមស្តង់ដាក្រសួងទេសចរណ៍ និងស្តង់ដាអាស៊ាន។

**ខ- <u>ការពង្រឹងគុណ ភាពសេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន</u>**

គ្រប់ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ទាំងអស់ ត្រូវគោរពទៅតាមស្តង់ដា "**ភោជនីយដ្ឋានស្អាត និងអាហារដ្ឋានស្អាត**" និង "**ភោជនីយដ្ឋាន និងអាហារដ្ឋានគ្មានសំរាមជាក្រដាសក្រោមតុ**"។

ដូចបានបង្ហាញក្នុងផ្នែកខាងលើ ខេត្តមណ្ឌលគិរីនៅមិនទាន់មានការរៀបចំវិថីម្ហូបអាហារ (Food Street) នៅឡើយ។ ក្នុងន័យនេះ ផែនការមេជំរុញឲ្យមានការរៀបចំជាវិថីម្ហូបអាហារមួយស្ថិតនៅក្នុងក្រុងសែនមនោរម្យ ដើម្បីទាក់ទាញភ្ញៀវទេសចរ ក៏ដូចជាតាំងបង្ហាញផលិតផល និងម្ហូបអាហាររបស់ប្រជាពលរដ្ឋទូទៅ និងជនជាតិដើមភាគតិច។

វិថីម្ហូបអាហារនេះ គួរត្រូវបានរៀបចំនៅតាមបណ្តោយវិថីជាប់នឹងរង្វង់មូលគោព្រៃ ដែលជាទីតាំងមានសក្តានុពល និងមានសម្បទាទេសចរណ៍ទ្រទ្រង់គ្រប់គ្រាន់ ហើយដែលអាចរៀបចំភ្ជាប់ជាមួយផ្សាររាត្រីតែម្តង។

**គ- ការជំរុញឱ្យមានទីភ្នាក់ងារទេសចរណ៍ក្នុងខេត្ត**

ដូចបានបង្ហាញនៅផ្នែកខាងលើ ខេត្តមណ្ឌលគិរី មិនទាន់មានទីភ្នាក់ងារទេសចរណ៍ក្នុងស្រុក ដែលរៀបចំជាកញ្ចប់ខ្សែទស្សនកិច្ចផ្ទាល់ខ្លួនសម្រាប់ខេត្តនៅឡើយ។ ភាគច្រើននៃភ្ញៀវទេសចរមកតាមកញ្ចប់ ទស្សនកិច្ចដែលត្រូវបានរៀបចំដោយក្រុមហ៊ុននៅរាជធានីភ្នំពេញ ឬនៅតាមបណ្តាខេត្តផ្សេង។ ដូចនេះ ការជំរុញ និងលើកទឹកចិត្តឱ្យមានការបង្កើតក្រុមហ៊ុនទេសចរណ៍ និងការីទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី នឹងជំរុញការរៀបចំកញ្ចប់ខ្សែទស្សនកិច្ចមកកាន់ខេត្តមណ្ឌលគិរីកាន់តែច្រើន។

ខណៈដែលភ្ញៀវទេសចរអន្តរជាតិ នឹងចូលមកកាន់ខេត្តមណ្ឌលគិរីកាន់តែច្រើនតាមរយៈព្រលានយន្តហោះខេត្តមណ្ឌលគិរីនាពេលខាងមុខ ត្រូវទប់ស្កាត់ការលក់កញ្ចប់ខ្សែទស្សនកិច្ចខាតដើម (Zero Cost Tour) ដើម្បីបង្កើនទំនុកចិត្តជូនភ្ញៀវទេសចរអន្តរជាតិ។

**ឃ- ការពង្រឹងគុណភាពផលិតផលទេសចរណ៍**

តាមរយៈយុទ្ធសាស្ត្រកំណត់តំបន់អាទិភាពសម្រាប់ការអភិវឌ្ឍ (Zoning) ក្រុងសែនមនោរម្យត្រូវបានរក្សាទុក និងលើកទឹកចិត្តឱ្យមានការអភិវឌ្ឍសកម្មភាពទេសចរណ៍កម្សាន្តសម្បូរបែប ដូចជាខារ៉ាអូខេ ម៉ាស្សា មណ្ឌលកម្សាន្តមនុស្សពេញវ័យជាដើម។ល។ ក្នុងន័យនេះ ការរៀបចំឱ្យមានមណ្ឌលកម្សាន្តនានា ចាំបាច់ត្រូវតែគោរពតាមគោលការណ៍ណែនាំ ស្តង់ដា និងបទដ្ឋាននានារបស់ក្រសួងទេសចរណ៍ ដើម្បីធានាបានទំនុកចិត្ត និងសុវត្ថិភាពជូនភ្ញៀវទេសចរ។

ដោយឡែក ភ្ញៀវទេសចរភាគច្រើនដែលមកទស្សនាខេត្តមណ្ឌលគិរី មិនទាន់បានធ្វើការចំណាយច្រើនលើការទិញវត្ថុអនុស្សាវរីយ៍ដែលផលិតដោយប្រជាពលរដ្ឋផ្ទាល់ក្នុងខេត្តមណ្ឌលគិរីទេ ពិសេសផលិតផល សិប្បកម្ម កសិកម្ម និងផលិតផលរបស់បងប្អូនជនជាតិដើមភាគតិច ដែលបង្កើតបានជាកាលានុវត្តភាពក្នុងការអភិវឌ្ឍកន្លែងលក់វត្ថុអនុស្សាវរីយ៍ និងផលិតផលទាំងនោះ។ ទន្ទឹមនេះ ចាំបាច់ត្រូវទប់ស្កាត់ការលក់វត្ថុអនុស្សាវរីយ៍ក្លែងបន្លំគុណភាព និងការលក់ក្នុងតម្លៃថ្លៃហួសហេតុ ដែលធ្វើឱ្យប៉ះពាល់ដល់មុខមាត់ និងទំនុកចិត្តរបស់ភ្ញៀវទេសចរ។ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើប ដូចជាការប្រើប្រាស់ប្រព័ន្ធ QR Code ជាដើម នឹងជួយពង្រឹងការគ្រប់គ្រងវត្ថុអនុស្សាវរីយ៍ ឱ្យកាន់តែមានប្រសិទ្ធភាព។

### ៣.២- ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍

ជាមួយការព្យាករណ៍ចំនួនភ្ញៀវទេសចរអន្តរជាតិប្រមាណ ៩០ ម៉ឺននាក់នៅឆ្នាំ២០៣៥ ចំនួនបុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ ត្រូវបានព្យាការណ៍ថានឹងកើនឡើងដល់ប្រមាណ ៨ ម៉ឺននាក់។ ជាចក្ខុវិស័យក្នុងផែនការមេ គឺគ្រប់បុគ្គលិកដែលបម្រើការក្នុងវិស័យទេសចរណ៍ទាំងអស់ ត្រូវតែទទួលបានការបណ្តុះបណ្តាលប្រកបដោយគុណភាព ស្របតាមស្តង់ដាជាតិ និងអាស៊ាន។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ផែនការមេកំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷

- ផ្តល់អាទិភាពដល់ការសិក្សាបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ឬវិទ្យាស្ថានទេសចរណ៍ប្រចាំខេត្តមណ្ឌលគិរី ដែលមិនត្រឹមតែផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ សម្រាប់ខេត្តមណ្ឌលគិរីតែប៉ុណ្ណោះទេ ប៉ុន្តែនឹងក្លាយជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ប្រចាំតំបន់ភូមិភាគឦសានទាំងមូល (ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី) ក្នុងការពង្រឹងគុណភាពធនធានមនុស្សក្នុងវិស័យទេសចរណ៍

- សិក្សាលទ្ធភាពបង្កើតសាកលវិទ្យាល័យជាតិខេត្តមណ្ឌលគិរី ដែលផ្តល់ការអប់រំ និងបណ្តុះបណ្តាលលើពហុជំនាញ គាំទ្រដល់ការអភិវឌ្ឍនាពេលអនាគតរបស់ខេត្តមណ្ឌលគិរី ក៏ដូចជាតំបន់ភូមិភាគឦសានទាំងមូល
- ជំរុញការសម្រេចឱ្យបានទស្សនទាន "**បុគ្គលិកម្នាក់ ជំនាញមួយ (One Staff, One Skill)**" ដោយក្នុងនោះបុគ្គលិកទាំងអស់ដែលបម្រើការងារក្នុងវិស័យទេសចរណ៍ ត្រូវទទួលបានការបណ្តុះបណ្តាលដែលមានលក្ខណៈស្តង់ដា និងអាចធ្វើការបំលាស់ទីពីតំបន់មួយទៅតំបន់មួយ
- ជំរុញការបណ្តុះបណ្តាលផ្ទៃកខាងក្នុង (In-House Training) តាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលដែលមានការទទួលស្គាល់ដោយក្រសួងទេសចរណ៍ និងកម្រិតអាស៊ាន
- ជំរុញដាក់ចេញកម្មវិធីហាត់ការតាមមូលដ្ឋានអាជីវកម្ម (Apprenticeship Program) ដោយលើកទឹកចិត្តឱ្យមូលដ្ឋានអាជីវកម្ម និងសេវាកម្មទាំងអស់ ទទួលយកសិស្ស-និស្សិតទៅបម្រើការ ដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍។

ស្របជាមួយចក្ខុវិស័យខាងលើ ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ជំរុញឱ្យមានការរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងរយៈពេលវែងនៅគ្រប់មជ្ឈដ្ឋានសម្រាប់សិស្ស-និស្សិត អ្នកមានតម្រូវការការងារ បុគ្គលិកអ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ ដើម្បីពង្រឹងសមត្ថភាពឆ្លើយតបទៅនឹងការវិវត្តនៃសង្គម និងវិស័យទេសចរណ៍។

ផែនការមេជំរុញឱ្យមានការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ខេត្ត ថ្នាក់តំបន់ និងមគ្គុទ្ទេសក៍សហគមន៍។ ជាក់ស្តែង ខេត្តមណ្ឌលគិរីមិនទាន់មានមគ្គុទ្ទេសក៍ទេសចរណ៍ផ្តល់សេវាកម្មជូនភ្ញៀវទេសចរនៅឡើយទេនាពេលបច្ចុប្បន្ន ដូចនេះការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ នឹងរួមចំណែកបង្កើនការទាក់ទាញភ្ញៀវទេសចរ ពិសេសការអធិប្បាយអំពីសក្តានុពលទេសចរណ៍ និងធនធានដែលមាននៅតាមភូមិជនជាតិដើមភាគតិចជាដើម។ ជាមួយគ្នានេះ ត្រូវជំរុញឱ្យមានមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងស្រុកសម្រាប់ភ្ញៀវទេសចរក្នុងស្រុកដែលចង់ស្វែងយល់អំពីដើមកំណើត និងអត្តសញ្ញាណរបស់បងប្អូនជនជាតិដើមភាគតិច ដែលនឹងរួមចំណែកក្នុងការអភិវឌ្ឍ និងបង្កើនប្រាក់ចំណូលរបស់បងប្អូនប្រជាពលរដ្ឋមូលដ្ឋាន។

ទន្ទឹមនឹងនេះ ត្រូវលើកទឹកចិត្តឱ្យមានមគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍ ពិសេសនៅក្នុងតំបន់ដែនជម្រកសត្វព្រៃ និងតំបន់អភិរក្ស ដោយប្រើប្រាស់មន្ត្រីឧទ្យានុរក្ស (Ranger) និងប្រជាពលរដ្ឋមូលដ្ឋាន ដោយសារពួកគាត់ស្គាល់ទីតាំងភូមិសាស្ត្រច្បាស់លាស់។

## ៤- ការផ្សព្វផ្សាយ និងការពង្រឹងរូបភាពវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី

ទន្ទឹមនឹងការជំរុញការអភិវឌ្ឍផលិតផលទេសចរណ៍ និងការពង្រឹងគុណភាពធនធានមនុស្ស ការជំរុញការផ្សព្វផ្សាយគោលដៅទេសចរណ៍ ក៏ជាកិច្ចការសំខាន់ដែលត្រូវមានការកំណត់នូវទិសដៅយុទ្ធសាស្ត្រច្បាស់លាស់។ ក្នុងន័យនេះ ផែនការមេកំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷

### ៤.១- ការរៀបចំអត្តសញ្ញាណ (Branding) ខេត្តមណ្ឌលគិរី

ខេត្តមណ្ឌលគិរី ដែលប្រជាពលរដ្ឋទូទៅស្គាល់ថាជាទឹកដីសមុទ្រឈើ និងសម្បូរទៅដោយធនធានធម្មជាតិ ចាំបាច់ត្រូវមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ ក្នុងន័យនេះ ផែនការមេ នឹងរៀបចំឱ្យមានអត្តសញ្ញាណផ្សព្វផ្សាយសម្រាប់ខេត្ត ដែលជាការគាំទ្រដល់យុទ្ធនាការផ្សព្វផ្សាយកម្ពុជា "**កម្ពុជា÷ ព្រះរាជាណាចក្រអច្ឆរិយៈ**"។

ពាក្យស្លោកដែលជាអត្តសញ្ញាណសម្រាប់ខេត្តមណ្ឌលគិរីមួយចំនួន ត្រូវបានស្នើឡើង ដូចជា÷

- **មណ្ឌលគិរី÷ ឋានសួគ៌អេកូទេសចរណ៍**
- **មណ្ឌលគិរី÷ គោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ**
- **មណ្ឌលគិរី÷ ទឹកដីកក់ក្ដៅសម្រាប់ទេសចរ។**

រូបភាពទី៧÷ ពង្រាងនិម្មិតសញ្ញាផ្សព្វផ្សាយទេសចរណ៍ (Branding) ខេត្តមណ្ឌលគិរី




(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### ៤.២- ការជំរុញការផ្សព្វផ្សាយខេត្តមណ្ឌលគិរីតាមគ្រប់រូបភាព

ព្រមជាមួយការរៀបចំនិម្មិតសញ្ញាផ្សព្វផ្សាយខាងលើ ផែនការមេជំរុញឱ្យមានការផ្សព្វផ្សាយតាមគ្រប់រូបភាព ទាំងការផ្សព្វផ្សាយតាមលក្ខណៈធម្មតា (Traditional Marketing) និងតាមលក្ខណៈឌីជីថល (Digital Marketing )។

**ក- <u>ការផ្សព្វផ្សាយតាមលក្ខណៈធម្មតា</u> (Traditional Marketing and Promotion)**

ការផ្សព្វផ្សាយបែបលក្ខណៈធម្មតានេះ គឺត្រូវជំរុញការផលិតឧបករណ៍ផ្សព្វផ្សាយនានា (Promotional Material) ដូចជាសៀវភៅមគ្គុទ្ទេសក៍ ប័ណ្ណផ្ទត់ ខិត្តប័ណ្ណ -ល- ដែលមានលក្ខណៈជាឯកសារផ្សព្វផ្សាយអំពីសក្ដានុពលទាំងអស់ក្នុងខេត្តមណ្ឌលគិរី សកម្មភាពទេសចរណ៍ ព្រឹត្តិការណ៍ផ្សេងៗ និងសេវាកម្មនានា។ ក្រសួងទេសចរណ៍ ត្រូវជំរុញការផ្សព្វផ្សាយក្នុងខេត្តមណ្ឌលគិរី នៅតាមកម្មវិធីពិព័រណ៍អន្តរជាតិ ដើម្បីឱ្យភ្ញៀវទេសចរអន្តរជាតិស្គាល់កាន់តែច្រើនពីគោលដៅទេសចរណ៍ខេត្តមណ្ឌលគិរី។

ទន្ទឹមនឹងនេះ ត្រូវជំរុញការរៀបចំចងក្រងជាឯកសារប្រវត្តិ ប្រពៃណី ទំនៀមទំលាប់ អត្តសញ្ញាណរបស់ខេត្ត និងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីបង្ហាញអំពីសក្ដានុពលដ៏ល្អរបស់ខេត្តមណ្ឌលគិរី ទៅដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

ដោយឡែក ខេត្តមណ្ឌលគិរីគួររៀបចំឱ្យមានជាកន្លែងសម្រាប់បង្ហាញពាក្យស្លោក ដែលសម្គាល់អត្តសញ្ញាណរបស់ខេត្ត ដើម្បីឱ្យភ្ញៀវទេសចរអាចធ្វើការថតរូបកម្សាន្ត ដូចជាកន្លែង “**ខ្ញុំស្រលាញ់ ខេត្តមណ្ឌលគិរី**” ជាដើម។

**ខ- <u>ការផ្សព្វផ្សាយតាមលក្ខណៈឌីជីថល</u> (Digital Marketing and Promotion)**

ការផ្សព្វផ្សាយតាមលក្ខណៈឌីជីថល គឺជំរុញការផ្សព្វផ្សាយបែបទំនើបតាមបណ្ដាញសង្គមនានា ដូចជា Facebook, Twitter, Instragram... និងការងារសំខាន់ៗមួយចំនួន រួមមាន÷

- រៀបចំឱ្យមានកម្មវិធី (Mobile App) ដែលជាកម្មវិធីផ្សព្វផ្សាយតាមរយៈទូរស័ព្ទឆ្លាតវៃ និងអនុញ្ញាតឱ្យភ្ញៀវទេសចរទទួលបានព័ត៌មានងាយស្រួលពីចម្ងាយ ចំណាយថវិកាតិច និងអាចស្វែងរកព័ត៌មានគ្រប់ជ្រុងជ្រោយ

អំពីគោលដៅទេសចរណ៍នៅក្នុងខេត្តមណ្ឌលគិរី រាប់តាំងពីផលិតផលទេសចរណ៍ គុណភាព និងតម្លៃសេវាកម្ម និងសកម្មភាពផ្សេងៗ

- គេហទំព័រមួយគួរតែត្រូវបានរៀបចំដាច់ដោយឡែកសម្រាប់ការផ្សព្វផ្សាយខេត្តមណ្ឌលគិរី (ឧទាហរណ៍÷ www.visitmondulkiri.travel) និងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ
- លើកទឹកចិត្តយុវជន សិស្ស-និស្សិត និងសាធារណជន ចូលរួមការប្រឡងប្រណាំងនានា ដូចជាការប្រឡងប្រណាំងវីដេអូ រូបភាព ក្រោមប្រធានបទផ្សេងៗអំពីខេត្តមណ្ឌលគិរីឱ្យបានច្រើន
- លើកទឹកចិត្តឱ្យមានការថតភាពយន្ត ទាំងភាពយន្តជាលក្ខណៈជាតិ និងអន្តរជាតិ ដើម្បីទាក់ទាញភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរីឱ្យបានច្រើន
- លើកទឹកចិត្តការថតកម្មវិធីរបស់បណ្តាញទូរទស្សន៍ និងសារព័ត៌មានល្បីៗជុំវិញពិភពលោក។

## ៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍

### ៥.១- ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងសម្បទាន្រទ្រង់ក្នុងខេត្ត

តាមរយៈការសិក្សាបច្ចេកទេសនៅក្នុងផ្នែកទី២ បណ្តាញតភ្ជាប់ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់នានានៅក្នុងខេត្តមណ្ឌលគិរី ពិសេសនៅក្រុងសែនមនោរម្យ មិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ ដោយសារបណ្តាញផ្លូវមួយចំនួនជាផ្លូវដីក្រហម ឬផ្លូវដែលមានការខូចខាតដោយសារភ្លៀងធ្លាក់នៅរដូវវស្សា លើកលែងតែផ្លូវជាតិលេខ៧៦ ដែលមានស្ថានភាព និងគុណភាពល្អ ងាយស្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរ។

ទន្ទឹមនឹងនេះ ខេត្តមណ្ឌលគិរីមានតំបន់រមណីយដ្ឋានធម្មជាតិ អេកូទេសចរណ៍ និងទេសចរណ៍វប្បធម៌ជាច្រើន ប៉ុន្តែមានតែរមណីយដ្ឋានសំខាន់ៗមួយចំនួនប៉ុណ្ណោះ ដែលមានភ្ញៀវទេសចរទៅដល់ ដោយសារបណ្តាញផ្លូវថ្នល់តភ្ជាប់មិនទាន់ល្អប្រសើរនៅឡើយ ជាពិសេសនៅរដូវវស្សា។ កត្តាស្ថានភាពផ្លូវថ្នល់មិនសូវអំណោយផល ធ្វើឱ្យការស្នាក់នៅរបស់ភ្ញៀវទេសចរមានរយៈពេលខ្លី ហើយការទៅកម្សាន្តតាមគោលដៅទេសចរណ៍នានានៅមានកម្រិត បើទោះបីជាភ្ញៀវទេសចរជាតិ និងអន្តរជាតិមកកាន់ខេត្តមណ្ឌលគិរីមានការកើនឡើងគួរឱ្យកត់សម្គាល់ក៏ដោយ។

ក្នុងន័យនេះ ផែនការមេកំណត់ទិសដៅជាយុទ្ធសាស្ត្រដូចខាងក្រោម÷

- ធ្វើការជួសជុលកែលម្អបណ្តាញផ្លូវតភ្ជាប់ពីក្រុងសែនមនោរម្យទៅកាន់គោលដៅទេសចរណ៍សំខាន់ៗ ដូចជាផ្លូវអ៊ុតកៅស៊ូដើម្បីធានាការប្រើប្រាស់បានយូរ ឬផ្លូវក្រាលគ្រួសក្រហមសម្រាប់គោលដៅទេសចរណ៍ដែលទើបតែរកឃើញថ្មី
- ផ្លូវតភ្ជាប់តំបន់រមណីយដ្ឋានប៊ូស្រា មកឃុំដាក់ដាំ ដែលមានសក្តានុពលក្នុងការអភិវឌ្ឍជាភូមិគំរូជនជាតិដើមភាគតិច គួរត្រូវបានអភិវឌ្ឍ ឬជួសជុលកែលម្អដើម្បីសម្រួលដល់ការធ្វើដំណើរ និងផ្តល់ភាពងាយស្រួលដល់ការរៀបចំជាកញ្ចប់ទស្សនកិច្ចជូនភ្ញៀវទេសចរដោយសារតំបន់ទាំងពីរនេះ ស្ថិតនៅក្នុងចក្ខុវិស័យនៃរបៀងអេកូទេសចរណ៍ប៊ូស្រា-ដាក់ដាំ ដូចបានបង្ហាញក្នុងយុទ្ធសាស្ត្រគោលទី១
- បណ្តាញផ្លូវក្នុងក្រុងសែនមនោរម្យ គួរត្រូវបានជួសជុល និងកែលម្អឱ្យស្របតាមស្តង់ដា ដោយរៀបចំឱ្យមានផ្លូវជិះកង់អមសងខាងផ្លូវ ផ្លូវថ្មើរជើងសម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរធ្វើដំណើរ និងបំពាក់អំពូលភ្លើងបំភ្លឺសាធារណៈ
- តំបន់មួយចំនួនគួររៀបចំជាសួនច្បារអមសងខាងផ្លូវ ដើម្បីបង្កើនសោភ័ណភាពទាក់ទាញទេសចរ។

មិនត្រឹមតែប៉ុណ្ណោះ គួរគិតគូរអំពីការរៀបចំ និងកែលម្អផ្លូវក្រវាត់ក្រុង រួមមានក្រវាត់ក្រុងទី១ ក្រវាត់ក្រុងទី២ និងក្រវាត់ក្រុងទី៣ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងចរាចរណ៍ និងសម្រួលការធ្វើដំណើររបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ នៅពេលដែលចំនួនភ្ញៀវទេសចរ និងប្រជាពលរដ្ឋក្នុងខេត្ត មានការកើនឡើងនាពេលអនាគត។

ផែនការមេ ក៏ស្នើឱ្យមានការរៀបចំចំណតរថយន្តសាធារណៈមួយក្នុងក្រុងសែនមនោរម្យ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រងលំហូរភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរី និងរក្សាសណ្តាប់ធ្នាប់ល្អរបស់ភ្ញៀវទេសចរ និងអ្នកធ្វើដំណើរ។ ទន្ទឹមនឹងនេះ គួរសិក្សារៀបចំឱ្យមានសេវារថយន្តក្រុងសាធារណៈសម្រាប់ការធ្វើដំណើរក្នុងក្រុងសែនមនោរម្យ និងតភ្ជាប់ក្រុងសែនមនោរម្យទៅកាន់តំបន់សំខាន់ៗក្នុងខេត្ត ទោះបីជានាពេលបច្ចុប្បន្ន ចំនួនប្រជាជននៅក្នុងខេត្តមានចំនួនតិចតួចនៅឡើយ។

លើសពីនេះទៀត ការជួសជុល និងស្ថាបនាផ្លូវទៅកាន់តំបន់សំខាន់ៗ ពិសេសផ្លូវក្រវ៉ាត់ក្រុងថ្មីដែលតភ្ជាប់ក្រុងសែនមនោរម្យទៅតំបន់ស្រុកអូររាំង ដែលជាទីតាំងគម្រោងសាងសង់ព្រលានយន្តហោះខេត្តមណ្ឌលគិរី គួរត្រូវបានគិតគូរបន្ថែម។ តាមការរំពឹងទុក តំបន់ស្រុកអូររាំងនេះនឹងក្លាយជាគោលដៅដ៏សំខាន់ ដែលមិនត្រឹមតែបម្រើដល់វិស័យទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់អន្តរវិស័យផ្សេងៗ ដូចជាពាណិជ្ជកម្ម ការដឹកជញ្ជូន និងវិស័យពាក់ព័ន្ធនានា។

ការដាក់ស្លាកសញ្ញាបង្ហាញទីតាំងសំខាន់ក្នុងក្រុង និងគោលដៅទេសចរណ៍សំខាន់ៗ នឹងផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរក្នុងការទៅកម្សាន្តគោលដៅទេសចរណ៍ដែលមានសក្តានុពល ដូចជាតំបន់ទេសចរណ៍ធម្មជាតិប៊ូស្រា រមណីយដ្ឋានសមុទ្រឈើជាដើម។ ក្នុងន័យនេះ ការតភ្ជាប់ទៅកាន់តំបន់អេកូទេសចរណ៍ក្នុងដែនអភិរក្សទាំង៥ ក៏មានភាពចាំបាច់ក្នុងការទាក់ទាញភ្ញៀវទេសចរដែលចូលចិត្តធម្មជាតិ ការផ្សងព្រេង ការបោះតង់ និងអេកូទេសចរណ៍ជាដើម ខណៈពេលបច្ចុប្បន្នចំនួនភ្ញៀវនៅមានកម្រិតទាប ហើយការផ្សព្វផ្សាយក៏មិនទាន់មានភាពទូលំទូលាយនៅឡើយ។

រូបភាពទី៨÷ ពង្រាងគំនូសប្លង់ចំណតរថយន្តសាធារណៈ





(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

រូបភាពទី៩÷ ពង្រាងគំនូសប្លង់ចំណតទោចក្រយានយន្ត និងកង់បី និងរថយន្តទេសចរណ៍ធុនតូច







(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

រូបភាពទី១០÷ ស្ថានភាពបច្ចុប្បន្ន និងពង្រាងគំនូសប្លង់កែសម្រួលបណ្តាញផ្លូវថ្នល់ក្នុងក្រុងសែនមនោរម្យ (រូបភាពថត ក្នុងកំឡុងខែកក្កដា ឆ្នាំ២០២០)



(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

ទន្ទឹមនឹងនេះ នៅតំបន់រង្វង់មូលគោព្រៃ ផែនការមេចង្អុលបង្ហាញឲ្យមានការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់មួយចំនួន រួមមាន÷

- កែលម្អសោភ័ណភាពតំបន់រង្វង់មូលគោព្រៃ ដែលចាត់ទុកជាបេះដូង និងជាចំណុចកណ្តាលរបស់ខេត្តមណ្ឌលគិរី និងជាអត្តសញ្ញាណបង្ហាញពីលក្ខណៈពិសេសរបស់ខេត្តមណ្ឌលគិរី
- កំណាត់ផ្លូវអមសងខាងនៅរង្វង់មូលគោព្រៃ គួរតែត្រូវបានកែលម្អបន្ថែមដើម្បីលើកកម្ពស់សោភ័ណភាព ដោយរៀបចំឲ្យមានសណ្តាប់ធ្នាប់ក្នុងការចតរថយន្តរបស់ភ្ញៀវទេសចរ និងអ្នកដំណើរ រួមជាមួយការដាំដើមឈើអមសងខាងផ្លូវ និងបរិវេណទ្រូងផ្លូវជាដើម
- ទន្ទឹមនឹងនេះ តំបន់រង្វង់មូលគោព្រៃ គួរត្រូវបានអភិវឌ្ឍន៍ជាតំបន់ទេសចរណ៍ថ្មើរជើងសម្រាប់ការដើរកម្សាន្ត និងសម្រាកលំហែមុន និងក្រោយពេលទស្សនានៅគោលដៅទេសចរណ៍នានា
- តំបន់រង្វង់មូលគោព្រៃនេះ ក៏មានសក្តានុពលក្នុងការរៀបចំសកម្មភាពពេលរាត្រី ដូចជាការបង្កើតជាផ្សាររាត្រី ដែលអាចឲ្យភ្ញៀវទេសចរអាចរកទិញផលិតផល និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋមូលដ្ឋាន អាចដាក់តាំង និងលក់ផលិតផល។

រូបភាពទី១១÷ ពង្រាងគំនូសប្លង់សម្រាប់កែសម្រួលបណ្តោយផ្លូវនៅតំបន់រង្វង់មូលគោព្រៃ



(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ដែលស្ថិតនៅតំបន់សួនច្បារជិតរង្វង់មូលគោព្រៃ គួរត្រូវបានអភិវឌ្ឍបន្ថែមឲ្យមានសម្ភារៈគ្រប់គ្រាន់ស្របតាមស្តង់ដាក្រសួងទេសចរណ៍ និងជាមជ្ឈមណ្ឌលផ្តល់ព័ត៌មាន ឯកសារ និងទិន្នន័យពាក់ព័ន្ធវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី។ មជ្ឈមណ្ឌលព័ត៌មាននេះ គួរត្រូវបានអភិវឌ្ឍភ្ជាប់ជាមួយសម្ភារៈសំខាន់ៗមួយចំនួន ដូចជាបន្ទប់ទឹកសាធារណៈ និងការដាក់តាំងបង្ហាញផលិតផលនានារបស់ខេត្តមណ្ឌលគិរី ដើម្បីឲ្យភ្ញៀវទេសចរបានស្វែងយល់បន្ថែម។

រូបភាពទី១២÷ ស្តង់ដាប្លង់មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ស្របតាមស្តង់ដាក្រសួងទេសចរណ៍





(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

ជាមួយគ្នានេះ វិសាលភាពនៃតំបន់សួនច្បារអតីតព្រលានយន្តហោះជាប់នឹងរង្វង់មូលគោព្រៃមានទំហំធំដែលអាចជំរុញការអភិវឌ្ឍជាសួនច្បារ ឬតំបន់បៃតង ដែលអាចឲ្យភ្ញៀវទេសចរ និងប្រជាពលរដ្ឋក្នុងខេត្ត ដើរកម្សាន្ត ស្រូបយកខ្យល់អាកាសបរិសុទ្ធ ហាត់ប្រាណ និងជួបជុំ ប៉ុន្តែមិនគួរលើកទឹកចិត្តឲ្យមានការលក់ដូរ ឬអភិវឌ្ឍន៍សម្បទាណាមួយដែលប៉ះពាល់ដល់សោភ័ណភាពតំបន់នេះទេ។

រូបភាពទី១៣÷ គម្រោងប្លង់សាងសង់សួនច្បារនៅចំណុចអតីតព្រលានយន្តហោះ





(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

ផែនការមេ ក៏ស្នើឲ្យមានការគិតគូរអភិវឌ្ឍន៍បន្ថែមនៅតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រភ្នំដោះក្រមុំ លើផ្នែកសោភ័ណភាព ការរៀបចំសណ្តាប់ធ្នាប់ ការរក្សាបាននូវភាពបៃតង ការដាំដើមឈើបន្ថែម និងជំរុញការកំណត់ព្រំដីតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រភ្នំដោះក្រមុំនេះឲ្យមានភាពច្បាស់លាស់ ដើម្បីទប់ស្កាត់ការទន្ទ្រានកាន់កាប់នាពេលអនាគត។

រូបភាពទី១៤÷ ពង្រាងគំនូសប្លង់លើកកម្ពស់សោភ័ណភាពរមណីយដ្ឋានវប្បធម៌ភ្នំដោះក្រមុំ







(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

ទន្ទឹមនឹងនេះ ផែនការមេ ជំរុញឱ្យមានការរៀបចំរចនាបថលំនៅដ្ឋាន ការធ្វើរបងលំនៅដ្ឋាន របងដីឡូតិ៍ ដោយរក្សាបាននូវសោភ័ណ្ឌភាព ទេសភាពធម្មជាតិ សណ្តាប់ធ្នាប់ របៀបរៀបរយត្រឹមត្រូវ ដើម្បីបង្កើតជាភាពទាក់ទាញបន្ថែមសម្រាប់ភ្ញៀវទេសចរ។

### ៥.២- ការប្រើប្រាស់ និងការផ្គត់ផ្គង់ទឹកស្អាត

ផ្អែកលើការសិក្សា និងលទ្ធផលនៃការចុះអង្កេត ការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋមូលដ្ឋានមិនទាន់មានលក្ខណៈពេញលេញ ខណៈដែលប្រជាពលរដ្ឋមួយចំនួននៅតាមស្រុកនានា ក្រៅពីក្រុងសែនមនោរម្យ នៅប្រើប្រាស់ទឹកអណ្តូង និងទឹកភ្លៀងប្រចាំថ្ងៃ ហើយវិស័យឯកជន ជាពិសេសមូលដ្ឋានអាជីវកម្មក្នុងក្រុងសែនមនោរម្យ ក៏បានលើកឡើងនូវបញ្ហាកង្វះទឹកស្អាតប្រើប្រាស់ ជាពិសេសនៅរដូវប្រាំង ខណៈដែលក្នុងឆ្នាំ២០១៩ ប្រភពទឹកធំៗមួយចំនួនក្នុងខេត្តមណ្ឌលគិរីទទួលរងនូវភាពរីងស្ងួត។

ទន្ទឹមនឹងនេះ ជាមួយការព្យាករណ៍ចំនួនភ្ញៀវទេសចរនាពេលអនាគត និងការកើនឡើងនៃចំនួនបន្ទប់តាមសណ្ឋាគារ ផ្ទះសំណាក់ និងសេវាស្នាក់នៅនានា បរិមាណនៃការប្រើប្រាស់ទឹក នឹងមានការកើនឡើង។ ដូច្នេះ ការគិតគូរ

អំពីទស្សនវិស័យក្នុងការផ្គត់ផ្គង់ទឹកឲ្យបានគ្រប់គ្រាន់ និងពេញលេញ គឺជាកិច្ចការមិនអាចខ្វះបាន និងទាមទារឲ្យមានការយកចិត្តទុកដាក់ទាំងថ្នាក់ខេត្ត និងថ្នាក់ជាតិ។

ដើម្បីសម្រេចកិច្ចការខាងលើ ផែនការមេ កំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷

- រក្សាការពារឲ្យបាននូវប្រភពទឹកដែលមានស្រាប់ ជាពិសេសប្រភពទឹកធៅទាំង ២ ទីតាំង ដែលស្ថិតនៅក្នុងក្រុងសែនមនោរម្យ សម្រាប់ផ្គត់ផ្គង់ការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងតម្រូវការរបស់ភ្ញៀវទេសចរ។ ក្នុងន័យនេះ តំបន់ប្រភពទឹកទាំង២ គួរត្រូវបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបន្ថែម រៀបចំកែលម្អផ្លូវជុំវិញប្រភពទឹក ដោយមានសួនច្បារនៅជុំវិញ ដើម្បីបង្កើនសោភ័ណភាព និងភាពស្អាត ដែលអាចប្រែក្លាយជាតំបន់ទេសចរណ៍មួយសម្រាប់ការសម្រាកលំហែរបស់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋក្នុងខេត្ត ជាពិសេសប្រជាពលរដ្ឋក្នុងក្រុងសែនមនោរម្យផ្ទាល់។ លើសពីនេះទៀត ត្រូវទប់ស្កាត់ឲ្យបាននូវការសាងសង់សំណង់ ឬសកម្មភាពណាមួយដែលប៉ះពាល់ដល់ប្រភពទឹកទាំង២នេះ ទាំងសោភ័ណភាព និងគុណភាពទឹក ជៀសវាងការបង្ហូរសំណល់រាវ និងបោះចោលសំរាមទៅក្នុងប្រភពទឹកទាំង២
- សិក្សាស្វែងរកប្រភពទឹកធៅបន្ថែមទៀត ដើម្បីធានានិរន្តរភាពការផ្គត់ផ្គង់ទឹកស្អាតឲ្យបានគ្រប់គ្រាន់ ពិសេសនៅរដូវប្រាំង ខណៈដែលទីតាំងភូមិសាស្ត្រខេត្តមណ្ឌលគិរីសម្បូរទៅដោយភ្នំ ខ្ពង់រាប និងព្រៃឈើ បង្កើតបានជាសក្តានុពលសំខាន់ៗ និងខ្សែទឹកជាច្រើនសម្រាប់ជាប្រភពទឹកប្រើប្រាស់របស់ខេត្ត។ ជាចក្ខុវិស័យ យ៉ាងយូរបំផុតក្នុងឆ្នាំ២០២៥ ប្រជាពលរដ្ឋនៅតាមទីប្រជុំជននឹងមានទឹកស្អាតប្រើប្រាស់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ដោយឡែក សម្រាប់ប្រជាពលរដ្ឋដាច់ស្រយាលនឹងមានទឹកស្អាតប្រើប្រាស់ ក្នុងឆ្នាំ២០២៥ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរអភិវឌ្ឍន៍ជនបទ
- សិក្សាបន្ថែមឲ្យមានអាងសម្រាប់ស្តុក និងចម្រោះទឹកស្អាតមួយ នៅក្នុងក្រុងសែនមនោរម្យដើម្បីធានាការផ្គត់ផ្គង់ទឹកជាប្រចាំ និងធានានិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត
- អប់រំប្រជាពលរដ្ឋ និងភ្ញៀវទេសចរ ឲ្យចូលរួមក្នុងយុទ្ធនាការសន្សំសំចៃទឹក តាមរយៈការប្រើប្រាស់ឡើងវិញនៅទឹកដែលប្រើប្រាស់រួច ដូចជាការស្រោចដំណាំ និងក្នុងគោលបំណងណាមួយធានាបានការសន្សំសំចៃទឹកជាអតិបរមា និងរួមចំណែកក្នុងការអភិវឌ្ឍបៃតងក្នុងខេត្ត
- បង្កើនសមត្ថភាពផលិត និងពង្រីកតំបន់សេវាកម្មតាមការណែនាំរបស់ក្រសួងអាណាព្យាបាលនៅតាមស្រុកទាំង ៤ ដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយនិរន្តរភាព និងឆ្លើយតបតាមចក្ខុវិស័យនៃការអភិវឌ្ឍនៅតាមស្រុកទាំង ៤ នាពេលអនាគត
- ធ្វើការការពារប្រភពទឹកសម្រាប់ការផលិត និងផ្គត់ផ្គង់ទឹកស្អាតជាអាទិភាព
- សិក្សា និងស្វែងរកប្រភពទឹកផ្សេងទៀត ដើម្បីធានានិរន្តរភាពក្នុងការផ្គត់ផ្គង់ទឹកស្អាតនាពេលអនាគត
- ធ្វើការអប់រំប្រជាពលរដ្ឋឲ្យយល់ដឹងអំពីការប្រើប្រាស់ទឹកស្អាត ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព ជាពិសេសរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

## ៥.៣- ការប្រើប្រាស់ និងការផ្គត់ផ្គង់ថាមពលអគ្គិសនី

ខេត្តមណ្ឌលគិរី អាចចាត់ទុកថាជាធុងអាគុយមួយសម្រាប់ការផ្គត់ផ្គង់អគ្គិសនី ដែលមិនត្រឹមតែសម្រាប់ប្រើប្រាស់ក្នុងខេត្តប៉ុណ្ណោះទេ តែក៏សម្រាប់ផ្គត់ផ្គង់ទៅតំបន់ផ្សេងទៀតក្នុងប្រទេសផងដែរ។ ការគៀងគរអ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុក គឺជាកិច្ចការសំខាន់ក្នុងវិស័យអគ្គិសនី ដើម្បីធានាបានការផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព និងគាំទ្រដល់ការវិនិយោគ និងការអភិវឌ្ឍវិស័យផ្សេងៗទៀតនៅក្នុងខេត្ត។ តាមការបញ្ជាក់របស់មន្ទីររ៉ែ និងថាមពលខេត្តមណ្ឌលគិរី នាចុងឆ្នាំ២០២០នេះ ខេត្តមណ្ឌលគិរីនឹងមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ តាមរយៈខ្សែតភ្ជាប់អគ្គិសនីពីខេត្តក្រចេះដែលកំពុងសាងសង់ ដែលមានអានុភាព ២៣០ គីឡូវ៉ាត់ និងការសាងសង់អនុស្ថានីយក្នុងខេត្តមណ្ឌលគិរី ដែលនឹងដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០២១នេះ។

ដើម្បីសម្រេចកិច្ចការទាំងនេះ ផែនការមេកំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- ដោយកត្តាទីតាំងភូមិសាស្ត្រខេត្តមណ្ឌលគិរី អំណោយផលក្នុងការអភិវឌ្ឍទំនប់វារីអគ្គិសនី ដូច្នេះ គប្បីសិក្សារៀបចំអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីតាមទីតាំងសំខាន់ៗក្នុងខេត្ត ប៉ុន្តែតម្រូវឱ្យមានការសិក្សាអំពីផលប៉ះពាល់ជាអប្បបរមាលើផ្នែកបរិស្ថាន
- សិក្សារៀបចំយន្តការ និងយុទ្ធសាស្ត្រ ដើម្បីឱ្យប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាលមានលទ្ធភាពប្រើប្រាស់អគ្គិសនី ពិសេសកំណត់បរិមាណនៃការប្រើប្រាស់ក្នុងតម្លៃសមរម្យ
- លើកទឹកចិត្តឱ្យមានការវិនិយោគថាមពលអគ្គិសនីដើរដោយថាមពលខ្យល់ ដោយសារទីតាំងភូមិសាស្ត្រខេត្តមណ្ឌលគិរីអំណោយផល អាចស្រូបទាញកម្លាំងខ្យល់ បង្កើតបានជាថាមពលអគ្គិសនី ដែលនេះអាចជាគំរូថ្មីមួយ រួមចំណែកដ៏សំខាន់ក្នុងកិច្ចការថែរក្សាបរិស្ថាន
- ពិនិត្យលទ្ធភាពក្នុងការសិក្សាស្វែងរកប្រភពថាមពលអគ្គិសនីបន្ថែម ដោយអាចទាញយកពីកម្លាំងទឹកទន្លេស្រែពក សម្រាប់ផលិតជាអគ្គិសនីប្រើប្រាស់បានកាន់តែច្រើន ដើម្បីផ្គត់ផ្គង់ក្នុងខេត្ត និងចែកចាយទៅតំបន់ផ្សេងក្នុងប្រទេស
- ជំរុញការផ្សព្វផ្សាយដល់មូលដ្ឋានអាជីវកម្ម និងវិស័យឯកជន ចូលរួមសន្សំសំចៃថាមពលឱ្យបានជាអតិបរមា ធ្វើយ៉ាងណាឱ្យការប្រើប្រាស់នោះទទួលបាននូវប្រសិទ្ធភាព។

## ៥.៤- ការគ្រប់គ្រងសំណល់រឹង និងរាវ

បញ្ហាសំរាមក្នុងក្រុងសែនមនោរម្យ និងតំបន់ផ្សេងទៀតក្នុងខេត្តមណ្ឌលគិរី គឺជាការងារចាំបាច់ដែលទាមទារការយកចិត្តទុកដាក់ឱ្យបានហ្មត់ចត់ ព្រោះការគ្រប់គ្រងសំរាមមិនបានត្រឹមត្រូវ នឹងធ្វើឱ្យប៉ះពាល់ទៅដល់សោភ័ណភាព និងសុខភាពរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។ ដូចបានបង្ហាញនៅផ្នែកខាងលើ ប្រជាពលរដ្ឋមូលដ្ឋាន និងអាជីវកម្មទេសចរណ៍មួយចំនួន ជាពិសេសមូលដ្ឋានអាជីវកម្មក្នុងក្រុងសែនមនោរម្យ ការប្រមូលសំរាមមានលក្ខណៈមិនសូវទៀងទាត់ ខណៈដែលមូលដ្ឋានអាជីវកម្ម ប្រជាពលរដ្ឋរស់នៅតាមជាយក្រុង និងឆ្ងាយពីទីប្រជុំជនក្រុងសែនមនោរម្យ មិនទាន់ទទួលបានសេវាប្រមូលសំរាមនៅឡើយ។

ទាក់ទងនឹងបញ្ហានេះ ផែនការមេកំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- រដ្ឋបាលខេត្តមណ្ឌលគិរី ពិសេសរដ្ឋបាលក្រុងសែនមនោរម្យ ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមឱ្យបានច្បាស់លាស់ និងជំរុញឱ្យក្រុមហ៊ុនប្រមូលសំរាមយកចិត្តទុកដាក់ លើការពង្រឹងសេវាប្រមូលសំរាមរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន និងទៀងទាត់ ជាពិសេសជំរុញឱ្យមានការពង្រីកសេវាប្រមូលសំរាមបន្ថែមដល់ទីប្រជុំជននៃ

ស្រុកទាំង៤ និងបើកឱ្យមានការដេញថ្លៃជ្រើសរើសក្រុមហ៊ុនប្រមូលសំរាមបន្ថែមទៀត ដើម្បីធានាការទុកដាក់សំរាមប្រកបដោយប្រសិទ្ធភាព
- ជំរុញការទាក់ទាញ និងលើកទឹកចិត្តឱ្យមានការវិនិយោគលើការកែច្នៃសំរាម និងការប្រើប្រាស់សំរាមឡើងវិញ ដូចជាការកែច្នៃជាជីកំប៉ុសជាដើម
- ជំរុញការប្រើប្រាស់ទីលានចាក់សំរាម ដែលមានទំហំប្រមាណ ១៣៤ ហិកតា និងមានចំងាយ ១៥ គ.ម ពីក្រុងសែនមនោរម្យឱ្យបានឆាប់ ដើម្បីរៀបចំជាកន្លែងចាក់សំរាមរិលជុំឱ្យបានសមរម្យ ដែលបច្ចុប្បន្នស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

ចំពោះការគ្រប់គ្រងសំណល់រាវ ទិសដៅយុទ្ធសាស្ត្រនៃផែនការមេ ត្រូវបានកំណត់ដូចខាងក្រោម÷
- ជំរុញឱ្យមានការវិនិយោគក្រុមហ៊ុនប្រមូលសំរាមចាប់ពី ២ឡើងទៅ ដោយត្រូវកំណត់យន្តការត្រួតពិនិត្យ និងវាយតម្លៃលើការប្រមូលសំរាមឱ្យបានច្បាស់លាស់
- សិក្សារៀបចំឱ្យមានអាងស្តុកប្រព្រឹត្តកម្មសំណល់រាវមួយក្នុងខេត្តមណ្ឌលគិរី ពិសេសក្នុងក្រុងសែនមនោរម្យ ដែលរួមចំណែកសំខាន់ដល់ការកែច្នៃ និងធ្វើប្រព្រឹត្តកម្មសំណល់រាវ និងអាចយកទឹកមកប្រើប្រាស់ឡើងវិញ
- ពង្រឹងកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធ ដូចជារវាងមន្ទីរសាធារណៈការ និងដឹកជញ្ជូន មន្ទីរបរិស្ថាន សាលាក្រុងសែនមនោរម្យ និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ក្នុងការរៀបចំផែនការ ពិសេសការអភិវឌ្ឍប្រព័ន្ធលូសាធារណៈឱ្យបានត្រឹមត្រូវ ដើម្បីបញ្ចៀសការបង្ហូរសំណល់រាវចូលទៅក្នុងប្រព័ន្ធលូបង្ហូរទឹកភ្លៀង
- ជំរុញការបំពាក់នូវធុងសំរាមឱ្យបានគ្រប់គ្រាន់នៅតាមគោលដៅសំខាន់ៗ និងរៀបចំឱ្យមានដេប៉ូស្តុកសំរាមនៅទីតាំងសមរម្យណាមួយ ដើម្បីកុំឱ្យប៉ះពាល់ដល់សោភ័ណភាព និងបង្កក្លិនមិនល្អដល់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋ
- ជំរុញ និងពង្រឹងការអនុវត្តវិធានបរិស្ថានសម្រាប់រោងចក្រ សហគ្រាស សិប្បកម្ម និងមូលដ្ឋានអាជីវកម្ម និងតម្រូវឱ្យមានការរៀបចំអាងប្រព្រឹត្តកម្មចម្រុះទឹកកខ្វក់ (Septic Tank) មុននឹងបញ្ចេញមកលូសាធារណៈ ឬប្រភពទឹកនានា
- លើកកម្ពស់ការអប់រំ និងបញ្ជ្រាបការយល់ដឹងទៅដល់ប្រជាពលរដ្ឋមូលដ្ឋានពីកិច្ចការពារបរិស្ថាន និងអនាម័យជាកិច្ចការចាំបាច់ដែលត្រូវធ្វើជាប្រចាំ ដើម្បីបំផុសចលនានៃការស្រលាញ់បរិស្ថាន និងការថែរក្សាអនាម័យនៅតាមទីសាធារណៈ។

ដោយឡែក ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ជាប្លាស្ទិក ផែនការមេកំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷
- ជំរុញការអភិវឌ្ឍខេត្តមណ្ឌលគិរីគឺជាគោលដៅអេកូទេសចរណ៍គ្មានសំណល់ប្លាស្ទិក
- ជំរុញការអនុវត្តគោលការណ៍ ៣ Rs ក្នុងការគ្រប់គ្រងសំណល់ជាប្លាស្ទិក រួមមានការកាត់បន្ថយ (Reduce) ការប្រើប្រាស់ឡើងវិញ (Reuse) និងការកែច្នៃឡើងវិញ (Recycle)
- ជំរុញឱ្យមានការវិនិយោគក្នុងការកែច្នៃសំណល់ជាប្លាស្ទិក
- ដាក់ចេញយុទ្ធនាការ និងកម្មវិធីនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងប្លាស្ទិក
- បំផុសទំលាប់ថ្មីក្នុងការប្រើប្រាស់ផលិតផលជំនួសប្លាស្ទិក។

### ៥.៥- ការអភិរក្សវប្បធម៌ជនជាតិដើមភាគតិច

ខេត្តមណ្ឌលគិរី គឺជាខេត្តដែលបណ្តុំជនជាតិដើមភាគតិចជាច្រើនរស់នៅរាយប៉ាយនៅតាមភូមិស្រុកនានា។ ទម្លាប់នៃការរស់នៅរបស់ជនជាតិដើមភាគតិចទាំងអស់នោះ បង្កើតបានជាសក្តានុពលទេសចរណ៍វប្បធម៌ដ៏សំខាន់ និងក្លាយជាកត្តាអំណោយផលដល់វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី។ ការរៀបចំតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រភ្នំដោះក្រមុំបានកំពុងក្លាយជាមេដែកឆក់ទាក់ទាញភ្ញៀវទេសចរឱ្យមកកម្សាន្តក្នុងខេត្តនេះ។ យ៉ាងណាក៏ដោយ ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច និងលំហូរចូលភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរី បានកំពុងធ្វើឱ្យមានការប្រែប្រួលវប្បធម៌ ប្រពៃណី និងរបៀបរបបរស់នៅរបស់បងប្អូនជនជាតិដើមភាគតិចទាំងអស់នោះ។

ផែនការមេ កំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷

- រៀបចំឱ្យមានគោលនយោបាយគាំទ្រដល់ជនជាតិដើមភាគតិច
- ពង្រឹងការអភិរក្សអត្តសញ្ញាណជនជាតិដើមភាគតិច តាមរយៈការធ្វើបញ្ជីសារពើភ័ណ្ឌសម្បត្តិបេតិកភណ្ឌវប្បធម៌ឱ្យបានច្បាស់លាស់ ព្រមជាមួយការរៀបចំផែនទីភូមិជនជាតិដើមភាគតិចដែលមាននៅខេត្តមណ្ឌលគិរី ដើម្បីធ្វើការសិក្សាស្វែងយល់ និងផ្សព្វផ្សាយទៅដល់ភ្ញៀវទេសចរ
- សិក្សារៀបចំសារៈមន្ទីរជនជាតិដើមភាគតិចឱ្យបានយ៉ាងតិចមួយនៅក្រុងសែនមនោរម្យ ឬនៅតាមទីតាំងសំខាន់ណាមួយ ពិសេសនៅឃុំដាក់ដាំក្នុងស្រុកអូររាំង ដែលមានសក្តានុពលក្នុងការទាក់ទាញភ្ញៀវទេសចរឱ្យមកស្វែងយល់អំពីការរស់នៅរបស់ជនជាតិដើមភាគតិច ដូចបានបង្ហាញក្នុងយុទ្ធសាស្ត្រគោលទី២
- ពង្រឹងការរៀបចំ និងផ្សព្វផ្សាយសក្តានុពលរបស់ខេត្តមណ្ឌលគិរី ក្នុងការផលិតភាពយន្ត ពិសេសទីតាំងអំណោយផលរបស់ភូមិជនជាតិដើមភាគតិច ទាំងភាពយន្តក្នុងស្រុក និងបរទេស
- រៀបចំឱ្យមានភូមិវប្បធម៌សហគមន៍ (Community-Base Cultural Village) ជនជាតិដើមភាគតិចមួយនៅឃុំដាក់ដាំក្នុងស្រុកអូររាំង ដែលអាចក្លាយទៅជាផលិតផលទេសចរណ៍ថ្មីមួយដ៏សំខាន់សម្រាប់ភ្ញៀវទេសចរស្វែងយល់សិក្សាអំពីតំបន់នោះ ដូចបានរៀបរាប់ខាងលើ
- សិក្សាលទ្ធភាពក្នុងការបង្កើតសាលាវប្បធម៌ និងវិចិត្រសិល្បៈសម្រាប់ជនជាតិដើមភាគតិច ធ្វើយ៉ាងណាដើម្បីពង្រឹងនូវការរក្សាអត្តសញ្ញាណ ក៏ដូចជាភាពដើមនៃជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរី
- សិក្សាបង្កើតមជ្ឈមណ្ឌលវប្បធម៌សហគមន៍ សារមន្ទីរ សាលតាំងពិព័រណ៍ រោងមហោស្រព សម្តែងសិល្បៈសម្រាប់ជនជាតិដើមភាគតិច
- ធ្វើការបណ្តុះបណ្តាលជំនាញចាំបាច់នានាដល់ជនជាតិដើមភាគតិចក្នុងសហគមន៍ ដែលពួកគាត់រស់នៅដើម្បីពង្រឹងសមត្ថភាព និងបង្កើតឱកាសការងារ។

### ៥.៦- ការផ្សារភ្ជាប់វិស័យរ៉ែ និងទេសចរណ៍

ការអភិវឌ្ឍវិស័យរ៉ែ ដើរតួនាទីសំខាន់ក្នុងការបង្កើនចំណូលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងរួមចំណែកបង្កើតការងារដល់ប្រជាពលរដ្ឋមូលដ្ឋាន។ យ៉ាងណាក៏ដោយ ក្រោយពីការបញ្ចប់ការវិនិយោគលើការធ្វើអាជីវកម្មធនធានរ៉ែក្នុងតំបន់មួយចំនួន នៅមិនទាន់មានការរៀបចំឱ្យមានលក្ខណៈល្អប្រសើរនៅឡើយ ពិសេសពាក់ព័ន្ធនឹងសោភ័ណភាពនៃតំបន់អាជីវកម្ម ការខូចខាតទ្រង់ទ្រាយដី និងធនធានធម្មជាតិជាដើម។ ទន្ទឹមនឹងនេះ ការអភិវឌ្ឍលើវិស័យរ៉ែប្រកបដោយនិរន្តរភាព ទាមទារឱ្យមានការចូលរួមគាំទ្រពីប្រជាពលរដ្ឋក្នុងតំបន់អាជីវកម្ម និងការបញ្ជ្រាបការយល់ដឹងអំពីដំណើរការអភិវឌ្ឍធនធានរ៉ែ ផលប្រយោជន៍ដែលប្រជាពលរដ្ឋមូលដ្ឋានទទួលបាន ផលប៉ះពាល់ និងវិធានការការពារដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ក្នុងតំបន់អាជីវកម្មរ៉ែ។

ក្នុងន័យនេះ ផែនការមេសម្រាប់ទិសដៅយុទ្ធសាស្ត្រត្រូវបានកំណត់ដូចខាងក្រោម÷

- កំណត់តំបន់អាទិភាព (Zoning) ក្នុងការទាញយកថ្ម និងអាចម៍ដីសម្រាប់បម្រើដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគលើគម្រោងអភិវឌ្ឍន៍នានាក្នុងខេត្តមណ្ឌលគិរី ឱ្យបានច្បាស់លាស់ ដោយផ្ដោតលើការគិតគូរបរិស្ថាន និងសោភ័ណភាពរបស់ខេត្ត និងចូលរួមដល់ការអភិរក្សធនធានព្រៃឈើសម្រាប់ភ្ញៀវទេសចរមកកម្សាន្ត
- ពិនិត្យលទ្ធភាពក្នុងការបង្កើតសារមន្ទីររ៉ែ ដើម្បីឱ្យភ្ញៀវទេសចរអាចចូលរួមមកទស្សនាសំណាកគំរូរ៉ែដែលជាធនធានធម្មជាតិដែលមាននៅក្នុងខេត្តនេះ និងយល់ដឹងពីសកម្មភាពនៃប្រតិបត្តិការធនធានរ៉ែដែលជាផ្នែកមួយក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ
- ពិនិត្យលទ្ធភាពក្នុងការបង្កើតកន្លែងសម្រាប់ភ្ញៀវទេសចរទៅទស្សនាអណ្ដូងរ៉ែមាស ដែលមានលក្ខណៈឆ្លើយតបតាមស្តង់ដារអន្តរជាតិ ធានាបានទាំងលើផ្នែកបច្ចេកទេស សុវត្ថិភាព និងផលប៉ះពាល់បរិស្ថាន
- ពិនិត្យលទ្ធភាពក្នុងការបង្កើតមណ្ឌលទេសចរណ៍រែងរ៉ែមាស និងត្បូងកម្សាន្ត ដើម្បីទាក់ទាញភ្ញៀវទេសចរចូលទៅទិញរ៉ែមាសដែលរៀបចំទុកជាស្រេច ហើយរែងដោយខ្លួនឯង ដោយមានការបង្ហាត់បង្ហាញពីបុគ្គលិកនៅទីនោះ ហើយកម្ទេចមាសឬត្បូងដែលទទួលបានអាចយកទៅរក្សាទុកជាវត្ថុអនុស្សាវរីយ៍
- ពិនិត្យលទ្ធភាពក្នុងការប្រែក្លាយតំបន់ដែលបញ្ចប់សកម្មភាពអាជីវកម្មរ៉ែទៅជាតំបន់ទេសចរណ៍បែបថ្មីមួយដោយត្រូវធានាឱ្យបានសុវត្ថិភាពជូនភ្ញៀវទេសចរ
- ពង្រឹងការអនុវត្ត និងការត្រួតពិនិត្យបទដ្ឋានបច្ចេកទេសក្នុងការធ្វើអាជីវកម្មរ៉ែ និងទប់ស្កាត់ការធ្វើអាជីវកម្មបែបអនាធិបតេយ្យ និងដែលមិនស្របតាមបទដ្ឋានបច្ចេកទេស
- ពិនិត្យលទ្ធភាពក្នុងការប្រែក្លាយតំបន់ភ្នំណាមលៀរ ដែលជាប្រភេទភ្នំថ្មក្រានីត ជាសួនភូគព្ភសាស្ត្រ (Geo Park) និងជាគោលដៅទេសចរណ៍ដ៏ទាក់ទាញ ដោយត្រូវមានការគិតគូរពីបញ្ហាសុវត្ថិភាពជូនភ្ញៀវទេសចរដែលឡើងទៅកម្សាន្ត។

### ៥.៧- ការផ្សារភ្ជាប់វិស័យកសិកម្ម និងទេសចរណ៍

យោងតាមការសិក្សាខាងលើ ខេត្តមណ្ឌលគិរីមានសក្ដានុពលខ្ពស់ក្នុងការអភិវឌ្ឍវិស័យកសិកម្ម។ ជាចក្ខុវិស័យខេត្តមណ្ឌលគិរីត្រូវបានរំពឹងថានឹងក្លាយជាគោលដៅផ្គត់ផ្គង់បន្លែ ផ្លែឈើ សាច់ ក៏ដូចជាកសិផលមួយចំនួន សម្រាប់ការប្រើប្រាស់ក្នុងខេត្ត និងសម្រាប់ការនាំចេញផងដែរ។ ទន្ទឹមនឹងនេះ កត្តាអាកាសធាតុត្រជាក់បង្គួរដែលអំណោយផលដល់ការអភិវឌ្ឍជាកសិដ្ឋានផ្កា នឹងធ្វើឱ្យខេត្តមណ្ឌលគិរីក្លាយ ជាមជ្ឈមណ្ឌលផ្គត់ផ្គង់ផ្កា ទៅដល់ផ្នែកផ្សេងៗនៃប្រទេស និងនាំចេញទៅក្រៅប្រទេស។

យ៉ាងណាក៏ដោយ កង្វះខាតបច្ចេកវិទ្យាទំនើបក្នុងការដាំដុះ ប្រភពទឹកស្រោចស្រពដំណាំ កង្វះខាត ការវិនិយោគ និងកម្លាំងពលកម្ម ធ្វើឱ្យការអភិវឌ្ឍវិស័យកសិកម្មនៅក្នុងខេត្តនេះមិនទាន់ឆ្លើយតបជាមួយសក្ដានុពល និងតម្រូវការក្នុងខេត្តនៅឡើយ។

នៅពេលចំនួនភ្ញៀវទេសចរមានការកើនឡើងនាពេលអនាគត តម្រូវការកសិផល ដូចជាបន្លែ ផ្លែឈើ និងផ្កានឹងមានការកើនឡើង។ ម្យ៉ាងវិញទៀត ក្នុងការគិតរបស់ប្រជាពលរដ្ឋកម្ពុជាទូទៅ ខេត្តមណ្ឌលគិរី គឺជាទឹកដីដែលអាចអភិវឌ្ឍន៍ជាកសិដ្ឋានផ្កា បន្លែ ផ្លែឈើ ដែលយើងអាចប្រៀបធៀបជាមួយនឹងខេត្តឈៀងម៉ៃ និងឈៀងរ៉ៃប្រទេសថៃ និងខេត្តដាក់ឡាក់ប្រទេសវៀតណាមជាដើម។

ក្នុងន័យនេះ ផែនការមេមណ្ឌលគិរី កំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷

- បង្កើតឲ្យមានផ្សារសហគមន៍ ដែលអាចផ្តល់ទីតាំងសម្រាប់លក់ផលិតផលកសិកម្ម និងជំរុញឲ្យមានការតាំងបង្ហាញ និងលក់កសិផលរបស់ជនជាតិដើមភាគតិច
- បង្កើតស្លាកសញ្ញាសម្គាល់ផលិតផលប្រចាំតំបន់ និងប្រចាំខេត្ត ដូចជាផ្លែប័រ ទុរេន កាហ្វេ ទឹកឃ្មុំ ស្រាផាស់សិន និងផលិតផលកសិកម្មផ្សេងទៀតដែលបង្ហាញពីអត្តសញ្ញាណរបស់ខេត្ត ដូចបានរៀបរាប់ខាងលើ
- ជំរុញឲ្យមានការចងក្រងជាក្រុម ឬសហគមន៍ក្នុងការដាំដុះ ដើម្បីធ្វើការចែករំលែកបច្ចេកទេស និងបង្កលក្ខណៈងាយស្រួលដល់ការស្វែងរកទីផ្សារសម្រាប់លក់ផលិតផល
- លើកទឹកចិត្តឲ្យមានការវិនិយោគដំណាំដែលមានសក្តានុពល ពិសេសដំណាំកសិកម្ម និងកសិ-ឧស្សាហកម្មមួយចំនួន ដូចជាបន្លែ ផ្កា និងផ្លែឈើ ដែលមានសក្តានុពលនាំចេញទៅក្រៅប្រទេស
- ជំរុញការចិញ្ចឹមសត្វ វារីវប្បកម្ម ជាពិសេសការចិញ្ចឹមត្រីដែលមានតម្លៃសេដ្ឋកិច្ច និងការងារទាក់ទងទៅនឹងសុវត្ថិភាពផលិតផលកសិកម្ម
- ខេត្តមណ្ឌលគិរីមានសក្តានុពលក្នុងការរៀបចំជាកន្លែងចិញ្ចឹមសត្វខ្នាតធំ សម្រាប់បម្រើដល់សកម្មភាពផ្គត់ផ្គង់សាច់ និងអាចប្រែក្លាយទៅកសិដ្ឋាន ឬតំបន់ទេសចរណ៍សម្រាប់ភ្ញៀវទេសចរទស្សនាកម្សាន្ត។ ក្នុងន័យនេះ ផែនការមេ លើកទឹកចិត្តឲ្យមានការវិនិយោគកសិដ្ឋានចិញ្ចឹមសត្វខ្នាតអន្តរជាតិសម្រាប់ធ្វើការផ្គត់ផ្គង់សាច់ និងប្រែក្លាយជាតំបន់ទេសចរណ៍សម្រាប់ភ្ញៀវទេសចរចូលទស្សនា
- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ ដាំដុះផ្កា បន្លែ ផ្លែឈើ ឲ្យស្របតាមស្តង់ដា ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងក្រៅប្រទេស
- ថែរក្សាប្រភពទឹក ដូចជាអូរ ស្ទឹង -ល- និងសិក្សាពីលទ្ធភាពក្នុងការស្ទាក់ទឹកភ្លៀងមករក្សាទុកសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ និងបម្រើដល់វិស័យកសិកម្ម តាមរយៈការថែរក្សាព្រៃឈើនៅតាមប្រភពទឹកទាំងអស់។

### ៥.៨- វិស័យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម

វិស័យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម រួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ តាមរយៈការចូលរួមកំណើនសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងលើកស្ទួយវិស័យទេសចរណ៍ជារួម និងវិស័យទេសចរណ៍នៅខេត្តមណ្ឌលគិរីផងដែរ។ ជាក់ស្តែង សហគ្រាសធុនតូច មធ្យម និងសិប្បកម្មនៅខេត្តមណ្ឌលគិរី បានចុះបញ្ជីសរុបមាន ៤៧០ មូលដ្ឋាន និងកំលាំងពលកម្ម ៩៤០ នាក់ ដែលឆ្លុះបញ្ចាំងពីការអភិវឌ្ឍមូលដ្ឋានសេដ្ឋកិច្ចនៅខេត្តមណ្ឌលគិរី ស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល សំដៅជំរុញការទាក់ទាញវិនិយោគគ្រប់ប្រភេទ ដើម្បីបង្កើត ការងារ បង្កើនចំណូលសេដ្ឋកិច្ចគ្រួសារ ការកែច្នៃ និងការច្នៃប្រឌិតផលិតផលថ្មីៗសម្រាប់បម្រើឲ្យអតិថិជន អ្នកប្រើប្រាស់ និងភ្ញៀវទេសចរជាដើម។

ក្នុងន័យនេះ វិស័យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម បាននឹងកំពុងជំរុញ និងបង្កើនល្បឿនផលិតកម្មសេដ្ឋកិច្ចជនបទ និងសហគ្រិនភាព នឹងរួមចំណែកគាំទ្រដល់ការបង្កើនប្រាក់ចំណូលនៅតាមគ្រួសារ ដើម្បីឲ្យប្រជាពលរដ្ឋតាមមូលដ្ឋានមានជីវភាពប្រសើរឡើង តាមរយៈការផ្តល់ជំនាញ បង្កើតការងារ ផ្តល់ឥណទានសមស្រប រកទីផ្សារ និងបង្កើនបរិយាកាសរស់នៅកាន់តែល្អប្រសើរ បង្កើនស្ថេរភាពប្រាក់ចំណូលតាមគ្រួសារនីមួយៗ និងទប់ស្កាត់ការធ្វើចំណាកស្រុកទាំងប្រថុយប្រថាន។

ក្នុងន័យនេះ ផែនការមេកំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷

- ជំរុញការកែច្នៃ និងច្នៃប្រឌិតអត្តសញ្ញាណមុខទំនិញ និងមុខផលិតផលរបស់ខេត្តមណ្ឌលគិរី សម្រាប់បម្រើឲ្យវិស័យទេសចរណ៍
- សិក្សាបង្កើតសាលាបណ្តុះបណ្តាល ឬវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសខេត្តមណ្ឌលគិរី ដើម្បីជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈចាំបាច់នានាក្នុងខេត្តមណ្ឌលគិរី សម្រាប់សិស្ស-និស្សិត យុវជន ដែលមានបំណងចាប់យកអាជីពការងារក្នុងវិស័យនេះ
- វិស័យសហគ្រាសធុនតូច និងមធ្យម ត្រូវចូលរួមពង្រឹងខ្លួនឯង តាមរយៈការរៀបចំស្លាកសញ្ញាឲ្យបានត្រឹមត្រូវ ឆ្លើយតបតាមស្តង់ដាគុណភាព និងសមាមាត្រតម្លៃ ធ្វើយ៉ាងណាឲ្យផលិតផលទាំងអស់នោះ អាចឆ្លើយតបទៅតាមតម្រូវការទីផ្សារ
- ជំរុញឲ្យមានការចងក្រងជាសមាគម ឬសហគមន៍អ្នកផលិតទៅតាមអនុវិស័យនីមួយៗ ដើម្បីជំរុញដល់ការចែករំលែកបច្ចេកវិទ្យា និងពង្រឹងកម្លាំងក្នុងការស្វែងរកទីផ្សារលក់ផលិតផល
- សិក្សាបង្កើតឲ្យមានកម្មវិធីកម្ចីពិសេស ក្នុងអត្រាការប្រាក់ទាប ដែលអនុញ្ញាតឲ្យសហគ្រាសធុនតូច និងមធ្យមទាំងអស់នោះ មានលទ្ធភាពទទួលបានកម្ចីក្នុងលក្ខខណ្ឌមួយសមរម្យ ដើម្បីពង្រីកអាជីវកម្ម និងសង្វាក់ផលិតកម្មរបស់ខ្លួន
- បង្កើតឲ្យមានកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់បងប្អូនប្រជាពលរដ្ឋលើការផលិតផលិតផលសម្រាប់បម្រើដល់វិស័យទេសចរណ៍ ដូចជាវត្ថុអនុស្សាវរីយ៍ និងការដាក់ចេញយុទ្ធសាស្ត្រសមស្របសម្រាប់ការស្វែងរកទីផ្សារ រួមចំណែកបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ជំរុញការប្រើប្រាស់សក្តានុពលធនធានក្នុងខេត្តមណ្ឌលគិរី ដើម្បីធ្វើការកែច្នៃ និងការផលិតសម្រាប់ធ្វើពិពិធកម្មមុខទំនិញក្នុងគោលដៅទេសចរណ៍។

## ៥.៩- ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ

ដូចបានបង្ហាញក្នុងផ្នែកខាងលើ ផ្ទៃដីប្រមាណ ៨០% នៃខេត្តមណ្ឌលគិរី ស្ថិតក្នុងដែនអភិរក្សដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលសម្បូរទៅដោយធនធានធម្មជាតិជាច្រើន ទាំងព្រៃឈើ សត្វព្រៃ ជីវៈចម្រុះ និងបង្កើតបានជារបៀងជីវៈចម្រុះសំខាន់ៗជាច្រើន។ ប៉ុន្តែ តំបន់អភិរក្សដ៏ធំក្នុងខេត្ត កំពុងទទួលរងការទន្ទ្រានដើម្បីជាប្រយោជន៍ឯកជនជាបន្តបន្ទាប់។

ក្នុងន័យនេះ ផែនការមេកំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷

- អនុវត្តឲ្យបានម៉ឺងម៉ាត់នូវបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការទន្ទ្រានដីរដ្ឋ ពិសេសរដ្ឋបាលខេត្តមណ្ឌលគិរីត្រូវសហការជាមួយក្រុមការងារក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការចុះបញ្ជីដីធ្លីក្នុងខេត្តមណ្ឌលគិរី ឲ្យបានរួចរាល់ ដើម្បីធ្វើការបែងចែកឲ្យដាច់ស្រេចរវាងតំបន់ដែលត្រូវអភិរក្ស និងតំបន់ដែលត្រូវអភិវឌ្ឍន៍ និងតំបន់ដែលមានប្រជាជនរស់នៅ ដើម្បីកុំឲ្យមានភាពប្រទាញប្រទង់គ្នាលើការអភិរក្ស និងការអភិវឌ្ឍ
- រដ្ឋបាលខេត្ត និងមន្ទីរទេសចរណ៍ ត្រូវសហការជាមួយក្រុមការងារចុះបញ្ជីដីធ្លីខេត្តមណ្ឌលគិរី ចុះបញ្ជីរមណីយដ្ឋានទេសចរណ៍សំខាន់ៗក្នុងខេត្តឲ្យបានឆាប់រហ័ស

- សិក្សាបង្កើតមជ្ឈមណ្ឌលអប់រំចម្រុះ និងសំបូរបែបទាក់ទងនឹងការគ្រប់គ្រងជីវៈចម្រុះ និងធនធានធម្មជាតិ ដែលអាចរួមបញ្ចូលទាំងគ្រឿងបរិក្ខារសម្រាប់ការបោះជំរុំវិស្សមកាល អគារសម្រាប់មន្ទីរពិសោធន៍ស្រាវជ្រាវ សិក្ខាសាលា និងកន្លែងចុះអនុវត្ត និងសិក្សាស្រាវជ្រាវនៅទីវាលជាក់ស្តែង
- សិក្សាបង្កើតជាសួនបូតានិច ឬសួនរុក្ខជាតិ (Botanical Garden)
- ជំរុញភាគីពាក់ព័ន្ធទាំងអស់ផ្តោតការយកចិត្តទុកដាក់លើវិធានការស្តារ និងបង្កើតចលនាដាំដើមឈើឡើងវិញ
- ទន្ទឹមនឹងនេះ បរិមាណដើមស្រល់នៅក្នុងស្រុកអូររាំង និងតាមបណ្តោយផ្លូវជាតិលេខ ៧៦ បានរងការគំរាមកំហែង ហើយតំបន់មួយចំនួននៃចម្ការស្រល់បានក្លាយជាកម្មសិទ្ធឯកជន ដែល តម្រូវឱ្យមានការគិតគូរជាចាំបាច់ ពីព្រោះការបាត់នូវបរិមាណដើមស្រល់នេះអាចធ្វើឱ្យប៉ះពាល់ ដល់សោភ័ណភាពបៃតង និងវិស័យទេសចរណ៍ខេត្តមណ្ឌលគិរីផងដែរ។ ក្នុងន័យនេះ គួររៀបចំ ឱ្យមានចលនាដាំដើមស្រល់ឡើងវិញនៅតាមតំបន់សំខាន់ៗមួយចំនួន។

## ៥.១០- ការគាំពារសេវាវេជ្ជសាស្ត្រ និងសុខាភិបាល

ការរៀបចំសេវាសុខាភិបាលនៅក្នុងភូមិសាស្ត្រខេត្តនីមួយៗ មានទម្រង់ខុសៗគ្នាតាមកម្រិតរដ្ឋបាល (ខេត្ត ស្រុក និងឃុំ)។ ស្រុកមួយចំនួន ត្រូវប្រមូលផ្តុំបង្កើតជាស្រុកប្រតិបត្តិ ដើម្បីបង្កលទ្ធភាពផ្តល់នូវសេវាសុខាភិបាលសម្រាប់ប្រជាជន។ ស្រុកប្រតិបត្តិនីមួយៗ មានមន្ទីរពេទ្យបង្អែកមួយដែលអាចបម្រើសេវាជូនប្រជាជនយ៉ាងតិច ៥០.០០០ នាក់ និងមណ្ឌលសុខភាពសម្រាប់ប្រជាជនយ៉ាងតិច ៥០០០ នាក់។ ដោយឡែក ខេត្តមណ្ឌលគិរី មានស្រុកប្រតិបត្តិតែមួយប៉ុណ្ណោះ រួមទាំងអតីតមន្ទីរពេទ្យស្រុកចំនួន០៣ និងមណ្ឌលសុខភាពចំនួន០៣។

ទន្ទឹមនឹងនេះ ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលគ្មានមជ្ឈដ្ឋានណាបានស្មានគិតដល់ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ពិភពលោកលើគ្រប់វិស័យ រួមទាំងការរស់នៅ និងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ដែលតម្រូវឱ្យមនុស្សគ្រប់គ្នា ត្រូវសម្របខ្លួនរស់នៅ “**ក្នុងទម្លាប់ថ្មី**”។

ក្នុងន័យនេះ ផែនការមេកំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធវិស័យវេជ្ជសាស្ត្រ និងសុខាភិបាលក្នុងខេត្តមណ្ឌលគិរីស្របតាមស្តង់ដាជាតិ និងអន្តរជាតិ ដើម្បីបង្កើនទំនុកចិត្តភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលនឹងមានកំណើននាពេលអនាគត
- ផ្តល់អាទិភាពដល់ការវិនិយោគ និងអភិវឌ្ឍវិស័យសុខាភិបាល តាមរយៈការបង្កើតមន្ទីរពេទ្យស្តង់ដាអន្តរជាតិក្នុងខេត្តមណ្ឌលគិរី ដែលនឹងក្លាយជាមជ្ឈមណ្ឌលសុខាភិបាលសម្រាប់តំបន់ភូមិភាគឦសាន នឹងរួមចំណែកពង្រឹងប្រតិបត្តិការនៃប្រព័ន្ធសុខាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសផ្តោតលើការផ្តល់សេវាថៃទាំសុខភាព ប្រកបដោយគុណភាព សុវត្ថិភាព សក្តិសិទ្ធភាព និងសមធម៌ ជូនប្រជាពលរដ្ឋ និងកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋទៅកាន់រាជធានីភ្នំពេញ និងប្រទេសជិតខាង
- ជំរុញឱ្យមានការធ្វើទំនើបកម្មសេវាសុខាភិបាលនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនានា ដើម្បីធានាការផ្តល់សេវាព្យាបាលជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាពជូនប្រជាពលរដ្ឋ
- ពង្រឹង និងពង្រីកធនធានមនុស្សបម្រើការក្នុងវិស័យសុខាភិបាល ពិសេសនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពក្នុងខេត្ត។

### ៥.១១- ការជំរុញការអភិវឌ្ឍបច្ចេកវិទ្យា នវានុវត្តន៍ និងភាពច្នៃប្រឌិត

ខណៈដែលក្រុងសែនមនោរម្យកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ដែលមានលក្ខណៈមិនស្មុគស្មាញខុសពីតំបន់ទីក្រុងផ្សេងដែលមានការអភិវឌ្ឍរួចហើយ ផែនការមេកំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷

- ក្រុងសែនមនោរម្យ គួរត្រូវបានសិក្សាអភិវឌ្ឍន៍ជាទីក្រុងឆ្លាតវៃ (Smart City) ដោយត្រូវបញ្ចូលទស្សនទាន និងបច្ចេកវិទ្យាថ្មីៗ ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ទាំងលើការហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទ្រទ្រង់ ប្រព័ន្ធគមនាគមន៍ ដឹកជញ្ជូន ការទំនាក់ទំនង ដំណើរការប្រតិបត្តិការ និងការបណ្តុះបណ្តាលជំនាញរឹង និងទន់ (Hard Skill and Soft Skill) ចាំបាច់នានា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការធ្វើទំនើបកម្មតំបន់ទីក្រុង និងទីប្រជុំជន ឆ្លើយតបទៅនឹងបរិបទបដិវត្តន៍ឧស្សាហកម្ម ៤.០
- ខេត្តមណ្ឌលគិរី គួរបញ្ចូលនូវបច្ចេកវិទ្យាវ៉ាយឆ្លាតគ្រីដ (Smart-grid Technology) សម្រាប់គាំទ្រដល់ការសន្សំសំចៃ និងគ្រប់គ្រងថាមពល និងការគាំទ្រខ្សែសង្វាក់ផ្គត់ផ្គង់តម្រូវការក្នុងវិស័យទេសចរណ៍
- ខេត្តមណ្ឌលគិរី គួរត្រូវបានសិក្សាលើការប្រើបច្ចេកវិទ្យា ដើម្បីគ្រប់គ្រងធនធានទឹកទៅលើភាពងាយរងគ្រោះនៃប្រភពទឹក
- គួរត្រូវបានគិតគូរដល់ការពង្រឹងសមត្ថភាពរបស់មន្ត្រីមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តមណ្ឌលគិរី លើការបន្សាំ និងការទទួលយកបច្ចេកវិទ្យាថ្មីៗ សម្រាប់គាំទ្រសហគ្រាសមីក្រូ ធុនតូច មធ្យម និងសិប្បកម្ម រួមទាំងសេវាកម្មផ្សេងៗទៀត
- ក្រុងសែនមនោរម្យ គួរបង្កើតឱ្យមានប្រព័ន្ធផ្ទុកទិន្នន័យ និងការគ្រប់គ្រងព័ត៌មានរួម (ប្រជាសាស្ត្រ ធនធានមនុស្ស សហគ្រាសមីក្រូ ធុនតូច មធ្យម និងសិប្បកម្ម សេវាកម្មសេដ្ឋកិច្ច ជាដើម)
- ខេត្តមណ្ឌលគិរី គួរត្រូវបានយកចិត្តទុកដាក់លើបច្ចេកវិទ្យាភ័ស្តុភារកម្ម (Logistic Technology) ផ្តោតលើតម្រូវការ និងការផ្គត់ផ្គង់លើវិស័យទេសចរណ៍
- ខេត្តមណ្ឌលគិរី គួរយកចិត្តទុកដាក់កសិកម្មវ៉ៃឆ្លាតផងដែរ (Smart Agriculture)។

បន្ថែមពីលើនេះ ដោយសារទីតាំងភូមិសាស្ត្រខេត្តមណ្ឌលគិរីសម្បូរទៅដោយខ្ពង់រាប និងភ្នំច្រើន ធ្វើឱ្យប្រព័ន្ធទំនាក់ទំនង សេវាទូរស័ព្ទ និងប្រព័ន្ធអ៊ិនធើណែត នៅមិនទាន់មានលក្ខណៈពេញលេញនៅឡើយ។ ក្នុងន័យនេះ ផែនការមេជំរុញឱ្យមានការសិក្សាតំឡើងប្រព័ន្ធអង់តែនទូរស័ព្ទ និងសេវាអ៊ិនធើណែតគ្របដណ្តប់ឱ្យបានពាសពេញខេត្ត រួមទាំងតំបន់ដែនជម្រកសត្វព្រៃទាំង៥ផងដែរ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការតភ្ជាប់តំបន់នានានៅទូទាំងប្រទេស។

## ៦- ការតភ្ជាប់ ការសម្រួលការធ្វើដំណើរ និងការធ្វើសមាហរណកម្មក្នុងក្របខណ្ឌជាតិ និងតំបន់

ដើម្បីជំរុញឱ្យខេត្តភូមិភាគឦសានមួយនេះ ដែលជាគោលដៅអេកូទេសចរណ៍ដ៏ធំរបស់កម្ពុជាក្លាយជាតំបន់ប៉ូលសេដ្ឋកិច្ចមួយក្នុងចំណោមតំបន់ប៉ូលសេដ្ឋកិច្ចទាំង៤ ក្នុងការទាក់ទាញវិនិយោគសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិ និងជាមេដែកស្រូបទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តមណ្ឌលគិរី គឺត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកដឹកជញ្ជូន និងពង្រឹងការតភ្ជាប់ផ្លូវអាកាស (Air Connectivity) ពិសេសគឺការគិតគូរដល់ការបង្កើតអាកាសយានដ្ឋានតំបន់ថ្មី (Regional Airport) ដែលមានតួនាទីសំខាន់បម្រើដល់ការដឹកជញ្ជូនទេសចរ អ្នកដំណើរតាមផ្លូវអាកាស និងទំនិញផ្សេងៗទៅកាន់គោលដៅនានាក្នុងប្រទេស និងទៅកាន់បណ្តាប្រទេសនានាក្នុងតំបន់។

### ៦.១- ការតភ្ជាប់តាមផ្លូវអាកាស និងហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន

ការអភិវឌ្ឍអាកាសយានដ្ឋានមណ្ឌលគីរីថ្មី លំដាប់ថ្នាក់ 4C និងតំបន់ឧស្សាហកម្មរណបអាកាសយានដ្ឋានថ្មីនេះ នឹងពង្រីកអាកាសដ្ឋាននាពេលអនាគត នឹងផ្តល់គុណប្រយោជន៍ជាច្រើនដល់ប្រទេសកម្ពុជា ដូចជាការរួមចំណែកដល់ការអនុវត្តគោលនយោបាយ និងផែនការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា ឡាវ វៀតណាម (CLV Triangle Development Plan) ស្របតាមគោលនយោបាយគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងវិថី (Belt and Road Initiative) ចូលរួមការអនុវត្តយុទ្ធសាស្ត្របង្កើនកំណើនសេដ្ឋកិច្ចកម្ពុជា ដែលរាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកតំបន់ភូមិភាគឦសានជាប៉ូលសេដ្ឋកិច្ចទី៤។ អាកាសយានដ្ឋានមណ្ឌលគីរី នឹងចូលរួមចំណែកធ្វើអតិបរមានីយកម្ម ក្នុងការកៀងគរចំណូលថវិកាជាតិពីវិស័យអាកាសចរ សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ជាពិសេសឆ្លើយតបទៅនឹងការលើកកម្ពស់ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស ទេសចរណ៍ និងអភិវឌ្ឍន៍ជនបទ ហើយអាកាសយានដ្ឋាននេះ នឹងបង្កើនការទាក់ទាញលំហូរចូលភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលមកទស្សនារមណីយដ្ឋានទេសចរណ៍ ធម្មជាតិនានាក្នុងខេត្ត តំបន់ភូមិភាគឦសានដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជា តារារះទិសឦសាន្ត បង្កើនចំណូលថវិការដ្ឋតាមរយៈការហោះហើរត្រង់ទៅកាន់អាកាសយានដ្ឋានមណ្ឌលគីរី។ ទាំងនេះ គឺជាការជួយជំរុញ ការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល និងបង្កើនចំណូលប្រជាពលរដ្ឋ តាមរយៈការរីកចម្រើនវិស័យពាណិជ្ជកម្ម និងទេសចរណ៍ ដូច្នេះការត្រៀមបម្រុង និងរក្សាដីទុកសម្រាប់ការអភិវឌ្ឍតំបន់ឧស្សាហកម្មរណបអាកាសយានដ្ឋាន ត្រូវតែមានការគិតគូរឱ្យបានគត់មុតទុកជាមុន។

បន្ថែមលើសពីនេះទៅទៀត ការអភិវឌ្ឍអាកាសយានដ្ឋានមណ្ឌលគីរីថ្មី (លំដាប់ថ្នាក់ 4C) ដែលស្ថិតនៅចម្ងាយប្រមាណ ២០ គីឡូម៉ែត្រភាគខាងត្បូងនៃក្រុងសែនមនោរម្យ អាចនឹងមានភាពទាក់ទាញ នឹងដើម្បីពង្រឹងឱ្យមានការហោះហើរត្រង់តភ្ជាប់ទៅកាន់គោលដៅទេសចរណ៍សំខាន់ៗ ទាំងក្នុងប្រទេស និងក្នុងតំបន់ទាំងឡាយណាដែលមានចរាចរណ៍ផ្លូវអាកាសមមាញឹក ដូចជា មកពីប្រទេសវៀតណាម ថៃ ឡាវ និងជាចលករមួយជំរុញការធ្វើសមាហរណកម្ម និងសុខដុមនីយកម្មបន្តិចម្តងៗ រវាងគោលនយោបាយបើកចំហជើងមេឃរបស់រាជរដ្ឋាភិបាល និងគោលនយោបាយបើកចំហជើងមេឃរបស់អាស៊ាន ក៏ដូចជាសម្រាប់ប្រទេសអនុតំបន់មេគង្គ រួមមាន កម្ពុជា ចិន ឡាវ ថៃ ភូមា និងវៀតណាម រួមទាំងក្របខណ្ឌបណ្តាប្រទេសកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង (Mekong Lancang Cooperation Countries) និងក្របខណ្ឌយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងក្របខណ្ឌជាតិ ផែនការមេជំរុញឱ្យមានការតភ្ជាប់ផ្លូវអាកាសពីបណ្តាខេត្តគោលដៅទេសចរណ៍មួយចំនួនដូចជារាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តបាត់ដំបង មកកាន់ខេត្តមណ្ឌលគីរី តាមរយៈជើងហោះហើរក្នុងស្រុក ក្នុងតម្លៃសមរម្យ និងមានការប្រកួតប្រជែងស្មើគ្នា។ ទន្ទឹមនឹងនេះ ត្រូវជំរុញឱ្យក្រុមហ៊ុនអាកាសចរក្នុងស្រុក រៀបចំកាលវិភាគ និងជើងហោះហើរឱ្យបានច្រើន និងទៀងទាត់ ភ្ជាប់គោលដៅសំខាន់ៗក្នុងប្រទេសមកកាន់អាកាសយានដ្ឋានខេត្តមណ្ឌលគីរី។ បច្ចុប្បន្ន ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក មានចំនួន ០៩ រួមមាន÷

១. ក្រុមហ៊ុនអាកាសចរ ខេមបូឌាអង្គរអ៊ែរ (Cambodia Angkor Air)
២. ក្រុមហ៊ុនអាកាសចរ ស្កាយអង្គរ (Sky Angkor Airlines)
៣. ក្រុមហ៊ុនអាកាសចរ ជេស៊ី (ខេមបូឌា) អាំងទែរណាស្យូណាល់ JC (Cambodia) International Airlines
៤. ក្រុមហ៊ុនអាកាសចរ ឡានមុី (Lanmei Airlines)
៥. ក្រុមហ៊ុនអាកាសចរ បាសាកា (Basaka Air)

៦. ក្រុមហ៊ុនអាកាសចរ ខេមបូឌាអ៊ែរវ៉េ (Cambodia Airways)

៧. ក្រុមហ៊ុនអាកាសចរ ខេមបូឌាបាយ័ន (Cambodia Bayon Airlines)

៨. ក្រុមហ៊ុនអាកាសចរ ហេលីកូបទែរខេមបូឌា (Helicopters Cambodia)

៩. ក្រុមហ៊ុនអាកាសចរ ហេលីស្តារខេមបូឌា (Helistar Cambodia)។

អាកាសយានដ្ឋានខេត្តមណ្ឌលគិរី នឹងពង្រីងសេវាកម្មអាកាសចរស៊ីវិល និងវិស័យក្រុមហ៊ុនអាកាសចរ រួមមានការបង្កើតភស្តុភារកម្មផ្លូវអាកាស (Air Logistic) សម្រាប់ការភ្ជាប់ទំនិញផ្លូវអាកាស (Air Bridge for Air logistic) និងបង្កើតស្ថានីយទំនិញផ្លូវអាកាស (Air Cargo Terminal) បង្កើតរោងជាងជុសជុលអាកាសយាន (Aircraft Maintenance and Repair) សេវាកម្មលាបថ្នាំអាកាសយាន (Aircraft Painting) សេវាកម្មសំអាតអាកាសយាន (Aircraft Cleaning) សាលាបណ្តុះបណ្តាលអាកាសចរស៊ីវិល និងហ្វឹកហ្វឺនអាកាសយានិក (Aviation and Pilot Training School) បង្កើតការហោះហើរកំសាន្ត (Scenery Flight) និងបង្កើតការហោះហើរបែបកីឡា (Sport Flight) ជាដើម ព្រមជាមួយការបំរ៉ុងនិងការរក្សាដីទុកសម្រាប់ការអភិវឌ្ឍមជ្ឈមណ្ឌលអាកាសចរ និងពង្រីកអាកាសដ្ឋាននាពេលអនាគត។

រូបភាពទី១៦÷ ការតភ្ជាប់គោលដៅសំខាន់ៗក្នុងក្របខណ្ឌតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម




(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

ក្នុងក្របខណ្ឌតំបន់ ផែនការមេជំរុញឲ្យមានការតភ្ជាប់ផ្លូវអាកាសពីបណ្តាប្រទេសជិតខាង រួមមានប្រទេសថៃ វៀតណាម និងឡាវ មកកាន់ខេត្តមណ្ឌលគិរី ព្រមជាមួយទីក្រុងសំខាន់ៗរបស់ប្រទេសអាស៊ាន និងប្រទេសផ្សេងទៀតដូចជាប្រទេសជប៉ុន កូរ៉េ និងតំបន់មជ្ឈឹមបូព៌ាជាដើម ដែលប្រើរយៈពេលហោះហើរចន្លោះពី ៥-៧ម៉ោង។

ក្រៅពីនេះ ផែនការមេចង្អុលបង្ហាញឲ្យមានការកែលម្អហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់មួយចំនួន ពិសេសនៅពេលដែលអាកាសយានដ្ឋានខេត្តមណ្ឌលគិរីត្រូវបានសាងសង់ឡើង ដែលរួមមាន÷

- សម្រួលបែបបទស្នើសុំទិដ្ឋាការឲ្យមានលក្ខណៈកាន់តែងាយស្រួល ពិសេសទីផ្សារទេសចរណ៍អន្តរជាតិសំខាន់ៗមួយចំនួនរបស់ប្រទេសថៃ វៀតណាម និងឡាវ (ចិន កូរ៉េ អូស្ត្រាលី អាមេរិក រុស្ស៊ី និងអឺរ៉ុបជាដើម)

- ប្រទេសចិនគឺជាទីផ្សារមួយដ៏សំខាន់សម្រាប់ប្រទេសក្នុងតំបន់ ក៏ដូចសម្រាប់កម្ពុជា ដូចនេះគួរសិក្សាពីគោលនយោបាយទិដ្ឋាការ ពិសេសនៅរដូវកាលដែលមានភ្ញៀវតិចសម្រាប់ភ្ញៀវទេសចរចិន
- រៀបចំសម្ភារទេសចរណ៍មួយចំនួននៅតាមច្រកទ្វារអន្តរជាតិ (នៅពេលដែលមានការតំឡើងកម្រិតច្រកទ្វារទ្វេរភាគីជាច្រកអន្តរជាតិនៅពេលអនាគត) ដូចជាស្លាកសញ្ញា មណ្ឌលព័ត៌មាន អគារអ្នកដំណើរ និងការរៀបចំឱ្យមាន (ASEAN Lane) សម្រាប់ភ្ញៀវទេសចរអាស៊ានជាដើម។

### ៦.២- ការតភ្ជាប់តាមផ្លូវគោក និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ

បច្ចុប្បន្ន ការតភ្ជាប់រវាងប្រទេសទាំង៣ កម្ពុជា ឡាវ និងវៀតណាម គឺត្រូវបានប្រើប្រាស់តាមបណ្ដាញផ្លូវគោកដូចខាងក្រោម÷

- ផ្លូវជាតិលេខ ៧ នៃប្រទេសកម្ពុជា
- ផ្លូវជាតិលេខ ១៣ នៃប្រទេសឡាវ
- ជាមួយទីក្រុងហាណូយ និងទីក្រុងហូជីមិញ តាមរយៈផ្លូវជាតិលេខ ១A។

នេះគឺជាលក្ខខណ្ឌអំណោយផលសម្រាប់ប្រទេសទាំង៣ ក្នុងការពង្រីកការផ្លាស់ប្តូរសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ប៉ុន្តែទន្ទឹមនេះ ចាំបាច់ត្រូវមានការសាងសង់ និងពង្រីកបន្ថែមទៀតនូវបណ្ដាញផ្លូវជាតិតភ្ជាប់សម្រាប់ប្រទេសទាំង៣។ ដូចនេះ ផែនការមេ កំណត់ទិសដៅយុទ្ធសាស្ត្រ ដូចខាងក្រោម÷

- ជំរុញឱ្យមានការសិក្សារៀបចំផ្លូវចរាចរណ៍ល្បឿនលឿន (Highway) តភ្ជាប់មជ្ឈមណ្ឌលទេសចរណ៍នៅតាមបណ្ដាខេត្តនានានៃប្រទេសទាំង៣
- ពង្រីកការតភ្ជាប់ផ្លូវគោកពីបណ្តាខេត្តគោលដៅទេសចរណ៍សំខាន់ៗមួយចំនួនក្នុងប្រទេស (តំបន់ឆ្នេរសមុទ្រ តំបន់សៀមរាប និងរាជធានីភ្នំពេញ) និងបណ្តាប្រទេសជិតខាង (ប្រទេសថៃ វៀតណាម និងឡាវ) មកកាន់ខេត្តមណ្ឌលគិរី ឱ្យបានកាន់តែច្រើនដើម្បីមានភាពងាយស្រួលក្នុងការជំរុញឱ្យមានចលនាទេសចរណ៍ផ្ទៃក្នុង និងជំរុញប្រភេទទេសចរណ៍បើកបរដោយខ្លួនឯង (Self-driving Tourism)
- ជាមួយគម្រោងសាងសង់ព្រលានយន្តហោះខេត្តមណ្ឌលគិរី គួរមានការសិក្សាតំឡើងកម្រិតច្រកព្រំដែនទ្វេភាគីមួយចំនួនក្នុងខេត្តមណ្ឌលគិរីទៅជាច្រកអន្តរជាតិ ដើម្បីឆ្លើយតបនឹងតម្រូវការនៃការធ្វើសមាហរណកម្ម ការពង្រឹងកិច្ចសហប្រតិបត្តិការ ការទាក់ទាញការវិនិយោគ និងលំហូរភ្ញៀវទេសចរប្រទេសទី៣ ដែលឆ្លងកាត់តាមប្រទេសវៀតណាម
- ជាមួយគ្នានេះ គួររៀបចំឱ្យមានចំណតរថយន្ត មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ភ្ជាប់ជាមួយមជ្ឈមណ្ឌលហាងទំនិញនានា និងសម្ភារទ្រទ្រង់ចាំបាច់នានា នៅច្រកចូលក្រុងសែនមនោរម្យដើម្បីផ្តល់ព័ត៌មាន និងជាទីសំចតសម្រាប់រថយន្តទេសចរណ៍ និងអ្នកដំណើរក្នុងការធ្វើដំណើរកម្សាន្តមកកាន់ខេត្តមណ្ឌលគិរី។

### ៦.៣- ការតភ្ជាប់តាមផ្លូវទឹក និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ

សក្តានុពលទេសចរណ៍នៅតាមដងទន្លេស្រែពក និងភាពមិនចេះរីងស្ងួតទាំងរដូវប្រាំង និងរដូវវស្សា ធ្វើឱ្យទន្លេស្រែពកមានសក្តានុពលក្នុងការប្រែក្លាយទៅជាគោលដៅទេសចរណ៍ថ្មីមួយទៀត សម្រាប់ខេត្តមណ្ឌលគិរី ក៏ដូចជាសម្រាប់ភូមិភាគឦសានទាំងមូល ដែលត្រូវមានការគិតគូរ និងទាញយកផលប្រយោជន៍ជាអតិបរមា។

ប៉ុន្តែផ្អែកលើកត្តាទីតាំងភូមិសាស្ត្រជាក់ស្តែង ដងទន្លេស្រែពកសម្បូរទៅដោយល្បាក់ថ្មប៉ប្រ៉ះទឹក ជាពិសេសល្បាក់ថ្មប៉ប្រ៉ះទឹកនៅចំណុចព្រំប្រទល់កម្ពុជា-វៀតណាម ចំណុចកោះម្រេចរហូតដល់ចំណុចប្រសព្វជាមួយទន្លេសេសានដែលបង្កជាឧបសគ្គក្នុងការធ្វើនាវាចរ រាំងស្ទះដល់ការតភ្ជាប់ការធ្វើដំណើរ និងទេសចរណ៍តាមផ្លូវទឹករវាងខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង និងមិនអាចឲ្យនាវាឆ្លងទៅកាន់ប្រទេសវៀតណាមបាន។ ជាមួយគ្នានេះ ដងទន្លេសេសាន ចាប់ពីចំណុចប្រសព្វជាមួយទន្លេស្រែពកទៅដល់ចំណុចប្រសព្វជាមួយទន្លេមេគង្គ សម្បូរទៅដោយថ្មប៉ប្រ៉ះទឹក និងកំណកខ្សាច់ទន្លេជាពិសេសសំណង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលជាឧបសគ្គក្នុងការធ្វើនាវាចរ រាំងស្ទះដល់ការតភ្ជាប់ការធ្វើដំណើរ និងទេសចរណ៍តាមផ្លូវទឹកចូលទៅកាន់ទន្លេមេគង្គ។ ដោយឡែក ដងទន្លេមេគង្គលើ ចាប់ពីចំណុចព្រំប្រទល់កម្ពុជា-ឡាវ ទៅដល់ក្រុងក្រចេះ ក៏សម្បូរទៅដោយថ្មប៉ប្រ៉ះទឹក ដែលជាឧបសគ្គក្នុងការធ្វើនាវាចរ រាំងស្ទះដល់ការតភ្ជាប់ការធ្វើដំណើរ និងទេសចរណ៍តាមផ្លូវទឹកពីក្រុងស្ទឹងត្រែងទីកាន់ក្រុងក្រចេះ ឬតំបន់បឹងទន្លេសាប ឬតំបន់ផ្សេងទៀត និងមិនអាចឲ្យនាវាឆ្លងទៅកាន់ប្រទេសឡាវបានឡើយ។

បញ្ហាខាងលើ បង្កជាឧបសគ្គក្នុងការសាងសង់កំពង់ផែទេសចរណ៍នៅតាមដងទន្លេស្រែពក និងមិនអំណោយផលដល់ការតភ្ជាប់ខេត្តមណ្ឌលគិរីជាមួយបណ្តាខេត្តជុំវិញ និងប្រទេសជិតខាងតាមផ្លូវទឹក។ ប៉ុន្តែយ៉ាងណាក៏ដោយ តំបន់នៅតាមដងទន្លេស្រែពក នៅតែមានសក្តានុពលទេសចរណ៍ផ្សេងទៀត។ ក្នុងន័យនេះ ផែនការមេជំរុញឲ្យមានសិក្សារៀបចំដូចខាងក្រោម÷

- សិក្សាលទ្ធភាពក្នុងការរៀបចំចំណតយន្តហោះនៅលើទឹក (Water Plane or Amphibious Plane) ដែលអាចសិក្សាជំហានដំបូងនៅតំបន់ប្រជុំជននៃស្រុកកោះញែក ដែលជាទីតាំងមានសក្តានុពលសម្រាប់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធនេះ ដែលនឹងជំរុញការតភ្ជាប់ពីតំបន់ភូមិភាគឦសានទៅកាន់តំបន់សមុទ្រ និងតំបន់បឹងទន្លេសាបខេត្តសៀមរាប តាមរយៈយន្តហោះលើទឹកនេះ
- សិក្សារៀបចំឲ្យមានការរៀបចំកញ្ចប់ខ្សែទស្សនកិច្ចតាមដងទន្លេស្រែពក និងបញ្ជ្រាបការយល់ដឹងទៅប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេ និងអាស្រ័យផលតាមដងទន្លេស្រែពក ដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងធនធានធម្មជាតិ និងជីវចម្រុះនៅក្នុងដែនជម្រកសត្វព្រៃស្រែពក ក៏ដូចជាការលើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន និងសាធារណជន ក្នុងការការពារ និងការអភិរក្សជីវចម្រុះ និងធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ប៉ុន្តែត្រូវគិតគូរអំពីហានិភ័យជាយថាហេតុនៃជំនន់ទឹកភ្លៀងផងដែរ។

រូបភាពទី១៧÷ ទិដ្ឋភាពទន្លេស្រែពក និងគំរូចំណតយន្តហោះលើទឹក






(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

## ផ្នែកទី២÷ ការកំណត់យន្តការអនុវត្ត

### ១- ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តផែនការមេ

ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) អាស្រ័យលើការគៀងគរធនធានហិរញ្ញវត្ថុចាំបាច់ ដើម្បីគាំទ្រការអនុវត្តផែនការសកម្មភាព ដែលបានស្នើឡើងក្នុងផែនការមេនេះ។

ប្រភពហិរញ្ញប្បទានទាំងនេះ រួមមាន÷

- **ទី១÷** ថវិកា និងហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល
- **ទី២÷** ថវិកា និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងប្រទេសដៃគូ
- **ទី៣÷** ការចូលរួមរបស់វិស័យឯកជនទាំងក្នុងស្រុក និងក្រៅស្រុក តាមរយៈការវិនិយោគក្រោមទម្រង់នានា ទាំងវិនិយោគសាធារណៈ និងវិនិយោគឯកជន
- **ទី៤÷** ថវិកា និងហិរញ្ញប្បទានពីប្រភពស្របច្បាប់នានា ដែលរួមមាន÷
    + ចំណូលពីការលក់សំបុត្រចូលរមណីយដ្ឋាន និងគោលដៅទេសចរណ៍នានា ដែលគ្រប់គ្រងដោយស្ថាប័នរដ្ឋ
    + ចំណូលផ្សេងៗពីការប្រើប្រាស់សេវា និងសម្បទាទេសចរណ៍នៅតាមរមណីយដ្ឋាន និងគោលដៅទេសចរណ៍នានា ដែលគ្រប់គ្រងដោយស្ថាប័នរដ្ឋ
    + ចំណូលពីការជួល ឬការផ្តល់សម្បទានវិនិយោគនានា

+ មូលនិធិបរិស្ថាន ដែលទទួលបានតាមរយៈការលក់កាបោន ការធ្វើអាជីវកម្មវ៉ែ និងប្រភពពីការប្រើប្រាស់ធនធានធម្មជាតិនានា

+ ប្រភពស្របច្បាប់ផ្សេងទៀត។

យុទ្ធសាស្ត្រជាក់លាក់ពាក់ព័ន្ធនឹងការគៀងគរធនធានហិរញ្ញវត្ថុចាំបាច់ នឹងរៀបចំឡើងដើម្បីធានាប្រសិទ្ធភាព និងសក្តិសិទ្ធភាពក្នុងការអនុវត្តផែនការមេនេះ។

## ២- យន្តការស្ថាប័ន និងអភិក្រមនៃការអនុវត្ត

ការកំណត់យន្តការស្ថាប័នច្បាស់លាស់ គឺជាកត្តាសំខាន់ក្នុងការធានាការអនុវត្តផែនការមេនេះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ក្នុងន័យនេះ ស្ថាប័នអនុវត្តផែនការមេនេះ ត្រូវបានស្នើឲ្យបង្កើតឡើង ដូចខាងក្រោម÷

- **កម្រិតថ្នាក់ជាតិ÷** គណៈកម្មការអន្តរក្រសួងមួយ ត្រូវបានបង្កើតឡើងដើម្បីដឹកនាំ និងសម្របសម្រួលការអនុវត្តផែនការមេនេះ ដោយអាចត្រូវបានកែសម្រួលសមាសភាព និងតួនាទី ភារកិច្ច ចេញពីគណៈកម្មការអន្តរក្រសួងដើម្បីសិក្សារៀបចំផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី និងមានលេខាធិការដ្ឋានមួយដើម្បីធានាដំណើរការការងារប្រចាំថ្ងៃ
- **កម្រិតថ្នាក់ក្រោមជាតិ÷** គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី គឺជាសេនាធិការឲ្យគណៈកម្មការអន្តរក្រសួងខាងលើ ក្នុងការជំរុញការអនុវត្តផែនការមេនេះ
- **យន្តការស្ថាប័នគាំទ្រមួយចំនួន** និងត្រូវបានបង្កើតឡើង ដើម្បីគាំទ្រការអនុវត្តផែនការមេនេះ ដូចជាការបង្កើតអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍អាទិភាពទាំង០៦ខាងលើ (DMO-Destination Management Organization) ដែលមានទម្រង់ជាយន្តការអន្តរក្រសួង និងយន្តការស្ថាប័នចាំបាច់នានា។

គណៈកម្មការអន្តរក្រសួងខាងលើ គឺជាសេនាធិការឲ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងសម្រួលកិច្ចដំណើរការនៃការអនុវត្តផែនការមេ ដោយផ្អែកលើអភិក្រមបុរេសកម្ម ដើម្បីបង្កើតនូវលក្ខខណ្ឌអំណោយផលក្នុងបរិយាកាសបរិយាប័ន្ន ឈរលើទស្សនទាន "ការអភិវឌ្ឍបម្រើការអភិរក្ស ការអភិរក្សទ្រទ្រង់ដល់ការអភិវឌ្ឍ"។

## ៣- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) នឹងត្រូវធ្វើឡើងរៀងរាល់ ៥ឆ្នាំម្តង ដោយគណៈកម្មការអន្តរក្រសួងដែលនឹងត្រូវបង្កើតឡើង ក្នុងនោះ÷

- លើកទី១ នៅឆ្នាំ២០២៥
- លើកទី២ នៅឆ្នាំ២០៣០
- ដោយឡែកលើកទី៣ នៅឆ្នាំ២០៣៥ ដើម្បីបូកសរុបលទ្ធផលនៃការអនុវត្តផែនការមេ និងដាក់ចេញនូវផែនការសម្រាប់រយៈពេលបន្ទាប់។

ការត្រួតពិនិត្យនៅដំណាក់កាលទី១ និងទី២ ត្រូវផ្តោតលើចំណុចសំខាន់ៗដើម្បីជាមូលដ្ឋានកែតម្រូវ និងតម្រង់ទិសក្នុងការអនុវត្តបន្ត ដោយផ្តោតលើ÷

- ការធ្វើបច្ចុប្បន្នភាពសភាពការណ៍វិស័យទេសចរណ៍ពិភពលោក តំបន់ និងវិស័យទេសចរណ៍កម្ពុជា
- ការធ្វើបច្ចុប្បន្នភាពសភាពការណ៍ និងការវិវត្តនៃវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី
- ការធ្វើបច្ចុប្បន្នភាពតំបន់សម្រាប់ការអភិវឌ្ឍជាអាទិភាព ដែលបានកំណត់ក្នុងផែនការមេ
- ការធ្វើបច្ចុប្បន្នភាពគម្រោងអាទិភាពនានា ដែលបានកំណត់ក្នុងផែនការមេ។

### ៤- ការគ្រប់គ្រងហានិភ័យដើម្បីត្រៀមដាក់ចេញសេណារីយ៉ូកែតម្រូវ

ក្រៅពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដូចបានគិតគូរខាងលើ ប្រសិទ្ធភាពនៃការអនុវត្ត "ផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី" ក៏អាស្រ័យផងដែរលើការប្រែប្រួលនៃសភាពការណ៍សាកលលោក និងតំបន់ដែលអាចបង្កជាហានិភ័យ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ និងត្រៀមលក្ខណៈដោះស្រាយ ដែលរួមមាន÷

**- ទី១- ហានិភ័យពាក់ព័ន្ធនឹងភាពងាយរងគ្រោះនៃវិស័យទេសចរណ៍សាកលលោក**

លំហូរភ្ញៀវទេសចរអន្តរជាតិដោយផ្ទាល់មកកាន់ខេត្តមណ្ឌលគិរី ត្រូវបានប្រមើលមើលថាជាក្តីសង្ឃឹមដ៏សំខាន់នៃការអភិវឌ្ឍព្រលានយន្តហោះខេត្តមណ្ឌលគិរី។ ប៉ុន្តែដូចបានបង្ហាញនៅផ្នែកខាងលើ បញ្ហាជាសាកលនានាដែលបានចោតឡើង ដូចជាការថយចុះកំណើនសេដ្ឋកិច្ចតំបន់អ៊ឺរ៉ុប សំណុំរឿង Brexit សង្គ្រាមពាណិជ្ជកម្ម និងជំលោះសេដ្ឋកិច្ចរវាងប្រទេសមហាអំណាច បញ្ហាបម្រែបម្រួលអាកាសធាតុ និងបញ្ហាសាកលមួយចំនួនទៀត បានធ្វើឱ្យស្ថានភាពវិស័យទេសចរណ៍សាកលលោក និងតំបន់ ប្រឈមនឹងកំណើនមិនប្រាកដប្រជាក្នុងឆ្នាំ២០២០ និងបណ្តាឆ្នាំខាងមុខ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់វិស័យទេសចរណ៍កម្ពុជានិយាយជារួម និងវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី និយាយដោយឡែក។

**- ទី២- ហានិភ័យពាក់ព័ន្ធនឹងការកើតឡើងនៃវិបត្តិសាកលដែលមិនអាចគ្រោងទុកបាន**

ឆ្នាំ២០២០ ត្រូវបានចាត់ទុកជាឆ្នាំដ៏លំបាកបំផុតសម្រាប់ពិភពលោក។ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ពិភពលោកលើគ្រប់វិស័យ រួមទាំងវិស័យទេសចរណ៍ផងដែរ។ សម្រាប់កម្ពុជាក្នុងឆ្នាំ២០២០កន្លងមកនេះ វិស័យទេសចរណ៍ បានទទួលរងនូវកំណើនអវិជ្ជមាន និងត្រូវបានព្យាករណ៍ក្រោមសេណារីយ៉ូប្រែប្រួលផ្សេងៗសម្រាប់ឆ្នាំបន្តបន្ទាប់។ ទេសចរណ៍កម្ពុជា ប្រហែលត្រូវចំណាយពេលវេលាពី ៣-៥ឆ្នាំ ដើម្បីវិលមករកស្ថានការណ៍ដូចដើមវិញ។ បទពិសោធន៍នៃការរក្សាកំណើនទេសចរណ៍នាអំឡុងវិបត្តិជំងឺ SARS នៅឆ្នាំ២០០៣ ក៏មិនអាចត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពក្នុងបរិបទនៃជំងឺកូវីដ-១៩នេះ។ ក្នុងន័យនេះ វិស័យទេសចរណ៍កម្ពុជា រួមទាំងវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ត្រូវត្រៀមខ្លួនទប់ទល់ និងសម្របខ្លួនជាមួយវិបត្តិជាសាកលនានា ដែលអាចកើតមានឡើងជាយថាហេតុ ដែលឃ្លាតពីគន្លងនៃការព្យាករណ៍ និងការគិតគូរ។

**- ទី៣- ហានិភ័យពាក់ព័ន្ធនឹងកត្តាបម្រែបម្រួលធម្មជាតិ**

ខណៈពេលដែលអាកាសធាតុនៅលើផែនដីបានឆ្លងកាត់អំឡុងពេលនៃការប្រែប្រួល ភ័ស្តុតាងតាមបែបវិទ្យាសាស្ត្រសម័យទំនើបបានបង្ហាញអំពីការកើនឡើងដ៏ឆាប់រហ័សនៃបញ្ហាបម្រែបម្រួលអាកាសធាតុនៅទូទាំងពិភពលោក ដែលកើតចេញពីសកម្មភាពផលិតកម្ម ការធ្វើឧស្សាហូបនីយកម្ម ការថយចុះនៃបរិមាណព្រៃឈើ និងបម្រែបម្រួលនៃការប្រើប្រាស់ដីជាដើម។ បញ្ហានេះបានបង្កើតជាហានិភ័យមិនអាចគ្រោងទុកបានជាច្រើន ដូចជាបាតុភូតធម្មជាតិប្រែប្រួលមិនទៀងទាត់ ភាពរាំងស្ងួត ការកើនឡើងរលកកំដៅ ភ្លើងឆេះព្រៃ ខ្យល់ព្យុះ និងគ្រោះទឹកជំនន់ជាដើម ដែលទាំងអស់នេះបានបង្កជាផលប៉ះពាល់ទៅដល់កិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចនានា រួមទាំងវិស័យទេសចរណ៍ផងដែរ។

ផ្អែកលើការតាមដាន និងត្រួតពិនិត្យការអនុវត្តជាប្រចាំនូវផែនការមេនេះ សេណារីយ៉ូផ្សេងៗពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី នឹងត្រូវបានសិក្សារៀបចំ និងកែតម្រូវ ពិសេសនាឱកាសត្រួតពិនិត្យ និងវាយតំលៃការអនុវត្តផែនការមេនៅដំណាក់កាលទី១ និងទី២។

រាជរដ្ឋាភិបាល នឹងខិតខំគ្រប់គ្រង និងដោះស្រាយហានិភ័យ និងបញ្ហាប្រឈមនានា ដើម្បីធានាប្រសិទ្ធភាព និងសក្តិសិទ្ធិភាពក្នុងការអនុវត្តផែនការមេ សម្រេចបានតាមចក្ខុវិស័យដែលបានកំណត់ ដោយឈរលើភាពបត់បែន និងអភិក្រមបុរេសកម្ម។

## សេចក្តីសន្និដ្ឋាន

ប្រៀបប្រដូចនឹងគ្រាប់ពេជ្រសម្រាប់ភូមិភាគឦសាន មណ្ឌលគីរីត្រូវបានចាត់ទុកជាខេត្តពោរពេញទៅដោយសក្តានុពលសម្រាប់ការអភិវឌ្ឍទេសចរណ៍ ទាំងបែបធម្មជាតិ និងវប្បធម៌ ដែលមាននៅពាសពេញ និងមិនទាន់ត្រូវបានប្រើប្រាស់អស់លទ្ធភាព។ ឧត្តមភាពនៃវិស័យទេសចរណ៍ គឺជាកាតាលីករដ៏សំខាន់ក្នុងការលើកស្ទួយសេដ្ឋកិច្ច ការអភិរក្សធនធានធម្មជាតិ វប្បធម៌ បរិស្ថាន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនក្នុងខេត្តដែលធ្លាប់តែដាច់ស្រយាលមួយនេះ។

ទស្សនទាន "**ការអភិវឌ្ឍបម្រើការអភិរក្ស ការអភិរក្សទ្រទ្រង់ដល់ការអភិវឌ្ឍ**" គឺជាឆ្អឹងកងមិនអាចខ្វះបានដើម្បីធានាការអភិវឌ្ឍមួយដែលមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយត្រឹមត្រូវ ឈរលើគុណតម្លៃធម្មជាតិ វប្បធម៌ សង្គម និងការតម្កល់ប្រយោជន៍ប្រជាជន និងប្រជាជាតិជាធំ។

ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តផែនការមេនេះ គឺអាស្រ័យលើការចូលរួម និងសហការស្អិតរមួតស៊ីជម្រៅ និងការទទួលខុសត្រូវរវាងភាគីពាក់ព័ន្ធនានា ជាពិសេសភាពជាដៃគូ "**រដ្ឋ-ឯកជន-ប្រជាពលរដ្ឋ**" ក្រោមមជ្ឈដ្ឋានសាកលភាវូបនីយកម្ម ដែលពោរពេញដោយភាពមិនច្បាស់លាស់ និងការប្រកួតប្រជែងខ្ពស់។

ឈរលើមូលដ្ឋានទាំងអស់នេះ ការរៀបចំផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគីរី ចក្ខុវិស័យ (២០២១-២០៣៥) គឺជាត្រីវិស័យ និងផែនទីបង្ហាញផ្លូវដ៏សំខាន់ជំរុញការអភិវឌ្ឍតំបន់ភូមិភាគឦសានជាប៉ូលសេដ្ឋកិច្ចទី៤របស់កម្ពុជា បង្កើតកាលានុវត្តថ្មី រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ក្នុងឆន្ទៈដ៏មុះមុត និងការប្តេជ្ញាចិត្តច្បាស់លាស់របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

ជារួម ផែនការមេដែលមានលក្ខណៈសមាហរណកម្មជាមួយវិស័យគាំទ្រនានានេះ តម្រង់ចក្ខុវិស័យទៅរកការសម្រេចមហិច្ឆតាអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគីរី ជាគោលដៅទេសចរណ៍លំដាប់ពិភពលោក ធានាបានផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន និងការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌ ក្នុងក្តីសង្ឃឹមប្រកបដោយសុទិដ្ឋិនិយមថា ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ឧត្តមានុវត្តន៍ និងការទទួលខុសត្រូវនៃវិស័យទេសចរណ៍ នឹងបង្កើតបានជាផលប្រយោជន៍សេដ្ឋកិច្ចសង្គមដល់ប្រជាពលរដ្ឋមូលដ្ឋានទូទាំងខេត្ត និងរួមចំណែកយ៉ាងសំខាន់ដល់ការថែរក្សាការពារ និងអភិរក្សធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ រក្សាបាននូវអត្តសញ្ញាណដើម ព្រមទាំងជំរុញការអភិវឌ្ឍ "**កម្ពុជា÷ ព្រះរាជាណាចក្រអច្ឆរិយៈ**"៕

## ឧបសម្ព័ន្ធ ក៖ តារាងផែនការសកម្មភាពអនុវត្តផែនការមេ

* រយៈពេលមធ្យម គឺត្រូវបានកំណត់ចាប់ពី ឆ្នាំ២០២១-២០២៥
* រយៈពេលវែង គឺត្រូវបានកំណត់ចាប់ពីក្រោយ ឆ្នាំ២០២៥

<table>
<tr><th>ផែនការសកម្មភាព</th><th>រយៈពេល</th><th>ស្ថាប័នដឹកនាំ<br>អនុវត្តផែនការមេ</th><th>ស្ថាប័នទទួលខុសត្រូវអនុវត្ត</th></tr>
<tr><td colspan="4">១). ការកំណត់តំបន់ទេសចរណ៍អាទិភាពសម្រាប់ការអភិវឌ្ឍ</td></tr>
<tr><td>- រៀបចំឯកសារ និងបទដ្ឋានគតិយុត្តកំណត់តំបន់អាទិភាពសំខាន់ៗទាំង០៦ ដែលត្រូវរក្សាទុកសម្រាប់ការអភិវឌ្ឍ រួមមាន÷ ១). តំបន់របៀងអេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិនៃដែនជម្រកសត្វព្រៃទាំង០៥ ២). តំបន់របៀងទេសចរណ៍វប្បធម៌ និងអេកូទេសចរណ៍ប៊ូស្រា-ដាក់ដាំ ៣). ក្រុងសែនមនោរម្យ ៤). តំបន់ស្រុកអូររាំង ៥). តំបន់ប្រជុំជននៃស្រុកកោះញែក និង ៦). តំបន់ទេសចរណ៍សមាហរណតាមច្រកព្រំដែន។</td><td rowspan="3">២០២១<br>ទៅមធ្យម</td><td rowspan="3">- គណៈកម្មការអន្តរក្រសួងដឹកនាំ និងសម្របសម្រួលការអនុវត្តផែនការមេ (គ.អ.ជ.ស)</td><td rowspan="3">- ក្រសួងទេសចរណ៍<br>- លេខាធិការដ្ឋានគណៈកម្មការអន្តរក្រសួង (គ.អ.ជ.ស)</td></tr>
<tr><td>- សិក្សាបង្កើតអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (Sub DMO-Destination Management Organization) សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍតំបន់អាទិភាពទាំង០៦ខាងលើ។</td></tr>
<tr><td>- សិក្សារៀបចំគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍ និងវិនិយោគក្នុងតំបន់អាទិភាពទាំង០៦។</td></tr>
<tr><td colspan="4">២). ការអភិវឌ្ឍផលិតផលទេសចរណ៍ និងវិនិយោគក្នុងវិស័យទេសចរណ៍</td></tr>
<tr><td colspan="4">២.១. ការជំរុញការវិនិយោគសម្បទានទ្រង់ទ្រាយធំសំខាន់ៗសម្រាប់វិស័យទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី</td></tr>
<tr><td>- ជំរុញ និងលើកទឹកចិត្តឱ្យមានការអភិវឌ្ឍសេវាស្នាក់នៅបន្ថែម ទាំងសណ្ឋាគារ ផ្ទះសំណាក់ អេកូឡូតប៊ីងហ្គាឡូ ម៉ូតែល ជាពិសេសការវិនិយោគលើសណ្ឋាគារលំដាប់ផ្កាយ៤ ផ្កាយ៥ សាលប្រជុំកម្រិតខ្ពស់ ទីលានវាយកូនហ្គោល សួនកម្សាន្ត សួនសត្វ និងសកម្មភាពទេសចរណ៍ផ្សេងៗ ដែលអាចទាក់ទាញភ្ញៀវទេសចរលំដាប់ខ្ពស់ ចំណាយច្រើន និងស្នាក់នៅបានយូរ។</td><td>២០២១<br>ទៅមធ្យម</td><td>- គ.អ.ជ.ស</td><td>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងទេសចរណ៍</td></tr>
</table>

| | | | |
|---|---|---|---|
| - សិក្សារៀបចំឱ្យមានការសាងសង់ និងកែលម្អពហុកីឡាដ្ឋានក្នុងខេត្ត និងតំបន់ដែលអាចបម្រើដល់ការរៀបចំជាព្រឹត្តិការណ៍កីឡា ក៏ដូចជាព្រឹត្តិការណ៍កីឡាទេសចរណ៍នានា។ | ២០២១ ទៅមុខ | - គ.អ.ជ.ស | - ក្រសួងអប់រំ យុវជន និងកីឡា<br>- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា<br>- ក្រសួងទេសចរណ៍ |
| - សិក្សារៀបចំផ្សាររាត្រីឱ្យមានលក្ខណៈស្តង់ដា ធានាបាននូវសណ្តាប់ធ្នាប់ល្អ និងមានសកម្មភាពសម្បូរបែប ព្រមជាមួយវិថីម្ហូបអាហារមួយ ដែលអាចនឹងត្រូវបានរៀបចំឡើងនៅតាមបណ្តោយវិថីក្នុងក្រុងសែនមនោរម្យ (ជាប់នឹងរង្វង់មូលគោព្រៃ)។<br>- ជំរុញ និងលើកទឹកចិត្តឱ្យមានការបង្កើតសេវាកម្ម និងសម្បទាទេសចរណ៍ផ្សេងៗ ដូចជាភោជនីយដ្ឋានអាហារដ្ឋានទេសចរណ៍ សេវាកម្មកម្សាន្តមនុស្សពេញវ័យ (ខារ៉ាអូខេ រង្គសាល ក្លឹប និងបៀរហ្គាឌិន) និងសេវាកម្សាន្តនានា ដោយត្រូវកំណត់តំបន់ (Zoning) ឱ្យបានច្បាស់លាស់។ | ២០២១ ទៅមុខ | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| **២.២. ការអភិវឌ្ឍសហគមន៍ទេសចរណ៍ អេកូទេសចរណ៍ និងទេសចរណ៍បៃតង** | | | |
| - ជំរុញការវិនិយោគអេកូទេសចរណ៍ខ្នាតតូចនៅក្នុងតំបន់ដែនជម្រកសត្វព្រៃ និងសិក្សាបញ្ចូល សកម្មភាពទេសចរណ៍ទៅក្នុងសហគមន៍ដែលមានសក្តានុពល ដើម្បីប្រែក្លាយទៅជាសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍។<br>- ជំរុញឱ្យមានសកម្មភាពទេសចរណ៍ផ្សងព្រេងបែបកម្សាន្ត រួមជាមួយការអភិវឌ្ឍទេសចរណ៍ កីឡាដែលមានលក្ខណៈផ្សងព្រេង ដូចជាការជិះកង់ក្នុងព្រៃ ការឡើងភ្នំ និងប្រភេទកីឡាផ្សេងៗ ។ | ២០២១ ទៅមុខ | - គ.អ.ជ.ស | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍<br>- ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |
| **២.៣. ការជំរុញការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍** | | | |
| - ជំរុញឱ្យមានការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍បែបកែច្នៃឱ្យបានច្រើនបន្ថែមពីលើរមណីយដ្ឋាន | ២០២១ | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍ |

| | | | |
|---|---|---|---|
| ទេសចរណ៍ដែលមានស្រាប់។ | ទៅមធ្យម | | - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |
| - រៀបចំផែនទីបង្ហាញគោលដៅទេសចរណ៍ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ភ្ញៀវទេសចរ។ | ២០២១<br>ទៅមធ្យម | - គ.អ.ជ.ស | - គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |
| **២.៤. ការរៀបចំព្រឹត្តិការណ៍ទេសចរណ៍** | | | |
| - សិក្សារៀបចំជាព្រឹត្តិការណ៍ទេសចរណ៍ និងព្រឹត្តិការណ៍កីឡានានា ដែលអាចជាព្រឹត្តិការណ៍រៀបចំជាលក្ខណៈរដូវកាល ឬជាលក្ខណៈទៀងទាត់ ដូចជាពិធីបុណ្យអេកូទេសចរណ៍ ពិធីបុណ្យដំរី និងពិធីបុណ្យជនជាតិភាគតិចជាដើម។ | ២០២១<br>ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |
| **២.៥. ការអភិវឌ្ឍទេសចរណ៍វ័យចំណាស់ ទេសចរណ៍សុខភាព និងទេសចរណ៍ផ្ទះទី២** | | | |
| - ជំរុញការអភិវឌ្ឍតំបន់ទេសចរណ៍ពិសិដ្ឋ ព្រមជាមួយនឹងការរៀបចំជាតំបន់រមណីយដ្ឋានសមាហរណ ដែលរួមបញ្ចូលនូវសកម្មភាព និងគោលនយោបាយលើកទឹកចិត្តជាពិសេស។ | មធ្យម<br>ទៅវែង | - គ.អ.ជ.ស | - គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍<br>- ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - សិក្សារៀបចំគោលនយោបាយពិសេស ដើម្បីជំរុញឲ្យភ្ញៀវទេសចរអន្តរជាតិមានលទ្ធភាពក្នុងការទិញអចលនទ្រព្យក្នុងកម្រិតណាមួយ និងមានសិទ្ធិប្រើប្រាស់អចលនទ្រព្យនោះក្នុងអំឡុងពេលស្នាក់នៅកម្ពុជា។ | ២០២១<br>ទៅវែង | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| - រៀបចំឲ្យមានទីតាំង ឬកន្លែងសមស្របណាមួយ សម្រាប់រៀបចំផលិតផលទេសចរណ៍បែបសមាធិ ដើម្បីទាក់ទាញភ្ញៀវទេសចរបន្ថែម។ | ២០២១<br>ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ |

| ៣). ការពង្រឹងគុណភាពទេសចរណ៍ និងធនធានមនុស្សគាំទ្រ | | | |
|---|---|---|---|
| **៣.១. ការពង្រឹងគុណភាពទេសចរណ៍** | | | |
| - សម្រេចឲ្យបានយុទ្ធនាការ "សេវាមួយ ស្តង់ដាមួយ" នៅគ្រប់មូលដ្ឋានអាជីវកម្មទេសចរណ៍។<br>- ជំរុញ និងលើកទឹកចិត្តឲ្យមានការបង្កើតក្រុមហ៊ុនទេសចរណ៍ និងការីទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី ដើម្បីជំរុញដល់ការរៀបចំកញ្ចប់ខ្សែទស្សនកិច្ចក្នុងខេត្ត។ | ២០២១ ទៅមុខ | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |
| - ជំរុញ និងលើកទឹកចិត្តការអភិវឌ្ឍហាងលក់វត្ថុអនុស្សាវរីយ៍ និងទប់ស្កាត់ការលក់វត្ថុអនុស្សាវរីយ៍ក្លែងបន្លំគុណភាព និងការលក់ក្នុងតម្លៃថ្លៃហួសហេតុ ដែលធ្វើឱ្យផលប៉ះពាល់ដល់ទំនុកចិត្តភ្ញៀវទេសចរ។ | ២០២១ ទៅមុខ | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| **៣.២. ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍** | | | |
| - ផ្តល់អាទិភាពដល់ការសិក្សាបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ឬវិទ្យាស្ថានទេសចរណ៍ប្រចាំខេត្តមណ្ឌលគិរី ដែលអាចជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ប្រចាំតំបន់ភូមិភាគឦសាន ក្នុងការពង្រឹងគុណភាពសម្រាប់វិស័យទេសចរណ៍។ | ២០២១ ទៅមុខ | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - សិក្សាលទ្ធភាពបង្កើតសាកលវិទ្យាល័យជាតិមួយនៅមណ្ឌលគិរី ដែលផ្តល់ការអប់រំ និងបណ្តុះបណ្តាលលើពហុជំនាញ ក៏ដូចជាតំបន់ភូមិភាគឦសានទាំងមូល។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - សម្រេចឲ្យបានយុទ្ធនាការ "បុគ្គលិកម្នាក់ ជំនាញមួយ" ដោយបុគ្គលិកទាំងអស់ដែលបម្រើការងារក្នុងវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ត្រូវទទួលបានការបណ្តុះបណ្តាលដែលមានលក្ខណៈស្តង់ដា និងអាចធ្វើការបំលាស់ទីពីតំបន់មួយទៅតំបន់មួយទៀត ព្រមជាមួយការជំរុញការបណ្តុះបណ្តាលផ្ទៃកខាងក្នុង (In-House Training) ដែលមានការទទួលស្គាល់ដោយក្រសួងទេសចរណ៍ និងកម្រិតអាស៊ាន។<br>- ដាក់ចេញកម្មវិធីហាត់ការតាមមូលដ្ឋានអាជីវកម្ម ដោយលើកទឹកចិត្តឲ្យមូលដ្ឋានអាជីវកម្ម និងសេវាកម្ម | ២០២១ ទៅមុខ | -គ.អ.ជ.ស | - គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី<br>- ក្រសួងទេសចរណ៍ |

| | | | |
|---|---|---|---|
| ទាំងអស់ ទទួលយកសិស្ស-និស្សិតទៅបម្រើការ ដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍។<br>- រៀបចំផែនការបណ្ដុះបណ្ដាលរយៈពេលខ្លី មធ្យម និងរយៈពេលវែង សម្រាប់គ្រប់មជ្ឈដ្ឋានទាំងអស់ ពិសេសសិស្ស-និស្សិត អ្នកមានតម្រូវការការងារ បុគ្គលិក អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ ក៏ដូចជាការបណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ខេត្ត ថ្នាក់តំបន់ និងមគ្គុទ្ទេសក៍ក្នុងស្រុក ដើម្បីពង្រឹងសមត្ថភាពឆ្លើយតបទៅនឹងការវិវត្តន៍នៃសង្គម និងវិស័យទេសចរណ៍។ | | | |
| - ជំរុញឱ្យមានមគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍ ជាពិសេសនៅក្នុងតំបន់ដែនជម្រកសត្វព្រៃ និងតំបន់អភិរក្ស ដោយលើកទឹកចិត្តការប្រើប្រាស់មន្ត្រីឧទ្យានុរក្ស និងប្រជាពលរដ្ឋមូលដ្ឋាន។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន |
| **៤). ការផ្សព្វផ្សាយ និងការពង្រឹងរូបភាពវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី** | | | |
| **៤.១. ការរៀបចំអត្តសញ្ញាណ (Branding) ខេត្តមណ្ឌលគិរី** | | | |
| - សិក្សារៀបចំឱ្យមានអត្តសញ្ញាណផ្សព្វផ្សាយសម្រាប់ខេត្តមណ្ឌលគិរី ដែលជាការគាំទ្រទៅដល់យុទ្ធនាការផ្សព្វផ្សាយកម្ពុជា "កម្ពុជា៖ ព្រះរាជាណាចក្រអច្ឆរិយៈ"។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |
| **៤.២. ការជំរុញការផ្សព្វផ្សាយខេត្តមណ្ឌលគិរីតាមគ្រប់រូបភាព** | | | |
| - ជំរុញការផ្សព្វផ្សាយបែបលក្ខណៈធម្មតា (Traditional Marketing) រួមមានការផលិតឧបករណ៍ផ្សព្វផ្សាយនានា ដូចជាសៀវភៅមគ្គុទ្ទេសក៍ ប័ណ្ណផ្ទត់ ឬខិត្តប័ណ្ណ ដើម្បីផ្សព្វផ្សាយអំពីសក្ដានុពលទាំងអស់ក្នុងខេត្តមណ្ឌលគិរី។<br>- រៀបចំកន្លែងសម្រាប់បង្ហាញពាក្យស្លោក សម្គាល់ពីអត្តសញ្ញាណខេត្តមណ្ឌលគិរី ដោយភ្ញៀវទេសចរអាចធ្វើការថតរូបកម្សាន្ត ដូចជាស្លាក "**ខ្ញុំស្រលាញ់ខេត្តមណ្ឌលគិរី**" ជាដើម។<br>- ជំរុញការផ្សព្វផ្សាយតាមបែបឌីជីថល ដោយការប្រើប្រាស់បណ្ដាញសង្គមនានា ដូចជា Facebook, Twitter, Instagram និងបណ្ដាញសង្គមផ្សេង និងការរៀបចំឱ្យមានជាកម្មវិធីទូរស័ព្ទ (Mobile App) ឬគេហទំព័រ ដែលអាចផ្សព្វផ្សាយ និងអនុញ្ញាតឱ្យភ្ញៀវទេសចរទទួលបានព័ត៌មានងាយស្រួលពីចំងាយ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |

| | | | |
|---|---|---|---|
| និងចំណាយថវិកាតិច។ | | | |
| - ផ្សព្វផ្សាយ និងលើកទឹកចិត្តឲ្យមានការថតភាពយន្ត ទាំងភាពយន្តជាលក្ខណៈជាតិ និងអន្តរជាតិ ក៏ដូចជាកម្មវិធីរបស់បណ្តាញទូរទស្សន៍ និងសារព័ត៌មានល្បីៗជុំវិញពិភពលោក។ | ២០២១ ទៅមុខ | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| - លើកទឹកចិត្តឲ្យយុវជន សិស្ស-និស្សិត និងសាធារណជន ចូលរួមការប្រឡងប្រណាំងនានា ដូចជាការប្រឡងប្រណាំងវីដេអូ និងរូបភាពក្រោមប្រធានបទផ្សេងៗទាក់ទងនឹងសក្តានុពលទេសចរណ៍ខេត្តមណ្ឌលគិរី។ | ២០២១ ទៅមុខ | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |
| **៥). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍** | | | |
| **៥.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងសម្បទាទ្រទ្រង់ក្នុងខេត្ត** | | | |
| - សិក្សាជួសជុល និងកែលម្អបណ្តាញផ្លូវតភ្ជាប់ក្រុងសែនមនោរម្យទៅកាន់គោលដៅទេសចរណ៍សំខាន់ៗក្នុងខេត្ត។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - សិក្សាអភិវឌ្ឍផ្លូវតភ្ជាប់តំបន់រមណីយដ្ឋានប៊ូស្រា មកឃុំដាក់ដាំ ដោយសារតំបន់ទាំងពីរនេះ ស្ថិតនៅក្នុងចក្ខុវិស័យនៃរបៀងអេកូទេសចរណ៍ប៊ូស្រា-ដាក់ដាំ ដូចបានបង្ហាញក្នុងយុទ្ធសាស្ត្រគោលទី១។ | | | |
| - សិក្សាជួសជុល និងកែលម្អបណ្តាញផ្លូវក្នុងក្រុងសែនមនោរម្យឲ្យស្របតាមស្តង់ដា ដោយរៀបចំឲ្យមានជាផ្លូវជិះកង់អមសងខាងផ្លូវ ផ្លូវថ្មើរជើងសម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ ធ្វើដំណើរ និងត្រូវបំពាក់អំពូលភ្លើងបំភ្លឺផ្លូវនៅទីសាធារណៈ។ តំបន់មួយចំនួនគួររៀបចំជាសួនច្បារអមសងខាងផ្លូវដើម្បីបង្កើនសោភ័ណភាព និងភាពស្អាតបន្ថែមទៀតសម្រាប់ទាក់ទាញភ្ញៀវទេសចរ។ | | | |
| - សិក្សារៀបចំឲ្យមានចំណតរថយន្តសាធារណៈមួយក្នុងក្រុងដើម្បីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រងលំហូរចូលនៃភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរី និងដើម្បីរក្សាសណ្តាប់ធ្នាប់។ | | | |
| - សិក្សារៀបចំឲ្យមានសេវារថយន្តក្រុងសាធារណៈ សម្រាប់ការធ្វើដំណើរក្នុងក្រុងសែនមនោរម្យ និងតភ្ជាប់ទៅកាន់តំបន់សំខាន់ៗក្នុងខេត្ត។ | | | |
| - គិតគូរបន្ថែមអំពីការជួសជុល និងស្ថាបនាផ្លូវទៅកាន់តំបន់សំខាន់ៗ ពិសេសផ្លូវតភ្ជាប់ក្រុងសែន | | | |

| | | | |
|---|---|---|---|
| មនោរម្យទៅតំបន់ស្រុកអូររាំង ដែលជាទីតាំងគម្រោងសាងសង់ព្រលានយន្តហោះខេត្តមណ្ឌលគិរីនាពេលអនាគត។ | | | |
| - ដាក់ស្លាកសញ្ញាបង្ហាញទីតាំងក្នុងក្រុង និងស្លាកសញ្ញាបង្ហាញគោលដៅទេសចរណ៍សំខាន់ៗ ដើម្បីផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរក្នុងការទៅកម្សាន្តគោលដៅទេសចរណ៍ដែលមានសក្តានុពល។ | | | |
| - កែលម្អសោភ័ណភាពតំបន់រង្វង់មូលគោព្រៃដែលចាត់ទុកជាបេះដូង និងជាចំណុចកណ្តាលរបស់ខេត្តមណ្ឌលគិរី និងជាអត្តសញ្ញាណបង្ហាញពីលក្ខណៈពិសេសរបស់ខេត្តមណ្ឌលគិរី ដោយរៀបចំឱ្យមានសណ្តាប់ធ្នាប់ក្នុងការចតរថយន្ត រួមជាមួយការដាំដើមឈើនៅអមសង ខាងផ្លូវ និងនៅបរិវេណទ្រូងផ្លូវជាដើម។ | | | |
| - ជំរុញឱ្យមានការអភិវឌ្ឍជាសួនច្បារ និងតំបន់បៃតង ផ្សារភ្ជាប់ជាមួយនឹងតំបន់សួនច្បារអតីតព្រលានយន្តហោះជាប់នឹងរង្វង់មូលគោព្រៃ ដែលអាចឱ្យភ្ញៀវទេសចរ និងប្រជាពលរដ្ឋក្នុងខេត្តដើរកម្សាន្តស្រូបយកខ្យល់អាកាសបរិសុទ្ធ ហាត់ប្រាណ និងជួបជុំគ្នា។ | | | |
| - កែលម្អមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ដែលស្ថិតនៅតំបន់សួនច្បារជិតរង្វង់មូលគោព្រៃឱ្យមានសម្ភារគ្រប់គ្រាន់ស្របតាមស្តង់ដាក្រសួងទេសចរណ៍។ | ២០២១ ទៅមធ្យម | - គ.អ.ដ.ស | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |
| - គិតគូរអភិវឌ្ឍបន្ថែមនៅតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រភ្នំដោះក្រមុំ លើផ្នែកសោភ័ណភាព ការរៀបចំសណ្តាប់ធ្នាប់ ការរក្សាបាននូវភាពបៃតង ការដាំដើមឈើបន្ថែម និងជំរុញការកំណត់ព្រំដីតំបន់នេះឱ្យបានច្បាស់លាស់ ដើម្បីទប់ស្កាត់ការទន្ទ្រាន។ | ២០២១ ទៅមធ្យម | - គ.អ.ដ.ស | - ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ជំរុញឱ្យមានការរៀបចំរចនាបថលំនៅដ្ឋាន ការធ្វើរបងលំនៅដ្ឋាន របងដីឡូតិ៍ ដោយរក្សាបាននូវសោភ័ណ្ឌភាព ទេសភាពធម្មជាតិ សណ្តាប់ធ្នាប់ និងរបៀបរៀបរយត្រឹមត្រូវ។ | ២០២១ ទៅមធ្យម | - គ.អ.ដ.ស | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| **៥.២. ការប្រើប្រាស់ និងការផ្គត់ផ្គង់ទឹកស្អាត** | | | |
| - ត្រឹមឆ្នាំ២០៣០ ប្រជាជនរស់នៅតំបន់ទីប្រជុំជន និងជនបទសម្រេចបាននូវការទទួលបានសាកលកម្ម | ២០២១ | - គ.អ.ដ.ស | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ |

| | | | |
|---|---|---|---|
| និងសមធម៌នូវទឹកបរិភោគដែលមានសុវត្ថិភាព និងតម្លៃសមរម្យសម្រាប់ប្រជាជនទាំងអស់។ | ទៅវែង | | បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងអភិវឌ្ឍន៍ជនបទ |
| - ចាត់វិធានការរក្សាការពារឲ្យបាននូវប្រភពទឹកដែលមានស្រាប់ ពិសេសប្រភពទឹកជៅទាំង០២ទីតាំងក្នុងក្រុងសែនមនោរម្យ ព្រមជាមួយការរៀបចំកែលម្អផ្លូវជុំវិញប្រភពទឹក ការរៀបចំសួនច្បារនៅជុំវិញ និងទប់ស្កាត់កុំឲ្យមាននូវការសាងសង់សំណង់ និងការបង្ហូរសំណល់រាវ និងបោះចោលសំរាមទៅក្នុងប្រភពទឹកទាំង២។ | ២០២១<br>ទៅវែង | - គ.អ.ជ.ស | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងធនធានទឹក និងឧតុនិយម<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - បង្កើនសមត្ថភាពផលិត និងពង្រីកតំបន់សេវាកម្មតាមការណែនាំរបស់ក្រសួងអាណាព្យាបាល នៅតាមស្រុកទាំង ៤ ដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយនិរន្តរភាព និងឆ្លើយតបតាម ចក្ខុវិស័យនៃការអភិវឌ្ឍនៅតាមស្រុកទាំង០៤ នាពេលអនាគត។ | មធ្យម<br>ទៅវែង | - គ.អ.ជ.ស | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងអភិវឌ្ឍន៍ជនបទ |
| - សិក្សារៀបចំឲ្យមានអាងសម្រាប់ស្តុក និងចម្រោះទឹកស្អាតមួយ នៅក្នុងក្រុងសែនមនោរម្យដើម្បីធានាការផ្គត់ផ្គង់ទឹកជាប្រចាំ និងធានានិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត។ | ២០២១<br>ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ធ្វើការអប់រំដល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពីការប្រើប្រាស់ទឹកស្អាត ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព ជាពិសេសកាត់បន្ថយភាពក្រីក្រ។ | | | |
| - ធ្វើការការពារប្រភពទឹកសម្រាប់ការផលិត និងផ្គត់ផ្គង់ទឹកស្អាតជាអាទិភាព និងសិក្សាស្វែងរកប្រភពទឹកផ្សេងទៀត ដើម្បីធានាបាននូវនិរន្តរភាពក្នុងការផ្គត់ផ្គង់ទឹកស្អាតនាពេលអនាគត។ | | | |
| - បង្កើនការយល់ដឹង និងអប់រំប្រជាពលរដ្ឋ និងភ្ញៀវទេសចរឲ្យចូលរួមក្នុងយុទ្ធនាការ សន្សំសំចៃទឹកសម្រាប់ការប្រើប្រាស់ឡើងវិញនូវទឹកដែលប្រើប្រាស់រួច ដូចជាការស្រោចដំណាំ និងក្នុងគោលបំណងណាមួយ ធានាបានការសន្សំសំចៃទឹកជាអតិបរមា រួមចំណែកដល់ការអភិវឌ្ឍបៃតងក្នុងខេត្ត។ | | | |
| - គិតគូរអំពីផលប៉ះពាល់ដល់បំពង់ចែកចាយទឹកក្នុងផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរយៈពេលខ្លី មធ្យម វែងរបស់រាជរដ្ឋាភិបាល។ | ២០២១<br>ទៅវែង | - គ.អ.ជ.ស | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | |
|---|---|---|---|
| **៥.៣. ការប្រើប្រាស់ និងការផ្គត់ផ្គង់ថាមពលអគ្គិសនី** | | | |
| - ធានាការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់អាចទុកចិត្តបាន មានគុណភាព និងតម្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទនៅទូទាំងខេត្តមណ្ឌលគិរី។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងរ៉ែ និងថាមពល<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- អគ្គិសនីកម្ពុជា (EDC)<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ផ្តួចផ្តើមការសិក្សា និងលើកទឹកចិត្តការវិនិយោគថាមពលអគ្គិសនីដើរដោយថាមពលខ្យល់ ដោយសារទីតាំងភូមិសាស្ត្រខេត្តមណ្ឌលគិរីអំណោយផលដល់ការស្រូបទាញកម្លាំងខ្យល់ និងបង្កើតបានជាថាមពលអគ្គិសនីដែលនេះជាគំរូថ្មីមួយ រួមចំណែកដ៏សំខាន់ក្នុងកិច្ចការថែរក្សាបរិស្ថាន។ | | | |
| - សិក្សាលទ្ធភាពក្នុងការសិក្សាស្វែងរកប្រភពថាមពលវារីអគ្គិសនីបន្ថែម ដោយអាចទាញយកពីកម្លាំងទឹកទន្លេស្រែពក សម្រាប់ផលិតជាអគ្គិសនីប្រើប្រាស់បានកាន់តែច្រើន ដើម្បីផ្គត់ផ្គង់ក្នុងខេត្ត និងចែកចាយទៅតំបន់ផ្សេងក្នុងប្រទេស។ | ២០២១ ទៅមធ្យម | | |
| - បង្កើនការយល់ដឹង និងផ្សព្វផ្សាយដល់មូលដ្ឋានអាជីវកម្ម និងវិស័យឯកជននានាចូលរួមសន្សំសំចៃថាមពលឲ្យបានជាអតិបរមា ធ្វើយ៉ាងណាឲ្យការប្រើប្រាស់នោះទទួលបាននូវប្រសិទ្ធភាព។ | | | |
| **៥.៤. ការគ្រប់គ្រងសំណល់រឹង រាវ និងប្លាស្ទិក** | | | |
| - រៀបចំផែនការគ្រប់គ្រងសំរាមឲ្យបានច្បាស់លាស់ និងជំរុញឲ្យក្រុមហ៊ុនប្រមូលសំរាមយកចិត្តទុកដាក់លើការពង្រឹងសេវាប្រមូលសំរាមរបស់ខ្លួនឲ្យបានខ្ជាប់ខ្ជួន និងទៀងទាត់ ពិសេសជំរុញឲ្យមានការពង្រីកសេវាប្រមូលសំរាមបន្ថែមដល់ទីប្រជុំជននៃស្រុកទាំង០៤ និងបើកឲ្យមានការដាក់ដេញថ្លៃជ្រើសរើសក្រុមហ៊ុនប្រមូលសំរាមបន្ថែមទៀត ដើម្បីធានាការទុកដាក់សំរាមប្រកបដោយប្រសិទ្ធភាព។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ជំរុញការទាក់ទាញ និងលើកទឹកចិត្តឲ្យមានការវិនិយោគលើការកែច្នៃសំរាម និងការប្រើប្រាស់ សំរាមឡើងវិញ ដូចជាការកែច្នៃជាជីកំប៉ុសជាដើម។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងបរិស្ថាន<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ជំរុញសំណើសុំការឯកភាពពីក្រសួងបរិស្ថាន ក្នុងការប្រើប្រាស់ទីលានចាក់សំរាមដែលមានទំហំប្រមាណ ១៣៤ ហិកតា និងមានចម្ងាយ ១៥ គ.ម ពីក្រុងសែនមនោរម្យឲ្យបានឆាប់ ដើម្បីរៀបចំជាកន្លែង | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |

| | | | |
|---|---|---|---|
| ចាក់សំរាមរិលជុំឲ្យបានសមរម្យ។ | | | |
| - សិក្សារៀបចំឲ្យមានអាងស្តុកប្រព្រឹត្តកម្មសំណល់រាវមួយ ពិសេសក្នុងក្រុងសែនមនោរម្យដែលរួមចំណែកដល់ការធ្វើប្រព្រឹត្តកម្មសំណល់រាវ និងអាចយកទឹកមកប្រើប្រាស់ឡើងវិញ។<br>- សិក្សារៀបចំប្រព័ន្ធលូសាធារណៈឲ្យស្របតាមបទដ្ឋានបច្ចេកទេស ដាច់ដោយឡែកពីលូបង្ហូរទឹកភ្លៀង ដើម្បីបញ្ចៀសការបង្ហូរសំណល់រាវចូលទៅក្នុងប្រព័ន្ធលូបង្ហូរទឹកភ្លៀង។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ជំរុញការបំពាក់នូវធុងសំរាមឲ្យបានគ្រប់គ្រាន់នៅតាមគោលដៅសំខាន់ៗ និងរៀបចំឲ្យមានដេប៉ូស្តុកសំរាមនៅទីតាំងសមរម្យណាមួយ កុំឲ្យប៉ះពាល់ដល់សោភ័ណភាព និងបង្កជាក្លិនមិនល្អដល់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋ។<br>- ពង្រឹងការអនុវត្តវិធានបរិស្ថានសម្រាប់រោងចក្រ សហគ្រាស សិប្បកម្ម ក៏ដូចជាមូលដ្ឋានអាជីវកម្មនានា ឲ្យមានការរៀបចំនៅអាងប្រព្រឹត្តកម្មចម្រោះទឹកកខ្វក់ (Septic Tank) មុននឹងបញ្ចេញមកលូសាធារណៈ ឬប្រភពទឹកនានា។<br>- លើកកម្ពស់ការអប់រំ និងបញ្ជ្រាបការយល់ដឹងទៅដល់ប្រជាពលរដ្ឋមូលដ្ឋានអំពីកិច្ចការពារបរិស្ថាន និងអនាម័យ ដែលជាកិច្ចការចាំបាច់ដែលត្រូវធ្វើជាប្រចាំ ដើម្បីបំផុសចលនានៃការស្រលាញ់បរិស្ថាន និងការថែរក្សាអនាម័យនៅតាមទីសាធារណៈ។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ជំរុញការអភិវឌ្ឍខេត្តមណ្ឌលគិរីគឺជាគោលដៅអេកូទេសចរណ៍គ្មានសំណល់ប្លាស្ទិក (Plastic-Free Zone)។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- គណៈកម្មាធិការជាតិវាយតំលៃទីក្រុងស្អាត<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ជំរុញការអនុវត្តគោលការណ៍ ៣ Rs ក្នុងការគ្រប់គ្រងសំណល់ជាប្លាស្ទិក រួមមានការកាត់បន្ថយ (Reduce) ការប្រើប្រាស់ឡើងវិញ (Reuse) និងការកែច្នៃឡើងវិញ (Recycle)។<br>- ដាក់ចេញយុទ្ធនាការ និងកម្មវិធីនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងប្លាស្ទិក។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងបរិស្ថាន<br>- គណៈកម្មាធិការជាតិវាយតំលៃទីក្រុងស្អាត |

| | | | |
|---|---|---|---|
| - បំផុសទំលាប់ថ្មីក្នុងការប្រើប្រាស់ផលិតផលជំនួសប្លាស្ទិក។ | | | - រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ជំរុញឱ្យមានការវិនិយោគក្នុងការកែច្នៃសំណល់ជាប្លាស្ទិក។ | មធ្យម<br>ទៅវែង | - គ.អ.ជ.ស | - ក្រសួងបរិស្ថាន<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| **៥.៥. ការអភិរក្សវប្បធម៌ជនជាតិដើមភាគតិច** | | | |
| - រៀបចំឱ្យមានគោលនយោបាយគាំទ្រដល់ជនជាតិដើមភាគតិច។ | ២០២១<br>ទៅវែង | - គ.អ.ជ.ស | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ពង្រឹងការអភិរក្សអត្តសញ្ញាណជនជាតិដើមភាគតិច តាមរយៈការធ្វើបញ្ជីសារពើភ័ណ្ឌសម្បត្តិបេតិកភណ្ឌវប្បធម៌ឱ្យបានច្បាស់លាស់ ព្រមជាមួយការរៀបចំផែនទីភូមិជនជាតិដើមភាគតិចដែលមាននៅខេត្តមណ្ឌលគិរី ដើម្បីធ្វើការសិក្សាស្វែងយល់ និងផ្សព្វផ្សាយទៅដល់ភ្ញៀវទេសចរ។ | | | |
| - សិក្សាបង្កើតមជ្ឈមណ្ឌលវប្បធម៌សហគមន៍ សារមន្ទីរ សាលតាំងពិព័រណ៍ រោងមហោស្រពសម្តែងសិល្បៈ សម្រាប់ជនជាតិដើមភាគតិច។ | | | |
| - ពង្រឹងការរៀបចំ និងផ្សព្វផ្សាយសក្ដានុពលរបស់ខេត្តមណ្ឌលគិរី ក្នុងការផលិតភាពយន្ត ពិសេសទីតាំងអំណោយផលរបស់ភូមិជនជាតិដើមភាគតិច ទាំងភាពយន្តក្នុងស្រុក និងបរទេស។ | ២០២១<br>ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- ក្រសួងទេសចរណ៍ |
| - រៀបចំឱ្យមានភូមិវប្បធម៌សហគមន៍ (Community- Base Cultural Village) ជនជាតិដើមភាគតិចមួយនៅឃុំដាក់ដាំ ក្នុងស្រុកអូររាំង ដែលអាចក្លាយទៅជាផលិតផលទេសចរណ៍ថ្មីមួយដ៏សំខាន់សម្រាប់ភ្ញៀវទេសចរស្វែងយល់សិក្សាអំពីតំបន់នោះ។ | ២០២១<br>ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - សិក្សារៀបចំឱ្យមានពិធីបុណ្យជនជាតិដើមភាគតិច ដែលអាចប្រារព្ធឡើងជារៀងរាល់ឆ្នាំផ្សារភ្ជាប់ជាមួយសកម្មភាពទេសចរណ៍នានា ដើម្បីទាក់ទាញភ្ញៀវទេសចរមកទស្សនាបន្ថែម។ | ២០២១<br>ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- ក្រសួងអភិវឌ្ឍន៍ជនបទ |
| - សិក្សាលទ្ធភាពបង្កើតសាលាវប្បធម៌ និងវិចិត្រសិល្បៈសម្រាប់ជនជាតិដើមភាគតិច ដើម្បីពង្រឹងនូវ | ២០២១ | - គ.អ.ជ.ស | - ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |

| | | | |
|---|---|---|---|
| អត្តសញ្ញាណ ក៏ដូចជាភាពដើមនៃជនជាតិដើមភាគតិច។ | ទៅវែង | | - ក្រសួងអភិវឌ្ឍន៍ជនបទ |
| - ធ្វើការបណ្តុះបណ្តាលជំនាញចាំបាច់នានាដល់ជនជាតិដើមភាគតិចក្នុងសហគមន៍ដែលពួកគេរស់នៅ ដើម្បីឱ្យពួកគាត់មានឱកាសទទួលបានការងារ និងពង្រឹងសមត្ថភាពបន្ថែម។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - សិក្សាបង្កើតឱ្យមានទីតាំងសមស្របណាមួយដើម្បីឱ្យជនជាតិដើមភាគតិចទាំងអស់ អាចយក ផលិតផលរបស់ខ្លួន មកតាំងបង្ហាញ និងលក់ជូនភ្ញៀវទេសចរ ដោយអាចរៀបចំភ្ជាប់ជាមួយគំនិតក្នុងការបង្កើតផ្សាររាត្រីតែម្តង។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ជំរុញផ្នែកឯកជនឱ្យចូលរួមចំណែកក្នុងការរៀបចំកញ្ចប់ទស្សនកិច្ចឱ្យបានច្រើនទៅកាន់តំបន់ជនជាតិដើមភាគតិច ដោយផ្សារភ្ជាប់ជាមួយគោលដៅទេសចរណ៍សំខាន់ៗក្នុងខេត្ត ជាពិសេសភូមិជនជាតិដើមភាគតិច ដែលត្រូវបានស្នើឱ្យបង្កើតឡើង។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី |
| **៥.៦. ការផ្សារភ្ជាប់វិស័យរ៉ែ និងទេសចរណ៍** | | | |
| - កំណត់តំបន់អាទិភាពក្នុងការទាញយកថ្ម និងអាចម៍ដីសម្រាប់បម្រើដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគគម្រោងអភិវឌ្ឍនានាក្នុងខេត្តមណ្ឌលគិរី ឱ្យបានច្បាស់លាស់ ដោយផ្តោតលើការគិតគូរពីបរិស្ថាន និងសោភ័ណភាពរបស់ខេត្ត និងចូលរួមដល់ការអភិរក្ស ធនធានព្រៃឈើ។<br>- ពង្រឹងការអនុវត្ត និងការត្រួតពិនិត្យបទដ្ឋានបច្ចេកទេសក្នុងការធ្វើអាជីវកម្មរ៉ែ និងទប់ស្កាត់ការធ្វើអាជីវកម្មបែបអនាធិបតេយ្យ និងដែលមិនស្របតាមបទដ្ឋានបច្ចេកទេស។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងរ៉ែ និងថាមពល<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ជំរុញ និងលើកទឹកចិត្តក្នុងការប្រែក្លាយតំបន់ដែលបញ្ចប់ការធ្វើអាជីវកម្មរ៉ែទៅជាតំបន់ទេសចរណ៍បែបថ្មីមួយ ដោយត្រូវគិតគូរម៉ត់ចត់អំពីសុវត្ថិភាពភ្ញៀវទេសចរ។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងរ៉ែ និងថាមពល<br>- ក្រសួងទេសចរណ៍ |
| - ពិនិត្យលទ្ធភាពក្នុងការបង្កើតសារមន្ទីររ៉ែ ដើម្បីឱ្យភ្ញៀវទេសចរណ៍អាចចូលរួមមកទស្សនាសំណាកត្បូងរ៉ែដែលជាធនធានធម្មជាតិដែលមាននៅក្នុងខេត្តនេះ និងយល់ដឹងពីសកម្មភាពនៃប្រតិបត្តិការ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងរ៉ែ និងថាមពល<br>- ក្រសួងទេសចរណ៍ |

| | | | |
|---|---|---|---|
| ធនធានរ៉ែដែលជាផ្នែកមួយក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ។ | | | |
| - ពិនិត្យលទ្ធភាពក្នុងការបង្កើតកន្លែងសម្រាប់ភ្ញៀវទេសចរទៅទស្សនាអណ្តូងរ៉ែមាស ដែលមានលក្ខណៈស្តង់ដារអន្តរជាតិដែលធានាបានទាំងផ្នែកបច្ចេកទេស ផ្នែកសុវត្ថិភាព និងបរិស្ថាន។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងរ៉ែ និងថាមពល<br>- ក្រសួងទេសចរណ៍ |
| - ពិនិត្យលទ្ធភាពក្នុងការបង្កើតមណ្ឌលទេសចរណ៍រែងរ៉ែមាស និងត្បូងកម្សាន្ត (ដើម្បីទាក់ទាញភ្ញៀវទេសចរ អាចចូលទៅទិញរ៉ែមាសដែលរៀបចំទុកជាស្រេច ហើយរែងដោយខ្លួនឯង ដោយមានការបង្ហាត់បង្ហាញពីបុគ្គលិកនៅទីនោះ ហើយកម្ទេចមាសឬត្បូងដែលទទួលបានអាចយកទៅរក្សាទុកជាវត្ថុអនុស្សាវរីយ៍។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងរ៉ែ និងថាមពល<br>- ក្រសួងទេសចរណ៍ |
| - សិក្សាលទ្ធភាពប្រែក្លាយតំបន់ភ្នំណាមលៀវដែលជាប្រភេទភ្នំថ្មក្រានីតទៅជាឧទ្យានភូគព្ភសាស្ត្រ (Geo Park) និងជាគោលដៅទេសចរណ៍ដ៏ទាក់ទាញ។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងរ៉ែ និងថាមពល<br>- ក្រសួងបរិស្ថាន<br>- ក្រសួងទេសចរណ៍ |
| **៥.៧. ការផ្សារភ្ជាប់វិស័យកសិកម្ម និងទេសចរណ៍** | | | |
| - ជំរុញការរៀបចំឱ្យមានស្លាកសញ្ញាសម្គាល់ផលិតផលប្រចាំតំបន់ និងប្រចាំខេត្ត ដូចជាម្រេចមណ្ឌលគិរី កាហ្វេមណ្ឌលគិរី ប៉ូរមណ្ឌលគិរី ទុរេនមណ្ឌលគិរី ទឹកឃ្មុំមណ្ឌលគិរី និងផលិតផលសិប្បកម្មមួយចំនួន ដូចជាស្រាផាស់សិនមណ្ឌលគិរីជាដើម ដើម្បីជាផលិតផលសម្គាល់អត្តសញ្ញាណរបស់ខេត្ត។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - សិក្សាអភិវឌ្ឍន៍ជាភូមិកសិ-ទេសចរណ៍គំរូ ដោយជ្រើសរើសទីតាំងណាមួយសមស្រប ពិសេសក្នុងក្រុងសែនមនោរម្យ ដែលសម្បូរទៅដោយចម្ការដំណាំនានា ដែលអាចជំរុញឱ្យម្ចាស់កសិដ្ឋានធ្វើការតាំងបង្ហាញដំណើរការនៃការរៀបចំកសិដ្ឋាន និងអាចឱ្យភ្ញៀវទេសចរចូលរួមដាំដុះបានដោយខ្លួនឯង។<br>- ជំរុញការរៀបចំសកម្មភាពទាក់ទងទៅនឹងការងារកសិ-ទេសចរណ៍ ពិសេសស្វែងរកភាពជាដៃគូក្នុងការចុះអនុស្សរណៈនៃការយោគយល់គ្នារវាងសហគមន៍ព្រៃឈើជាមួយសហគមន៍អេកូទេសចរណ៍ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងទេសចរណ៍<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |

| | | | |
|---|---|---|---|
| ក្នុងគោលបំណងទទួលបានផលប្រយោជន៍រួមគ្នា | | | |
| - បង្កើតឱ្យមានផ្សារសហគមន៍ ដើម្បីជាទីតាំងសម្រាប់លក់ផលិតផល និងកសិផលនានា និងជំរុញឱ្យមានការតាំងបង្ហាញ និងលក់កសិផលរបស់ជនជាតិដើមភាគតិច។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - រដ្ឋបាលខេត្តមណ្ឌលគិរី |
| - លើកទឹកចិត្តឱ្យមានការវិនិយោគដំណាំដែលមានសក្តានុពល ដូចជាបន្លែ ផ្កា និងផ្លែឈើ ដែលមានសក្តានុពលក្នុងការនាំចេញទៅក្រៅប្រទេស ពិសេសដំណាំកសិកម្ម ដូចជា ស្វាយចន្ទី កាហ្វេ ដូង ចេក ប៉ះ ស្វាយ សាវម៉ាវ ទុរេន ក្រូច និងដំណាំទៀបជាដើម និងដំណាំកសិ-ឧស្សាហកម្មមួយចំនួន ដូចជាកៅស៊ូ សណ្តែកបាយ សណ្តែកដី សណ្តែកអង្គុយ ដំឡូងមី អំពៅ ម្រេច ។ល។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - ជំរុញឱ្យមានការចងក្រងជាក្រុម ឬសហគមន៍ដើម្បីចែករំលែកបច្ចេកទេស បង្កលក្ខណៈងាយស្រួលដល់ការស្វែងរកទីផ្សារសម្រាប់លក់ផលិតផលរបស់ពួកគេ។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងពាណិជ្ជកម្ម |
| - ជំរុញការចិញ្ចឹមសត្វ វារីវប្បកម្ម ជាពិសេសការចិញ្ចឹមត្រីដែលមានតម្លៃសេដ្ឋកិច្ច និងការងារទាក់ទងទៅនឹងសុវត្ថិភាពផលិតផលកសិកម្ម។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - លើកទឹកចិត្តឱ្យមានការវិនិយោគកសិដ្ឋានចិញ្ចឹមសត្វខ្នាតអន្តរជាតិសម្រាប់ផ្គត់ផ្គង់សាច់ និងប្រែក្លាយជាតំបន់ទេសចរណ៍សម្រាប់ភ្ញៀវទេសចរចូលទស្សនា។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| - ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ ដាំដុះ បន្លែ ផ្លែឈើ ឱ្យស្របតាមស្តង់ដា ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងឈានទៅនាំចេញទៅក្រៅប្រទេស។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| - ចាត់វិធានការថែរក្សាការពារប្រភពទឹកនានា និងសិក្សាពីការស្តុកទឹកភ្លៀងមករក្សាទុកសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ និងបម្រើដល់វិស័យសេដ្ឋកិច្ចនានា។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងធនធានទឹក និងឧតុនិយម<br>- ក្រសួងបរិស្ថាន |

| | | | |
|---|---|---|---|
| | | | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| **៥.៨. វិស័យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម** | | | |
| - សិក្សាបង្កើតសាលាបណ្តុះបណ្តាល ឬវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសមណ្ឌលគិរី ដើម្បីជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈចាំបាច់នានា។ | ២០២១ ទៅមធ្យម | - គ.អ.ដ.ស | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| - សិក្សារៀបចំស្លាកសញ្ញា និងចងក្រងជាសមាគម ឬសហគមន៍អ្នកផលិតទៅតាមអនុវិស័យនីមួយៗ ដើម្បីជំរុញការចែករំលែកបច្ចេកវិទ្យា ក៏ដូចជាពង្រឹងកម្លាំងក្នុងការស្វែងរកទីផ្សារលក់ផលិតផល។ | ២០២១ ទៅមធ្យម | - គ.អ.ដ.ស | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម |
| - សិក្សាបង្កើតឲ្យមានកម្មវិធីកម្ចីពិសេសក្នុងអត្រាការប្រាក់ទាប ដែលអនុញ្ញាតឲ្យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម មានលទ្ធភាពទទួលបានកម្ចីក្នុងលក្ខខណ្ឌមួយសមរម្យ។ | ២០២១ ទៅមធ្យម | - គ.អ.ដ.ស | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| - រៀបចំផែនការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ប្រជាពលរដ្ឋលើការផលិតនូវផលិតផលសម្រាប់បម្រើដល់វិស័យទេសចរណ៍ ដូចជាវត្ថុអនុស្សាវរីយ៍ និងការដាក់ចេញយុទ្ធសាស្ត្រសមស្របសម្រាប់ការស្វែងរកទីផ្សារ ដើម្បីចូលរួមបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ | ២០២១ ទៅមធ្យម | - គ.អ.ដ.ស | - ក្រសួងទេសចរណ៍<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| **៥.៩. ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ** | | | |
| - ទប់ស្កាត់ការទន្ទ្រានដីរដ្ឋមកធ្វើជាកម្មសិទ្ធឯកជន និងធ្វើការចុះបញ្ជីដីធ្លីក្នុងខេត្តមណ្ឌលគិរីឲ្យបាន | ២០២១ | - គ.អ.ដ.ស | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម |

| | | | |
|---|---|---|---|
| រួចរាល់ ដើម្បីធ្វើការបែងចែកឱ្យដាច់ស្រេចរវាងតំបន់ដែលត្រូវអភិរក្ស តំបន់ដែលត្រូវអភិវឌ្ឍ និងតំបន់ដែលមានប្រជាជនរស់នៅ ដើម្បីកុំឱ្យមានភាពប្រទាញប្រទង់គ្នាលើការអភិរក្ស និងការអភិវឌ្ឍ។ | ទៅមធ្យម | | និងសំណង់<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - ធ្វើការចុះបញ្ជីរមណីយដ្ឋានទេសចរណ៍សំខាន់ៗក្នុងខេត្តឱ្យបានឆាប់រហ័ស។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - សិក្សាបង្កើតមជ្ឈមណ្ឌលអប់រំចម្រុះ និងសំបូរបែបទាក់ទងនឹងការគ្រប់គ្រងជីវៈចម្រុះ និងធនធានធម្មជាតិ ដែលអាចរួមបញ្ចូលសម្បទាសម្រាប់ការបោះជំរុំវិស្សមកាល អគារសម្រាប់មន្ទីរពិសោធន៍ស្រាវជ្រាវ សិក្ខាសាលា កន្លែងចុះអនុវត្ត និងសួនបូតានិច ឬសួនរុក្ខជាតិ (Botanical Garden) ជាដើម។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| - រៀបចំវិធានការស្តារ និងបង្កើតចលនាដាំដើមឈើឡើងវិញ។<br>- ជំរុញឱ្យមានចលនាដាំដើមស្រល់ឡើងវិញនៅតាមតំបន់សំខាន់ៗក្នុងខេត្ត ។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| **៥.១០. ការគាំពារសេវាវេជ្ជសាស្រ្ត និងសុខាភិបាល** | | | |
| - ពង្រឹងហេដ្ឋារចនាសម្ព័ន្ធវិស័យវេជ្ជសាស្រ្ត និងសុខាភិបាលក្នុងខេត្តមណ្ឌលគិរីស្របតាមស្តង់ដាជាតិ និងអន្តរជាតិ ដើម្បីបង្កើនទំនុកចិត្តភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលនឹងមានការកើនឡើងនាពេលអនាគត។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងសុខាភិបាល |
| - ផ្តល់អាទិភាពដល់ការវិនិយោគ និងអភិវឌ្ឍវិស័យសុខាភិបាល ពិសេសការបង្កើតមន្ទីរពេទ្យស្តង់ដាអន្តរជាតិក្នុងខេត្តមណ្ឌលគិរី ដែលនឹងក្លាយជាមជ្ឈមណ្ឌលសុខាភិបាលសម្រាប់តំបន់ភូមិភាគឦសាន។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងសុខាភិបាល<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

| | | | |
|---|---|---|---|
| - ជំរុញឱ្យមានការធ្វើទំនើបកម្មសេវាសុខាភិបាលនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនានា ដើម្បីធានាការផ្តល់សេវាព្យាបាលជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាពជូនប្រជាពលរដ្ឋ។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងសុខាភិបាល<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - ពង្រឹង និងពង្រីកធនធានមនុស្សបម្រើការក្នុងវិស័យសុខាភិបាល ពិសេសនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពក្នុងខេត្ត។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងសុខាភិបាល |
| **៥.១១. ការជំរុញការអភិវឌ្ឍបច្ចេកវិទ្យា នវានុវត្តន៍ និងភាពច្នៃប្រឌិត** | | | |
| - សិក្សាអភិវឌ្ឍក្រុងសែនមនោរម្យ ជាទីក្រុងឆ្លាតវៃ (Smart City) ដោយបញ្ចូលទស្សនទាន និងបច្ចេកវិទ្យាថ្មីៗ ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ទាំងលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទ្រទ្រង់ ប្រព័ន្ធគមនាគមន៍ ដឹកជញ្ជូន ការទំនាក់ទំនង ដំណើរការប្រតិបត្តិការ និងការបណ្តុះបណ្តាលជំនាញរឹង និងទន់ (Hard Skill and Soft Skill) ចាំបាច់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការធ្វើទំនើបកម្មតំបន់ទីក្រុង និងទីប្រជុំជន ឆ្លើយតបទៅនឹងបរិបទបដិវត្តន៍ឧស្សាហកម្ម ៤.០។ | មធ្យម ទៅវែង | - គ.អ.ជ.ស | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - សិក្សាបញ្ចូលបច្ចេកវិទ្យាវ៉ៃឆ្លាតគ្រីដ (Smart-grid Technology) សម្រាប់គាំទ្រដល់ការសន្សំសំចៃ និងគ្រប់គ្រងថាមពល និងការគាំទ្រខ្សែសង្វាក់ផ្គត់ផ្គង់តម្រូវការក្នុងវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី និងបច្ចេកវិទ្យាភ័ស្តុភារកម្ម (Logistic Technology) ផ្តោតលើតម្រូវការ និងការផ្គត់ផ្គង់លើវិស័យទេសចរណ៍។<br>- សិក្សាលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាដើម្បីគ្រប់គ្រងធនធានទឹកទៅលើភាពងាយរងគ្រោះនៃប្រភពទឹក ការអភិវឌ្ឍកសិកម្មវ៉ៃឆ្លាតផងដែរ (Smart Agriculture) និងការសិក្សាបង្កើតឱ្យមានប្រព័ន្ធផ្ទុកទិន្នន័យ និងការគ្រប់គ្រងព័ត៌មានរួម (ប្រជាសាស្ត្រ ធនធានមនុស្ស សហគ្រាស មីក្រូ ធុនតូច មធ្យម និងសិប្បកម្ម សេវាកម្ម សេដ្ឋកិច្ច ជាដើម)។ | មធ្យម ទៅវែង | - គ.អ.ជ.ស | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| - ពង្រឹងសមត្ថភាពរបស់មន្ត្រីមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងភាគីពាក់ព័ន្ធនានាក្នុងខេត្តមណ្ឌលគិរី លើការបន្សាំ និងការទទួលយកបច្ចេកវិទ្យាថ្មីៗ សម្រាប់គាំទ្រសគ្រាស មីក្រូ ធុនតូច មធ្យម និងសិប្បកម្ម រួមទាំងសេវាកម្មផ្សេងៗទៀត។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| - សិក្សាឱ្យមានការតំឡើងប្រព័ន្ធអង់តែនទូរស័ព្ទ និងសេវាអ៊ិនធើណែតគ្របដណ្តប់ឱ្យបានពេញក្នុង | ២០២១ | - គ.អ.ជ.ស | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

| | | | |
|---|---|---|---|
| ខេត្តក៏ដូចជាតំបន់ផ្សេងៗនៅក្នុងខេត្តមណ្ឌលគិរី ពិសេសក្នុងតំបន់ដែនជម្រកសត្វព្រៃ។ | ទៅមធ្យម | | |
| **៦. ការតភ្ជាប់ ការសម្រួលការធ្វើដំណើរ និងការធ្វើសមាហរណកម្មក្នុងក្របខណ្ឌជាតិ និងតំបន់** | | | |
| **៦.១. ការតភ្ជាប់តាមផ្លូវអាកាស និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ** | | | |
| - ជំរុញការអភិវឌ្ឍព្រលានយន្តហោះខេត្តមណ្ឌលគិរី។ | ២០២១<br>ទៅមធ្យម | - គ.អ.ជ.ស | - រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - ជំរុញឱ្យក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក រៀបចំកាលវិភាគ និងជើងហោះហើរឱ្យបានច្រើន និងទៀងទាត់ភ្ជាប់គោលដៅសំខាន់ៗក្នុងប្រទេសមកខេត្តមណ្ឌលគិរី។ | មធ្យម<br>ទៅវែង | - គ.អ.ជ.ស | - រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>- ក្រសួងទេសចរណ៍ |
| - ជំរុញឱ្យមានការតភ្ជាប់ផ្លូវអាកាសពីបណ្ដាប្រទេសជិតខាង រួមមានថៃ វៀតណាម និងឡាវ មកកាន់ខេត្តមណ្ឌលគិរី និងទីក្រុងសំខាន់ៗរបស់អាស៊ាន និងប្រទេសផ្សេងទៀតក្នុងតំបន់។ | | | |
| **៦.២. ការតភ្ជាប់តាមផ្លូវគោក និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ** | | | |
| - សិក្សាលទ្ធភាពក្នុងការរៀបចំផ្លូវចរាចរណ៍ដែលមានល្បឿនលឿន (Highway) តភ្ជាប់រាជធានី ភ្នំពេញ និងខេត្តមណ្ឌលគិរី។ | មធ្យម<br>ទៅវែង | - គ.អ.ជ.ស | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| - សិក្សាលទ្ធភាពក្នុងការតំឡើងកម្រិតច្រកព្រំដែនទ្វេភាគីមួយចំនួនក្នុងខេត្តមណ្ឌលគិរីទៅជាច្រកអន្តរជាតិស្របជាមួយគម្រោងសាងសង់ព្រលានយន្តហោះខេត្តមណ្ឌលគិរី។ | មធ្យម<br>ទៅវែង | - គ.អ.ជ.ស | - ក្រសួងមហាផ្ទៃ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងទេសចរណ៍ |
| - សិក្សារៀបចំឱ្យមានចំណតរថយន្ត មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ភ្ជាប់ជាមួយមជ្ឈមណ្ឌល ហាងទំនិញនានា និងសម្បទាទ្រទ្រង់ចាំបាច់នានា នៅច្រកចូលក្រុងសែនមនោរម្យ ដើម្បីផ្តល់ ព័ត៌មានដល់ភ្ញៀវទេសចរ និងជាទីសំចតសម្រាប់រថយន្តទេសចរណ៍ និងអ្នកដំណើរក្នុងការធ្វើដំណើរកម្សាន្តមកកាន់ខេត្តមណ្ឌលគិរី។ | មធ្យម<br>ទៅវែង | - គ.អ.ជ.ស | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងទេសចរណ៍<br>- រដ្ឋបាលខេត្តមណ្ឌលគិរី |
| **៦.៣. ការតភ្ជាប់តាមផ្លូវទឹក និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ** | | | |

| | | | |
|---|---|---|---|
| - សិក្សាលទ្ធភាពក្នុងការរៀបចំចំណតយន្តហោះនៅលើទឹក ដែលអាចសិក្សាជំហានដំបូង នៅតំបន់ប្រជុំជននៃស្រុកកោះញែក ដើម្បីជំរុញការតភ្ជាប់ពីតំបន់ភូមិភាគឦសានទៅកាន់តំបន់ឆ្នេរសមុទ្រ និងតំបន់បឹងទន្លេសាបខេត្តសៀមរាប។ | មធ្យម ទៅវែង | - គ.អ.ជ.ស | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងទេសចរណ៍ |
| - រៀបចំខ្សែទស្សនកិច្ចតាមដងទន្លេស្រែពក និងបញ្ជ្រាបការយល់ដឹងទៅប្រជាពលរដ្ឋដែលរស់នៅ និងអាស្រ័យផលតាមដងទន្លេស្រែពក។ | ២០២១ ទៅមធ្យម | - គ.អ.ជ.ស | - ក្រសួងទេសចរណ៍ |
| **៧. ការគៀងគរធនធានហិរញ្ញវត្ថុ** | | | |
| - សិក្សារៀបចំយុទ្ធសាស្ត្រជាក់លាក់ពាក់ព័ន្ធនឹងការគៀងគរធនធានហិរញ្ញវត្ថុចាំបាច់ ដើម្បីធានាប្រសិទ្ធភាព និងសក្តិសិទ្ធភាពក្នុងការអនុវត្តផែនការមេ។ | ២០២១ ទៅវែង | - គ.អ.ជ.ស | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងទេសចរណ៍ |

## ឧបសម្ព័ន្ធ ៦៖ វិធីសាស្ត្រស្រាវជ្រាវ និងចងក្រងផែនការមេ

ផែនការមេសម្រាប់អភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ត្រូវបានរៀបចំឡើងដោយផ្អែកលើការវិភាគស្ថានភាពជាក់ស្តែងខេត្តមណ្ឌលគិរី ដោយផ្តោតលើវិធីសាស្ត្រស្រាវជ្រាវសំខាន់ៗដូចខាងក្រោម៖

**វិធីសាស្ត្រទី១៖** ការពិនិត្យ និងវិភាគលើឯកសារដែលមានស្រាប់ (Document Consultation) ដែលរួមមាន គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងឯកសាររបស់អង្គភាពជំនាញនានាពាក់ព័ន្ធការអភិវឌ្ឍខេត្តមណ្ឌលគិរី។

**វិធីសាស្ត្រទី២៖** ការចុះប្រមូលទិន្នន័យតាមរយៈការធ្វើអង្កេត (Survey) ទៅលើក្រុមមនុស្សចំនួន ០៤ ប្រភេទ ដែលត្រូវបានជ្រើសរើសដោយចៃដន្យ និងបានប្រព្រឹត្តទៅកាលពីកំឡុងខែមិថុនា ឆ្នាំ២០២០។ ការវិភាគទិន្នន័យបែបបរិមាណវិស័យ (Quantitative Method) ត្រូវបានប្រើប្រាស់ ដើម្បីវិភាគទិន្នន័យដែលទទួលបានពីការចុះធ្វើអង្កេតនេះ។

- **ប្រភេទទី១៖** ការស្ទង់មតិជាមួយភ្ញៀវទេសចរជាតិ និងអន្តរជាតិនៅខេត្តមណ្ឌលគិរី ដើម្បីស្វែងយល់ពីតម្រូវការ ឥរិយាបថ និងមតិយោបល់របស់ភ្ញៀវទេសចរពាក់ព័ន្ធការអភិវឌ្ឍក្នុងខេត្តមណ្ឌលគិរី។ ភ្ញៀវទេសចរជាតិ ៥០ នាក់ និងភ្ញៀវទេសចរអន្តរជាតិ ៥០ នាក់ បានចូលរួមក្នុងការស្ទង់មតិប្រភេទទី០១នេះ។
- **ប្រភេទទី២៖** ការស្ទង់មតិម្ចាស់ និងអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មទេសចរណ៍សំខាន់ៗក្នុងខេត្តមណ្ឌលគិរី ជាពិសេសសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងរមណីយដ្ឋាន ដើម្បីស្វែងយល់អំពីដំណើរប្រតិបត្តិការធុរកិច្ច និងមតិយោបល់ក្នុងការអភិវឌ្ឍខេត្តមណ្ឌលគិរី។ សណ្ឋាគារ ៣កន្លែង ផ្ទះសំណាក់ ៧កន្លែង ភោជនីយដ្ឋាន ៦កន្លែង រមណីយដ្ឋាន ៥កន្លែង បានចូលរួមក្នុងការស្ទង់មតិប្រភេទទី២នេះ។
- **ប្រភេទទី៣៖** ការស្ទង់មតិជាមួយបុគ្គលិកបម្រើការតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ ដើម្បីស្វែងយល់អំពីស្ថានភាពការងារក្នុងវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី។ បុគ្គលិកចំនួន ៤២ នាក់ បានចូលរួមក្នុងការស្ទង់មតិប្រភេទទី៣នេះ។
- **ប្រភេទទី៤៖** ការស្ទង់មតិជាមួយប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីស្វែងយល់ពីលទ្ធភាពនៃការចូលរួមរបស់ពួកគាត់ក្នុងការទាញយកផលប្រយោជន៍ពីវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី។ ប្រជាពលរដ្ឋ ១០០នាក់ ក្នុងភូមិចំនួន ៨ ក្នុងខេត្ត រួមមាន ភូមិឡៅកា ភូមិពូតាំង ភូមិពូល្វុង ភូមិអណ្តូងក្រឡឹង ភូមិពូឆប ភូមិពូត្រែង ភូមិពូឡោះ និងភូមិកណ្តាល បានចូលរួមក្នុងការស្ទង់មតិប្រភេទទី៤នេះ។

**វិធីសាស្ត្រទី៣៖** បន្ទាប់ពីការចុះធ្វើអង្កេត ក្រុមការងារបច្ចេកទេសរបស់គណៈកម្មការអន្តរក្រសួង បានចុះជួបពិភាក្សា និងប្រមូលទិន្នន័យជាមួយមន្ទីរជំនាញ និងស្ថាប័នពាក់ព័ន្ធក្នុងខេត្តមណ្ឌលគិរី ក្រោមរូបភាពជាការប្រជុំពិភាក្សា និងការសម្ភាសន៍ (Focused Group Discussion and In-dept Interview) ដែលបានប្រព្រឹត្តទៅកាលពីកំឡុងខែមិថុនា និងខែកក្កដា ឆ្នាំ២០២០។ ការវិភាគទិន្នន័យបែបគុណភាពវិស័យ (Qualitative Method) ត្រូវបានប្រើប្រាស់ដើម្បីវិភាគទិន្នន័យដែលទទួលបានពីការចុះជួបពិភាក្សា និងប្រមូលទិន្នន័យនេះ។ ក្រុមការងារបច្ចេកទេស បានជួបពិភាក្សាជាមួយអង្គភាពជំនាញចំនួន ១៣ ក្នុងខេត្ត រួមមាន មន្ទីរទេសចរណ៍ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរផែនការ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន មន្ទីររ៉ែ និងថាមពល មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរអភិវឌ្ឍន៍ជនបទ និងសាលាក្រុងសែនមនោរម្យ។

ព្រមជាមួយការប្រមូលទិន្នន័យខាងលើ គណៈកម្មការអន្តរក្រសួងរៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ សិក្ខាសាលាពិគ្រោះយោបល់ កិច្ចប្រជុំក្រុមការងារបច្ចេកទេស និងកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងជាច្រើនដង មុននឹងឈានដល់ការសម្រេចបានទូវផែនការមេនេះ។

# ឧបសម្ព័ន្ធ គ៖ ទិន្នន័យបន្ថែមជាក្រាហ្វិក តារាង និងរូបភាព

## ក. ទិន្នន័យបន្ថែមជាក្រាហ្វិក

### ក្រាហ្វិកបន្ថែមទី១÷ គោលបំណងភ្ញៀវទេសចរមកទស្សនាខេត្តមណ្ឌលគិរី




(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### ក្រាហ្វិកបន្ថែមទី២÷ ស្ថានភាពមុខរបររបស់ភ្ញៀវទេសចរដែលមកកម្សាន្តនៅខេត្តមណ្ឌលគិរី




(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### ក្រាហ្វិកបន្ថែមទី៣÷ មូលហេតុដែលភ្ញៀវទេសចរមិនបានទៅដល់គោលដៅទេសចរណ៍មួយចំនួន




(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### ក្រាហ្វិកបន្ថែមទី៤÷ ការប្រើប្រាស់ទឹកស្អាតនៅតាមអាជីវកម្មទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី




| | សណ្ឋាគារ | ផ្ទះសំណាក់ | ភោជនីយដ្ឋាន | រមណីយដ្ឋាន |
|---|---|---|---|---|
| ទឹករដ្ឋ | 50% | 58% | 72% | 0% |
| ទឹកអណ្ដូង | 40% | 42% | 28% | 92% |
| ទឹកភ្លៀង | 10% | 0% | 0% | 2% |
| ប្រភពផ្សេងៗ | 0% | 0% | 0% | 6% |

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### ក្រាហ្វិកបន្ថែមទី៥÷ ភាគរយនៃការប្រើប្រាស់ទឹកស្អាតរបស់ប្រជាពលរដ្ឋមូលដ្ឋាន




(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### ក្រាហ្វិកបន្ថែមទី៦÷ ការប្រើប្រាស់ថាមពលអគ្គិសនីនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍




| | សណ្ឋាគារ | ផ្ទះសំណាក់ | ភោជនីយដ្ឋាន | រមណីយដ្ឋាន |
|---|---|---|---|---|
| អគ្គិសនីរដ្ឋ | ៨៧% | ៨៩% | ៩៦% | ៨0% |
| ម៉ាស៊ីនភ្លើង | ១៣% | ១0% | ២% | 0% |
| សូឡា | 0% | ១% | ២% | ២0% |

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### ក្រាហ្វិកបន្ថែមទី៧÷ ការបែងចែកសំណល់រឹង និងសំរាមនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍




| | សំណល់ផ្ទះបាយ | ប្លាស្ទិក | ក្រដាស | សំបកដប/កំប៉ុង | សំណល់មិនអាចកែច្នៃ | សំណល់ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| សណ្ឋាគារ | ៤៥% | ១០% | ៥% | ៣០% | ៥% | ៥% |
| ផ្ទះសំណាក់ | ៣០% | ២៥% | ១៥% | ២០% | ៥% | ៥% |
| រមណីយដ្ឋាន | ៣៧% | ១៩% | ១០% | ២១% | ៥% | ៨% |
| ភោជនីយដ្ឋាន | ៤១% | ២២% | ៧% | ២១% | ៤% | ៥% |

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### ក្រាហ្វិកបន្ថែមទី៨÷ ការប្រើប្រាស់ផលិតផលកសិកម្មនៅតាមភោជនីយដ្ឋាន និងរមណីយដ្ឋានទេសចរណ៍




| | រមណីយដ្ឋាន | ភោជនីយដ្ឋាន |
|---|---|---|
| បន្លែ | ៣៣% | ៣៥% |
| ផ្លែឈើ | ១៦% | ១២% |
| សាច់ជ្រូក | ១២% | ១៥% |
| សាច់គោ | ១៤% | ១៥% |
| បក្សី | ១៧% | ៩% |
| សាច់ត្រី | ៨% | ១១% |
| គ្រឿងសមុទ្រ | ០% | ២% |

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

## ខ. ទិន្នន័យបន្ថែមជាតារាង

### តារាងបន្ថែមទី១÷ មតិយោបល់ភ្ញៀវទេសចរលើសេវាកម្មទេសចរណ៍

| សេវាកម្ម | ល្អណាស់ | ល្អ | មធ្យម | ពង្រឹងបន្ថែម | ផ្សេងៗ |
|---|---|---|---|---|---|
| កន្លែងស្នាក់នៅ | ១០% | ៧២% | ១២% | ៦% | ០% |
| ម្ហូបអាហារ និងភេសជ្ជៈ | ១២% | ៣៨% | ១២% | ៣៦% | ២% |

| | | | | | |
|---|---|---|---|---|---|
| មគ្គុទ្ទេសក៍តំបន់ (ប្រសិនបើមាន) | ២% | ២៨% | ១០% | ២០% | ៤០% |
| មធ្យោបាយធ្វើដំណើរ | ២% | ៤២% | ២៤% | ៣២% | ៨% |
| កម្មវិធីកម្សាន្ត | 0% | ២២% | ២២% | ១៦% | ៤៨% |
| អ្នកបម្រើការក្នុងវិស័យទេសចរណ៍ | ២% | ៣០% | ៣៨% | ២៦% | ៤% |

(ប្រភព៖ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

**តារាងបន្ថែមទី២៖ មតិយោបល់ភ្ញៀវទេសចរលើការអភិវឌ្ឍផលិតផលទេសចរណ៍**

| ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ | ចាំបាច់ខ្លាំង | ចាំបាច់ | មិនសូវចាំបាច់ | មិនចាំបាច់ | គ្មានយោបល់ |
|---|---|---|---|---|---|
| | ៥ | ៤ | ៣ | ២ | ១ |
| សកម្មភាពទេសចរណ៍ផ្សងព្រេង បោះតង់ ដើរព្រៃ | ៤៦% | ៣៤% | ៦% | ៦% | ៨% |
| សកម្មភាពរស់នៅជាមួយបងប្អូនជនជាតិដើមភាគតិច | ១២% | ៥៤% | ២០% | ៨% | ៦% |
| សកម្មភាពធ្វើសិប្បកម្មជាមួយប្រជាជន | ៥៦% | ២៤% | ១០% | ២% | ៨% |
| សកម្មភាពកសិ-ទេសចរណ៍ | ៥២% | ៣២% | ៨% | ៤% | ៤% |
| សកម្មភាពកម្សាន្តនា ពេលរាត្រី ឬកម្មវិធីផ្សេងៗ | ៣៨% | ៣៦% | ១៨% | ៤% | ៤% |
| សកម្មភាពដាំដើមឈើអនុស្សាវរីយ៍ | ៥២% | ៣២% | ៤% | ៨% | ៤% |
| សកម្មភាពរៀនធ្វើម្ហូប | ១៨% | ៣៦% | ៦% | ៦% | ៣២% |
| សកម្មភាពកីឡាទេសចរណ៍ | ៣០% | ៥៨% | ៦% | ២% | ៤% |

(ប្រភព៖ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

**តារាងបន្ថែមទី៣៖ មតិយោបល់ភ្ញៀវទេសចរលើហេដ្ឋារចនាសម្ព័ន្ធ**

| ហេដ្ឋារចនាសម្ព័ន្ធ | ចាំបាច់ខ្លាំង | ចាំបាច់ | មិនសូវចាំបាច់ | មិនចាំបាច់ | គ្មានយោបល់ |
|---|---|---|---|---|---|
| | ៥ | ៤ | ៣ | ២ | ១ |
| ផ្លូវតភ្ជាប់ទៅកាន់តំបន់ទេសចរណ៍សំខាន់ៗជាមួយបង្គោលភ្លើង | ៧២% | ១៨% | ៤% | ៤% | ២% |
| បញ្ជរព័ត៌មានទេសចរណ៍/មជ្ឈមណ្ឌលព័ត៌មាន | ៦៨% | ២០% | ៤% | ២% | ៦% |
| ស្លាកសញ្ញាបង្ហាញផ្លូវ/តំបន់គ្រោះថ្នាក់ | ៦៨% | ២៤% | ៤% | ២% | ២% |
| ស្លាកសញ្ញាទៅកាន់គោលដៅទេសចរណ៍នានា | ៧២% | ២០% | ៤% | ២% | ២% |
| ចំណតរថយន្ត/បន្ទប់ទឹក | ៥៨% | ២៨% | ១០% | ២% | ២% |
| មានធុងសំរាមគ្រប់គ្រាន់ និងធ្វើការបែងចែកសំរាមទៅតាមប្រភេទ | ៥៨% | ២៤% | ១២% | ២% | ៤% |

(ប្រភព៖ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### តារាងបន្ថែមទី៤÷ មតិយោបល់ភ្ញៀវទេសចរលើសុវត្ថិភាពភ្ញៀវទេសចរ និងគុណភាព និងតម្លៃសេវាកម្ម

| សុវត្ថិភាពភ្ញៀវទេសចរ | ចាំបាច់ខ្លាំង | ចាំបាច់ | មិនសូវចាំបាច់ | មិនចាំបាច់ | គ្មានយោបល់ |
|---|---|---|---|---|---|
| | ៥ | ៤ | ៣ | ២ | ១ |
| មានប៉ូលីសទេសចរណ៍នៅគោលដៅទេសចរណ៍ | ៧២% | ៣៤% | ៤% | 0% | ២% |
| មានភ្នាក់ងារសង្គ្រោះបឋមនៅតាមគោលដៅទេសចរណ៍ | ៥២% | ៣៨% | ១៤% | ២% | ២% |
| លេខទូរស័ព្ទទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន | ៦៤% | ៣៦% | ១០% | 0% | ១០% |
| គុណភាព និងតម្លៃ | | | | | |
| គុណភាពផលិតផល និងតម្លៃសមរម្យ | ២៦% | ៦៤% | ១០% | 0% | 0% |

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

### គ. ទិន្នន័យបន្ថែមជារូបភាព

#### រូបភាពបន្ថែមទី១÷ សូចនាករសំខាន់ៗសម្រាប់វិស័យទេសចរណ៍កម្ពុជា ក្នុងឆ្នាំ២០១៩




(ប្រភព÷ ក្រសួងទេសចរណ៍)

#### រូបភាពបន្ថែមទី២÷ គំរូសាលប្រជុំស្របតាមស្តង់ដា MICE អាស៊ាន

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

**រូបភាពបន្ថែមទី៣÷ សកម្មភាពទេសចរណ៍ផ្សងព្រេងកម្សាន្ត**

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

**រូបភាពបន្ថែមទី៤÷ និមិត្តសញ្ញាគំរូសម្រាប់វត្ថុអនុស្សាវរីយ៍ខ្មែរ**

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

**រូបភាពបន្ថែមទី៥÷ គំរូនិមិត្តសញ្ញាកសិដ្ឋានសរីរាង្គ មណ្ឌលគិរី**

(ប្រភព÷ ការសិក្សារបស់គណៈកម្មការអន្តរក្រសួង)

# ឯកសារយោង

១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣
២. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា
៣. គោលនយោបាយជាតិទេសចរណ៍, ២០០៩
៤. គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០
៥. គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥
៦. ផែនការអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០,ក្រសួងទេសចរណ៍, ឆ្នាំ២០១២
៧. របាយការណ៍បច្ចេកទេសស្តីពីផែនការរៀបចំដែនដីខេត្តមណ្ឌលគិរី, គណៈកម្មការរៀបចំដែនដី និងនគរូបនីយកម្មខេត្តមណ្ឌលគិរី, ឆ្នាំ២០២១
៨. សេចក្តីព្រាងផែនការអភិវឌ្ឍតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម ២០២១-២០៣៥ ឆ្ពោះទៅចក្ខុវិស័យ ២០៣០, ឆ្នាំ២០១៩
៩. ឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០២០, មន្ទីរផែនការខេត្តមណ្ឌលគិរី, ឆ្នាំ២០២០
១០. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ២០១៤-២០១៨ និង ២០១៩-២០២៣, មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី, ឆ្នាំ២០១៣ និងឆ្នាំ២០១៨
១១. គោលការណ៍ណែនាំ និងឧបករណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃសហគមន៍ទេសចរណ៍ និងអេកូ ទេសចរណ៍ខេត្តមណ្ឌលគិរី, មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី និងអង្គការ WWF, ឆ្នាំ២០១៥
១២. សៀវភៅវគ្គបណ្តុះបណ្តាល គោលការណ៍ណែនាំ និងឧបករណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ខេត្តមណ្ឌលគិរី, មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី និង អង្គការ WWF, ឆ្នាំ២០១៥
១៣. កម្រងបញ្ជីរមណីយដ្ឋានទេសចរណ៍, មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី, ឆ្នាំ២០១៩
១៤. កម្មវិធីវិនិយោគ ៣ឆ្នាំរំកិល និង៥ឆ្នាំរំកិល ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី, សាលាក្រុងសែនមនោរម្យ, ឆ្នាំ២០២០
១៥. របាយការណ៍ការងារប្រចាំឆ្នាំ២០១៩, មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តមណ្ឌលគិរី, ឆ្នាំ២០១៩
១៦. ផែនការអភិវឌ្ឍន៍វិស័យវប្បធម៌ និងវិចិត្រសិល្បៈ រយៈពេល៥ឆ្នាំ, មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគិរី, ឆ្នាំ២០២០
១៧. ឯកសារស្រាវជ្រាវប្រវត្តិប្រពៃណី ទំនៀមទម្លាប់ជនជាតិដើមភាគតិចព្នង ថ្វន រអ៊ូង ក្រោល ចារ៉ាយ ភ្នំដោះក្រមុំ ភ្នំក្រោល មុខម្ហូបជនជាតិដើមភាគតិចព្នង វិធីសាស្ត្រធ្វើស្រាតាប៉ៃ និងបិតស្រាពាង, មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តមណ្ឌលគិរី, ឆ្នាំ២០១៨
១៨. ស្ថិតិសហគ្រាសគ្រឹះស្ថានសរុបឆមាសទី១ ឆ្នាំ២០២០, មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី, ឆ្នាំ២០២០

១៩. របាយការណ៍ស្តីពីការផ្សព្វផ្សាយការប្រើប្រាស់ពលកម្មកុមារ ការប្រយុទ្ធប្រឆាំង ការជួញដូរស្ត្រី និងកុមារ និងការគ្រប់គ្រងពលករចំណាកស្រុកក្នុង ក្រៅប្រទេស, មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី, ឆ្នាំ ២០២០

២០. ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២, មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី, ឆ្នាំ ២០២០

២១. តារាងស្ថានភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាស្រុក ក្រុង, មន្ទីររ៉ែ និងថាមពលខេត្តមណ្ឌលគិរី, ឆ្នាំ២០២០

២២. ផែនការសកម្មភាពឆ្នាំ២០២០, មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តមណ្ឌលគិរី, ឆ្នាំ២០២០

២៣. ក្របខណ្ឌវិនិយោគរយៈពេលប្រាំឆ្នាំរបស់មន្ទីរបរិស្ថានខេត្តមណ្ឌលគិរី, ឆ្នាំ២០២០

២៤. លទ្ធផលនៃការចុះអង្កេត និងប្រមូលទិន្នន័យរបស់ក្រុមការងារបច្ចេកទេសនៃគណៈកម្មការអន្តរក្រសួងសិក្សារៀបចំផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី, ឆ្នាំ២០២០។

## មាតិកាលម្អិត


**ខ្លឹមសារសង្ខេបប្រតិបត្តិ.......................................................................................i-ii**

**សេចក្តីផ្តើម៖ ភាពចាំបាច់នៃផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី.......................................១**

**ជំពូកទី១៖ ការវិភាគវិស័យទេសចរណ៍ និងអន្តរវិស័យគាំទ្រក្នុងខេត្តមណ្ឌលគិរី ចក្ខុវិស័យ ២០២១-២០៣៥....... ៣**

**ផ្នែកទី១៖ ការវិភាគយុទ្ធសាស្រ្ត.......................................................................................៤**

១-វិស័យទេសចរណ៍ក្នុងបរិបទមិនច្បាស់លាស់.......................................................................៤

១.១- បម្រែបម្រួលនៃវិស័យទេសចរណ៍សាកលលោក និងតំបន់................................................... ៤

១.២- ភាពធន់នឹងវិបត្តិនៃវិស័យទេសចរណ៍កម្ពុជា...........................................................................៦

២- ទិដ្ឋភាពរួមនៃការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី.................................................... ៧

២.១- ចរិតលក្ខណៈ និងតម្រូវការភ្ញៀវទេសចរ........................................................................... ៧

២.២- ការផ្គត់ផ្គង់សេវា និងសម្បទាទ្រទ្រង់..................................................................................១៣

២.៣- ធនធានមនុស្ស និងបុគ្គលិកបម្រើការ............................................................................... ១៤

៣- បរិការណ៍សំខាន់ៗនៃអន្តរវិស័យគាំទ្រដល់វិស័យទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី......................... ១៥

៣.១- ការរៀបចំដែនដី និងការប្រើប្រាស់ដីធ្លី............................................................................. ១៥

៣.២- ការអភិរក្សបរិស្ថាន និងធនធានធម្មជាតិ...........................................................................១៧

៣.៣- ការប្រើប្រាស់ និងផ្គត់ផ្គង់ទឹកស្អាត.................................................................................... ១៩

៣.៤- ការប្រើប្រាស់ និងផ្គត់ផ្គង់អគ្គិសនី.................................................................................... ២១

៣.៥- ការគ្រប់គ្រងសំរាម និងសំណល់........................................................................................ ២៣

៣.៦- ការអភិវឌ្ឍវប្បធម៌ និងជនជាតិដើមភាគតិច......................................................................... ២៥

៣.៧- ការគ្រប់គ្រង និងការអភិវឌ្ឍធនធានរ៉ែ.................................................................................. ២៦

៣.៨- កសិកម្ម និងការផ្គត់ផ្គង់ផ្កា បន្លែ ផ្លែឈើ និងសាច់................................................................ ២៨

៣.៩- វិស័យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម....................................................................... ២៩

៣.១០-ការដឹកជញ្ជូន ប្រព័ន្ធគមនាគមន៍ និងការតភ្ជាប់...................................................................៣០

៤- ការវិភាគ SWOT នៃវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី............................................................ ៣៣

**ផ្នែកទី២៖. ការកំណត់ចក្ខុវិស័យ គោលបំណង និងគោលដៅ...........................................................៣៦**

១- ចក្ខុវិស័យ....................................................................................................................៣៦

២- គោលបំណង................................................................................................................ ៣៧

៣- គោលដៅ..................................................................................................................... ៣៧

**ជំពូកទី២៖ ការកំណត់យុទ្ធសាស្រ្ត និងយន្តការអនុវត្ត..................................................................៣៨**

**ផ្នែកទី១៖ ក្របខណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យទេសចរណ៍............................................................ ៣៩**

**១- ការកំណត់តំបន់ទេសចរណ៍អាទិភាពសម្រាប់ការអភិវឌ្ឍ............................................................ ៣៩**

**២- ការអភិវឌ្ឍផលិតផលទេសចរណ៍ និងវិនិយោគក្នុងវិស័យទេសចរណ៍.................................... ៤២**
២.១- ការវិនិយោគសម្បទាទ្រទ្រង់សំខាន់ៗសម្រាប់វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី..................... ៤២
២.២- ការអភិវឌ្ឍសហគមន៍ទេសចរណ៍ អេកូទេសចរណ៍ និងទេសចរណ៍បៃតង.............................. ៤៤
២.៣- ការជំរុញការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍..................................................... ៤៥
២.៤- ការអភិវឌ្ឍផលិតផលទេសចរណ៍វប្បធម៌ជនជាតិដើមភាគតិច....................................... ៤៦
២.៥- ការរៀបចំព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗ.......................................................... ៤៧
២.៦- ការជំរុញសកម្មភាពកសិ-ទេសចរណ៍.................................................................. ៤៨
២.៧- ការអភិវឌ្ឍទេសចរណ៍វ័យចំណាស់ ទេសចរណ៍សុខភាព និងទេសចរណ៍ផ្ទះទី២.................. ៤៨
**៣- ការពង្រឹងគុណភាពទេសចរណ៍ និងធនធានមនុស្សគាំទ្រ ................................................... ៤៩**
៣.១- ការពង្រឹងគុណភាពទេសចរណ៍......................................................................... ៤៩
៣.២- ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍.................................................... ៥០
**៤- ការផ្សព្វផ្សាយ និងពង្រឹងរូបភាពវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ........................................ ៥១**
៤.១- ការរៀបចំអត្តសញ្ញាណ (Branding) ខេត្តមណ្ឌលគិរី................................................ ៥១
៤.២- ការជំរុញការផ្សព្វផ្សាយខេត្តមណ្ឌលគិរីតាមគ្រប់រូបភាព........................................... ៥២
**៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអន្តរវិស័យគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ............................ ៥៣**
៥.១-ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងសម្បទាទ្រ ទ្រង់ក្នុងខេត្ត..............................................៥៣
៥.២- ការប្រើប្រាស់ និងការផ្គត់ផ្គង់ទឹកស្អាត............................................................. ៥៩
៥.៣- ការប្រើប្រាស់ និងការផ្គត់ផ្គង់ថាមពលអគ្គិសនី .................................................... ៦១
៥.៤- ការគ្រប់គ្រងសំណល់រឹង និងរាវ..................................................................... ៦១
៥.៥- ការអភិរក្សវប្បធម៌ជនជាតិដើមភាគតិច...............................................................៦៣
៥.៦- ការផ្សាភ្ជាប់វិស័យរ៉ែ និងទេសចរណ៍ ..................................................................៦៣
៥.៧- ការផ្សាភ្ជាប់វិស័យកសិកម្ម និងទេសចរណ៍.......................................................... ៦៤
៥.៨- វិស័យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម....................................................... ៦៥
៥.៩- ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ............................................................៦៦
៥.១០- ការគាំទ្រសេវាវេជ្ជសាស្ត្រ និងសុខាភិបាល..........................................................៦៧
៥.១១- ការជំរុញការអភិវឌ្ឍបច្ចេកវិទ្យា នវានុវត្តន៍ និងភាពច្នៃប្រឌិត.................................... ៦៨
**៦- ការតភ្ជាប់ សម្រួលការធ្វើដំណើរ និងការធ្វើសមាហរណកម្មក្នុងក្របខណ្ឌជាតិ និងតំបន់..................... ៦៨**
៦.១- ការតភ្ជាប់តាមផ្លូវអាកាស និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ..............................................៦៩
៦.២- ការតភ្ជាប់តាមផ្លូវគោក និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ................................................ ៧១
៦.៣- ការតភ្ជាប់តាមផ្លូវទឹក និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ................................................. ៧១
**ផ្នែកទី២÷ ការកំណត់យន្តការអនុវត្ត............................................................................ ៧៣**
១- ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តផែនការមេ.......................................................... ៧៣

២- យន្តការស្ថាប័ន និងអភិក្រមនៃការអនុវត្ត ........................................................................ ៧៤
៣- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ............................................................................ ៧៤
៤- ការគ្រប់គ្រងហានិភ័យដើម្បីត្រៀមដាក់ចេញសេណារីយ៉ូកែតម្រូវ............................................ ៧៥
**សេចក្តីសន្និដ្ឋាន ....................................................................................................................៧៦**
**ឧបសម្ព័ន្ធ ក- ផែនការសកម្មភាពអនុវត្តផែនការមេ.................................................................. ៧៧**
**ឧបសម្ព័ន្ធ ខ- វិធីសាស្ត្រស្រាវជ្រាវ និងចងក្រងផែនការមេ ............................................................. ៩៦**
**ឧបសម្ព័ន្ធ គ- ទិន្នន័យបន្ថែមជាក្រាហ្វិក តារាង និងរូបភាព................................................................ ៩៧**
ឯកសារយោង........................................................................................................................ ១០៣